ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៣

## ស្តីពី

# ការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

រៀបចំដោយ៖ ក្រសួងផែនការ
រាជធានីភ្នំពេញ ខែមេសា ឆ្នាំ២០១៤

# មាតិកា


**អារម្ភកថា** ..... IV

**ខ្លឹមសារសង្ខេប** ..... VI

**ជំពូកទី១ ៖ សេចក្តីផ្តើម** ..... ១

១. បរិបទនៃការអភិវឌ្ឍ ..... ១

២. ទស្សនទានម៉ាក្រូសេដ្ឋកិច្ច ..... ១

៣. សមិទ្ធផលតាមវិស័យ ..... ២

៤. គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា-ខ្លឹមសារសង្ខេប ..... ៤

**ជំពូកទី២ ៖ ការសម្រេចបាន គ.អ.ស.ក.** ..... ៦

សេចក្តីផ្តើម ..... ៦

គោលដៅទី១ លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ ..... ៦

១.១. ភាពក្រីក្រ និងវិសមភាព ..... ៦

១.២. អាហារូបត្ថម្ភ ..... ១០

១.៣. ពលកម្មកុមារ ..... ១២

គោលដៅទី២ សម្រេចឱ្យបានសកលកម្មអក្ខរកម្ម និងការអប់រំបឋមសិក្សា ..... ១៣

២.១. អត្រាអក្ខរភាព ..... ១៣

២.២. អត្រានៃការសិក្សាអត្រាបញ្ចប់ការសិក្សា និងអត្រាបោះបង់ការសិក្សា ..... ១៤

២.៣. យុគភាពយេនឌ័រ ..... ១៨

គោលដៅទី៣ លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ..... ២០

៣.១. យុគភាពយេនឌ័រក្នុងវិស័យអប់រំ ..... ២០

៣.២. ការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ..... ២១

៣.៣. ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ ..... ២៣

គោលដៅទី៤ កាត់បន្ថយអត្រាមរណភាពកុមារ ..... ២៥

៤.១. មរណភាពរបស់កុមារ និងកុមារអាយុក្រោម៥ឆ្នាំ ..... ២៥

៤.២. ការផ្តល់ថ្នាំបង្ការជំងឺសម្រាប់កុមារ ..... ២៦

គោលដៅទី៥ ការធ្វើឱ្យប្រសើរឡើងសុខភាពមាតា ..... ២៨

៥.១. អត្រាមរណភាពមាតានិងការសម្រាលកូនដោយបុគ្គលិកសុខាភិបាលជំនាញ ..... ២៨

៥.២. អត្រាផ្តល់កំណើតសរុប ..... ២៩

៥.៣. ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើបនិងការពិគ្រោះយោបល់ពីការថែទាំមុនពេលសម្រាល ..... ៣០

៥.៤. ការសម្រាលដោយវះកាត់ ..... ៣០

គោលដៅទី៦ ការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត ..... ៣១

៦.១. មេរោគអេដស៍ជំងឺអេដស៍ ..... ៣១

៦.២. ជំងឺគ្រុនចាញ់គ្រុនឈាមនិងជំងឺផ្សេងៗ ..... ៣២

គោលដៅទី៧ ការធានាចីរភាពបរិស្ថាន ..... ៣៣

៧.១. គម្របព្រៃឈើ ..... ៣៣

៧.២. តំបន់អភិរក្សព្រៃឈើ ..... ៣៤

៧.៣. កិច្ចខិតខំប្រឹងប្រែងក្នុងដាំកូនឈើឡើងវិញ ..... ៣៥

៧.៤. វិស័យជលផល ..... ៣៦

៧.៥. ទឹកស្អាត និងអនាម័យ ..... ៣៦

៧.៦. ការប្រើប្រាស់អុស ..... ៣៧

៧.៧. កម្មសិទ្ធិដីធ្លី ..... ៣៨

គោលដៅទី៨ បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ ..... ៣៩

៨.១. ការកៀរគរធនធាន ការសម្របសម្រួល និងសុខដុមនីយកម្ម ..... ៣៩

៨.២. ដំណើរការនៃភាពជាដៃគូការសម្របសម្រួល និងសុខដុមនីយកម្ម ..... ៣៩

៨.៣. ការបើកចំហរសេដ្ឋកិច្ច ..... ៤១

៨.៤. អត្ថប្រយោជន៍នៃបច្ចេកវិទ្យាថ្មី ការភ្ជាប់ទំនាក់ទំនង ..... ៤១

គោលដៅទី៩ ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងសង្គ្រោះជនរងគ្រោះការវិភាគពីស្ថានភាពមីននៅកម្ពុជា ..... ៤២

**ជំពូកទី៣ ៖ ដំណើរឆ្ពោះទៅមុខ និងក្រោយឆ្នាំ២០១៥** ..... ៤៦

១. ការរំពឹងទុកសម្រាប់ពេលអនាគត

២. ក្របខ័ណ្ឌដែលបានស្នើឡើង សម្រាប់ពន្លឿន គ.អ.ស.ក. ..... ៥០

៣. តម្រូវការសកម្មភាពនៅកម្រិតមូលដ្ឋាននិងធានាការសម្របសម្រួល ..... ៥៨

៤. ការផ្តល់ហិរញ្ញប្បទាននិងការកៀរគរធនធាន ..... ៥៨

៥. សេចក្តីសង្ខេប ..... ៥៨

**ជំពូកទី៤ ៖ សេចក្តីសន្និដ្ឋាន** ..... ៥៩

**ឧបសម្ព័ន្ធទី ១ ៖ វឌ្ឍនភាពស្តីពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** ..... ៦១

**ឧបសម្ព័ន្ធទី ២ ៖ ម្ចាស់រូបភាព** ..... ៦៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធ្វើឱ្យសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ ដើម្បីសម្រេចឱ្យបានការប្តេជ្ញាចិត្តនេះ រាជរដ្ឋាភិបាលបានធ្វើឱ្យមានបរិយាប័ន្ននៃកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍន៍ផែនការក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ ។ វិធីសាស្ត្រនេះត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលជារបៀបវារៈគោលនយោបាយសម្រាប់តម្រង់ទិសការអភិវឌ្ឍន៍សម្រាប់នីតិកាលទី ៥ ឆ្នាំ ២០១៣-២០១៨ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធ្វើសមាហរណកម្មពេញលេញទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងក្នុងការដាក់វិធានការជាក់លាក់គ្រប់ជ្រុងជ្រោយ ដើម្បីទទួលបានផលប្រយោជន៍ពីការធ្វើសមាហរណកម្មនេះ ។ បន្ថែមលើនេះទៀត រាជរដ្ឋាភិបាលបានផ្តល់អាទិភាពមួយក្នុងចំណោមអាទិភាពខ្ពស់នានាដែលចាំបាច់ត្រូវតែសម្រេចឱ្យបាននោះ គឺការសម្រេចឱ្យកម្ពុជាបានចាកចេញពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ។ ពេលវេលាដែលត្រូវឈានសម្រេចឱ្យបាននូវចំណុចដៅ និងគោលដៅដ៏ច្រើនទាំងនេះនៅមានរយៈពេលខ្លីណាស់ដែលគោលដៅ និងចំណុចដៅខ្លះត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០១៥ ចំណែកមួយចំនួនទៀតត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០១៨ ។ ដូចនេះ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តខ្ពស់ ដើម្បីសម្រេចឱ្យបាននូវគោលដៅទាំងនេះ ដែលជាបំណងប្រាថ្នារបស់ប្រជាជន និងតម្រូវការអភិវឌ្ឍន៍ប្រទេស ។

នៅក្នុងអាណត្តិកាលរបស់ខ្លួនក្នុងនីតិកាលទី ៤ រាជរដ្ឋាភិបាលកម្ពុជាបានបន្ស៊ីអាណត្តិកាលរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ជាមួយអាណត្តិរបស់ខ្លួន ។ ក្រសួងផែនការដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា បាននាំមុខក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំឆ្នាំនៃការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដោយចាប់ផ្តើមពីឆ្នាំ ២០១០ មក ។ របាយការណ៍ពីសមិទ្ធផលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ ២០១៣ នេះ គឺជារបាយការណ៍ប្រចាំឆ្នាំលើកទី ៤ ដែលជាប្រភេទរបាយការណ៍បង្ហាញពីការវិវត្តន៍ និងវិភាគពីស្ថានភាពនៅថ្នាក់ក្រោមជាតិ ដែលបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើវិសមភាព និងប្រជាជននៅមូលដ្ឋាន ។ លើសពីនេះទៀត របាយការណ៍នេះក៏បានបង្ហាញពីក្របខ័ណ្ឌនៃការបង្កើនល្បឿនដែលជាមូលដ្ឋានដ៏មានសារសំខាន់សម្រាប់កម្ពុជាក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ។ របាយការណ៍នេះក៏ត្រូវបានធ្វើការកែសម្រួលពាក់ព័ន្ធនឹងការប្រើប្រាស់ប្រភពទិន្នន័យ និងវិធីសាស្ត្រដើម្បីឱ្យស្របតាមគោលនយោបាយនានា ។ ខ្ញុំសូមសម្តែងនូវអំណរសរសើរចំពោះក្រសួងផែនការ ដែលបានខិតខំប្រឹង

ប្រែងនាំមុខក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍មួយចំនួន ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃរបាយការណ៍ស្ដីពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ ២០១៣ នេះ ។

របាយការណ៍នេះបានបង្ហាញពីមូលដ្ឋានម៉ាក្រូសេដ្ឋកិច្ចរឹងមាំ ដែលជាសមិទ្ធិផលរួមជាទីមោទនៈរបស់កម្ពុជា ។ កម្ពុជាបានសម្រេចជោគជ័យក្នុងវិស័យជាច្រើន ដូចជាកំណើនក្នុងវិស័យកសិកម្មដែលបានធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយដែលនាំចេញអង្ករទៅទីផ្សារបរទេស ដែលពីមុនជាប្រទេសខ្វះខាតស្បៀងអាហារការបែងចែក និងការផ្តល់កម្មសិទ្ធិដីធ្លីជូនប្រជាជនត្រូវបាន និងកំពុងដំណើរការយ៉ាងល្អប្រសើរវិស័យហេដ្ឋារចនាសម្ព័ន្ធត្រូវបានធ្វើឱ្យមានការរីកចម្រើនយ៉ាងលឿន ។ កំណើនក្នុងវិស័យមិនមែនកសិកម្មដែលមានការថយចុះនៅក្នុងឆ្នាំ ២០០៩ ដោយសារតែត្រូវបានទទួលរងនូវផលប៉ះពាល់បណ្ដាលមកពីកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះសេដ្ឋកិច្ចសកលលោកក៏កំពុងមានការកើនឡើងវិញ ។ ជាលទ្ធផល វិសមភាពនៃចំណូល (ការប្រើប្រាស់) កំពុងត្រូវបានកាត់បន្ថយហើយប្រជាជនកំពុងទទួលបានចំណូលច្រើនបន្ថែមទៀត និងកំពុងរស់នៅក្នុងស្ថានភាពល្អប្រសើរជាងមុនបើប្រៀបធៀបទៅនឹងរយៈពេលពីរបីឆ្នាំកន្លងទៅ ។ ពិសេសជាងនេះទៀត កម្ពុជាសម្រេចបាននូវការកាត់បន្ថយអត្រាភាពក្រីក្រគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ លើសពីនេះ ការងារអភិបាលកិច្ចក៏ត្រូវលើកកម្ពស់នៅក្នុងគ្រប់រូបភាព ដូចបានបង្ហាញនៅក្នុងរបាយការណ៍ពាក់កណ្ដាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ហើយពេលនេះក៏ត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ ។ ទោះជាដូចនេះក្តី កម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយជាបន្តទៀតដូចជាការបញ្ចប់ការសិក្សាជាមូលដ្ឋានរយៈពេល ៩ ឆ្នាំ នៅមានកម្រិតទាបនៅឡើយដែលបញ្ហានេះ រាជរដ្ឋាភិបាលបានប្ដេជ្ញាចិត្តក្នុងការផ្តល់ការសិក្សាដល់កុមារកម្ពុជាគ្រប់រូបទោះបីជាភាគច្រើននៃកុមារទទួលបានការសិក្សានៅសាលាក៏ដោយ ។ ម្យ៉ាងទៀត សុខភាព និងអាហារូបត្ថម្ភរបស់កុមារ និងអាហារូបត្ថម្ភរបស់ស្ត្រីនៅតែបន្តជាការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ។ បន្ថែមលើនេះទៀត គឺការងារដែលមិនទាន់ត្រូវបានបញ្ចប់ពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ។ ដូចនេះ ទន្ទឹមនឹងវឌ្ឍនភាពដែលសម្រេចបានជាច្រើននាពេលកន្លងមកក៏នៅមានការងារមួយចំនួនទៀតមិនទាន់បានសម្រេចនៅឡើយ ដែលកម្ពុជាបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីដោះស្រាយនូវបញ្ហានានាដែលសេសសល់ដូចជាភាពក្រីក្រ និងក្ដីកង្វល់របស់ប្រជាជន ។

ជាមួយមូលវិចារណ៍ដ៏ថ្លៃថ្លា ចំពោះក្រសួងស្ថាប័នរបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជាសូមថ្លែងអំណរគុណយ៉ាងកក់ក្ដៅ ចំពោះការចូលរួមចំណែករបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍នានា ដែលបានគាំទ្រដល់ដំណើរការរៀបចំរបាយការណ៍នេះ រហូតទទួលបានជារូបរាងឆ្លុះបញ្ចាំងនូវសមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងមក ។

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ០៧ ឆ្នាំ ២០១៤*

**ហ៊ុន សែន**

# ខ្លឹមសារសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការវាយតម្លៃសមិទ្ធផលដែលសម្រេចបានលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.) ប្រចាំឆ្នាំចាប់តាំងពីឆ្នាំ២០១០មក។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការសម្រេចបាន គ.អ.ស.ក. ឆ្នាំ២០១៣នេះ ក៏បានបង្ហាញពីវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងមករួមទាំងប្រធានបទពិសេសមួយស្តីពីក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ផ្តល់នូវគោលនយោបាយនិងនីតិវិធីសំខាន់ៗសំដៅពន្លឿនវឌ្ឍនភាពគ.អ.ស.ក. និងបណ្តាគោលដៅអភិវឌ្ឍន៍ធនធានមនុស្សដទៃទៀតដែលជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ លើសពីនេះទៀតរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការសម្រេចបាន គ.អ.ស.ក. ឆ្នាំ២០១៣នេះបានបង្ហាញពីវឌ្ឍនភាពនៅថ្នាក់ក្រោមជាតិនិងបានគូសបញ្ជាក់ពីទំហំវិសមភាពនៅក្នុងប្រទេស ក៏ដូចជា ផលប៉ះពាល់ពីវិសមភាពមកលើការសម្រេចបានគ.អ.ស.ក.។

## វឌ្ឍនភាពស្តីពីការសម្រេចបានគ.អ.ស.ក.

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាមានគោលដៅចំនួន៩។ គោលដៅនីមួយៗ ក៏រួមមាននូវចំណុចដៅនិងសូចនាករ។ ខ្លឹមសារសង្ខេបនេះ បង្ហាញនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តគ.អ.ស.ក. កន្លងមក តាមរយៈសូចនាករចម្បងៗ មួយចំនួនដូចខាងក្រោម ៖ ***ការវាយតម្លៃ៖*** *ចំណុចដៅនៃការកាត់បន្ថយភាពក្រីក្រសម្រេចបានហើយទោះបីកង្វះអាហារូបត្ថម្ភរបស់កុមារនៅតែភាពប្រឈម។*

### គោលដៅទី១ លុបបំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ

**អត្រាភាពក្រីក្រ៖** ទិន្នន័យឆ្នាំ២០០៧ មានប្រហែលជា ៤៧,៨% នៃប្រជាជនសរុប។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១១ មានប្រហែលជា ១៩,៨%។ ចំណុចដៅ ឆ្នាំ២០១៥ គឺ ១៩,៥%។

**វិសមភាពការប្រើប្រាស់** ៖ ទិន្នន័យដើមគ្រា ឆ្នាំ២០០៧ មានប្រហែលជា ៧% ក្នុងចំណោមប្រជាជន ក្រីក្របំផុត។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១១ មានប្រហែលជា ៩%។ ចំណុចដៅ ឆ្នាំ២០១៥ គឺ ១១%។

***ការវាយតម្លៃ*** *៖ សម្រេចបានបណ្តាចំណុចដៅនៃការកាត់បន្ថយភាពក្រីក្រមុនកាលបរិច្ឆេទកំណត់ និងនឹងសម្រេចបានការកាត់បន្ថយវិសមភាព។ ប៉ុន្តែស្ថានភាពអាហារូបត្ថម្ភរបស់កុមារនិងស្ត្រីស្ថិតនៅកម្រិតមួយដែលទាមទារកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការលើកកម្ពស់ស្ថានភាពនេះ។*

### គោលដៅទី២ សម្រេចឱ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា

**អត្រាពិតនៃការសិក្សានៅបឋមសិក្សា** ៖ ទិន្នន័យដើមគ្រា ឆ្នាំសិក្សា ២០០៨/២០០៩ ប្រមាណជា ៩៤% នៃកុមារសរុបអាយុចាប់ពី ៦-១១ឆ្នាំ។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំសិក្សា២០១២/២០១៣ ប្រមាណជា ៩៧% ចំណុចដៅ ឆ្នាំ២០១៥ គឺ ៩៩%។

**អត្រាអក្ខរកម្មក្នុងក្រុមអាយុ ១៥-២៤ឆ្នាំ** ៖ ទិន្នន័យដើមគ្រា ឆ្នាំ ២០០៥ មាន ៨០%។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១២ មាន ៩២,១០%។ ចំណុចដៅឆ្នាំ២០១៥ គឺ ៩៤,៥%។

***ការវាយតម្លៃ៖*** *អាចនឹងសម្រេចបានចំណុចដៅនៃការអប់រំកម្រិតបឋមសិក្សា និងអត្រាអក្ខរកម្ម ប៉ុន្តែ ចាំបាច់ទាមទារកិច្ចខំប្រឹងប្រែងបន្ថែមទៀតសម្រាប់ការអប់រំក្រោយបឋមសិក្សា ដើម្បីធានាបានការបង្កើតមូលធនមនុស្សឱ្យបានឆាប់រហ័ស។*

### គោលដៅទី៣ លើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

**ផលធៀបអត្រាពិតនៃការសិក្សានៅបឋមសិក្សា និងអត្រារួមនៃការសិក្សានៅមធ្យមសិក្សារវាង សិស្សប្រុសនិងសិស្សស្រី** ៖ សម្រេចបាន និងរក្សាបានសមិទ្ធផលនេះ។

**ផលធៀបអត្រាសរុបនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិរវាងសិស្សប្រុសនិងសិស្សស្រី** ៖ ទិន្នន័យដើមគ្រាឆ្នាំសិក្សា២០០៧/២០០៨ មាន ៦៩%។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំសិក្សា២០១២/២០១៣ មាន ៩៣%។ ចំណុចដៅ ឆ្នាំ២០១៥ គឺ ១០០%។

***ការវាយតម្លៃ៖*** *អាចនឹងសម្រេចបានចំណុចដៅជាច្រើន ហើយចំណែកចំណុចដៅមួយចំនួនទៀតមានវឌ្ឍនភាពល្អ។ រីឯ ចំណុចដៅដែលពាក់ព័ន្ធនឹងសមាមាត្រស្ត្រីនៅនីតិប្បញ្ញត្តិ ឬស្ត្រីជាថ្នាក់ដឹកនាំ ក្នុងវិស័យសាធារណៈ នឹងមិនទាន់សម្រេចបានទេសម្រាប់រយៈពេលដែលនៅសេសសល់។*

### គោលដៅទី៤ កាត់បន្ថយមរណភាពកុមារ

**អត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ (ក្នុង១ ០០០កំណើតរស់)៖** ទិន្នន័យដើមគ្រា ឆ្នាំ ២០០០ មានចំនួន ៩៥នាក់ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១០ មានចំនួន៤៥នាក់។ ចំណុចដៅឆ្នាំ២០១៥ គឺ ៥០នាក់។

**អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ (ក្នុង ១ ០០០ កំណើតរស់)៖** ទិន្នន័យដើមគ្រាឆ្នាំ២០០០ មានចំនួន ១២៤នាក់។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១០ មាន៥៤នាក់។ ចំណុចដៅ ឆ្នាំ២០១៥ គឺ៦៥នាក់។

***ការវាយតម្លៃ៖*** *សម្រេចបានចំណុចដៅទាំងនេះមុនកាលបរិច្ឆេទកំណត់។*

### គោលដៅទី៥ លើកកម្ពស់សុខភាពមាតា

**អត្រាមរណភាពមាតា (ក្នុង ១០០ ០០០ កំណើតរស់)** ៖ ទិន្នន័យដើមគ្រា ឆ្នាំ២០០០ មានចំនួន ៤៣៧ នាក់។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១០ មានចំនួន ២០៦ នាក់។ ចំណុចដៅ ឆ្នាំ២០១៥ គឺ ២៥០ នាក់។

**សមាមាត្រនៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ** ៖ ទិន្នន័យដើមគ្រា ឆ្នាំ២០០៨ មាន៥៨%នៃស្ត្រីមានគភ៌រំពឹងទុក។ ទិន្នន័យបច្ចុប្បន្នឆ្នាំ២០១២ មាន៧៥%។ ចំណុចដៅឆ្នាំ២០១៥ គឺ៨៧%។

***ការវាយតម្លៃ៖*** *នឹងសម្រេចបានចំណុចដៅទាំងនេះ។*

### គោលដៅទី៦ ប្រយុទ្ធនឹងមេរោគអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត

**ប្រេវ៉ាឡង់មេរោគអេដស៍** ៖ ទិន្នន័យដើមគ្រាឆ្នាំ២០០៨ មាន០,៧% នៃចំនួនប្រជាជនសរុប។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១០ មាន០,៧%។ ចំណុចដៅ ឆ្នាំ២០១៥ គឺ០,៤%។

**គ្រុនចាញ់** ៖ ទិន្នន័យដើមគ្រា ឆ្នាំ១៩៩៣ មាន១,៥% (ក្នុងចំណោមប្រជាជន ១០០ ០០០នាក់)។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១២មាន០,៣%។ ចំណុចដៅ ឆ្នាំ២០១៥ គឺ០,៨%។

*ការវាយតម្លៃ៖ ចំណុចដៅទាំងនេះសម្រេចបានមុនកាលបរិច្ឆេទកំណត់។*

### គោលដៅទី៧ ធានាចីរភាពបរិស្ថាន

គម្របព្រៃឈើ៖ ទិន្នន័យដើមគ្រា ឆ្នាំ២០០៨ ប្រមាណជា ៥៦%។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១៣ (ប៉ាន់ស្មាន ៥៩%) នៃផ្ទៃដីសរុប។ ចំណុចដៅ ឆ្នាំ២០១៥ គឺ ៦០%។

**អត្រានៃប្រជាពលរដ្ឋទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ៖** ទិន្នន័យដើមគ្រា ឆ្នាំ២០០៩ (៤២% នៅជនបទ និង ៧៨% នៅទីប្រជុំជន។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១១ (៤៣% នៅជនបទ និង ៨១% នៅទីប្រជុំជន)។ ចំណុចដៅ ឆ្នាំ២០១៥ (៥០% នៅជនបទ និង ៨០% នៅទីប្រជុំជន)។

**អត្រានៃប្រជាពលរដ្ឋទទួលបានការផ្គត់ផ្គង់អនាម័យដែលមានការកែលម្អ៖** ទិន្នន័យដើមគ្រា ឆ្នាំ២០០៩ (២៣% នៅជនបទ និង ៨៥% នៅទីប្រជុំជន)។ ទិន្នន័យបច្ចុប្បន្ន ឆ្នាំ២០១១ (៣៣% នៅជនបទ និង ៨៨% នៅទីប្រជុំជន)។ ចំណុចដៅ ឆ្នាំ២០១៥ (៣៣% នៅជនបទ និង ៧៤% នៅទីប្រជុំជន)។

**ការវាយតម្លៃ៖** ទោះបីជា ចំណុចដៅទាំងឡាយនៅទីប្រជុំជនសម្រេចបានរួចហើយក៏ដោយ ក៏នៅមាន ភាពចាំបាច់មួយចំនួន សម្រាប់តាមដានវឌ្ឍនភាពការបង្កើនការដាំកូនឈើ និងការស្ដារព្រៃឈើឡើងវិញ និងផ្គត់ផ្គង់ទឹក និងអនាម័យនៅតាមទីជនបទ។

### គោលដៅទី៨ បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ

គោលដៅនេះ មិនមានសូចនាករសម្រាប់វាស់វែងពីវឌ្ឍនភាពនោទេ។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តពង្រឹងភាពជាដៃគូ និងរក្សាភាពជាដៃគូល្អជាមួយតួអង្គអភិវឌ្ឍទាំងអស់ស្របតាមគោលការណ៍សកលចម្បងៗនៃភាពជាដៃគូដែលបានឯកភាពក្នុងវេទិកាកំពូលនានាដើម្បីលើកកម្ពស់ប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ប្រការនេះ ដៃគូអភិវឌ្ឍអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន នៅតែបន្តពង្រឹងតួនាទីរបស់ខ្លួនក្នុងការដោះស្រាយកិច្ចអភិវឌ្ឍ និងកង្វល់នានាពាក់ព័ន្ធនឹងធុរកិច្ច។

**ការវាយតម្លៃ** ៖ ជាមួយនឹងការផ្លាស់ប្ដូរយុគសម័យនៃការអភិវឌ្ឍទាំងសេដ្ឋកិច្ចបើកចំហរ ទាំងភាពជាដៃគូអភិវឌ្ឍន៍ ក៏នឹងទទួលរងនូវការផ្លាស់ប្ដូរនេះដែរ។ ដូច្នេះ ប្រការប្រឈមនេះ រាជរដ្ឋាភិបាលនឹងផ្ដោតការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង និងពង្រឹងការប្រើប្រាស់លំហូរហិរញ្ញប្បទានឥតសំណង ប្រកបដោយប្រសិទ្ធភាព និងផ្ដោតជាសំខាន់លើការអភិវឌ្ឍមូលធនមនុស្ស។

### គោលដៅទី៩ ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនពិការដោយសារមីន

គោលដៅទី៩ មិនមានសូចនាករវាស់វែងចំណុចដៅនោះទេ។ ប៉ុន្តែគោលដៅនេះ គឺជាការប្ដេជ្ញាចិត្ត និងគាំទ្ររួមគ្នា រវាងរាជរដ្ឋាភិបាលនិងបណ្ដាតួអង្គពាក់ព័ន្ធ ក្នុងសកម្មភាពបោសសម្អាតមីន។ ទន្ទឹមនេះ ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅតែបន្តមាន ទោះបីជាផ្ទៃដីដែលគម្រាមកំហែងដោយសារមីនជាច្រើនត្រូវបានបោសសម្អាតរួចហើយក៏ដោយ។ ដោយឡែក ការធ្លាក់ចុះនូវជំនួយថវិកា គឺប៉ះពាល់ដល់និរន្តរភាពនិងប្រសិទ្ធភាពនៃសកម្មភាពបោសសម្អាតមីន។

**ការវាយតម្លៃ៖** សកម្មភាពនេះ ពិបាកនឹងសម្រេចបាន ដោយសារបញ្ហាធនធាន និងទំហំនៃបញ្ហា។

## ការរៀបចំផែនការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

ដោយសារគោលដៅនីមួយៗរបស់ គ.អ.ស.ក.មានទំនាក់ទំនងគ្នាខ្លាំង ដូច្នេះរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្ដីពីការសម្រេចបានគ.អ.ស.ក.ឆ្នាំ២០១៣នេះ បានរៀបចំផ្នែកមួយស្ដីពីក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដើម្បីសម្រេចបាន គ.អ.ស.ក. ទាំងអស់ តាមរយៈការតភ្ជាប់ទំនាក់ទំនងសមាសភាគនីមួយៗរបស់គ.អ.ស.ក. ជាមួយនឹងយុទ្ធសាស្ត្រកំណើនតាមវិស័យទាំងអស់។ ដូច្នេះ ក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នេះ ចែកជា៧ផ្នែកធំៗ ដូចខាងក្រោម ៖

១ កំណើនប្រកបដោយចីរភាព និងបរិយាប័ន្នសម្រាប់កាត់បន្ថយភាពក្រីក្រ។

២ គោលនយោបាយកាត់បន្ថយភាពក្រីក្រ។

៣ មូលធនមនុស្សសម្រាប់ការអភិវឌ្ឍធនធានមនុស្ស។

៤ ការអភិរក្សធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងជីវភាពរស់នៅ។

៥ ការចូលរួម និងការផ្ដល់សិទ្ធិអំណាចស្មើភាពគ្នាដល់ស្ត្រី។

៦ ការកែលម្អកម្មវិធីសុខភាពមាតា ទារក និងកុមារ និងការគ្រប់គ្រងជំងឺ។

៧ ជំរុញការប្រើប្រាស់ទឹកស្អាត និងលើកកម្ពស់អនាម័យ ជាពិសេសក្នុងតំបន់ជនបទ។

ទោះបីជាក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នេះ បានគ្រប់ដណ្ដប់លើវិស័យសេដ្ឋកិច្ចស្ទើរតែទាំងស្រុង ប៉ុន្តែនៅមានផ្នែកវិស័យៗមួយចំនួនទៀតសម្រាប់ការកំណត់ចំណុចដៅការវិនិយោគលើវិស័យ រួមមានកសិកម្មខ្នាតតូច ធារាសាស្ត្រ សហគ្រាសមិនមែនកសិកម្ម ការអប់រំនៅគ្រប់កម្រិត គុណភាពមូលធនមនុស្ស អាហារូបត្ថម្ភ សេវាសុខភាពដែលមានតម្លៃទាប ទឹកស្អាតនិងអនាម័យឱ្យបានទូទាំងប្រទេស ប្រភពធនធានថាមពលផ្សេងទៀត ការកំណត់ព្រំដីនិងការផ្ដល់ប័ណ្ណកម្មសិទ្ធ ការបោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងការពង្រឹងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ចំពោះវិស័យយេនឌ័រនិងបរិស្ថាន គឺជាបញ្ហាអន្តរវិស័យសម្រាប់គ្រប់ផ្នែកទាំងអស់។ ដូច្នេះ ការអនុវត្តយុទ្ធសាស្ត្រទាំងមូលទាមទារឱ្យមានភាពជាដៃគូគ្រប់កម្រិត រវាងរាជរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍទាំងអស់។



កសិករកម្ពុជាកំពុងសំអាតគ្រាប់ស្រូវបន្ទាប់ពីប្រមូលផល-ខេត្តព្រៃវែង

ជំពូកទី ១

# សេចក្តីផ្តើម

## ១. បរិបទនៃការអភិវឌ្ឍ

ប្រទេសកម្ពុជាត្រូវបានចាត់ចូលជាប្រទេសដែលមានការអភិវឌ្ឍតិចតួចដោយអង្គការសហប្រជាជាតិ។ ក្នុងនោះ ចំណូលសម្រាប់មនុស្សម្នាក់មានប្រមាណជា ១០០០ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានប្តូរពីរបបសេដ្ឋកិច្ចផែនការមកជារបបសេដ្ឋកិច្ចបើកចំហរ ក្រោយពីសង្គ្រាមហើយកម្ពុជាក៏ជាប្រទេសមានព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០។

ប្រទេសកម្ពុជាមានផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិតាមរយៈការអភិវឌ្ឍតាមផែនការក្នុងក្របខ័ណ្ឌទីផ្សារ។ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំយុទ្ធសាស្រ្តចតុកោណដែលបង្ហាញពីគោលនយោបាយ អាទិភាពរបស់រាជរដ្ឋាភិបាលចាប់តាំងពីឆ្នាំ២០០៤។យុទ្ធសាស្រ្តចតុកោណបានផ្តល់ជាក្របខ័ណ្ឌអភិវឌ្ឍន៍ដែលត្រូវបានអនុវត្តតាមរយៈផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ។ យុទ្ធសាស្រ្តចតុកោណគឺជាឯកសារជវភាពដែលបានបង្ហាញពីបម្រែបម្រួលបីសំខាន់ៗក្នុងទសវត្សរ៍ចុងក្រោយនេះ ដើម្បីអភិវឌ្ឍឱ្យបានស្របតាមសភាពការណ៍ប្រែប្រួលសេដ្ឋកិច្ចនិងសង្គម។ សមាសធាតុសំខាន់ៗចំនួន៤គឺ៖

១. ការធានាបាននូវកំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ។ កំណើននេះចាំបាច់ជាកំណើនប្រកបដោយចីរភាពបរិយាប័ន្នសមធម៌និងធននឹងវិបត្តិនានាតាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចដើម្បីសម្រេចបានរចនាសម្ព័ន្ធសេដ្ឋកិច្ចមួយដែលមានលក្ខណៈប្រកួតប្រជែងនិងគ្រប់ដណ្តប់ច្រើនជាងមុនដោយមានអតិផរណាទាបនិងអាចគ្រប់គ្រងបានអត្រាប្តូរប្រាក់ដែលមានស្ថិរភាពនិងថវិកាបម្រុងអន្តរជាតិមានកំណើនថេរ។

២. ការបង្កើតការច្រើនជាងមុនជាពិសេសសម្រាប់យុវជនតាមរយៈការកែលម្អបន្ថែមទៀតលើភាពប្រកួតប្រជែងរបស់កម្ពុជាដើម្បីទាក់ទាញនិងជំរុញការវិនិយោគទាំងក្នុងស្រុកនិងក្រៅស្រុក។

៣. ការសម្រេចបានការកាត់បន្ថយភាពក្រីក្រ១%ក្នុងមួយឆ្នាំរួមទាំងការសម្រេចបានគ.អ.ស.ក.ដោយផ្តល់អាទិភាពខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស និងការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថានប្រកបដោយចីរភាព។

៤. ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិបាលកិច្ចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនិងការធានាបាន នូវប្រសិទ្ធិភាពនិងប្រសិទ្ធផលនៃការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរដល់ប្រជាជន។

សមាសធាតុភាគច្រើនរបស់យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ បញ្ជាក់ពីកត្តារួមផ្សំបន្ថែមទៀត ដែលត្រូវការជាចាំបាច់សម្រាប់សម្រេចបានគ.អ.ស.ក.។

## ២. ទស្សនទានម៉ាក្រូសេដ្ឋកិច្ច

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជានៅឆ្នាំ២០១៣ មានលក្ខណៈល្អប្រសើរទោះបីជាមានផលប៉ះពាល់ខ្លះពីភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក និងពីកត្តាធម្មជាតិលើវិស័យកសិកម្មក្នុងរដូវវស្សាដែលមានសភាពធ្ងន់ធ្ងរ។ កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១៣ត្រូវបានប៉ាន់ប្រមាណស្មើនឹង៧,៥% តាមថ្លៃថេរ ក្នុងនោះផ្នែកកសិកម្មមានកំណើន១,៧% ផ្នែកឧស្សាហកម្មមានកំណើន ១១,០% និងផ្នែកសេវាកម្មមានកំណើន៨,៧%។ ប្រសិនបើប្រៀបធៀបនឹង៥ឆ្នាំកន្លងទៅវិស័យដំណាំមានកំណើនទាបបំផុត ប៉ុន្តែអាចរក្សាបានកំណើនខ្ពស់ដោយសារការរីកចម្រើនខ្ពស់ផ្នែកឧស្សាហកម្មនិងក្នុងនិន្នាការពិពិធកម្មផងដែរ។ ផ.ស.ស. សម្រាប់មនុស្សម្នាក់បានកើនឡើងលើសពី១ ០០០ដុល្លារអាមេរិកឬ១ ០៣៦ដុល្លារអាមេរិក ( ការប៉ាន់ស្មាន ) ក្នុងឆ្នាំ២០១៣សម្រាប់តម្លៃបច្ចុប្បន្ន។

អតិផរណានៅកម្ពុជាស្ថិតនៅក្នុងកម្រិតមួយទាប ដោយសារស្ថិរភាពតម្លៃម្ហូបអាហារ ទោះបីជាមានការប្រែប្រួលពីតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិក៏ដោយ។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំក្រោយពីវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៩ ត្រូវបានកាត់បន្ថយមកកម្រិតទាបជាបន្តបន្ទាប់ ដោយនៅឆ្នាំ២០១៣ កន្លងទៅមានចំនួនត្រឹមតែ៣,០%ប៉ុណ្ណោះ។ ការសម្រេចបាននូវស្ថិរភាពអតិផរណានេះ គឺដោយសារមានការគ្រប់គ្រងប្រុងប្រយ័ត្នបំផុតទៅលើគោលនយោបាយរូបិយវត្ថុនិងហិរញ្ញវត្ថុសាធារណៈក្នុងការបង្កើនសកម្ម



អ្នកនេសាទកំពុងជញ្ជូនត្រីតូចៗដែលនេសាទបានក្នុងបឹងទន្លេសាប-ខេត្តសៀមរាប

ភាពសេដ្ឋកិច្ចសង្គមកិច្ច ទោះបីជាអតិផរណានៅក្នុងតំបន់និងពិភពលោកមានកម្រិតខ្ពស់ ហើយប្រាក់ដុល្លារគ្មានស្ថិរភាពក៏ដោយ។

អត្រាប្តូរប្រាក់មានស្ថិរភាពល្អធៀបជាមួយប្រាក់ដុល្លារអាមេរិក ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានតម្លៃជាមធ្យម៤.០២៥រៀលក្នុង១ដុល្លារអាមេរិក នៅឆ្នាំ២០១៣។ ប្រាក់រៀលរឹងមាំបន្តមានស្ថេរភាព ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា ជាពិសេសកំណើនខ្ពស់ក្នុងវិស័យកសិកម្ម និងការជឿទុកចិត្តពីសាធារណជននិងជាពិសេសការបន្តអនុវត្តគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុសមស្រប។ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ជាកម្មវត្ថុចម្បង គឺដើម្បីរក្សាតុល្យភាពនៃការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុកការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោកនិងការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។

នៅឆ្នាំ២០១៣ ឱនភាពគណនីចរន្តបានកើនឡើងវិញដល់៩,៤៥% នៃផ.ស.ស. ពីចំនួន ១០,២២% នៃផ.ស.ស. កាលពីឆ្នាំ២០១២ ដោយសារការកើនឡើងការនាំចូលវត្ថុធាតុដើម និងឧបករណ៍បរិក្ខារផលិតកម្មនៃវិនិយោគផ្ទាល់ពីបរទេស។ ឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះនៅឆ្នាំខាងមុខដែលនិន្នាការនៃការធ្លាក់ចុះនេះដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសការនាំចូលជាបណ្តើរៗ។ ទុនបម្រុងអន្តរជាតិមានចំនួន៣.៥៦៤លានដុល្លារអាមេរិក ឬប្រមាណ៤,១ខែនៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុកនៅឆ្នាំ២០១៣។ នៅឆ្នាំខាងមុខទុនបម្រុងត្រូវបានកំណត់ទំហំប្រមាណជាង ៤,៥ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

## ៣. សមិទ្ធផលតាមវិស័យ

### ៣.១. វិស័យកសិកម្ម

ទោះបីកម្ពុជាបានជួបប្រទះគ្រោះមហន្តរាយធម្មជាតិខ្លះៗនាពេលកន្លងមកក្តី វិស័យកសិកម្មក៏នៅតែមានការកើនឡើងជាបន្តបន្ទាប់ ដោយសារកំណើនទិន្នផលកសិផលដូចជា ស្រូវ ពោតដំឡូងមី កៅស៊ូ និងអំពៅជាដើម សម្រាប់ប្រើប្រាស់ក្នុងស្រុក និងផ្គត់ផ្គង់តម្រូវការទីផ្សារអន្តរជាតិ។

ផ្ទៃដីដំណាំស្រូវមានប្រមាណ៧២%នៃផ្ទៃដីដាំដំណាំសរុបនាឆ្នាំ២០១២។ តារាង១.១ បង្ហាញពីទិន្នន័យដែលទាក់ទងនឹងវិស័យកសិកម្ម។ ទោះបីជាទិន្នផលស្រូវបានកើនឡើងយ៉ាងឆាប់រហ័សក៏ដោយក៏ផលិតកម្មស្រូវនេះមិនទាន់មានសក្តានុពលគ្រប់គ្រាន់នៅឡើយ ដែលអាចទទួលបានទិន្នផលពីចន្លោះពី៤ទៅ៥តោនក្នុងមួយហិកតា ដែលប្រទេសចិន និងវៀតណាមសម្រេចបាននូវទិន្នផលនេះរួចហើយ។ រាជរដ្ឋាភិបាលកំពុងលើកកម្ពស់ប្រព័ន្ធស្រោចស្រព ការសាងសង់ទំនប់ប្រព័ន្ធជាពាសាស្ត្រធំៗ រួមទាំងប្រឡាយចែកចាយទឹក និងពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកសម្រាប់ការប្រើប្រាស់ទឹកឱ្យអស់លទ្ធភាព។ នៅពេលថ្មីៗនេះ ផ្ទៃដីដំណាំគ្រប់ប្រភេទបានកើនឡើងប្រមាណ ៥% រៀងរាល់ឆ្នាំ ដោយសារការកើនឡើងនៃផលិតកម្មកសិកម្ម និងចំណូលរបស់កសិករ។ ប៉ុន្តែនិន្នាការនេះនៅមិនទាន់អាចសម្រេចបានប្រកបដោយចីរភាពនៅឡើយទេ ដោយសារទំហំផ្ទៃដីមានកំណត់។ ដូចនេះ កំណើននៅពេលអនាគតនឹងត្រូវទទួលបានពីកំណើនទិន្នផលនៃផលិតកម្មដំណាំស្រូវឬដំណាំផ្សេងៗទៀត។

ការវិនិយោគលើដំណាំឧស្សាហកម្ម ជាពិសេសដំណាំកៅស៊ូកាន់តែមានសកម្មភាពខ្លាំងក្លាឡើងដោយសារការរឹតបន្តឹងការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ហើយផលិតកម្មកៅស៊ូនឹងបន្តកើនឡើងក្នុងកម្រិតខ្ពស់ដោយសារផ្ទៃដីដំណាំកៅស៊ូដល់ពេលប្រមូលផលមានចំនួនកាន់តែច្រើនខណៈដែលកៅស៊ូនៅលើទីផ្សារអន្តរជាតិនៅតែមានតម្លៃសមរម្យ។ រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដាក់បន្ថែមទៀតលើ ការវិនិយោគក្នុងវិស័យបសុសត្វ និងវារីវប្បកម្ម។

**តារាងទី១.១ ៖ ទិន្នន័យវិស័យកសិកម្ម**

| ឆ្នាំ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| ទិន្នផលស្រូវ (តោន/ហិកតា) | ២,៧៥ | ២,៨៤ | ២,៩៧ | ៣,១៧ | ៣,១៧ | ៣,៣ |
| ផ្ទៃដីដំណាំគ្រប់មុខ រួមទាំងដំណាំអចិន្ត្រៃយ៍ | ៣.៣១៩.៩៣៥ | ៣.៦៩៣.៥២៣ | ៣.៣១៩.៩៦១ | ៤.២០៣.២៥០ | ៤.៣៩៤.៥៣៤ | ៤.៥០៥.២៦៧ |
| ផ្ទៃដីស្រូវដែលបានប្រមូលផល(ហិកតា) | ២.៦១៣.៣៦៣ | ២.៦៧៤.៦០៣ | ២.៧៧៧.៣២៣ | ២.៧៦៦.៦១៧ | ២.៩៨០.២៩៧ | ២.៩៦៨.៩៦៣ |
| % ផ្ទៃដីកសិកម្ម ទទួលបានការស្រោចស្រព | ៤២,០ | ៤១,៨ | ៤១,៥ | ៤៦,៨ | ៤៧,៧ | |

*ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម*

### ៣.២. ឧស្សាហកម្ម

**ផលិតកម្ម ៖** ផ្នែកឧស្សាហកម្មបានបង្ហាញពីភាពរីកចម្រើនយ៉ាងឆាប់រហ័សនាក្នុងទសវត្សរ៍ចុងក្រោយនេះ។ បន្ទាប់ពីការធ្លាក់ចុះក្នុងឆ្នាំ២០០៩ ដោយសាររងផលប៉ះពាល់ពីវិបត្តិហិរញ្ញវត្ថុពិភពលោកមក ផលិតកម្មសម្លៀកបំពាក់បានកើនឡើងវិញយ៉ាងឆាប់រហ័សរហូតដល់ចំណុចកំពូល។ ចំណែកវិស័យសំណង់ក៏បានចាប់ផ្តើមកើនឡើងវិញនៅឆ្នាំ២០១១។

គោលនយោបាយនាំចេញទៅសហគមន៍អឺរ៉ុបនៅបន្តមិនយកពន្ធក្រោមកម្មវិធី "ទំនិញគ្រប់មុខលើកលែងតែសព្វាវុធ" និងសក្តានុពលដែលអាចពង្រីកផលិតកម្ម និងទីផ្សារនៃវិស័យនេះ ព្រមទាំងការជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម គឺជាកត្តាជំរុញការរីកចម្រើនផ្នែកឧស្សាហកម្ម។ ម្យ៉ាងវិញទៀតគោលនយោបាយស្តីពីការជំរុញផលិតកម្ម



ផ្លូវកសាងថ្មីៗកាត់ព្រៃ-ខេត្តកោះកុង

ស្រូវ និងការនាំចេញអង្ករ ក៏បានជំរុញឱ្យមានការកើនឡើងខ្ពស់ខាងវិស័យកែច្នៃម្ហូបអាហារ និងវិស័យដែលទាក់ទងមួយចំនួនទៀត ដែលបានបង្កើនតម្លៃបន្ថែមលើផលិតផលដែលមានស្រាប់។ លើសពីនេះ គម្រោងវិនិយោគមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី និងអគ្គិសនីប្រើប្រាស់ធ្យូងថ្មបានដាក់ឱ្យដំណើរការជាបន្តបន្ទាប់ និងឧស្សាហកម្មធុនស្រាលដទៃទៀតក៏បង្កើនសកម្មភាពកាន់តែខ្លាំងក្លាដែរ។

### ថាមពលអគ្គិសនី

ការប្រើប្រាស់ថាមពលអគ្គិសនីសម្រាប់មនុស្សម្នាក់ បានកើនឡើងជាមធ្យមប្រមាណ១៤% ក្នុងមួយឆ្នាំ គឺកើនពី១៣៩kWh នៅឆ្នាំ២០០៨ ដល់២៦៨kWh នៅឆ្នាំ២០១៣។ ប្រភពអគ្គិសនីដែលកម្ពុជាមាននៅដំណាច់ឆ្នាំ២០១៣នេះ អាចគ្របដណ្តប់បានស្ទើរទាំងស្រុងលើសេចក្តីត្រូវការប្រើប្រាស់។ ចំនួននៃបណ្តាញអគ្គិសនីគ្រប់ប្រភេទដែលបានដាក់ឱ្យដំណើរការ ក្នុងរយៈពេលពីឆ្នាំ២០០៨ ដល់ឆ្នាំ ២០១៣ មានការកើនឡើងខ្លាំងគួរឱ្យកត់សម្គាល់ ធ្វើឱ្យភូមិចំនួន៥១% នៅទូទាំងប្រទេសនៅឆ្នាំ២០១៣ បានទទួលការផ្គត់ផ្គង់ពីបណ្តាញអគ្គិសនី។ បញ្ហាប្រឈមសំខាន់ៗបន្តទៀត គឺការពង្រីកផលិតកម្មអគ្គិសនីឱ្យទាន់កំណើននៃសេចក្តីត្រូវការ និងការបង្កើនវិសាលភាពនៃបណ្តាញផ្គត់ផ្គង់ឱ្យគ្របដណ្តប់លើភូមិដែលនៅសល់ឱ្យកាន់តែឆាប់រហ័ស និងការរៀបចំថ្លៃអគ្គិសនីឱ្យកាន់តែបានសមរម្យសម្រាប់អ្នកប្រើប្រាស់។

### ហេដ្ឋារចនាសម្ព័ន្ធ

វិស័យហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រផ្នែកឧស្សាហកម្ម ក៏មានការរីកចម្រើនដែរដោយរហូតមកដល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានផ្លូវជាតិប្រវែង៥៦២៣គ.ម. ផ្លូវខេត្តមានប្រវែង៦៦៤១គ.ម.។ ប៉ុន្តែ ប្រវែងផ្លូវនេះនៅមិនទាន់បំពេញបាននូវតម្រូវការគ្រប់គ្រាន់ ជាពិសេសនៅពេលកម្ពុជាមិនទាន់មានផ្លូវដែកគ្រប់គ្រាន់។ កំណើនការសាងសង់ផ្លូវថ្នល់និងស្ពានបានកើនឡើងយ៉ាងឆាប់រហ័សដែលមានប្រវែងពី៦០០គ.ម. ទៅ ៧០០គ.ម. ក្នុងមួយឆ្នាំ សម្រាប់ផ្លូវថ្នល់សំខាន់ៗ។ កំពង់ផែសមុទ្រស្វយ័តខេត្តព្រះសីហនុទទួលទំនិញអន្តរជាតិច្រើនជាងគេ។ កម្ពុជាមានកំពង់ផែសមុទ្រជាច្រើនដែលមានទីតាំងនៅក្នុងខេត្តកោះកុងនិងកំពត។ ផ្លូវទឹករបស់កម្ពុជាមានប្រមាណ១.៧៥០គ.ម.។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានចាប់ផ្តើមការងារស្តារនិងកែលម្អផ្លូវដែកប្រវែង២៦៥គ.ម. ពីសំរោងទៅបាត់ដឹងក្នុងតំបន់ភាគខាងត្បូងប្រទេស និងផ្លូវដែកប្រមាណជា ៧១គ.ម. ពីស្វាយស៊ីសុផុនទៅប៉ោយប៉ែត នៅតំបន់ភាគខាងជើងប្រទេស។ ការសិក្សាពីបុរេលទ្ធភាពត្រូវបានរៀបចំឡើងសម្រាប់តភ្ជាប់ពីខេត្តបាត់ដំបងជាមួយនឹងត្រពាំងស្រែ និងប៉ោយប៉ែតជាមួយខេត្តសៀមរាប។ នៅពេលផ្លូវទាំងនេះដាក់ឱ្យដំណើរការកម្ពុជានឹងមានភាពងាយស្រួលក្នុងការតភ្ជាប់រវាងតំបន់នានាក្នុងប្រទេសទាំងមូល និងជាមួយនឹងបណ្តាប្រទេសអាស៊ាន។

## ៣.៣. សេវាកម្ម

**ទេសចរណ៍** ៖ ផ្នែកសេវាមានការរីកលូតលាស់ខ្ពស់ដោយសារការកើនឡើងវិស័យទេសចរណ៍វិស័យដឹកជញ្ជូន វិស័យហិរញ្ញវត្ថុ និងវិស័យសេវាបម្រើម្ចាស់អចលនទ្រព្យ។ វិស័យហិរញ្ញវត្ថុដែលជាស្នូលទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចទូទៅនឹងបន្តកើនឡើងក្នុងល្បឿនលឿននិងស្ថិរភាពគោលនយោបាយរូបិយវត្ថុ។ វិស័យអចលនទ្រព្យនិងសំណង់នឹងបន្តកើនឡើងដោយសារតម្រូវការមានការកើនឡើងតាមរយៈលំហូរទុនចូលពីវិនិយោគបរទេស និងកំណើនសេដ្ឋកិច្ចខ្ពស់។

វិស័យទេសចរណ៍មានការទាក់ទាញ ដោយចំនួនភ្ញៀវទេសចរមានការកើនឡើងវិញយ៉ាងឆាប់រហ័សក្នុងឆ្នាំ២០១០ ដែលមានភ្ញៀវទេសចរប្រមាណ២,៥១លាននាក់ គឺបានកើនឡើងប្រមាណ១៦%ធៀបនឹងឆ្នាំ២០០៩។ ក្នុងឆ្នាំ២០១១ មានភ្ញៀវទេសចរណ៍ប្រមាណ២,៨៨លាននាក់ ឆ្នាំ២០១២ មានភ្ញៀវទេសចរណ៍ប្រហែល៣,៥៨លាននាក់ និងឆ្នាំ២០១៣ មានភ្ញៀវទេសចរប្រហែល៤,២២លាននាក់ ក្នុងនោះភ្ញៀវទេសចរណ៍មកពីអាស៊ីមានចំនួនច្រើនជាងគេ។ ភ្ញៀវទេសចរណ៍មកពីប្រទេសអឺរ៉ុប និងអាមេរិកមានកំណើនប្រមាណ១២%ទៅ១៣% ក្នុងឆ្នាំ២០១២ ធៀបនឹងឆ្នាំ២០១១ ទោះបីសេដ្ឋកិច្ចប្រទេសលោកខាងលិចនៅមានបញ្ហាក្នុងរយៈពេលនោះក៏ដោយ។ នៅឆ្នាំ២០១២ វិស័យទេសចរណ៍បាននាំមកនូវចំណូលប្រមាណ២.២១០លានដុល្លារអាមេរិក និងប្រមាណ២.៥៤៧លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣។ វិស័យនេះ ក៏បានផ្តល់កាលានុវត្តភាពការងារជាច្រើនដល់ប្រជាពលរដ្ឋ និងផ្តល់ប្រាក់ចំណូល សម្រាប់លើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រ។



កសិករកំពុងប្រមូលផលស្រូវសរីរាង្គ-ខេត្តព្រៃវែង

ការអភិវឌ្ឍវិស័យទេសចរណ៍សម្រេចបានដោយពឹងផ្អែកមួយភាគធំលើការទស្សនាតំបន់អង្គរ ដែលជាគោលដៅទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ និងភ្នំពេញជារាជធានីភ្នំពេញ។ការធ្វើពិពិធកម្មទៅជាកន្លែងទាក់ទាញផ្សេងទៀតដូចជាតំបន់ឆ្នេរសមុទ្រតំបន់អេកូទេសចរណ៍យុទ្ធសាស្ត្រការអភិវឌ្ឍទេសចរណ៍បៃតងកំពុងត្រូវបានយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្ម។

### ៣.៤. កម្លាំងពលកម្ម

ដំណើរការនៃកំណើន ជាពិសេស វិស័យប្រពលវប្បកម្ម ពលកម្មបានធ្វើឱ្យមានការផ្ទេរពលករ ពីសកម្មភាពកសិកម្មស្រែចំការទៅសកម្មភាពមិនមែនកសិកម្ម។ក្នុងឆ្នាំ២០០៩ប្រមាណជា៦៦%នៃពលករបានធ្វើការក្នុងវិស័យកសិកម្មស្រែចំការដែលក្រោយមកបានថយចុះមកត្រឹម៦២% នៅក្នុងឆ្នាំ២០១១។

### ៣.៥. អភិបាលកិច្ច

អត្រាវិនិយោគក្នុងឆ្នាំថ្មីៗនេះមានប្រមាណ២៤%ទៅ២៥% នៃផលិតផលក្នុងស្រុកសរុប។ វិនិយោគផ្ទាល់ពីបរទេសកើនឡើងក្នុងឆ្នាំ២០០៧ បានលាក់ចុះបន្តិចក្នុងឆ្នាំ២០០៨ និងបានកើនឡើងខ្ពស់បន្ទាប់ពីឆ្នាំ២០០៩។ ការកើនឡើងនៃការវិនិយោគនេះបង្ហាញពីជំនឿទុកចិត្តរបស់អ្នកវិនិយោគហើយក៏បានឆ្លុះបញ្ចាំងពីអភិបាលកិច្ចក្នុងវិស័យសេដ្ឋកិច្ចត្រូវបានលើកកម្ពស់។

រាជរដ្ឋាភិបាលកម្ពុជា ធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការធ្វើកំណែទម្រង់ សំដៅលើកកម្ពស់អភិបាលកិច្ចល្អ។ សមាសធាតុទាំង ៤ នៃអភិបាលកិច្ចល្អ រួមមាន៖

១. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

២. កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

៣. កំណែទម្រង់រដ្ឋបាលសាធារណៈ

៤. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

## ៤. គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា-ខ្លឹមសារសង្ខេប

ឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (គ.អ.ស.) ដែលមានចំនួន៨គោលដៅ ដោយមានការកែសម្រួលតាមលក្ខខណ្ឌស្ថានភាពជាក់ស្តែងនៃប្រទេសកម្ពុជា។ ជាលទ្ធផលគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.) ត្រូវបានរៀបចំឡើងដោយ មានការបន្ថែមនូវគោលដៅការបោសសម្អាតមីនយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការជួយសង្គ្រោះជនរងគ្រោះជាគោលដៅទី៩នៃគ.អ.ស. មូលហេតុដោយសារតែសង្គ្រាមកាលពីជាងពីរទសវត្សរ៍មុន បានបន្សល់ទុកផ្ទៃដីជាច្រើនមានគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។

តារាង១.២ គោលដៅអភិវឌ្ឍន៍សហប្សវត្សរ៍កម្ពុជា

1 គោលដៅទី១ លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ

2 គោលដៅទី២ សម្រេចឱ្យបានសកលកម្មការអប់រំបឋមសិក្សា

3 គោលដៅទី៣ លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

4 គោលដៅទី៤ កាត់បន្ថយមរណភាពកុមារ

5 គោលដៅទី៥ លើកកម្ពស់សុខភាពមាតា

6 គោលដៅទី៦ ប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត

7 គោលដៅទី៧ ធានាចីរភាពបរិស្ថាន

8 គោលដៅទី៨ បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍

9 គោលដៅទី៩ ការបោសសម្អាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការជួយជនរងគ្រោះ



កសិករកំពុងនេសាទត្រីតាមវាលស្រែនាជាយក្រុងភ្នំពេញ

ដូចបានបញ្ជាក់ពីខាងដើមរាជរដ្ឋាភិបាលបានកំណត់ចំណុចដៅនិងសូចនាកររបស់គ.អ.ស.ក. ឱ្យត្រូវតាមស្ថានភាពពិតរបស់ប្រទេស។ ចំណុចដៅនានារបស់គ.អ.ស.ក. មិនតម្រូវឱ្យសម្រេចបានដូចគ្នានឹងគោលដៅដូចមានក្នុងគ.អ.ស.ទ្បើយ ឧទាហរណ៍ការកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាល ឬអត្រាមរណភាពឱ្យបាន១ភាគ៣ជាដើម។ ដូចនេះរាជរដ្ឋាភិបាលបានកែសម្រួលចំណុចដៅសម្រាប់សូចនាករស្ទើរតែទាំងអស់ដែលបន្សីគ្នាជាមួយចំណុចដៅនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ ដោយផ្អែកលើចំណុចដៅថ្មីៗ។ ក្នុងករណីនេះ ចំណុចដៅតាមវិស័យនៅក្នុងផែនការត្រូវបានកែសម្រួលឱ្យស៊ីគ្នាជាមួយគ.អ.ស.ក. (ដែលត្រូវបានកែសម្រួលក្នុងឆ្នាំ២០០២-២០០៣)។ សមាសធាតុ របស់គ.អ.ស.ក. ពាក់ព័ន្ធនឹងបណ្តាក្រសួង ទាំងវិស័យសង្គមកិច្ចទាំងវិស័យសេដ្ឋកិច្ចដូចនេះសមាសធាតុទាំងនោះ គឺជាផ្នែករួមមួយនៃដំណើរការរៀបចំផែនការដែលមានរយៈពេល៥ឆ្នាំ។

## របាយការណ៍វឌ្ឍនភាពនៃការសម្រេចបានគ.អ.ស.ក.

សម្រាប់របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការសម្រេចបានគ.អ.ស.ក. ឆ្នាំ២០១៣នេះកម្ពុជាបានរៀបចំធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំស្តីពីវឌ្ឍនភាពក្នុងការអនុវត្តផែនការរយៈពេល៥ឆ្នាំដោយផ្តោតលើ គ.អ.ស.ក.។ របាយការណ៍ឆ្នាំ២០១៣នេះ គឺជារបាយការណ៍លើកទី៤ដែលបានបង្ហាញនិងពិភាក្សាពីបញ្ហាទាំងអស់ដែលកើតមានជាពិសេសផ្តោតលើថ្នាក់ក្រោមជាតិ។ របាយការណ៍នេះ ក៏ផ្តោតផងដែរលើកម្រិតវិសមភាព និងបង្ហាញពីក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដោយផ្អែកលើបណ្តាសមិទ្ធផលដែលសម្រេចបាននាពេលកន្លងមក និងការពិភាក្សាលម្អិតជាមួយមន្ត្រីរាជរដ្ឋាភិបាលកម្រិតខ្ពស់ និងស្ថាប័នដៃគូអភិវឌ្ឍនានា។ របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការសម្រេចបាន គ.អ.ស.ក. ឆ្នាំ២០១៣នេះ គឺជាការងារលើកដំបូងដែលបានដាក់បញ្ចូលក្របខ័ណ្ឌពន្លឿនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

# ជំពូកទី ២

# ការសម្រេចបាន គ.អ.ស.ក.

## សេចក្តីផ្តើម

ជំពូកនេះនឹងបង្ហាញពីវឌ្ឍនភាពនៃគោលដៅទាំង៩ របស់គ.អ.ស.ក. នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទិន្នន័យត្រូវបានបំបែកទៅដល់ថ្នាក់ខេត្ត។ ដោយឡែករបាយការណ៍មួយចំនួនបានបង្ហាញពីស្ថានភាពនៅថ្នាក់ក្រោមជាតិ ដោយសារផ្អែកលើទិន្នន័យរបស់គម្រោងដូច្នេះ របាយការណ៍ទាំងនោះមិនបង្ហាញពីបណ្តាចំណុចដៅ និងសូចនាកររបស់គ.អ.ស.ក. ឱ្យបានសព្វគ្រប់ឡើយ។ ប៉ុន្តែរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនៃការសម្រេចបាន គ.អ.ស.ក ឆ្នាំ២០១៣ គឺជារបាយការណ៍គ.អ.ស.។

**ដែនកំណត់៖** ទោះបីជាទិន្នន័យមួយចំនួនមិនត្រូវបានផលិតឡើងជាប្រចាំឆ្នាំក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងមួយត្រូវបានធ្វើឡើង សំដៅរៀបចំទិន្នន័យពីសមិទ្ធផលនានាឱ្យមានបច្ចុប្បន្នភាព។ ទិន្នន័យត្រូវបានផលិតឡើងជាក្រាហ្វិកដែលធ្វើនៅក្នុងកម្មវិធី Excel ហើយទិន្នន័យប៉ាន់ស្មានត្រូវបានធ្វើនៅក្នុងកម្មវិធីSTATA។

រូបភាពស្មុគស្មាញ ដូចជាផែនទី ឬក្រាហ្វិក3-D មិនត្រូវបានប្រើឡើយ។

### 1 គោលដៅទី១ លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ

ចំណុចដៅផ្សេងៗក្នុងគោលដៅនេះ មានដូចខាងក្រោម៖

១. កាត់បន្ថយសមាមាត្រប្រជាជនដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រមកនៅតិចជាងឬស្មើ១៩,៥% និងសមាមាត្រប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន ឱ្យបានតិចជាងឬស្មើ១០% ក្នុងឆ្នាំ២០១៥។

២. បង្កើនចំណែកនៃលទ្ធភាពចំណាយរបស់ប្រជាជនក្រីក្របំផុត ២០% ក្នុងចំណោមប្រជាជនទាំងអស់ ឱ្យបានច្រើនជាងឬស្មើ ១០% ក្នុងឆ្នាំ២០១៥។

៣. កាត់បន្ថយប្រេវ៉ាឡង់នៃកុមារខ្វះទម្ងន់ (អាយុក្រោម៥ឆ្នាំ) មកនៅតិចជាងឬស្មើ១៩%កុមារក្រិន(អាយុក្រោម៥ឆ្នាំ) មកនៅតិចជាងឬស្មើ២៥% កុមារស្គមស្គាំង(ក្រោម៥ឆ្នាំ) មកនៅតិចជាងឬស្មើ៦% ក្នុងឆ្នាំ២០១៥។

៤. កាត់បន្ថយប្រេវ៉ាឡង់កង្វះគ្រាប់ឈាមរបស់ក្មេងអាយុ៦-៩ខែមកត្រឹម៤២%និងស្ត្រីអាយុ១៥-៤៩ឆ្នាំមក៤២%ក្នុងឆ្នាំ២០១៥។

៥. បង្កើនសមាមាត្រគ្រួសារប្រើប្រាស់អំបិលអ៊ីយ៉ូដឱ្យដល់៩០% ក្នុងឆ្នាំ២០១៥។

៦. កាត់បន្ថយប្រេវ៉ាឡង់ពលកម្មកុមារ (ឱ្យតិចជាងឬស្មើអាយុ ១៧ឆ្នាំ) មកនៅតិចជាងឬស្មើ៨%ក្នុងចំណោមកុមារសរុបនៅក្នុងក្រុមអាយុនេះ នាឆ្នាំ២០១៥។

## ១.១. ភាពក្រីក្រ និងវិសមភាព

**ទិន្នន្នាការភាពក្រីក្រ ៖** រវាងទសវត្សរ៍ឆ្នាំ១៩៩០ និងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ភាពក្រីក្រដោយប្រើខ្សែបន្ទាត់ភាពក្រីក្រដែលត្រូវបានរៀបចំឡើងដោយធនាគារពិភពលោកក្នុងឆ្នាំ១៩៩៧ ដោយផ្អែកលើទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៣-១៩៩៤ ជាលើកដំបូង។ ក្នុងឆ្នាំ១៩៩៣-១៩៩៤អត្រាភាពក្រីក្រមានប្រមាណ៣៩% ដែលមានន័យថាគោលដៅរបស់ គ.អ.ស.ក. នឹងត្រូវកាត់បន្ថយអត្រាភាពក្រីក្រឱ្យមកនៅត្រឹម១៩,៥% សម្រាប់ឆ្នាំ២០១៥។

យោងតាមខ្សែបន្ទាត់ភាពក្រីក្រចាស់នេះ អត្រាភាពក្រីក្រមានកម្រិត ១៤,៦% នៅឆ្នាំ២០០៩ដែលមានន័យថាចំណុចដៅនេះសម្រេចបានរួចហើយ។ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានកំណត់ខ្សែបន្ទាត់ភាពក្រីក្រឡើងវិញក្នុងឆ្នាំ២០១១។ ចំណុចដៅសម្រាប់ការកាត់បន្ថយភាពក្រីក្រនឹងបន្តសម្រេចបានក្នុងអត្រា១៩,៥%នៅឆ្នាំ២០១៥ទោះបីជាមានការកែសម្រួលខ្សែបន្ទាត់ភាពក្រីក្រក៏ដោយ។

### ប្រអប់ទី២.១ ខ្សែបន្ទាត់ភាពក្រីក្រ

១. ខ្សែបន្ទាត់ភាពក្រីក្រម្ហូបអាហារ ត្រូវបានកំណត់និយមន័យថាជាចំណាយលើម្ហូបអាហារស្មើនឹង២២០០គីឡូកាឡូរីនៅក្នុងកញ្ចប់ម្ហូបអាហារ។លទ្ធភាពចំណាយលើម្ហូបអាហារត្រូវបានធ្វើការបែងចែកដើម្បីឆ្លុះបញ្ចាំងពីលទ្ធភាពចំណាយលើម្ហូបអាហាររបស់ប្រជាជនក្រុមទី៥ ដល់ក្រុមទី៣០។ ដូច្នេះ គំរូអាហារូបត្ថម្ភ ដែលស្មើនឹង២ ២០០ គីឡូកាឡូរីត្រូវបានយកមកប្រើប្រាស់សម្រាប់ការគណនាខុសបែន្ទាត់ភាពក្រីក្រម្ហូបអាហារនៅទូទាំងប្រទេសកម្ពុជា។

២. ចំណាយលើទំនិញមិនមែនម្ហូបអាហារ គឺជាតម្លៃមធ្យមនៃទំនិញមិនមនែម្ហូបអាហារដលែមានប្រមាណ២០% ទៅ៣០% នៃចំណាយសរុបសម្រាប់មនុស្សម្នាក់ៗដែលត្រូវបានគណនាដាច់ដោយឡែកសម្រាប់តំបន់ជនបទតំបន់ទីប្រជុំជននិងរាជធានីភ្នំពេញ។

៣. ចំណាយលើទឹកស្អាតត្រូវបានរាប់បញ្ចូលជាលើកដំបូងនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

***សម្គាល់៖** រាល់ការគណនាទាំងអស់ត្រូវបានធ្វើឡើងដោយប្រើទិន្នន័យ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាដែលរៀបចំឡើងប្រចាំឆ្នាំចាប់តាំងពីឆ្នាំ២០០៧មក។*

និន្នាការថ្មីនៃអត្រាភាពក្រីក្រដោយផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រថ្មីមានបង្ហាញក្នុងរូបភាពទី២.១។ ចំណុចដៅសម្រាប់កាត់បន្ថយនូវសមាមាត្រប្រជាជន ដែលមានប្រាក់ចំណូលទាបជាងខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឱ្យបានពាក់កណ្ដាលរវាងឆ្នាំ១៩៩០ និងឆ្នាំ២០១៥ (ឧទាហរណ៍ កាត់បន្ថយភាពក្រីក្រឱ្យមកនៅត្រឹម១៩,៥%) ជិតសម្រេចបានហើយទោះបីជាមានការកែសម្រួលខ្សែបន្ទាត់ភាពក្រីក្រក្ដី។ នេះគឺជាសមិទ្ធផលដ៏សំខាន់មួយដែលជាលទ្ធផលនៃកំណើនសេដ្ឋកិច្ចពីរខ្ទង់នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) សម្រាប់រយៈពេល៣ទៅ៤ឆ្នាំនគរូបនីយកម្មការស្រូបកម្លាំងពលកម្មក្នុងវិស័យមិនមែនកសិកម្មនិងការកាត់បន្ថយវិសមភាព។

ការគណនាដោយផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រថ្មីបានបង្ហាញថា អត្រាភាពក្រីក្រនៅតាមតំបន់ជនបទបានកាត់បន្ថយពីកម្រិត ៥៣% ក្នុងឆ្នាំ២០០៧មកប្រហែលជា២១% ក្នុងឆ្នាំ២០១១ដោយមានការធ្លាក់ចុះខ្លាំងរវាងឆ្នាំ២០០៨ និងឆ្នាំ២០០៩។ ការធ្លាក់ចុះនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងនិន្នាការរួមនៃការធ្លាក់ចុះនៃអត្រាភាពក្រីក្រនៅពេលដែលសមាមាត្រចំនួនប្រជាជនរស់នៅតំបន់ជនបទមានជិត៨០%នៃប្រជាជនសរុប។ ទន្ទឹមនេះ អត្រាភាពក្រីក្រក៏បានធ្លាក់ចុះផងដែរ នៅតាមតំបន់ទីប្រជុំជន និងរាជធានីភ្នំពេញ។ ចំណុចដែលគួរឱ្យកត់សម្គាល់នោះគឺ និន្នាការនៃការថយចុះនៃអត្រាភាពក្រីក្រ គឺបណ្ដាលមកពីការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃអត្រាភាពក្រីក្រនៅតំបន់ជនបទ ដែលតំបន់ទាំងអស់នោះ ត្រូវបានធ្វើការវិនិយោគប្រកបដោយចីរភាពក្នុងវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទ។

រូបភាពទី២.១៖ និន្នាការអត្រាភាពក្រីក្រនៅកម្ពុជា ពីឆ្នាំ២០០៧-២០១១




| | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|
| កម្ពុជា | 47.8 | 29.9 | 22.9 | 21.1 | 19.8 |
| ភ្នំពេញ | 19.1 | 13.6 | 12.8 | 12.4 | 10.9 |
| ទីប្រជុំជនផ្សេងទៀត | 41 | 30.5 | 19.2 | 17 | 22.5 |
| ជនបទ | 53.2 | 31.9 | 24.6 | 22.7 | 20.7 |

*ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

## អត្រាភាពក្រីក្រនៅថ្នាក់ក្រោមជាតិ

អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាគឺជាប្រភពទិន្នន័យមួយ ដែលប្រមូលទិន្នន័យស្ដីពីលទ្ធភាពចំណាយលើការប្រើប្រាស់ និងជីវភាពរស់នៅរបស់ប្រជាជននៅកម្ពុជា ប៉ុន្តែសំណាកគំរូ និងការរៀបចំមិនបានអនុញ្ញាតសម្រាប់ការវិភាគទៅដល់តាមកម្រិតខេត្តទេ។ ប៉ុន្តែការប្រើប្រាស់ទិន្នន័យឃុំ-សង្កាត់អាចបង្កើតសូចនាករជំនួសភាពក្រីក្រដើម្បីបានសន្ទស្សន៍ភាពក្រីក្រ និងអត្រាភាពក្រីក្រ ( សូមមើលប្រអប់ទី២.២ )។

រូបភាព២.២ ៖ អត្រាភាពក្រីក្រតាមខេត្ត ឆ្នាំ២០១១




*ប្រភព៖ ទិន្នន័យឃុំ-សង្កាត់ និងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

**ប្រអប់ទី២.២ ការគណនាអត្រាភាពក្រីក្រជំនួសនៅថ្នាក់រាជធានី ខេត្ត**

សន្ទស្សន៍ភាពក្រីក្រត្រូវបានគណនាដោយមានអញ្ញាត៥ក្រុម៖

១. ទ្រព្យសម្បត្តិ (ម៉ូតូកង់ផ្ទះនៅក្នុងភូមិ)

២. បរិក្ខារផ្សេងៗ (អគ្គិសនីទឹកស្អាតអនាម័យនៅក្នុងភូមិ)

៣. ធនធានមនុស្ស (អក្ខរភាពការចូលរៀននៅក្នុងភូមិ)

៤. ការងារ/ផលិតភាព (ការងារមិនមែនកសិកម្មផលិតកម្មស្រូវកសិករមានដីតិចជាង១ហិកតាផលធៀបភាពនៅក្នុងបន្ទុកនៅក្នុងភូមិ)

៥. ចម្ងាយផ្លូវ (ចម្ងាយរបស់ភូមិទាំងអស់ពីតំបន់ទីប្រជុំជន)

អត្រាភាពក្រីក្រតាមខេត្ត រាជធានីត្រូវបានគណនា ដោយមានបីដំណាក់កាលដោយប្រើវិធីសាស្ត្រសម្រាប់បង្កើតសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស។

ដំណាក់កាលទី១៖ គណនាសន្ទស្សន៍អញ្ញាតនីមួយៗ (EVI) (សម្រាប់ Xi) = [(Actual (Xi) - Min (Xi)]/[(Max (Xi)- Min_(Xi)]

ដំណាក់កាលទី២៖ គណនាសមាសធាតុសន្ទស្សន៍ភាពក្រីក្រ = SUM (EVI)/k (ដែលk ជាចំនួនអញ្ញាតដែលមានអញ្ញាត្តចំនួន ១៣)

ដំណាក់កាលទី៣៖ គណនាសមាសធាតុសន្ទស្សន៍ភាពក្រីក្រជាមួយអត្រាភាពក្រីក្រជាតិ និងទទួលបានអត្រាភាពក្រីក្រតាមរាជធានីខេត្តអាស្រ័យលើបម្រែបម្រួលនៅក្នុងសមាសធាតុសន្ទស្សន៍ភាពក្រីក្រទាំងអស់តាមរាជធានីខេត្តអញ្ញាតទាំងអស់ត្រូវបានវាស់វែងជាផលធៀបទៅនឹងចំនួនប្រជាជនសរុបដើម្បីជៀសវាងបញ្ហានៃការប្រៀបធៀបខេត្តនៅពេលមានចំនួនប្រជាជននិងដង់ស៊ីតេប្រជាជនមិនស្មើនៅតាមខេត្ត។

ទិន្នន័យនៃអត្រាភាពក្រីក្រជំនួសត្រូវបានបង្កើតឡើងនៅថ្នាក់រាជធានីខេត្ត ដូចក្នុង(រូបភាពទី២.២) ខាងលើ។ ខេត្តទាំងអស់នៅភាគខាងត្បូងនិងខេត្តភាគនិរតី មានប្រជាជនច្រើននិងប្រកបមុខរបរកសិកម្មបែបប្រពៃណីមានអត្រាភាពក្រីក្រទាបជាងប្រជាជនក្នុងខេត្តភាគខាងជើងខេត្តភាគឦសាន និងបណ្តាខេត្តនៅភាគខាងលិច ដូចជា ខេត្តសៀមរាប និងខេត្តបាត់ដំបង។បណ្តាខេត្តភាគឦសាន ដែលមានជនជាតិភាគតិចរស់នៅច្រើនជាតំបន់ដទៃទៀត គួរត្រូវបានផ្តោតការយកចិត្តទុកដាក់។ ខេត្តទាំងនេះភាគច្រើនជាតំបន់ជនបទ និងមិនទាន់បានធ្វើសមាហរណកម្មពេញលេញជាមួយប្រព័ន្ធជាតិ។ ដោយឡែក អត្រាភាពក្រីក្រមានកម្រិតខ្ពស់នៅខេត្តសៀមរាបនិងខេត្តបាត់ដំបងទោះបីជាខេត្តទាំងពីរនេះមានប្រពៃណីប្រកបរបរកសិកម្មក៏ដោយ។ ខេត្តសៀមរាបគឺជាតំបន់ទេសចរណ៍របស់កម្ពុជាចំណែកខេត្តបាត់ដំបងគឺជាខេត្តជង្រុកស្រូវ។ បញ្ហាទាំងនេះតម្រូវឱ្យមានការវិភាគលម្អិតបន្ថែមនិងការស្រាវជ្រាវច្បាស់លាស់ និងដែលជារបៀបវារៈសម្រាប់ការសិក្សាស្រាវជ្រាវនាពេលអនាគត។

## និន្នាការភាពក្រីក្រម្ហូបអាហារ

និន្នាកាភាពក្រីក្រម្ហូបអាហារ (ភាពអត់ឃ្លាន) មានបង្ហាញនៅក្នុងរូបភាពទី២.៣។

**រូបភាពទី២.៣ ៖ និន្នាការក្នុងភាពក្រីក្រម្ហូបអាហារឆ្នាំ២០០៧-២០១១**




| | 2007y | 2008y | 2009y | 2010y | 2011y |
|---|---|---|---|---|---|
| កម្ពុជា | 18.7 | 7.7 | 4.3 | 4.1 | 2.7 |
| ភ្នំពេញ | 0.3 | 0.3 | 0.3 | 0.4 | 0.0 |
| ទីប្រជុំជនផ្សេងទៀត | 16.0 | 7.1 | 2.0 | 3.0 | 2.4 |
| ជនបទ | 21.3 | 8.6 | 5.1 | 4.7 | 3.0 |

*ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*



សុជាតិ អាយុ២៩ឆ្នាំ កំពុងបង់សំណាញ់ក្នុងឃុំបាល័ង្គ-ខេត្តសៀមរាប

ទិន្នន័យនេះបង្ហាញថានៅឆ្នាំ២០០៧ (ឬនៅមុនឆ្នាំ២០០៧ ដែលពុំមានទិន្នន័យបង្ហាញនៅក្នុងឯកសារនេះ)ភាពអត់ឃ្លានបានកើតមាននៅប្រទេសកម្ពុជាទាំងនៅតំបន់ជនបទ ទាំងនៅតំបន់ទីប្រជុំជន (រួមទាំងតំបន់ទីប្រជុំជនដែលនៅក្រៅរាជធានីភ្នំពេញ)។ក្រោយមក ភាពអត់ឃ្លាននេះត្រូវបានថយចុះយ៉ាងច្រើន។ នៅឆ្នាំ២០១១ ភាពអត់ឃ្លាននេះបានធ្លាក់ចុះមកនៅតិចជាង៤%នៅគ្រប់តំបន់។ ពាក់ព័ន្ធនឹងគ.អ.ស. ចំណុចដៅនេះសម្រេចបាននៅដើមឆ្នាំ២០០៨ហើយស្ថានភាពនេះក៏ត្រូវបានធ្វើប្រសើរឡើងចាប់តាំងពីពេលនោះមក។

ភាពក្រីក្រម្ហូបអាហារនឹងមិនមែនជាវិបត្តិតទៅទៀតទេនៅកម្ពុជា។ មូលហេតុមួយក្នុងចំណោមមូលហេតុទាំងអស់ គឺដោយសារមានការពង្រីកផ្ទៃដីដាំដុះដែលធ្វើឱ្យផលធៀបផ្ទៃដី និងកម្លាំងពលកម្មកសិកម្មមិនប្រែប្រួលឬត្រូវបានធ្វើឱ្យប្រសើរឡើងថែមទៀត ទោះបីជាប្រជាជនមានការកើនឡើងក៏ដោយ។ លើសពីនេះ ការកើនឡើងនៃផលិតកម្មស្បៀងអាហារបានធានាដល់លទ្ធភាពមានម្ហូបអាហារដែលនឹងនាំឱ្យភាពក្រីក្រម្ហូបអាហារធ្លាក់ចុះ។ បច្ចុប្បន្ននេះបញ្ហាមិនមានដីកសិកម្មមិនមែនជាប៉ារ៉ាម៉ែត្រសំខាន់ទៀតទេសម្រាប់ការត្រួតពិនិត្យទោះបីវាមិនទាន់ត្រឹមត្រូវទាំងស្រុងនៅក្នុងក្របខ័ណ្ឌផែនការក៏ដោយ។

### ប្រអប់២.៣ ពិពិធកម្មការងារ និងប្រភពចំណូលផ្សេងៗ

ស្ត្រីវ័យក្មេងបានផ្លាស់លំនៅដ្ឋានពីតំបន់ជនបទទៅធ្វើការនៅក្នុងឧស្សាហកម្មកាត់ដេរដោយទទួលបាន ចំណូលសរុបប្រមាណពី៨០ទៅ១២០ដុល្លារអាមេរិក្នុង១ខែ។ ពួកគេអាចផ្ញើលុយកាក់ទៅស្រុកកំណើតប្រហែល៣០ដុល្លារអាមេរិកក្នុង១ខែ។ ប្រាក់បញ្ញើរនេះបានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារនៅក្នុងភូមិមានស្ថិរភាពលែងមានភាពប្រឈមនឹងភាពមិនច្បាស់លាស់ទាក់ទងនឹងបរាជ័យក្នុងការធ្វើស្រូវឬតម្លៃផលិតផលកសិកម្មធ្លាក់ចុះ។ លើសពីនេះទៀតគ្រួសារទាំងនោះអាចបង់រំលោះប្រាក់កម្ចីរបស់ខ្លួនបានទៀតផងប្រសិនបើពួកគេមានខ្ចីប្រាក់។ គ្រួសារជាច្រើនអាចទទួលបានចំណូលពីប្រភពផ្សេងៗទៀតហើយការធ្វើស្រែលែងជាប្រភពចំណូលសំខាន់តែមួយទៀតហើយ។

ស្រដៀងគ្នានេះដែរប្រជាជនដែលទទួលបានដីបោសសម្អាតមីនរួចនៅក្នុងតំបន់នេះទទួលបានចំណូលកាន់តែច្រើនទោះបីដីទាំងនេះមិនសូវមានជីជាតិឬមានទីតាំងនៅតំបន់ដាច់ស្រយាលដែលមិនមានសេវាវិបុលកម្មកសិកម្មនៅទីនោះ។ កសិករជាច្រើនទទួលបានប្រយោជន៍ពីការបោសសម្អាតមីនដោយសារពួកគាត់មានដីធ្លីសម្រាប់ធ្វើកសិកម្មទោះបីជាដីដែលពួកគាត់ស្ថិតនៅតំបន់ដាច់ស្រយាលក៏ដោយ។ កសិករទាំងនោះ សប្បាយចិត្តដោយទទួលបានចំណូលបន្ថែមទៀត។

ចំណាកស្រុកឆ្លងព្រំដែនទៅកាន់ប្រទេសថៃកើតមានច្រើនទោះបីជាមានគ្រោះថ្នាក់ក៏ដោយ។ ការឆ្លងកាត់ព្រំដែនខុសច្បាប់មានការលំបាកនិងអាចប្រឈមនឹងការចាប់ខ្លួនគ្រប់ពេល។ អ្នកធ្វើចំណាកស្រុកភាគច្រើនមិនមានអារម្មណ៍ទុកចិត្តក្នុងការចាកចេញពីគ្រួសារទៅស្វែងអនាគតដែលមិនមានភាពច្បាស់លាស់។ ប៉ុន្តែកង្វះខាតក្នុងជីវភាពរស់នៅបានបង្ខំឱ្យពួកគេធ្វើចំណាកស្រុក។ ចំណូលបានពីការធ្វើចំណាកស្រុកទៅប្រទេសផ្សេងគឺប្រហែលពី៣០០ទៅ៤០០ដុល្លារអាមេរិកក្នុង១ខែសម្រាប់អ្នកធ្វើចំណាកស្រុកខុសច្បាប់។

ប្រជាជនមានការភ័យខ្លាចនៅពេលពួកគេឈឺ។ ជំងឺធ្វើឱ្យពួកគេប្រឈមនឹងការដកចេញពីការងារហើយ ការព្យាបាលក៏មានតម្លៃខ្ពស់។

*ប្រភព៖ បទសម្ភាសន៍នៅបាត់ដំបងព្រៃវែងនិងសៀមរាប*

## គម្លាតភាពក្រីក្រនិងភាពងាយរងគ្រោះ

សន្ទស្សន៍ Foster-Greer-Thorbecke ដែលវាស់វែងគម្លាតភាពក្រីក្រត្រូវបានគណនាដើម្បីវាយតម្លៃគម្លាតភាពក្រីក្រ ដែលពិនិត្យថាតើក្រីក្រដូចម្តេច ហើយមានប៉ុន្មាន។ រូបភាពទី២.៤បង្ហាញថាគម្លាតភាពក្រីក្រមានកម្រិតទាប (តិចជាង៥%) ហើយបានធ្លាក់ចុះជាបន្តបន្ទាប់លើកលែងក្នុងតំបន់ទីប្រជុំជនមួយចំនួនដែលគម្លាតនេះបានកើនឡើងបន្តិច (១%)នៅក្នុងឆ្នាំ២០១១។ ដូចនេះប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រអាចនឹងចាកចេញផុតពីភាពក្រីក្រ។ ភាពក្រីក្រនឹងលែងជាបញ្ហាធំទៀតហើយសម្រាប់កម្ពុជា។

រូបភាពទី២.៥ដែលបង្ហាញពីការបែងចែកចំណាយសរុបបានបង្ហាញថាខ្សែកោងចំណាយបានធ្លាក់ចុះយ៉ាងខ្លាំង។ រូបភាពនេះបង្ហាញថាមានប្រជាជនជាច្រើនបានរស់នៅលើនិងក្បែរខ្សែបន្ទាត់ភាពក្រីក្រ។ ទោះបីភាពក្រីក្រនឹងលែងជាក្តីបារម្ភ ប៉ុន្តែប្រជាពលរដ្ឋដែលរស់នៅលើ និងក្បែរខ្សែបន្ទាត់ភាពក្រីក្រងាយនឹងរងគ្រោះក្នុងធ្លាក់ចូលក្នុងភាពក្រីក្រវិញ។ ដូចនះេបុរសិនបីចំណូលធុលាក់ចុះបុរជាជនជាចុំរនដលែបចចុបុបននាលីខុសែបន្ទាត់ភាពក្រីក្រអាចប្រឈមនឹងការធ្លាក់ទៅក្រោមខ្សែបន្ទាត់ភាពក្រីក្រវិញ។ ជាការពិត បញ្ហានេះអាចនឹងកើតមាននៅពេលមានគ្រោះធម្មជាតិដូចជាទឹកជំនន់ឬគ្រោះរាំងស្ងួតវិបត្តិសេដ្ឋកិច្ចសកលលោកលទ្ធផលពីសមាហរណកម្មសកលលោកជាដើម។

ទោះបីជាកម្ពុជាទទួលបានសមិទ្ធផលល្អប្រសើរនៅក្នុងពេលថ្មីៗនេះក៏ដោយ ក៏ភាពក្រីក្រនៅតែជាក្តីព្រួយបារម្ភនៅឡើយ។ កម្មវិធីប្រយុទ្ធប្រឆាំងភាពក្រីក្រអាចជួយដល់ប្រជាជនជាច្រើនជាពិសេសប្រជាជនក្រីក្របំផុត។

រូបភាពទី២.៤ ៖ និន្នាការក្នុងសន្ទស្សន៍ Foster-Greer-Thorbecke ឆ្នាំ២០០៧-២០១១




*ប្រភព ៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

រូបភាពទី២.៥ ៖ ការបែងចែកចំណាយសរុបរបស់ប្រជាជនតាមក្រុមចំណាយស្មើគ្នា ( ពាន់រៀល )




*ប្រភព ៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

## វិសមភាព

ការវាស់វែងវិសមភាព អាចធ្វើឡើងតាមពីររបៀប គឺចំណែកនៃលទ្ធភាពចំណាយរបស់ក្រុមប្រជាជនក្រីក្របំផុត២០% និងមេគុណជីនី (Gini) នៃវិសមភាព។សម្រាប់វិធីសាស្ត្រទី១ចំណុចដៅ គឺត្រូវសម្រេចឱ្យបាន១១%ចំណែកវិធីសាស្ត្រទី២មិនមានចំណុចដៅនោះទេ។ លទ្ធភាពចំណាយរបស់ប្រជាជនក្រីក្របំផុត បាននិងកំពុងកើនឡើងយឺតៗ ប៉ុន្តែផ្អែកតាមការព្យាករលីណេអ៊ែបង្ហាញថាចំណុចដៅនេះនឹងសម្រេចបាននៅឆ្នាំ២០១៥ (តារាងទី២.១)។

តម្លៃមេគុណជីនី(Gini)នៃវិសមភាពការប្រើប្រាស់ក៏បង្ហាញពីការធ្លាក់ចុះផងដែរ។ មេគុណជីនី (Gini) ដែលមានចំនួន ០,៣១ មានលក្ខណៈប្រសើរជាងប្រទេសជាច្រើនក្នុងអាស៊ីអាគ្នេយ៍ឬតំបន់អាស៊ីទាំងមូល។

តារាងទី២.១ ៖ និន្នាការលើវិសមភាពការប្រើប្រាស់

| ឆ្នាំ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|
| មេគុណ Gini | ០,៤១១ | ០,៣៨១ | ០,៣៤៣ | ០,៣៤១ | ០,៣១៣ |
| ការប្រើប្រាស់របស់ក្រុមប្រជាជនក្រីក្រំផុត២០ភាគរយ | ៦,៨៥ | ៧,៤៦ | ៨,០០ | ៨,៣៤ | ៨,៩៨ |

*ប្រភព ៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

ការធ្លាក់ចុះយ៉ាងខ្លាំងនូវអត្រាភាពក្រីក្រចាប់តាំងពីឆ្នាំ២០០៧មកដូចបានឃើញពីខាងដើម អាចជាផ្នែកមួយសម្រាប់ពន្យល់ ចំពោះការថយចុះនៃវិសមភាពក្នុងសង្គម។



កំពុងដកសំណាបក្នុងស្រែដែលបានបោសសំអាតមីននិងសំណល់មិនទាន់ផ្ទុះក្នុងស្រុកសំឡូត ខេត្តបាត់ដំបង

## ១.២. អាហារូបត្ថម្ភ

### ស្ថានភាពអាហារូបត្ថម្ភ -- កុមារ និងស្ត្រី

ទិន្នន័យក្នុងតារាងទី២.២ បង្ហាញថាកង្វះខាតអាហារូបត្ថម្ភរបស់កុមារនៅមានកម្រិតខ្ពស់នៅឡើយ។ ភាពក្រិនរបស់កុមារបានធ្លាក់ចុះតែ ៣% ប៉ុណ្ណោះ ពោលគឺពី ៤៣% មក ៤០% រវាងឆ្នាំ២០០៥ និងឆ្នាំ២០១០ ដែលជាការធ្លាក់ចុះតិចតួចបំផុតក្នុងរយៈពេល៥ឆ្នាំ។ ប្រសិនបើនិន្នាការនេះនៅតែបន្ត នោះចំណុចដៅ២៥% ក្នុងឆ្នាំ២០១៥ នឹងមិនអាចសម្រេចបានឡើយ។ កុមារខ្វះទម្ងន់មិនបានបង្ហាញពីវឌ្ឍនភាពឡើយ។ ដោយឡែកកុមារស្គមស្គាំងបានកើនឡើងរវាងឆ្នាំ២០០៥ និងឆ្នាំ២០១០។ ប្រេវ៉ាឡង់ស្ត្រី និងកុមារដែលខ្វះគ្រាប់ឈាមក្រហមមិនមានការប្រែប្រួលទេក្នុងរវាងឆ្នាំ២០០៥និងឆ្នាំ២០១០។ សរុបមក មានតែសូចនាករការប្រើប្រាស់អំបិលអ៊ីយ៉ូដទេដែលស្ថិតតាមគន្លងនៃការសម្រេចគោលដៅ។

តារាងទី២.២ ៖ សូចនាករអាហារូបត្ថម្ភ

| | ២០០៥ | ២០១០ | ២០១៥ (ចំណុចដៅ) |
|---|---|---|---|
| កុមារក្រិនអាយុពី ០ ទៅ ៥៩ខែ | ៤៣% | ៤០% | ២៥% |
| កុមារស្គមស្គាំងអាយុពី ០ ទៅ ៥៩ ខែ | ៨% | ១១% | ៦% |
| កុមារខ្វះទម្ងន់អាយុពី ០ ទៅ ៥៩ ខែ | ២៨% | ២៨% | ១៩% |
| ប្រេវ៉ាឡង់កុមារខ្វះគ្រាប់ឈាមក្រហម អាយុពី ៦ ទៅ ៥៩ខែ | ៦២% | ៥៥% | ៤២% |
| ប្រេវ៉ាឡង់ស្ត្រីខ្វះគ្រាប់ឈាមក្រហមអាយុពី ១៥ ទៅ ៥៩ ឆ្នាំ | ៤៧% | ៤៤% | - |
| សមាមាត្រប្រជាជនដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ | ៧៣% | ៨៣% | ៩០% |

*ប្រភព ៖ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០១០*

ការសន្និដ្ឋានណាមួយដោយផ្អែកលើតួរលេខខាងលើនេះអាចជាការប្រញាប់ពេកពីព្រោះថា ស្ថានភាពទាំងអស់នេះមានលក្ខណៈស្មុគស្មាញជាងអ្វីដែលបានពិនិត្យឃើញ។ ការសង្កេតមួយចំនួនមានដូចខាងក្រោម៖

១. អត្រាភាពក្រីក្រធ្លាក់ចុះពីឆ្នាំ២០០៧-២០០៩ ប៉ុន្តែចំណូលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស រីឯ ស្ថានភាពសុខភាពរបស់ប្រជាជនមិនផ្លាស់ប្តូរលឿនឡើយ។ ជាក់ស្តែងបញ្ហាសុខភាពខាងលើនេះមិនមានផលប៉ះពាល់ដល់អត្រាភាពក្រីក្រឡើយ។ ប៉ុន្តែក្នុងរយៈពេល៣ទៅ៥ឆ្នាំខាងមុខបញ្ហាសុខភាព និងភាពក្រីក្រ នឹងមានការផ្លាស់ប្តូរជាច្រើន។

២. កំណើនចំណូលមានកម្រិតតិចតួច (រូបភាពទី២.៥) ហើយមិនមានភាពចាំបាច់ទេថា ប្រជាជនគួរចំណាយបន្ថែមទៀតលើអាហារូបត្ថម្ភកុមារ។ នេះអាស្រ័យលើចំណេះដឹងឥរិយាបទ និងការអនុវត្តរបស់ប្រជាជនដែលមិនចាំបាច់ផ្លាស់ប្តូរក្នុងរយៈពេលខ្លីឡើយជាពិសេសនៅពេលដែលកំណើននៃចំណូលនៅមានកម្រិតទាបនៅឡើយ។

៣. អាហារូបត្ថម្ភ គឺជាបញ្ហាអន្តរវិស័យ។ ឧទាហរណ៍ប្រជាជន (កុមារ) អាចទទួលបានអាហារប៉ុន្តែមិនទទួលបានទឹកស្អាត និងអនាម័យ។ ជាលទ្ធផលក្មេងៗអាចមានជំងឺរាកនិងប៉ារ៉ាស៊ីតក្នុងប្រព័ន្ធរំលាយអាហារដែលធ្វើឱ្យការស្រូបជីវជាតិទៅក្នុងរាងកាយធ្លាក់ចុះ។ ដូចនេះការពង្រីកកម្មវិធីទឹកស្អាតនិងអនាម័យអាចជួយដោះស្រាយបញ្ហានេះបានច្រើននៅពេលអនាគត។

ប្រទេសកម្ពុជា ក៏ដូចជាប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ីដែលសម្រេចបានការកាត់បន្ថយភាពក្រីក្របានយ៉ាងលឿនប៉ុន្តែការកាត់បន្ថយកង្វះអាហារូបត្ថម្ភសម្រេចបានមិនសូវលឿនឡើយ។ ទោះជាដូចនេះក្តីចំណុចដៅនេះអាចនឹងសម្រេចបានក្នុងរយៈពេល២-៣ឆ្នាំខាងមុខ។

## ស្ថានភាពអាហារូបត្ថម្ភតាមរាជធានីខេត្ត

ស្ថានភាពអាហារូបត្ថម្ភរបស់កុមារនៅតាមបណ្តារាជធានី ខេត្តមានលក្ខណៈផ្ទុយពីការរៀបរាប់ខាងលើ (រូបភាពទី២.៦ កនិងខ)។ ទំនាក់ទំនងរវាងអត្រាក្រិននិងខ្វះទម្ងន់នៅតាម រាជធានី ខេត្ត មានកម្រិត០,៨០ មានន័យថាកុមារក្រិនក៏អាចជាកុមារមិនគ្រប់ទម្ងន់ផងដែរ។ ដូចនេះកង្វះអាហារូបត្ថម្ភប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជនម្នាក់ៗ។ ដោយឡែកទំនាក់ទំនងរវាងអត្រាភាពក្រីក្រនិងអត្រាកុមារក្រិននៅតាមបណ្តារាជធានីខេត្តមានកម្រិត០,៥៦ហើយរវាងអត្រាភាពក្រីក្រនិងអត្រាកុមារខ្វះទម្ងន់គឺ០,៥០។ ខេត្តក្រីក្រជាងគេមានសមាមាត្រកុមារខ្វះអាហារូបត្ថម្ភច្រើនជាងគេ។

ការបែងចែកតាមរាជធានី ខេត្ត ដែលខេត្តនៅភាគខាងត្បូងកណ្តាល និងខេត្តភាគនិរតីដូចជារាជធានីភ្នំពេញខេត្តកណ្តាលខេត្តព្រះសីហនុខេត្តកែបខេត្តកំពតនិងខេត្តស្វាយរៀងមានលទ្ធផលល្អប្រសើរជាងខេត្តនៅភាគខាងជើង និងភាគឦសានដូចជាខេត្តរតនគិរីខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តសៀមរាបពាក់ព័ន្ធនឹងស្ថានភាពអាហារូបត្ថម្ភកុមារ (រូបភាព ទី២.៧)។ បញ្ហានេះបង្ហាញពីទំនាក់ទំនងរវាងភាពក្រីក្រជាមួយនឹងស្ថានភាពអាហារូបត្ថម្ភ។

បន្ថែមលើនេះទៀតនៅខេត្តមណ្ឌលគិរីខេត្តរតនគិរីខេត្តស្ទឹងត្រែងខេត្តព្រះវិហារនិងខេត្តសៀមរាបសមាមាត្រកុមារក្រិនលើសពី៥០% និងកុមារខ្វះទម្ងន់ប្រហែលពី៣៥% ទៅ ៤០%។ សកម្មភាពដែលត្រូវអនុវត្តបន្ទាន់ គឺកត្តាជាប់ពាក់ព័ន្ធជាមួយនឹងទឹកស្អាតនិងអនាម័យត្រូវបានដោះស្រាយក្នុងខេត្តទាំងឡាយបន្ថែមលើសកម្មភាពផ្ទាល់មួយចំនួនដូចជាការលើកកម្ពស់សកម្មភាពបង្កើនប្រាក់ចំណូល។

**រូបភាពទី២.៦៖(កនិងខ) កុមារក្រិន និងខ្វះទម្ងន់តាមខេត្តឆ្នាំ២០១០**







*ប្រភព៖ អង្កេតសុខភាពប្រជាសាស្ត្រឆ្នាំ២០១០*

**រូបភាពទី២.៧ ៖ (កនិងខ) ការពង្រាយតាមខេត្តនៃកុមារក្រិន និងកុមារមិនគ្រប់ទម្ងន់តាមភាពក្រីក្រ**







*ប្រភព៖ អង្កេតសុខភាពប្រជាសាស្ត្រឆ្នាំ២០១០ និងរូបភាពទី២.២ខាងលើ*

## ស្ថានភាពអាហារូបត្ថម្ភតាមស្ថានភាពសេដ្ឋកិច្ច

រូបភាពទី២.៨ ដែលដកយកទិន្នន័យពីតារាងទី២.២ តាមស្ថានភាពសេដ្ឋកិច្ចគ្រួសារបង្ហាញថាស្ថានភាពសេដ្ឋកិច្ចគ្រួសារអាចធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពអាហារូបត្ថម្ភ។

ប៉ុន្តែរូបភាពទី២.៨ ក៏បានបង្ហាញផងដែរថា មានកង្វះអាហារូបត្ថម្ភជាពិសេសបញ្ហាកង្វះគ្រាប់ឈាមក្រហមរបស់ស្ត្រី និងកុមារក៏បានពិនិត្យឃើញមាននៅក្នុងគ្រួសារមានចំណូលខ្ពស់មួយចំនួនផងដែរ។

រូបភាពទី២.៨៖ សូចនាករអាហារូបត្ថម្ភសំខាន់ៗតាមស្ថានភាពសេដ្ឋកិច្ចគ្រួសារឆ្នាំ២០១០




| | Lowest20% | 20%-40% | 40%-60% | 60%-80% | highest20% |
|---|---|---|---|---|---|
| Stunded children | 51.1 | 44.4 | 39.3 | 34.2 | 23.1 |
| Underweight children | 35.4 | 32.6 | 27.8 | 24.6 | 15.9 |
| Anaemia in children | 59.6 | 58.8 | 57.4 | 52.2 | 43.4 |
| Anaemia in women | 52.9 | 47.8 | 47 | 43 | 34.4 |

Stunted children — Underweight children — Anaemia in children — Anaemia in women

*ប្រភព៖ អង្កេតប្រជាសាស្ត្រនិងសុខភាពឆ្នាំ២០១០*

បុព្វហេតុទាំងអស់នេះ គឺជាសូចនាករដែលបញ្ជាក់ថាស្ថានភាពសេដ្ឋកិច្ចគ្រួសារធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពអាហារូបត្ថម្ភ ប៉ុន្តែទិដ្ឋភាពផ្សេងៗទៀតដូចជាទម្លាប់បរិភោគអាហារទឹកស្អាតនិងអនាម័យក៏បង្កជាផលប៉ះពាល់ផងដែរ។ គោលនយោបាយកាត់បន្ថយភាពក្រីក្រកំណើនបរិយាប័ន្ន និងកិច្ចខំប្រឹងប្រែងផ្សេងទៀតនឹងត្រូវរួមគ្នាជាមួយទឹកស្អាត និងអនាម័យនិងការប្រែប្រួលនៃចំណេះដឹងឥរិយាបទនិងការអនុវត្តរបស់ប្រជាជន។

## ១.៣. ពលកម្មកុមារ

ច្បាប់របស់កម្ពុជាចែងថាជនណាមានអាយុតិចជាង ១៨ឆ្នាំ មិនអាចចូលរួមក្នុងកម្លាំងពលកម្មបានឡើយ។ ការផ្ទុយនឹងច្បាប់នេះត្រូវបានចាត់ទុកថាជាពលកម្មកុមារ។ ក្នុងឆ្នាំ២០០៩អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាបានប្រមូលទិន្នន័យស្តីពីការចូលរួមតាមស្ថានរំលឹក (Usual Status Engagement) ដែលមានស្ថានភាពរយៈពេលវែង (លើស៦ខែ) របស់មនុស្សម្នាក់ដែលមានអាយុយ៉ាងតិច៥ឆ្នាំ។ ទិន្នន័យត្រូវបានគណនាឡើងវិញដើម្បីរកអត្រាការចូលរួមក្នុងកម្លាំងពលកម្មរបស់កុមារដែលមានអាយុតិចជាង១៨ឆ្នាំ (រូបភាពទី២.៩)។

### ពលកម្មកុមារ-សមាមាត្រ

ភាពសមាមាត្រពលកម្មកុមារធៀបនឹងកុមារសរុបបានធ្លាក់ចុះយ៉ាងច្រើនចាប់ពីឆ្នាំ២០០៩ដល់ឆ្នាំ២០១១(១៤%)។ ការបញ្ចូលគ្នានៃការកាត់បន្ថយសមាមាត្រនៃភាពក្រីក្រ និងកិច្ចប្រឹងប្រែងដើម្បីឱ្យកុមារចូលរៀនឱ្យលើសពីកម្រិតបឋមសិក្សា បានចូលរួមក្នុងការសម្រេចបានការលុបបំបាត់ពលកម្មកុមារ។ ប៉ុន្តែតួលេខនេះនៅធំជាងចំណុចដៅ៨% នៅឆ្នាំ២០១៥ នៅឡើយ។

រូបភាពទី២.៩ ៖ ពលកម្មកុមារជាសមាមាត្រនៃចំនួនកុមារសរុបអាយុពី៦-១៧ឆ្នាំ (%)




*ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

## ពលកម្មកុមារតាមស្ថានភាពសេដ្ឋកិច្ចនិងទីតាំងភូមិសាស្ត្រ

រូបភាពទី២.១០ក បង្ហាញថាស្ថានភាពសេដ្ឋកិច្ចប៉ះពាល់ដល់ពលកម្មកុមារ។ កម្រិតជីវភាពរស់នៅ និងទីតាំងភូមិសាស្ត្ររបស់គ្រួសារក៏ជះឥទ្ធិពលដល់ពលកម្មកុមារដែរ។ ប្រេវ៉ាឡង់ពលកម្មកុមារនៅតាមតំបន់ជនបទមានកម្រិតខ្ពស់ជាងតំបន់ទីប្រជុំជនដោយសារតែតំបន់ទីប្រជុំជនមានអត្រាភាពក្រីក្រទាប និងមានសាលារៀនច្រើន (រូបភាពទី២.១០ខ)។ ការវិភាគមានបង្ហាញក្នុងប្រអប់ទី២.៣។

នៅពេលដែលប្រេវ៉ាឡង់ពលកម្មកុមារមានការធ្លាក់ចុះ គឺកម្រិតជីវភាពរស់នៅមានការកើនឡើងនោះ ការចំណាយកាន់តែខ្ពស់ (រូបភាពទី២.១០ក)។

មូលហេតុមួយដែលបណ្តាលមកពីការមិនមានសាលារៀនជាពិសេសអនុវិទ្យាល័យនៅតាមតំបន់ជាច្រើន ប៉ុន្តែបញ្ហានេះតម្រូវឱ្យមានការត្រួតពិនិត្យឡើងវិញដើម្បីអនុវត្តសកម្មភាពឱ្យកាន់តែមានប្រសិទ្ធភាព។

រូបភាពទី២.១០៖ (កនិងខ) ប្រេវ៉ាឡង់ពលកម្មកុមារតាមក្រុមចំណាយសម្រាប់មនុស្សម្នាក់ប្រចាំខែនិងទីតាំងឆ្នាំ២០១១




*ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

### ប្រអប់ទី២.៤ ការពន្យល់ពីប្រេវ៉ាឡង់ពលកម្មកុមារ

ជាទូទៅការជួយផ្គត់ផ្គង់បន្ថែមដល់គ្រួសារគឺហេតុផលដ៏សំខាន់មួយដែលកុមារចេញទៅរកការងារនៅតាម កសិដ្ឋានរបស់គ្រួសារ។ គ្រួសារដែលមានធនធានគ្រាប់គ្រាន់បានបញ្ជូនកូនទៅសាលារៀន។ ទិដ្ឋភាពសំខាន់ចំនួនពីរគឺលទ្ធភាពនិងចំណាយលើការអប់រំ។ ការពន្យល់នេះអាចត្រូវបានមួយផ្នែក។ ដូចនេះអញ្ញាត (តំបន់ជនបទ=0 និងតំបន់ទីប្រជុំជន=១)ត្រូវបានបន្ថែមទៅក្នុងសមីការពីព្រោះតំបន់ទីប្រជុំជនមានសាលារៀនច្រើនជាងតំបន់ជនបទ ។ប៉ុន្តែអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាមិនបានផ្តល់ទិន្នន័យផ្នែកផ្គត់ផ្គង់ទេពីព្រោះជាអង្កេតតាមគ្រួសារ។

សមីការដែលបានប៉ាន់ស្មានចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១១ដោយប្រើប្រាស់វិធីសាស្ត្រ Logistic Reg ressionបង្ហាញថាចំណាយខ្ពស់លើការសិក្សានិងការមិនមានសាលារៀនគួរប់គួរាន់ហានផ្ចុវិឱ្យកុមារមិនចូលរៀននិងផ្ចុវិឱ្យកុមារទាំងនោះក្លាយជាពលកម្មកុមារ។

CL = 5.91 - 0.56LnMPCE - 0.030ACE + 0.20RU

(0.11)   (0.001)   (0.005)

Nagelkerke R2 = 0.40;predicted correct = 85,2%;n = 3,986

ដែល CL = ពលកម្មកុមារ; MPCE = ចំណាយសម្រាប់មនុស្សម្នាក់ប្រចាំខែ; ACE = ចំណាយផ្ទាល់ខ្លួនលើការអប់រំជាសមាមាត្រនៃការចំណាយសម្រាប់មនុស្សម្នាក់ប្រចាំខែ; និង RU = ទីតាំង។ លេខក្នុងវង្វង់ក្រចក គឺកំហុសស្តង់ដារ( standard errors ) ។ សមីការនេះសមរម្យសម្រាប់Logistic Regression ហើយមេគុណនៃអញ្ញាតនីមួយៗ ឆ្លើយតបនឹងកម្រិតសំខាន់ក្នុងន័យស្ថិតិ។

### ប្រអប់ទី២.៥ ភាពក្រីក្រកុមារនិងកម្មករកុមារ

កុមារក៏មានភាពក្រីក្រផងដែរ ។ការគណនាដែលធ្វើឡើងដោយក្រសួងផែនការនិងមូលនិធិសហប្រជាជាតិដើម្បីកុមារបានបង្ហាញថា អត្រាភាពក្រីក្រកុមារខ្ពស់ជាងអត្រាភាពក្រីក្ររួមនៅថ្នាក់ជាតិប្រមាណ ៧% ទៅ ៨%។ រូបភាពទី២.១០បង្ហាញថាគ្រួសារក្រីក្រមានអត្រាពលកម្មកុមារខ្ពស់ជាងគ្រួសារដែលមានធនធានខ្ពស់។ កុមារទាំងនេះត្រូវចេញទៅរកចំណូលសម្រាប់គ្រួសារប៉ុន្តែនៅពេលនោះដែរកុមារទាំងនោះបាត់បង់ឱកាសអភិវឌ្ឍខ្លួនឯងដូចជាការអប់រំជាដើម។ កុមារដែលមិនចេះអក្សរឬចេះអក្សរតិចតួចនៅពេលធំពេញវ័យពួកគេមិនបានចូលរួមចំណែកក្នុងមូលធនមនុស្សដែលមានការទទួលស្គាល់ក្នុងសេដ្ឋកិច្ចពុទ្ធិសម័យទំនើបឡើយហើយក៏អាចបន្តរស់នៅក្នុងភាពក្រីក្រទៀត។ នេះគឺជាវដ្តនៃការប្រែប្រួលភាពក្រីក្ររវាងជំនាន់នីមួយៗ។ រាជរដ្ឋាភិបាល ទទួលស្គាល់ថា បន្ទុកនៃការថែទាំកុមារត្រូវតែធ្វើឱ្យប្រសើរឡើងតាមរយៈវិធានការណ៍ ដូចជា កម្មវិធីគាំពារសង្គមដែលផ្តោតលើកុមារដើម្បីធានាថាកុមារទាំងនោះមិនត្រូវបានបោះបង់ចោល។

### លទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

**អលទ្ធផលដែលសម្រេចបាន ៖** ប្រទេសកម្ពុជា បានសម្រេចបាននូវចំណុចដៅនៃការកាត់បន្ថយភាពក្រីក្រ និងលុបបំបាត់ភាពភាពអត់ឃ្លានធ្ងន់ធ្ងរ។ កម្ពុជាក៏ទទួលបានជោគជ័យជាបន្តបន្ទាប់ក្នុងការកាត់បន្ថយវិសមភាពចំណាយប្រើប្រាស់។ទោះបីជាដូចនេះក្តី នៅពេលដែលមានកុមារជាច្រើនមានស្ថានភាពល្អធៀបនឹងចំណុចដៅដែលបានកំណត់ សូចនាករភាពក្រិន កង្វះទម្ងន់ និងស្គមស្គាំងរបស់កុមារ (កម្ពស់ និង ទម្ងន់)នៅពុំទាន់មានការប្រែប្រួលខ្លាំងឡើយសម្រាប់រយៈពេលខ្លី។ ប៉ុន្តែបណ្តាសូចនាករទាំងអស់នេះ ស្ថិតទិសដៅវិជ្ជមានឆ្ពោះទៅរកចំណុចដៅ។ ជាមួយគ្នានេះ កម្ពុជាក៏សម្រេចបានចំណុចដៅនៃគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ។

**បញ្ហាប្រឈម ៖** ទោះបីជាសម្រេចបាននូវសមិទ្ធផលជាច្រើនពាក់ព័ន្ធនឹងអាហារូបត្ថម្ភដូចបានបង្ហាញខាងលើក៏ដោយក៏រាជរដ្ឋាភិបាលបានទទួលស្គាល់ថាការងារសេសសល់មួយចំនួននៅមិនទាន់បានបញ្ចប់សព្វគ្រប់នៅឡើយ។ បញ្ហាកង្វះគ្រាប់ឈាមក្នុងចំណោមស្ត្រីនិងកុមារនៅតែមានកម្រិតមួយខ្ពស់ធៀបនឹងចំណុចដៅឆ្នាំ២០១៥។ រីឯពលកម្មកុមារក៏នៅតែមានសមាមាត្រខ្ពស់ជាងចំណុចដៅដែលបានកំណត់។

**គោលនយោបាយរាជរដ្ឋាភិបាល ៖** រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់លើការកាត់បន្ថយភាពក្រីក្រនិងនាំមកនូវសមភាពល្អប្រសើរជាងមុន ដោយបានប្តេជ្ញាកាត់បន្ថយភាពក្រីក្រយ៉ាងហោចណាស់ឱ្យបាន ១%ក្នុងមួយឆ្នាំ។ ដូចបានពិភាក្សានៅក្នុងជំពូកទី១ យុទ្ធសាស្ត្រចតុកោណបានផ្តោតលើការសម្រេចបានកំណើនប្រកបដោយបរិយាប័ន្ន និងការបង្កើតការងារ ដែលជាមធ្យោបាយដ៏សំខាន់សម្រាប់កាត់បន្ថយភាពក្រីក្រ។ ដោយសារពលកម្មកុមារ និងស្ថានភាពអាហារូបត្ថម្ភកុមារមានការពាក់ព័ន្ធជាមួយនឹងកម្រិតជីវភាពរស់នៅ ដូចនេះ ការកើនឡើងចំណូល និងសមភាពកាន់តែខ្ពស់នឹងជួយលើកកម្ពស់ស្ថានភាពទាំងនេះ។ ក្នុងន័យនេះដែរ យុទ្ធសាស្ត្រចតុកោណបានផ្តោតការលើកកម្ពស់អាហារូបត្ថម្ភនៅក្នុងផ្នែក "ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស"។

## គោលដៅទី២ សម្រេចឱ្យបានសកលកម្មអក្ខរកម្ម និងការអប់រំបឋមសិក្សា

១. សម្រេចឱ្យបានអត្រាអក្ខរភាពសម្រាប់ប្រជាជនអាយុ១៥-២៤ឆ្នាំ ឱ្យបាន៩៤,៥%នៅឆ្នាំ២០១៥។

២. បង្កើនអត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សាឱ្យបាន ៩៩% នៅឆ្នាំ២០១៥ និងអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិឱ្យបាន៧៤%នៅឆ្នាំ២០១៥។

៣. សម្រេចឱ្យបានអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាឱ្យបាន១០០% និងអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិឱ្យបាន ៥៧% នៅឆ្នាំ២០១៥។

៤. សម្រេចឱ្យបានយុគភាពយេនឌ័រក្នុងការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

## ២.១. អត្រាអក្ខរភាព

ក្នុងរូបភាពទី២.១១បានបង្ហាញថា អត្រាអក្ខរភាពរបស់ប្រជាជននៅក្នុងក្រុមអាយុ១៥-២៤ឆ្នាំត្រូវបានធ្វើឲប្រសើរឡើងជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០០៤មក។ ទោះជាដូចនេះក្តី ចាប់ពីឆ្នាំ២០០៧ដល់ឆ្នាំ២០១១ វឌ្ឍនភាពនេះមានភាពមិនទៀងទាត់ទេ។ ការប្រៀបធៀបរវាងចំណុចមួយធៀបនឹងចំណុចមួយ ឆ្នាំ២០០៤ ឆ្នាំ២០០៧ និងឆ្នាំ២០០៨ និងការប្រៀបធៀបរវាងឆ្នាំ២០០៩ ឆ្នាំ២០១០ និងឆ្នាំ២០១១ គឺជាលទ្ធផលល្អបំផុត។ លើសពីនេះទៀតទិន្នន័យសម្រាប់ឆ្នាំ២០១២ និង២០១៣ដែលទទួលបានពីប្រភពផ្សេងទៀតមិនអាចប្រៀបធៀបពេញលេញបានជាមួយទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាទេ។ ទោះជាដូចនេះក្តី អត្រាអក្ខរភាពបានកើនឡើងប្រមាណ១,៦%ទៅ១,៨%។ តាមរយៈអត្រាកំណើននេះ អត្រាអក្ខរភាពកម្ពុជានឹងអាចមានកម្រិត ៩៨% នៅឆ្នាំ ២០១៥ ដែលតាមរយៈនេះ សង្គមនីមួយៗត្រូវបានពិចារណាលើអក្ខរភាពពេញលេញ ។

រូបភាពទី២.១១ ៖ អត្រាអក្ខរភាពក្នុងចំណោមប្រជាជនក្នុងក្រុមអាយុពី ១៥-២៤ឆ្នាំ




*ប្រភព ៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា(ឆ្នាំ២០០៤ ដល់ ឆ្នាំ២០១១) និងក្រសួងអប់រំយុវជននិងកីឡា (២០១២-២០១៣)*

គម្លាតយេនឌ័រកំពុងកាត់បន្ថយបានយ៉ាងលឿន។ សមាមាត្រនៃអក្ខរជនជាស្ត្រីធៀបនឹងបុរសច្រើនជាង៩៩% ក្នុងឆ្នាំ២០១១ប្រៀបធៀបនឹង ៩១,៣% ក្នុងឆ្នាំ២០០៤ហើយនិន្នាការនេះកំពុងស្ថិតក្នុងលើគន្លងឆ្ពោះទៅសម្រេចចំណុចដៅ (រូបភាពទី២.១២)។

រូបភាពទី២.១២ ៖ ផលធៀបអត្រាអក្ខរភាពស្ត្រីធៀបនឹងបុរសអាយុពី ១៥-២៤ឆ្នាំ




*ប្រភព ៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

រូបភាពទី២.១៣ ៖ (កនិងខ)អត្រាអក្ខរភាពអាយុពី ១៥-២៤ឆ្នាំតាមចំណាត់ថ្នាក់ផ្សេងៗ







*ប្រភព ៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

ស្របពេលដែលក្នុងចំណោមប្រជាជនដែលមានជីវភាពធូរធារ២៥% នៃប្រជាជនសរុបដែលចំណុចដៅទំនងជាអាចសម្រេចបាននៅក្នុងចំណោមប្រជាជនក្រីក្របំផុត នៅមានគម្លាតធំនៅឡើយ (រូបភាពទី២.១៣ក)។ ដោយសារតែចំណុចដៅតាមតំបន់ ចំណុចដៅនៅរាជធានីភ្នំពេញសម្រាប់អត្រាអក្ខរភាពអាចសម្រេចបាន ប៉ុន្តែនៅតំបន់ជនបទគោលដៅនេះនៅឆ្ងាយនៅឡើយ (រូបភាពទី២.១៣ខ)។ រូបភាពទាំងពីរនេះបង្ហាញថាប្រជាជនក្រីក្រដែលភាគច្រើនរស់នៅតំបន់ជនបទក៏មានអក្ខរភាពទាបដែរ។

រាជរដ្ឋាភិបាលទទួលស្គាល់នូវសេចក្តីត្រូវការជាចាំបាច់ក្នុងការពង្រឹងអក្ខរភាពឬការអប់រំនៅតាមតំបន់ជនបទនិងតំបន់ដាច់ស្រយាលព្រមទាំងពង្រឹងយ៉ាងម៉ឺងម៉ាត់ក្នុងការអនុវត្តគោលនយោបាយអប់រំសិក្សាដោយមិនគិតប្រាក់កម្រៃ នៅគ្រឹះស្ថានអប់រំរបស់រដ្ឋ។

## ២.២. អត្រានៃការសិក្សាអត្រាបញ្ចប់ការសិក្សា និងអត្រាបោះបង់ការសិក្សា

ពិតនៃការសិក្សានៅកម្រិតបឋមសិក្សា មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ ដោយសម្រេចបានច្រើនជាង ៩០%(តារាងទី២.៣)។ តុល្យភាពយេនឌ័រក្នុងការទទួលបានការសិក្សាអប់រំមានភាពខុសគ្នាជិត១% ក្នុងឆ្នាំ២០១០ហើយត្រូវបានលុបបំបាត់នៅគ្រាបន្ទាប់មក។ រីឯគ្រប់ខេត្តទាំងអស់បានបង្ហាញពីតួលេខប្រហាក់ប្រហែលគ្នាមេគុណអញ្ញាតនៃអត្រាការសិក្សាទូទាំងខេត្តទាំងអស់គឺមានតែ១,៧% ប៉ុណ្ណោះ។ ដូចនេះចំណុចដៅនៃការសិក្សា ទាំងនៅថ្នាក់ជាតិទាំងនៅថ្នាក់ខេត្តនឹងអាចសម្រេចបាន។

អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាក្នុងឆ្នាំសិក្សា២០១២-២០១៣ នៅមានកម្រិតទាបក្នុងចន្លោះពី៨៧-៨៨%សម្រាប់សិស្សប្រុស និងសិស្សស្រីមានន័យថាកុមារ៩,៦% បានបោះបង់ការសិក្សាឬរៀនត្រួតថ្នាក់ក្នុងឆ្នាំដដែល។ អត្រាបោះបង់ការសិក្សាមានកម្រិត៥,៣%ចំណែកអត្រារៀនត្រួតថ្នាក់មាន៣,៧%សរុបបញ្ចូលគ្នាគឺ៩%។ ប៉ុន្តែគម្លាតនេះមិនមានការប្រែប្រួលទេក្នុងរយៈពេល៥ឆ្នាំ ដូចមានបង្ហាញក្នុងទិន្នន័យនេះ។ បញ្ហាកើតមានច្រើននៅថ្នាក់ទី១ដែលមានការបោះបង់ការសិក្សាប្រមាណជា ៩% អត្រារៀនត្រួតថ្នាក់ច្រើនបំផុត ក៏កើតមាននៅថ្នាក់ទី១នេះដែរ។ ភាគច្រើននៃសិស្សទាំងអស់នោះជាសិស្សក្រីក្រនិង/ឬរស់នៅតំបន់ដាច់ស្រយាល។ ដូចមានក្នុងចំណុចដៅគ.អ.ស.ក. ការកាត់បន្ថយអត្រាបោះបង់ការសិក្សាឱ្យមកនៅសូន្យ%គឺជាការងារមួយដ៏លំបាក។

បញ្ហាប្រឈមចម្បងៗ បានកើតមាននៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ការបោះបង់ការសិក្សាមានកម្រិតខ្ពស់នៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងឆ្នាំសិក្សា២០១២-២០១៣។ សិស្សចំនួនប្រមាណ៨៧,៤%បានបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាប៉ុន្តែមានតែ៥៣,៦% ប៉ុណ្ណោះដែលបានបន្តចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិដូចនេះសិស្សចំនួន ៣៤% ទៀតបានបញ្ចប់ការសិក្សារបស់ខ្លួន។ អត្រាសិក្សានៅកម្រិតមធ្យមសិក្សាមានបម្រែបម្រួលច្រើន ជាពិសេសនៅតាមខេត្តនានាដោយមានមេគុណអញ្ញាតស្មើនឹង២០,៦%។ ខេត្តដែលបានបង្ហាញការសម្រេចបានទាបជាងគេ គឺខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន។ ខេត្តចំនួន៤ក្នុងចំណោមខេត្តទាំងនេះស្ថិតនៅភាគខាងជើង និងភាគឦសានចំណែកឯខេត្ត២ទៀតស្ថិតនៅភាគពាយព្យ។ ដូចបានរៀបរាប់មកខាងលើនេះភាពក្រីក្រនិងការផ្តល់សេវាអប់រំមិនគ្រប់គ្រាន់ គឺជាកត្តាដែលធ្វើឱ្យមានអត្រាការបោះបង់ការសិក្សាខ្ពស់។

តារាងទី២.៣ បង្ហាញថា អត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៩) តាមបណ្ដាឆ្នាំខុសៗគ្នាភាគច្រើននៅតំបន់ជនបទមានកម្រិតទាបជាងការចុះឈ្មោះចូលរៀនប្រមាណ ១០-១៤%។ ចំណុចដៅនៃគ.អ.ស.ក. អត្រាបោះបង់ការសិក្សានៅឆ្ងាយពីចំណុចដៅដែលបានកំណត់នៅឡើយ។

### តារាងទី២.៣ ៖ អត្រានៃការសិក្សានិងអត្រាបញ្ចប់ការសិក្សា

| | | ២០០៨/០៩ | ២០០៩/១០ | ២០១០/១១ | ២០១១/១២ | ២០១២/១៣ |
|---|---|---|---|---|---|---|
| អត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា | | | | | | |
| សរុប | ភាគរយ | ៩៤,៤ | ៩៤,៨ | ៩៥,២ | ៩៦,៤ | ៩៧ |
| ប្រុស | ភាគរយ | ៩៤,៨ | ៩៥ | ៩៥,៨ | ៩៦,៧ | ៩៧ |
| ស្រី | ភាគរយ | ៩៤ | ៩៤,៦ | ៩៤,៦ | ៩៦,១ | ៩៧ |
| អត្រាសរុបនៃការសិក្សានៅកម្រិតមធ្យមសិក្សា (ថ្នាក់ទី៩) | | | | | | |
| សរុប | ភាគរយ | ៦១,៦ | ៥៨,១ | ៥៨,៥ | ៥៥ | ៥៣,៦ |
| ប្រុស | ភាគរយ | ៥៩,២ | ៥៩ | ៥៩ | ៥៥ | ៥៣ |
| ស្រី | ភាគរយ | ៦៤ | ៥៧,១ | ៥៧,៨ | ៥៥ | ៥៤,២ |
| អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា (ថ្នាក់ទី៦) | | | | | | |
| សរុប | ភាគរយ | ៨៥,៦ | ៨៣,២ | ៨៥,៣ | ៨៩,៧ | ៨៧,៤ |
| ប្រុស | ភាគរយ | ៨៥,៤ | ៨២,៨ | ៨៥,៦ | ៨៩,៦ | ៨៦,៩ |
| ស្រី | ភាគរយ | ៨៥,៧ | ៨៣,៦ | ៨៥ | ៨៩,៩ | ៨៧,៨ |
| អត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៩) | | | | | | |
| សរុប | ភាគរយ | ៤៩,១ | ៤៨,៧ | ៤៦,៨ | ៤២,១ | ៤០,៦ |
| ប្រុស | ភាគរយ | ៥២,១ | ៥០ | ៤៩,២ | ៤២,៦ | ៤២,២ |
| ស្រី | ភាគរយ | ៤៥,៩ | ៤៧,៣ | ៤៤,៣ | ៤១,៦ | ៤០,៤ |

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

## កុមារក្នុងវិស័យអប់រំ

រូបភាព២.១៤កបង្ហាញថាសមាមាត្រកុមារដែលបោះបង់ការសិក្សាបានធ្លាក់ចុះយ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុន្តែ១ភាគ៥នៃចំនួនកុមារសរុប មិនបានចូលសិក្សាទេ។ នេះអាចបណ្ដាលមកពីកត្តាផ្គត់ផ្គង់ដែលធ្វើឱ្យកុមារមិនបានចូលសិក្សានៅថ្នាក់បន្ទាប់ៗទៀតដោយនៅក្នុងឆ្នាំសិក្សា២០១២-២០១៣នៅទូទាំងប្រទេសសាលាបឋមសិក្សាមានចំនួន ៦៩១០ និងនៅកម្រិតមធ្យមសិក្សាបឋមភូមិមានសាលារៀនចំនួន១ ២១៤។ លើសពីនេះទៀតដោយសារចម្ងាយមធ្យមពីភូមិទៅសាលាបឋមសិក្សាមានប្រវែង១,២គ.ម.ហើយសម្រាប់សាលាមធ្យមសិក្សាមានចង្ងាយជាមធ្យមប្រវែង៤,២គ.ម.ធ្វើឱ្យមានការលំបាកដល់សិស្សធ្វើដំណើរទៅសិក្សា។

ដូចបានបង្ហាញក្នុងរូបភាពទី២.១៤ខចំណាយប្រចាំខែសម្រាប់មនុស្សម្នាក់ (សូចនាករជំនួសសម្រាប់ចំណូល) មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងកុមារអាយុពី៦-១៧ឆ្នាំដែលកំពុងរៀននៅសាលារៀន។ គ្រួសារដែលមានជីវភាពធូរជាមានលទ្ធភាពបញ្ជូនកូនឱ្យទៅរៀនបានខ្ពង់ខ្ពស់ជាងគ្រួសារក្រីក្រ។ ប៉ុន្តែកន្លងមកថ្មីៗនេះសមាមាត្រកុមារដែលចូលរៀនត្រូវបានកែលម្អច្រើន ដោយសារតែអត្រាភាពក្រីក្រត្រូវបានកាត់បន្ថយ។



សិស្សសាលាកំពុងលេងក្នុងពេលសំរាក-ខេត្តកំពង់ធំ

### រូបភាពទី២.១៤ ៖ (កនិងខ) %នៃកុមារសិក្សានៅសាលាអាយុពី៦-១៧ឆ្នាំ២០០៩-២០១១និងតាមក្រុមចំណាយប្រចាំខែសម្រាប់មនុស្សម្នាក់ (២០១១)




*ប្រភព៖ គណនាចេញពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

### ប្រអប់ទី២.៦ ការអប់រំស្ថានភាពទូទៅនិងបញ្ហានានា

ទាំងឪពុកម្តាយនិងកុមារនៅក្នុងភូមិ បានចាប់ផ្តើមទទួលស្គាល់ថា ការអប់រំមានសារសំខាន់ណាស់ សម្រាប់ចាកចេញឱ្យផុតពីភាពក្រីក្រ។ ឪពុកម្តាយ ជាពិសេស ម្តាយបានឱ្យដឹងថា ពួកគាត់មានសេចក្តីរីករាយដែលបានឃើញកូនៗរបស់ពួកគាត់មានលទ្ធភាពអាចអាននិងសរសេរបាន។ ឪពុកម្តាយបានផ្តល់សារៈសំខាន់ដូចគ្នាក្នុងអប់រំសម្រាប់កូនទាំងពីរភេទ (ការឱ្យតែកូនប្រុសចូលរៀនគឺជាគំនិតហួសសម័យ)។ ប្រជាជនមានអារម្មណ៍កាន់តែសប្បាយចិត្តនិងមានសុវត្ថិភាពប្រសិនបើកូនស្រីរបស់ខ្លួនបានរៀនច្រើនពីព្រោះឪពុកម្តាយនឹងត្រូវរស់នៅជាមួយកូនស្រីមិនមែនកូនប្រុសទេ។

ក្នុងរយៈពេលពីបីឆ្នាំចុងក្រោយនេះកុមារដែលមានអាយុពី ៦-៧ ឆ្នាំបានទៅចុះឈ្មោះសិក្សានៅសាលារៀនបឋមសិក្សា។ លទ្ធភាពប្រសើរជាងមុននិងភាពអាចទៅដល់សាលារៀន (ចម្ងាយផ្លូវថ្នល់) បានចូលរួមចំណែកដល់ការងារនេះ។ ប៉ុន្តែកុមារមួយចំនួនដែលបានចូលរៀននៅអាយុពី ៨-១០ ឆ្នាំបច្ចុប្បន្នកំពុងប្រឈមនឹងបញ្ហាជាច្រើន។ កុមារទាំងនោះនៅពេលរៀនថ្នាក់ទី៥ ឬ ទី៦ (អាយុ១៣-១៦ ឆ្នាំ) មានអារម្មណ៍ថាខ្លួនវ័យចំណាស់ដែលអង្គុយរៀនជាមួយជាសិស្សក្មេងជាងខ្លួននៅក្នុងថ្នាក់រៀន។ សិស្សប្រភេទនេះ ភាគច្រើនបានបោះបង់ចោលការសិក្សាដើម្បីចូលរួមក្នុងកម្លាំងពលកម្ម។ ជាទូទៅសិស្សបានបញ្ចប់ការសិក្សាមូលដ្ឋានរយៈពេល ៩ឆ្នាំ។ បញ្ហាសំខាន់នៃលទ្ធភាពសម្រាប់បន្តការសិក្សានៅមធ្យមសិក្សាគឺចម្ងាយពីសាលារៀនមធ្យមសិក្សាទៅភូមិ។ឪពុកម្តាយជាច្រើនបញ្ជាក់ថាគ្រួសារក្រីក្រដែលផ្លាស់ប្តូរលំនៅដ្ឋាន ជាទូទៅតែងតែយកកូនរបស់ពួកគេដែលមានអាយុប្រហែល១០ឆ្នាំទៅជាមួយដែលជាហេតុនាំឱ្យសិស្សទាំងនោះបោះបង់ការសិក្សា។

ក្តីបារម្ភដ៏សំខាន់មួយគឺគុណភាពនៃការអប់រំ។ ក្រៅពីបញ្ហាធម្មតាដែលបានរៀបរាប់ក្នុងទ្រឹស្តី ឪពុកម្តាយបានរាយការណ៍ថាវិធីសាស្ត្របង្រៀនត្រូវបានផ្លាស់ប្តូរក្នុងពេលថ្មីៗនេះ។ សិស្សសិក្សាភាសាខ្មែរមិនសូវបានល្អទេពីព្រោះការបង្រៀនឥឡូវនេះបង្រៀនជាពាក្យៗ បណ្តាលឱ្យសិស្សមិនចេះផ្គុំព្យញ្ជនៈនិងស្រៈបញ្ចូលគ្នា។ ឪពុកម្តាយគិតថា រាជរដ្ឋាភិបាលគួរពិនិត្យមើលគោលការណ៍នេះដើម្បីធ្វើឱ្យគោលការណ៍នេះមានន័យប្រសើរជាងនេះ។ ឪពុកម្តាយជាច្រើនក៏បានត្អូញត្អែរពីអវត្តមានច្រើនរបស់គ្រូបង្រៀនជាពិសេសគ្រូបង្រៀនប្រុស នៅកម្រិតបឋមសិក្សា។ គ្រូបង្រៀនទាំងនោះទៅបង្រៀនតែ២ថ្ងៃប៉ុណ្ណោះក្នុង១សប្តាហ៍។

ប្រធានការិយាល័យអប់រំបានបញ្ជាក់ថាមានហេតុផលបីដែលធ្វើឱ្យមានការបោះបង់ការសិក្សារបស់សិស្សជាពិសេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ គឺចម្ងាយទៅសាលាមធ្យមសិក្សាបឋមភូមិនៅក្នុងតំបន់នោះ ការហាមឃាត់សិស្សដែលមានអាយុច្រើនរៀនជាមួយសិស្សក្មេងៗជាង និងឪពុកម្តាយក្រីក្រផ្លាស់ទីលំនៅទាំងគ្រួសារ។ ពាក់ព័ន្ធនឹងឥរិយាបទរបស់គ្រូបង្រៀនអាជ្ញាធរបានបញ្ជាក់ថាមានកង្វះខាតគ្រូបង្រៀនហើយការបង្ខំឱ្យអនុវត្តវិន័យដល់គ្រូបង្រៀនមួយចំនួននឹងធ្វើឱ្យចំនួនគ្រូបង្រៀនកាន់តែតិច។

*ប្រភព៖ បទសម្ភាសន៍នៅក្នុងខេត្តក្រចេះ និងខេត្តកំពង់ធំ*

## កុមារក្នុងវិស័យអប់រំ-ការពន្យល់

ផ្នែកនេះ បង្ហាញពីក្របខ័ណ្ឌអញ្ញាតចម្រុះមួយសម្រាប់ពន្យល់ពីការសិក្សារបស់កុមារនៅតាមសាលា យោងតាមទ្រឹស្តីស្តីពីមូលធនមនុស្ស។ ជាទូទៅកុមារត្រូវបានបញ្ជូនទៅរៀននៅសាលានៅពេលដែលគ្រួសារបានយល់ឃើញពីផលប្រយោជន៍ពីការចូលរៀន។ ឪពុកម្តាយបានថ្លឹងថ្លែងពីផលប្រយោជន៍ រវាងការអប់រំជាមួយនឹងចំណាយនៅពេលបច្ចុប្បន្នក្នុងការបញ្ជូនកូនៗទៅសាលារៀនឬមិនបញ្ជូន។

សមីការរីក្រេសិន (Regression) ចំនួន២ត្រូវបានធ្វើការប៉ាន់ស្មាន។ សមីការទី១បង្ហាញពីហេតុផលក្នុងការបញ្ជូនកូនៗទៅសាលារៀន និងសមីការទី២បង្ហាញពីចម្ងាយផ្លូវពីផ្ទះទៅសាលារៀន ថាតើគួរឬមិនគួរបញ្ជូនកូនទៅសាលារៀន។ ព័ត៌មានលម្អិតរបស់សមីការរីក្រេសិន មានបង្ហាញក្នុងប្រអប់ទី២.៧ និងការប៉ាន់ស្មានក្នុងប្រអប់ទី២.៨។

ការប៉ាន់ស្មានដែលទទួលបានពីLogistic Regression (សមីការទី១. ប្រអប់២.៨) បង្ហាញថាក្រុមអាយុ និងចំណាយក្នុងមួយខែសម្រាប់មនុស្សម្នាក់ គឺជាកត្តាសំខាន់ដែលមានឥទ្ធិពលលើការអប់រំរបស់កុមារ។ តម្លៃអវិជ្ជមាននៃអត្រានៃការសិក្សាតាមក្រុមអាយុ គឺធំជាង១០០% ព្រមទាំងបានឆ្លុះបញ្ចាំងពីតម្រូវការនៃការផ្គត់ផ្គង់ការអប់រំនៅពេលកុមារកាន់តែមានអាយុច្រើន។ ដោយសារសមីការនេះឆ្លុះបញ្ចាំងពីការផ្គត់ផ្គង់ និងតម្រូវការទំហំនៃភាពយឺតពិបាកក្នុងការបកស្រាយ។ តាមតម្លៃភាពយឺតជាមួយនឹងចំណាយសម្រាប់មនុស្សម្នាក់ប្រចាំខែការបង្កើនចំណាយប្រចាំខែសម្រាប់មនុស្សម្នាក់អាចបង្កើនការចូលរៀនបាន៨៩%។ ជារួមសមីការនេះបង្ហាញថា កត្តាតម្រូវការ និងការផ្គត់ផ្គង់មានឥទ្ធិពលលើការចូលរៀនរបស់កុមារ។ ការប៉ាន់ស្មានរបស់សមីការទី២ក្នុងប្រអប់ទី២.៨បង្ហាញថាកត្តាចំណូលមានឥទ្ធិពលខ្លាំងជាងគេបើប្រៀបធៀបនឹងកត្តាផ្សេងៗទៀតមានន័យថាប្រជាជនអប់រំកូនចៅរបស់ខ្លួនដើម្បីទទួលបានអនាគតល្អ។ លទ្ធផលរបស់សមីការទាំង២មានលក្ខណៈស្រដៀងគ្នាទោះបីប្រើប្រាស់ទិន្នន័យពីផ្សេងគ្នាក៏ដោយ។

ទី១សមីការទាំងពីរបង្ហាញថាប្រជាជនត្រូវមានកម្រិតជីវភាពយ៉ាងហោចណាស់ត្រឹមកម្រិតជីវភាពរស់នៅអប្បបរមាដើម្បីជានាដល់ការបញ្ជូនកូនចៅរបស់ពួកគាត់ទៅសាលារៀន។ ដូចនេះ ភាពក្រីក្រមានឥទ្ធិពលដល់ការអប់រំដែលអាចធ្វើឱ្យអ្នកជំនាន់ក្រោយមានភាពទន់ខ្សោយផ្នែកសេដ្ឋកិច្ចសង្គមកិច្ចដែលនឹងអាចធ្វើឱ្យបន្តមានភាពក្រីក្រ។

ទី២តំបន់ដាច់ស្រយាល មិនត្រូវបានរៀបចំប្រព័ន្ធអប់រំបានល្អប្រសើរទេ។ ក្នុងករណីកម្ពុជាប្រជាជនមានប្រមាណ១៤លាននាក់កំពុងរស់នៅក្នុងប្រមាណ១៤០០០ភូមិដូចនេះការបែងចែកដើម្បីឱ្យប្រជាជនគ្រប់ភូមិទាំងនោះទទួលបានផលប្រយោជន៍ គឺនៅជាបញ្ហាប្រឈម។

ទី៣ការអប់រំដល់ប្រជាជនអាចត្រូវបានជំរុញបន្ថែមទៀត តាមរយៈការផ្តល់ឱ្យទទួលបានការបញ្ចប់ការសិក្សា និងផ្តល់ការគាំទ្រដល់សិស្សដែលត្រូវការជំនួយជាមូលដ្ឋាន ទាំងការពង្រឹងផ្នែកផ្គត់ផ្គង់ និងពង្រឹងផ្នែកតម្រូវការផ្សេងៗ។

### ប្រអប់ទី២.៧ លក្ខណៈបច្ចេកទេសរបស់សមីការរីក្រេសិន (Regression)

**សមីការទី១៖** Logistic Regression ពន្យល់ពីការចូលរៀន ឬមិនចូលរៀនរបស់កុមារ

អញ្ញាតដែលបានពន្យល់គឺជាទ្វេភាគី៖ ទោះបីជាកុមារស្ថិតក្នុងក្រុមអាយុពី ៦-១៧ឆ្នាំដែលបានចូលរៀន (តម្លៃ=១) ឬមិនចូលរៀន (តម្លៃ=0)

**អញ្ញាតសម្រាប់ពន្យល់**

១. ចំណាយគ្រួសារ (ជំនួសឱ្យចំណូល)៖ ជំរុញឱ្យសិស្សបានចូលរៀន។ ការវាស់វែង ៖ ចំណាយប្រចាំខែសម្រាប់មនុស្សម្នាក់

២. ការងាររបស់មេគ្រួសារ ៖ ពិពិធកម្មខ្ពស់មុខរបរ ក្នុងការងារក្រៅពីវិស័យកសិកម្មស្រែចំការបង្កើតឱ្យមានតម្រូវការសម្រាប់ការអប់រំដែលជាវិស័យមិនមែនកសិកម្មមានផលិតភាពខ្ពស់តម្រូវការជំនាញកាន់តែច្រើន និងធានាដល់ការមិនមានការចូលរួមពលកម្មកុមារក្នុងវិស័យកសិកម្មស្រែចំការ។ ការវាស់វែង៖ (កសិកម្ម=0វិស័យផ្សេងទៀត=១)។

៣. ថាតើមេគ្រួសារមានការអប់រំដែរឬទេ? មេគ្រួសារដែលជាអក្ខរជន/មានការអប់រំនឹងបញ្ជូនកូនរបស់ពួកគេទៅសាលារៀន។ ការវាស់វែង ៖ (មេគ្រួសារជាអនក្ខរជន=0មេគ្រួសារមានការអប់រំ=១)

៤. អាយុ៖ សេចក្តីត្រូវការប្រភេទនៃការអប់រំតាមអាយុដោយសារមិនមានសាលារៀនច្រើននៅតាមសហគមន៍ និងចំណាយកើនឡើង។ ការវាស់វែង ៖ អាយុពិតប្រាកដ។

**ទិន្នន័យ៖ ទិន្នន័យពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ច ឆ្នាំ២០១១**

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាមិនបានផ្តល់ទិន្នន័យស្តីពីអញ្ញាតផ្នែកផ្គត់ផ្គង់ទេប៉ុន្តែយ៉ាងហោចណាស់អញ្ញាតចំនួន២ក្នុងចំណោមអញ្ញាតដែលបានរៀបរាប់ខាងលើបង្ហាញពីផលប៉ះពាល់ផ្នែកផ្គត់ផ្គង់។ ឧទាហរណ៍មេគ្រួសារធ្វើការក្នុងវិស័យឧស្សាហកម្ម (តាមរយៈទីតាំងដែលឆ្លុះបញ្ចាំងពីការផ្គត់ផ្គង់-ការងារមិនមែនកសិកម្មជាទូទៅស្ថិតក្នុងតំបន់ដែលមានប្រជានជនច្រើនដែលមានសាលារៀនច្រើន) និងអាយុ (កុមារក្នុងក្រុមអាយុខ្ពស់ មាននិន្នាការតិចតួចក្នុងការចូលរៀននៅសាលារៀនមធ្យមសិក្សា)។

**សមីការទី២៖** OLS Regression ដែលពន្យល់ពី%នៃកុមារក្នុងសាលារៀនតាមភូមិ

អញ្ញាតសម្រាប់ពន្យល់គឺជា%នៃអាយុកុមារក្នុងសាលារៀនធៀបនឹងចំនួនកុមារសរុបក្នុងក្រុមអាយុ១២-១៧ឆ្នាំនៅតាមភូមិ។ បញ្ហាសំខាន់នោះគឺទិន្នន័យនៃក្រុមអាយុពី ៦-១១ឆ្នាំមិនមានគុណភាពល្អទេ។

**អញ្ញាតសម្រាប់ពន្យល់**

**ផ្នែកតម្រូវការ៖** មិនមានទិន្នន័យស្តីពីចំណូលតាមភូមិទេ ដូចនេះសូចនាករជំនួសត្រូវបានប្រើប្រាស់ដូចជាចំនួនម៉ូតូនៅក្នុងភូមិសមាមាត្រទៅនឹងគ្រួសារទាំងអស់ចំនួនកង់នៅក្នុងភូមិសមាមាត្រទៅនឹងគ្រួសារទាំងអស់ចំនួនគ្រួសារដែលរស់នៅក្នុងផ្ទះស្បូវជាសមាមាត្រទៅនឹងគ្រួសារទាំងអស់ចំនួនបណ្តាញទឹកឯកជនជាសមាមាត្រទៅនឹងគ្រួសារទាំងអស់ចំនួនបង្គន់អនាម័យសមាមាត្រទៅនឹងគ្រួសារទាំងអស់ចំនួនកសិករដែលភ្ជួរដីតិចជាង១ហិកតាសមាមាត្រទៅនឹងគ្រួសារទាំងអស់ទិន្នផលស្រូវវស្សានិងទិន្នផលស្រូវប្រាំង។

**ផ្នែកផ្គត់ផ្គង់៖** ត្រូវបានវាស់វែងដោយចម្ងាយពីអនុវិទ្យាល័យនិងចម្ងាយពីវិទ្យាល័យទៅភូមិនិងចម្ងាយពីភូមិទៅទីរួមខេត្ត។

*ទិន្នន័យ៖ ទិន្នន័យកម្រិតភូមិពីទិន្នន័យឃុំ សង្កាត់ឆ្នាំ២០១១*



សិស្សកំពុងស្តាប់គ្រូពន្យល់ក្នុងសាលារៀនបឋមសិក្សាវត្តអន់នូ-ខេត្តក្រចេះ

### ប្រអប់ទី២.៨ ការប៉ាន់ស្មាននៃសមីការទាំងពីរក្នុងប្រអប់ទី២.៧

| សមីការទី១ Logistic Regression បញ្ជាក់ពីការចូលរៀនរបស់សិស្ស | | | |
|---|---|---|---|
| | មេគុណ | ស្តង់ដានៃកំហុស | Quasi Elasticity at mean |
| ចំណាយប្រចាំខែសម្រាប់មនុស្សម្នាក់ (រៀល)<br>ឧស្សាហកម្មដែលមានមេគ្រួសារធ្វើការ<br>អាយុ (ឆ្នាំ)មេគ្រួសារទទួលការអប់រំឬអត់(ថេរ) | 0.00005 | .000002 | 0.892 |
| | .1595 | .003 | 0.164 |
| | -.1693 | .0004 | -1.606 |
| | .2983 | .003 | 0.192 |
| | 2.0182 | 0.006 | |
| អញ្ញាតប្រែប្រួល៖ថាតើកុមារអាយុ៦-១៧ឆ្នាំចូលរៀនឬអត់ | | | |
| Nagelkerke R2 = 0.162; ភាពត្រឹមត្រូវប៉ាន់ស្មាន = 81.3%; n = 3,986 | | | |

*សម្គាល់៖ អញ្ញាតដូចជាភេទរបស់កុមារភេទរបស់មេគ្រួសារនិងជនជាតិភាគតិចរបស់អ្នកឆ្លើយត្រូវបានប្រទះថា មិនមានភាពជាក់លាក់ផ្នែកស្ថិតិទេ។*

| សមីការទី២ OLS Regression បញ្ជាក់ពី%កុមារក្នុងសាលារៀនតាមភូមិ | | | |
|---|---|---|---|
| | តម្លៃនៃមេគុណ | t | ភាពយឺតនៃមធ្យាបាយ |
| (ថេរ) | 63.8943 | 68.7636 | |
| ចម្ងាយរបស់អនុវិទ្យាល័យ(គ.ម.) | -0.0028 | -1.2274 | -0.0002 |
| ចម្ងាយរបស់វិទ្យាល័យ(គ.ម.) | -0.0034 | -1.6081 | -0.0005 |
| ទិន្នផលស្រូវវស្សា | 1.4567 | 5.0639 | 0.0391 |
| ចម្ងាយផ្លូវពីភូមិទៅទីរួមខេត្ត | -0.0489 | -7.1378 | -0.0272 |
| ចំនួនម៉ូតូធៀបនឹងគ្រួសារ (%) | 0.0159 | 1.9869 | 0.0106 |
| ចំនួនកង់ធៀបនឹងគ្រួសារ (%) | 0.0723 | 16.2546 | 0.0630 |
| ចំនួនគ្រួសាររស់នៅក្នុងផ្ទះស្បូវធៀបនឹងគ្រួសារសរុប(%) | -0.1806 | -16.2717 | -0.0422 |
| ចំនួនគ្រួសារដែលមានផ្ទៃដីដំណាំតិចជាង១ហិកតាធៀបនឹងគ្រួសារសរុប (%) | -0.0043 | -2.6795 | -0.0008 |
| ចំនួនបង្គន់ធៀបនឹងចំនួនគ្រួសារសរុប (%) | 0.1168 | 16.1083 | 0.0551 |
| ចំនួនគ្រួសារដែលមានបណ្តាញទឹកប្រើប្រាស់ធៀបនឹងចំនួនគ្រួសារសរុប (%) | 0.0540 | 11.9045 | 0.0331 |
| ទិន្នផលស្រូវវស្សាំង | 0.3676 | 2.5133 | 0.0047 |
| R2 = 0.150; F = 192.063; n = 11,882 | | | |

*ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងទិន្នន័យឃុំ សង្កាត់*

## ២.៣. យុគភាពយេនឌ័រ

យុគ្គភាពយេនឌ័រស្ទើរតែកើតមាន នៅក្នុងអត្រានៃការសិក្សាក្នុងទាំងក្នុងកម្រិតបឋមសិក្សា និងមធ្យមសិក្សា (រូបភាពទី២.១៥)។

ការបំបែកទិន្នន័យតាមថ្នាក់ខេត្តបង្ហាញថាពុំមាននិន្នាការប្រែប្រួលច្រើនទេពីព្រោះមេគុណអញ្ញាតមិនមានច្រើនជាង៣%។ ដូចនេះ បញ្ហានេះនឹងមិនបន្តកើតមានទៀតឡើយ។

ចំណុចដៅរបស់គ.អ.ស.ក. ដែលពាក់ព័ន្ធនឹងយុគ្គភាពយេនឌ័រក្នុងការអប់រំនៅកម្រិត ទាំងនេះបានសម្រេចរួចហើយ។

### រូបភាពទី២.១៥ ៖ សន្ទស្សន៍យុគភាពយេនឌ័រក្នុងការសិក្សា




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

## លទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

**លទ្ធផលដែលសម្រេចបាន ៖** ប្រទេសកម្ពុជាសម្រេចបាននូវបណ្តាចំណុចដៅនានា ដូចជាសកលកម្មនៃអត្រាអក្ខរភាពសម្រាប់ប្រជាជនអាយុ១៥-២៤ឆ្នាំ អត្រាពិតនៃការសិក្សា និងអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាកំពុងឆ្ពោះទៅរកចំណុចដៅដែលបានកំណត់ ហើយចំណុចដៅយុត្តភាពយេនឌ័រក្នុងការសិក្សាក៏បានសម្រេច និងរក្សាបានទាំងនៅកម្រិតនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

**បញ្ហាប្រឈម៖** បញ្ហាប្រឈមក្នុងការសម្រេចបាននូវចំណុចដៅនៃការអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិ ទាំងការសិក្សាទាំងការបញ្ចប់ការសិក្សានៅតែបន្តមាននៅឡើយ។ មូលហេតុពីរយ៉ាងក្នុងចំណោមមូលហេតុទាំងអស់ រួមមាន(១) កត្តាផ្គត់ផ្គង់មិនគ្រប់ចំនួន (ចំនួនសាលាបឋមសិក្សាមានចំនួនតែ ៦.៩១០ និងសាលាមធ្យមសិក្សាបឋមភូមិមានតែ ១.២១៤ ប៉ុណ្ណោះ នៅឆ្នាំ២០១២)។ (២) ថ្វីត្បិតតែអត្រាភាពក្រីក្រត្រូវបានកាត់បន្ថយបានច្រើនក៏ដោយក៏កម្រិតជីវភាពរស់នៅរបស់ប្រជាជននៅមិនទាន់បានល្អប្រសើរដល់កម្រិតដែលគ្រួសារអាចមានលទ្ធភាពបញ្ជូនកូនទៅសាលារៀនប្រកបដោយប្រសិទ្ធភាពនៅឡើយ។

**គោលនយោបាយរាជរដ្ឋាភិបាល ៖** រាជរដ្ឋាភិបាលទទួលស្គាល់ថាវិស័យអប់រំ គឺជាស្នូលនៃពុទ្ធិសេដ្ឋកិច្ច។ ការបញ្ចប់ការសិក្សានៅបឋមសិក្សាគ្រាន់តែជាជំហានដំបូងដើម្បីឆ្ពោះទៅរកផ្នែកមួយនៃពុទ្ធិសេដ្ឋកិច្ចហើយប្រទេសជាតិតម្រូវឱ្យប្រជាជនទទួលយកការអប់រំច្រើនជាងកម្រិតបច្ចុប្បន្ន ៤-៥ឆ្នាំបន្ថែមទៀត។ យុទ្ធសាស្ត្រចតុកោណបានកំណត់ថា វិស័យអប់រំ និងមូលធនមនុស្សជាកត្តាដ៏សំខាន់សម្រាប់ការអភិវឌ្ឍ ដូចមានក្នុងចតុកោណទី៤ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។ ចតុកោណទី៤នេះ បានដាក់ចេញនូវកម្មវិធីនយោបាយចំនួន១០ សំដៅ (១) ធ្វើឱ្យប្រសើរឡើងការអប់រំ និងការរៀបចំមូលធនមនុស្សដែលរួមទាំងការពង្រឹងវិស័យអប់រំដើម្បីបង្កើនមូលធនមនុស្សសម្រាប់ភាពប្រកួតប្រជែងច្រើនជាងមុន (២) ការលើកកម្ពស់មូលដ្ឋានចំណេះដឹង និងការបណ្តុះបណ្តាលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (៣) ការបង្កើនភាពងាយស្រួលនៃលទ្ធភាពទទួលបានសេវាអប់រំនៅគ្រប់កម្រិតសិក្សា (៤) ការកសាងសមត្ថភាពស្ថាប័នក្នុងវិស័យអប់រំ និងការបែងចែកជំនាញ (៥) ធ្វើឱ្យប្រសើរឡើងគុណភាព និងប្រសិទ្ធភាពនៃការអប់រំ និង (៦) ការពង្រឹងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ រាជរដ្ឋាភិបាលក៏បានរៀបចំផែនការតាមវិស័យ សំដៅសម្រេចបាននូវគោលបំណងទាំងអស់នេះ។



សិស្សសាលាបឋមសិក្សាទួលពង្រ កំពុងលេងក្នុងពេលសំរាក

## គោលដៅទី៣ លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

យេនឌ័រផ្សារភ្ជាប់នឹងគោលដៅជាច្រើន ដូចជាក្នុងវិស័យអប់រំវិស័យសុខាភិបាល និងវិស័យការងារដោយមានចំណុចដៅជាតិចំនួន៤ដូចខាងក្រោម៖

១. កាត់បន្ថយឱ្យបានច្រើននូវគម្លាតយេនឌ័រក្នុងការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។

២. លុបបំបាត់គម្លាតយេនឌ័រក្នុងការងារទទួលប្រាក់កម្រៃ នៅក្នុងគ្រប់វិស័យ។

៣. លុបបំបាត់គម្លាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ។

៤. កាត់បន្ថយឱ្យបានច្រើនរាល់ទម្រង់អំពើហិង្សាប្រឆាំងនឹងស្ត្រី និងកុមារ។

### ៣.១. យុគភាពយេនឌ័រក្នុងវិស័យអប់រំ

រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការសម្រេចឱ្យបានយុគភាពយេនឌ័រក្នុងវិស័យអប់រំកម្រិតខ្ពស់ ព្រមទាំងការរក្សាបាននូវសមិទ្ធផលនានា ដែលមាននៅកម្រិតបឋមសិក្សា។ ទោះជាយ៉ាងណាក៏ដោយ ក៏គម្លាតនៅបន្តមាននៅក្នុងការអប់រំកម្រិតខ្ពស់ដែលគម្លាតនេះចាំបាច់ត្រូវបង្រួមឱ្យនៅក្នុងកម្រិតតូចបំផុតហើយត្រូវបង្រួមដូចម្តេច ក្នុងកម្រិតណា?

រូបភាព២.១៦៖ ផលធៀបសិស្សស្រី និងសិស្សប្រុសចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០០៧-២០១៣




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

រូបភាពទី២.១៦ បង្ហាញពីផលធៀបសិស្សស្រី និងសិស្សប្រុសដែលចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំសិក្សា២០០៧-២០០៨រហូតដល់ឆ្នាំសិក្សា២០១២-២០១៣។ ផលធៀបនេះមាន៦៩,៤%សម្រាប់ឆ្នាំសិក្សា ២០០៧-២០០៨ហើយបានកើនដល់៨៧,៣%សម្រាប់ឆ្នាំសិក្សា២០១២-២០១៣។ យោងតាមទិន្នន័យនេះ ផលធៀបសិស្សស្រីនិងសិស្សប្រុសដែលចូលរៀននៅកម្រិតមធ្យម សិក្សាទុតិយភូមិឱ្យបាន១០០%ប្រហែលអាចនឹងសម្រេចបាននៅឆ្នាំ២០១៥។

ការបែងចែកតាមខេត្ត (រូបភាពទី២.១៧) បង្ហាញពីលទ្ធផលខុសគ្នារបស់បណ្តាខេត្តមួយចំនួន។ ខេត្តសៀមរាប បាត់ដំបង កំពង់ចាម កំពង់ធំ កែប ក្រចេះ និងខេត្តពោធិសាត់អាចនឹងសម្រេចបានយុគភាពយេនឌ័រសម្រាប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ។ ចំណែកខេត្តរតនគិរី ស្ទឹងត្រែង កំពង់ស្ពឺ និងខេត្តមណ្ឌលគិរីសម្រេចបានលទ្ធផលតិចតួចតែប៉ុណ្ណោះ។ នេះមិនមែនមានន័យថាខេត្តដែលមានការអភិវឌ្ឍច្រើនមានតុល្យភាពយេនឌ័រល្អនោះទេ ប៉ុន្តែខេត្តដែលមានការអភិវឌ្ឍតិចតួចមានគម្លាតយេនឌ័រយ៉ាងខ្លាំង។ នៅពេលប្រទេសមួយដែលមានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ហើយកម្រិតជីវភាពរស់នៅរបស់ប្រជាជនមានភាពប្រសើរឡើងនោះមិនមានន័យថា ប៉ារ៉ាម៉ែត្រអភិវឌ្ឍន៍ផ្សេងៗទៀតនឹងប្រសើរឡើងដូចគ្នានោះទេ។

រូបភាព២.១៧ ៖ ផលធៀបសិស្សស្រីនិងសិស្សប្រុសចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ តាមខេត្តឆ្នាំ២០០៧-២០១៣




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

យុគភាពយេនឌ័រនៅកម្រិតឧត្តមសិក្សា (ផលធៀបសិស្សស្រីនិងសិស្សប្រុសចូលរៀននៅកម្រិតឧត្តមសិក្សា) សម្រាប់ឆ្នាំ២០០៤រហូតដល់ឆ្នាំ២០០៩ (រូបភាពទី២.១៨) បង្ហាញពីភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល២ឆ្នាំកន្លងទៅ។ វឌ្ឍនភាពរបស់ចំណុចដៅនេះស្ថិតនៅតាមគន្លងហើយអាចនឹងសម្រេចបានក្នុងឆ្នាំ២០១៥ជាមួយនឹងកិច្ចខំប្រឹងប្រែងបន្ថែមទៀត។

រូបភាព២.១៨ ៖ ផលធៀបសិស្សស្រី និងសិស្សប្រុសចូលរៀននៅកម្រិតឧត្តមសិក្សា ឆ្នាំ២០០៤ ឆ្នាំ២០០៩ និងឆ្នាំ២០១៥




*ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤ និង២០០៩*

រូបភាព២.១៩ ៖ ផលធៀបសិស្សស្រី និងសិស្សប្រុសចូលរៀននៅកម្រិតឧត្តមសិក្សា តាមខេត្ត ឆ្នាំ២០១១




*ប្រភព៖ ទិន្នន័យឃុំ សង្កាត់*

ឯកសារស្ថានភាពរាជធានី ខេត្តស្តីពីការសិក្សានៅកម្រិតឧត្តមសិក្សាដែលទទួលបានពីទិន្នន័យឃុំ-សង្កាត់ សម្រាប់ឆ្នាំ២០១១បង្ហាញពីស្ថានភាពយុគភាពយេនឌ័រក្នុងការសិក្សានៅកម្រិតឧត្តមសិក្សានិងកម្រិតនៃការអភិវឌ្ឍឬភាពក្រីក្រ(រូបភាពទី២.១៩)ដែលមិនមានទំនាក់ទំនងរវាងគ្នា។ ឧទាហរណ៍ខេត្តមួយចំនួនដូចជាខេត្តឧត្តរមានជ័យខេត្តកំពង់ស្ពឺនិងខេត្តរតនគិរីមានអនុបាតយុគភាពយេនឌ័រក្នុងកម្រិតទាបចំណែកឯរាជធានីខេត្តផ្សេងៗទៀតដូចជារាជធានីភ្នំពេញខេត្តព្រះវិហារ និងខេត្តសៀមរាបបង្ហាញពីយុគភាពយេនឌ័រស្មើរស្មើ១០០%ឬលើស១០០%។ រាជរដ្ឋាភិបាលបានទទួលស្គាល់ពីបញ្ហាទាំងនេះ។

ទោះបីមិនទាក់ទងទៅនឹងគ.អ.ស.ក. ប៉ុន្តែបញ្ហាប្រឈមចម្បង គឺមានតែប្រមាណ៣-៤%នៃប្រជាជនក្នុងក្រុមអាយុ១៥-២៤ឆ្នាំប៉ុណ្ណោះដែលចូលរៀននៅកម្រិតឧត្តមសិក្សា។លើសពីនេះទៀតសិស្សជាច្រើនចូលរៀនផ្នែកទូទៅជាជាងក្នុងផ្នែកវិទ្យាសាស្ត្រ និងវិស្វកម្ម។តួលេខដាច់ខាតទាំងពីរនេះ ចាំបាច់ត្រូវតែបង្កើនឡើងហើយនិស្សិតគួរតែត្រូវបានជ្រើសរើសបន្ថែមសម្រាប់ជំនាញវិទ្យាសាស្ត្រប្រសិនបើការអប់រំនៅកម្រិតឧត្តមសិក្សាដើម្បីបង្កើតមូលធនមនុស្សឱ្យបានប្រសើរជាងមុន ហើយក៏ជាបុរេប្បទានសម្រាប់ឧស្សាហូបនីយកម្ម។



ឆ វិច្ឆរា កំពុងត្បាញក្រមានៅមណ្ឌលអភិវឌ្ឍន៍ស្ត្រី-ខេត្តកំពង់ស្ពឺ

## ៣.២. ការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

រាជរដ្ឋាភិបាលបានទទួលស្គាល់ពីសារៈសំខាន់និងភាពចាំបាច់ពីការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ច។ ក្នុងន័យនេះការបង្កើនការចូលរួមរបស់កម្មករស្ត្រីក្នុងកម្លាំងពលកម្មជាកម្មករទទួលប្រាក់កម្រៃត្រូវបានជំរុញបន្ថែមទៀតដោយប្រភេទនៃការងារនេះត្រូវបានចាត់ទុកថា ជាប្រភេទដ៏ប្រសើរធៀបនឹងការងារដែលស្ត្រីមានប្រពៃណីអនុវត្ត ដូចជា ការងារក្នុងគ្រួសារដែលមិនទទួលបានប្រាក់កម្រៃជាដើម។ ចំណុចដៅរបស់គ.អ.ស.ក. នៅឆ្នាំ២០១៥ គឺធ្វើឱ្យមានសមភាពរវាងស្ត្រី និងបុរសក្នុងការទទួលបានប្រាក់កម្រៃ។

ទិន្នន័យទទួលបានពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ ឆ្នាំ២០១០ និង ឆ្នាំ២០១១ បង្ហាញថាផលធៀបនេះនៅចន្លោះពី៤២% ទៅ៤៥%ដែលទាបជាងចំណុចដៅ៥០%។ ចំណុចដៅនេះសម្រេចបានក្នុងវិស័យកសិកម្ម និងវិស័យឧស្សាហកម្ម ប៉ុន្តែសមាមាត្រនេះនៅមានកម្រិតទាបជាងនៅក្នុងវិស័យសេវាកម្ម។ ម្យ៉ាងវិញទៀតនៅក្នុងទីផ្សារកម្លាំងពលកម្មពុំមានការរើសអើងឡើយប៉ុន្តែបញ្ហានោះគឺជារចនាសម្ព័ន្ធរបស់វិស័យសេវាកម្មប៉ុណ្ណោះ សហគ្រាសភាគច្រើនជាសហគ្រាសខ្នាតតូចដែលគ្រប់គ្រងដោយខ្លួនឯងហើយភាគច្រើនជាស្ត្រី។ ដូចនេះផលធៀបនេះនឹងត្រូវធ្វើការបកស្រាយដោយភាពប្រយ័ត្នប្រយែងបំផុត។



អ្នកស្រី ឈាល សុវណ្ណ កំពុងធ្វើផ្កាសប្បនិម្មិតនៅសមាគមសប្បកម្មស្ត្រីខ្មែរ-ខេត្តតាកែវ

### តារាងទី២.៤ ៖ %នៃស្ត្រីធ្វើការក្នុងការងារទទួលបានប្រាក់កម្រៃតាមវិស័យ

| ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលបានប្រាក់កម្រៃតាមវិស័យ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|
| សមាមាត្រស្ត្រីធ្វើការក្នុងការងារទទួលបានប្រាក់កម្រៃក្នុងវិស័យកសិកម្ម | ៥១,៨ | ៥៣,១ | ៥៣,៨ |
| សមាមាត្រស្ត្រីធ្វើការក្នុងការងារទទួលបានប្រាក់កម្រៃក្នុងវិស័យឧស្សាហកម្ម | ៧១,២ | ៧៣,៧ | ៧០,៨ |
| សមាមាត្រស្ត្រីធ្វើការក្នុងការងារទទួលបានប្រាក់កម្រៃក្នុងវិស័យសេវាកម្ម | ២៩,៩ | ២៧,៤ | ២៨,៨ |
| %ស្ត្រីធ្វើការក្នុងការងារទទួលបានប្រាក់កម្រៃ ក្នុងវិស័យទាំងអស់ | ៤៥ | ៤២,២ | ៤៥,៨ |

*ប្រភព ៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា*

#### ប្រអប់ទី២.៩ ស្ត្រីក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់

ស្ត្រីដែលធ្វើការក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ទទួលបានទំនុកចិត្តខ្លួនឯងច្រើន។ ស្ត្រីទាំងនោះទទួលបានការគោរពច្រើនជាងមុនយ៉ាងហោចណាស់នៅតាមភូមិរបស់ពួកគេដោយសារការចូលរួមចំណែករបស់ពួកគេនៅក្នុងសកម្មភាពដែលទទួលបានប្រាក់កម្រៃ។ ជាពិសេសការងារក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ត្រូវបានចាត់ទុកថា ជាការចូលរួមដ៏ប្រសើរមួយទោះបីជាទទួលបានប្រាក់កម្រៃតិចជាង បើធៀបនឹងកន្លែងម៉ាស្សាឬក្លឹបកម្សាន្តក៏ដោយ។ ការគោរពនេះបានធ្វើឱ្យអំពើហឹង្សាក្នុងគ្រួសារថយចុះហើយនៅតាមភូមិការគោរពនេះបានជួយលើកកម្ពស់ស្ថានភាពស្ត្រីដែលជាជំហានវិជ្ជមានមួយឆ្ពោះទៅរកការលើកកម្ពស់ស្ថានភាពយេនឌ័រក្នុងសង្គមកម្ពុជា។

ស្ត្រីជាកម្មកររោងចក ជ្រាទូទៅស្នាក់នៅតាមផ្ទះជួលដែលមានទីតាំងនៅជិតរោងចក្រដែលខ្លួនធ្វើការហើយពួកគេអាចដើរទៅធ្វើការបានដោយមិនចាំបាច់ចំណាយ និងពេលវេលាច្រើនសម្រាប់ការធ្វើដំណើរឡើយ។ ស្ត្រីជាកម្មកររោងចក្រជាទូទៅបានជួលបន្ទប់មួយនៅជាមួយគ្នាប្រមាណ៣-៤នាក់ដោយបន្ទប់ជួលទាំងនោះមានទឹក និងភ្លើងសម្រាប់ប្រើប្រាស់។ ប៉ុន្តែក្នុងរដូវវស្សាបរិស្ថានមិនសូវមានអនាម័យល្អទេដោយប្រព័ន្ធលូត្រូវស្ទះហើយបន្ទប់ទឹក និងបង្គន់ដំណើរការមិនល្អ។

ស្ត្រីភាគច្រើនស្វែងរកការងារដែលមានបរិស្ថានសមរម្យ គឺរោងចក្រដែលគោរពតាមច្បាប់ការងារហើយកម្មករ ជាសមាជិករបស់សហជីពកម្មករ។ នៅពេលមានហេតុការមិនប្រក្រតីណាមួយកើតឡើងពីអ្នកគ្រប់គ្រងពួកគាត់អាចតវ៉ាបានតាមរយៈសហជីពទាំងនោះ។ ប៉ុន្តែសុខភាពនៅតែជាបញ្ហាដោយសារនៅក្នុងរោងចក្រមួយចំនួនមិនមានខ្យល់បរិសុទ្ធគ្រប់គ្រាន់ដែលបណ្តាលឱ្យកម្មករជាច្រើនសន្លប់ត្រូវឈរច្រើនម៉ោង ត្រូវទទួលកំដៅពីម៉ាស៊ីនអ៊ុតបណ្តាលឱ្យបែកញើស និងពិបាកដកដង្ហើមហើយកម្មករមួយចំនួនទៀតស្រូបយកក្លិនដែលមានជាតិពុលចេញពីជាតិគីមីនៅក្នុងពណ៌ក្រណាត់។ ទោះបីកម្មករទាំងអស់មានធានារ៉ាប់រងសុខភាពក៏ដោយប៉ុន្តែបញ្ហាសុខភាពរយៈពេលវែងនឹងកើតមានដោយសារការធ្វើការនៅក្នុងបរិស្ថានមិនល្អ។

*ប្រភព ៖ បទសម្ភាសន៍ជាមួយកម្មករនៅខេត្តព្រៃវែង មកធ្វើការក្នុងរោងចក្រនៅរាជធានីភ្នំពេញ*

តួនាទីរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចត្រូវបានលើកកម្ពស់ តាមរយៈការផ្តល់កាលានុវត្តភាពផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រីដោយរួមមានការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីដែលមកដល់ពេលបច្ចុប្បន្ននេះ បានបង្កើតនៅក្នុងខេត្តចំនួន១៣រួចហើយ។ មជ្ឈមណ្ឌលទាំងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាអភិវឌ្ឍន៍សេដ្ឋកិច្ចដល់ស្ត្រី។ ស្ត្រីចំនួន១៣.១០២នាក់បានទទួលការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈនៅមជ្ឈមណ្ឌលទាំងនេះ។ សមាគមសហគ្រិនស្ត្រីកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២មានសមាជិកចំនួន១៥០នាក់បានលើកកម្ពស់ស្ត្រីក្នុងពាណិជ្ជកម្ម និងពង្រឹងសម្លេងស្ត្រីក្នុងវិស័យឯកជន។

ក្រសួងកិច្ចការនារីបានបង្កើតក្របខ័ណ្ឌជំរុញមួយសម្រាប់បង្កើនល្បឿនក្នុងការសម្រេចបានចំណុចដៅទាំងឡាយក្នុងគោលដៅទី៣នៃគ.អ.ស.ក. ការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចរបស់ស្ត្រី។ ក្របខ័ណ្ឌនេះមានគោលបំណងកៀរគរស្ថាប័នសាធារណៈនិងវិស័យឯកជនដែលជាដៃគូអភិវឌ្ឍដើម្បី ៖

១. ពង្រឹងមុខជំនាញវិជ្ជាជីវៈសម្រាប់ស្ត្រីតាមតម្រូវការទីផ្សារ។

២. អភិវឌ្ឍមីក្រូសហគ្រាសខ្នាតតូច និងមធ្យម។

៣. លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់គ្រួសារនៅតាមតំបន់ជនបទ។

ទោះបីជាកិច្ចខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើងក៏ដោយក៏បញ្ហាមួយចំនួនដែលត្រូវប្រឈមគឺ ៖

១. កិច្ចសហការនៅមានកម្រិតរវាងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចអន្តរាគមន៍សម្រាប់ជំរុញស្ត្រីឱ្យទទួលបានកាលានុវត្តភាពការងារឬលើកកម្ពស់សហគ្រិនភាពរបស់ស្ត្រី។

២. កិច្ចសហការ និងទំនាក់ទំនងនៅមានកម្រិតរវាងវិស័យសាធារណៈនិងវិស័យឯកជនសម្រាប់បង្កើនសេវានៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី។

## ៣.៣. ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ

### ស្ត្រីក្នុងស្ថាប័ននីតិប្បញ្ញត្តិ

ចំនួនអាសនៈស្ត្រីក្នុងរដ្ឋសភាបានកើនឡើងជាលំដាប់ដោយនៅក្នុងឆ្នាំ១៩៩៣មានតំណាងរាស្ត្រជាស្ត្រីចំនួន៥%នៃចំនួនសរុបហើយបានកើនឡើងដល់១៩%ក្នុងឆ្នាំ២០០៣និង២០,៣%ក្នុងឆ្នាំ២០១៣។សមាមាត្រស្ត្រីនៅក្នុងព្រឹទ្ធសភានៅថេរគឺ១៤,៧៥%ក្នុងឆ្នាំ១៩៩៩និងឆ្នាំ២០១២។ ចំណុចដៅសម្រាប់ឆ្នាំ២០១៥គឺ៣០%សម្រាប់ករណីនីមួយៗនៅមិនទាន់សម្រេចនៅឡើយទេ។

រាជរដ្ឋាភិបាលកំពុងស្វែងរកការគាំទ្រមតិពីគណបក្សនយោបាយនានាក្នុងការបង្កើនតំណាងរាស្ត្រជាស្ត្រីក្នុងរដ្ឋសភាក្នុងការបោះឆ្នោតលើកក្រោយទៀត។ ការលំបាកនោះ គឺមិនមានការកំណត់ចំនួនស្ត្រីទេដូចនេះកិច្ចខិតខំប្រឹងប្រែងត្រូវធ្វើតាមការស្វែងរកការគាំទ្រមតិតែម្យ៉ាងប៉ុណ្ណោះ។

### ស្ត្រីជាសមាជិករបស់រាជរដ្ឋាភិបាល

ចំណុចដៅគ.អ.ស.ក. គឺត្រូវមានរដ្ឋមន្ត្រីជាស្ត្រីយ៉ាងហោចណាស់ឱ្យបាន១៥% នៃចំនួនរដ្ឋមន្ត្រីសរុបរដ្ឋលេខាធិការជាស្ត្រី១៨% និងអនុរដ្ឋលេខាធិការជាស្ត្រី២០%។ ក្នុងដើមឆ្នាំ២០១៣ស្ត្រីជាឧបនាយករដ្ឋមន្ត្រីមាន០១រូបរដ្ឋមន្ត្រី០៣រូបរដ្ឋលេខាធិការ៣៨រូប និងអនុរដ្ឋលេខាធិការឬឋានៈស្មើ៤៨រូប។ រាជរដ្ឋាភិបាលនឹងបង្កើនការចូលរួមរបស់ស្ត្រីក្នុងតំណែងនៃការសម្រេចចិត្តក្នុងរាជរដ្ឋាភិបាលថ្មីក្នុងអាណត្តិក្រោយៗទៀត។

### ស្ត្រីក្នុងរដ្ឋបាលសាធារណៈ

ក្នុងឆ្នាំ២០០៧តាមរយៈរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈរាជរដ្ឋាភិបាលបានចេញសេចក្តីណែនាំមួយដល់ក្រសួងស្ថាប័នទាំងអស់ឱ្យបង្កើនសមាមាត្រស្ត្រីពី២០%-៥០%នៅពេលមានការជ្រើសរើសមន្ត្រីថ្មី។ ដូចនេះចំនួនមន្ត្រីរាជការជាស្ត្រីបានកើនឡើងពី៣២%ក្នុងឆ្នាំ២០០៧ដល់៣៧%ក្នុងឆ្នាំ២០១៣។ លើសពីនេះទៀតរាជរដ្ឋាភិបាលបានផ្សព្វផ្សាយអនុក្រឹត្យស្តីពីការកែសម្រួលការចូលនិវត្តរបស់មន្ត្រីរាជការជាស្ត្រីដោយបង្កើនអាយុចូលនិវត្តន៍របស់ស្ត្រីដល់៦០ឆ្នាំនិងតាមគោលការណ៍ស្ម័គ្រចិត្ត។

## ស្ត្រីក្នុងការសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ

### ចំណុចដៅ

១. តំណាងស្ត្រីត្រូវបានតែងតាំងជាអភិបាលរងរាជធានី ខេត្ត និងក្រុង ស្រុកខណ្ឌមាន១៥%។

២. នៅកម្រិតឃុំសង្កាត់ស្ត្រីដែលជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានប្រមាណ២៥% (ជាង៣០០រូប)។

ស្ត្រីនៅមិនទាន់មានតំណាងនៅកម្រិតអភិបាលរាជធានីខេត្តទេ។ សមាមាត្រអភិបាលរងជាស្ត្រីនៅថ្នាក់ខេត្តមាន២១%ក្នុងឆ្នាំ២០១៣លើសចំណុចដៅ។ តំណាងស្ត្រីជាអភិបាលក្រុង ស្រុក ខណ្ឌ មានតែ២រូបប៉ុណ្ណោះ (២%គឺស្ថិតនៅក្រោមចំណុចដៅយ៉ាងឆ្ងាយ) ហើយស្ត្រីជាអភិបាលរង ក្រុង ស្រុក ខណ្ឌ មានចំនួន១៨៦រូប (ស្មើនឹង២៩%លើសចំណុចដៅដែលបានកំណត់)។ ក្នុងការបោះឆ្នោតក្រុមប្រឹក្សារាជធានីខេត្តឆ្នាំ២០០៩ស្ត្រីចំនួន៣៨រូប (១០%) ត្រូវបានជ្រើសរើសជាសមាជិកក្រុមប្រឹក្សារាជធានីខេត្ត និងចំនួន៣៦៣រូប (១៣%) ជាសមាជិកក្រុមប្រឹក្សាក្រុងស្រុកខណ្ឌទូទាំងប្រទេស។ សមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់បានកើនឡើងពី ១៤,៦% ក្នុងឆ្នាំ២០០៧មក ១៧,៨% ក្នុងឆ្នាំ២០១២ ប៉ុន្តែនៅទាបជាងចំណុចដៅ។

ក្នុងឆ្នាំ២០០៧ស្ត្រីជាមេឃុំឬចៅសង្កាត់មានចំនួន៦៧រូប (៤,១%) ជំទប់ទី១ចំនួន១៥១រូប (៩,៣%) និងជំទប់ទី២ចំនួន១៣រូប (៨%)។ ក្នុងឆ្នាំ២០១២ស្ត្រីជាមេឃុំឬចៅសង្កាត់មានចំនួន ៦៩រូប (៤,២%) ជំទប់ទី១ចំនួន១៨៩រូប (១១,៥៧%) និងជំទប់ទី២ចំនួន១៥១រូប (៩,២៤%) និង៣០%ជាមេភូមិ។

### អំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ

ប្រទេសកម្ពុជាចាត់ទុកអំពើហិង្សាប្រឆាំងស្ត្រីជាបទឧក្រិដ្ឋមួយហើយបានអនុម័តច្បាប់សម្រាប់ការពារស្ត្រីប្រឆាំង នឹងការរំលោភបំពានផ្សេងៗដូចជា៖

១. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ។

២. ច្បាប់ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ។

ការអនុវត្តគោលនយោបាយភូមិឃុំសុវត្ថិភាពបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សីលធម៌សង្គម និងតម្លៃស្ត្រី និងគ្រួសារជាពិសេសដូចបានកំណត់ក្នុងគោលដៅទី៣នៃគ.អ.ស.ក.។ គោលនយោបាយលើកឡើងថា "មិនមានអំពើអបាយមុខមិនមានការជួញដូរស្ត្រី និងកុមារ និងមិនមានអំពើហិង្សាក្នុងគ្រួសារ"។

យោងតាមលទ្ធផលដែលទទួលបានពីការត្រួតពិនិត្យ ករណីអំពើហិង្សាក្នុងគ្រួសារបានធ្លាក់ចុះពី៤១.៤៧២ករណីក្នុងឆ្នាំ២០០៦មក៣៥.៤០៨ករណីក្នុងឆ្នាំ២០០៩។ ចំនួនគ្រួសារបានកើនពី ២.៥៩៦.៣២២ គ្រួសារមក២.៨៥២.៩៤៣ គ្រួសារដូចនេះអំពើហិង្សាក្នុងគ្រួសារបានធ្លាក់ចុះមកប្រមាណ២៣,៩%។

ការប្រៀបធៀបទិន្នន័យក្នុងឆ្នាំ២០០៥ និងឆ្នាំ២០០៩ បង្ហាញថាស្ត្រីកាន់តែច្រើនបានទទួលស្គាល់ថាអំពើហិង្សាលើពួកគេ គឺជាសកម្មភាពខុសច្បាប់ (រូបភាពទី២.២០)។

រូបភាពទី២.២០ ៖ %ស្ត្រីដែលយល់ដឹងថាអំពើហិង្សាក្នុងគ្រួសារជាបទឧក្រិដ្ឋ




*ប្រភព៖ ក្រសួងកិច្ចការនារី*

មាត្រាទី២០នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះបញ្ជាក់ថាតុលាការ នឹងចេញដីកាការពារដល់ជនរងគ្រោះតាមការស្នើសុំ។ ក្នុងឆ្នាំ២០១២តុលាការបានចេញដីកាការពារចំនួន១៤ច្បាប់។ យោងតាមមាត្រា១៤នៃច្បាប់នេះអាជ្ញាធរមូលដ្ឋានបានចេញការសម្រេចផ្នែករដ្ឋបាលចំនួន១៣០៥៣ច្បាប់ក្នុងឆ្នាំ២០០៩ និងចំនួន១១១៣៦ច្បាប់ក្នុងឆ្នាំ២០១០យោងតាមកំណត់ត្រានៅថ្នាក់ឃុំសង្កាត់។

ក្រសួងកិច្ចការនារីដោយមានកិច្ចសហការជាមួយមជ្ឈមណ្ឌលស្ត្រីមានវិបត្តិនៅកម្ពុជាបានផ្តល់ការប្រឹក្សាដល់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារចំនួន៧២០រូបក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣ក្នុងខេត្តសៀមរាប បន្ទាយមានជ័យ និងរាជធានីភ្នំពេញ។

ក្នុងឆ្នាំ២០១៣មន្ត្រីរាជការរបស់ក្រសួងកិច្ចការនារីចំនួន១៤១រូបនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានទទួលការបណ្តុះបណ្តាលជាភ្នាក់ងារប៉ូលីសយុត្តិធម៌ស្តីពីការការពារ និងជំនួយដល់ជនរងគ្រោះពីអំពើហិង្សាលើស្ត្រី។

ដើម្បីទប់ស្កាត់ការជួញដូរមនុស្សក្រសួងកិច្ចការនារីបានរៀបចំផែនការសកម្មភាពជាតិសម្រាប់ឆ្នាំ២០១២-២០១៤។ ក្រសួងបានធ្វើវិសោធនកម្មអនុស្សារណៈយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ



និសិត្សសាកលវិទ្យាល័យកំពុងពិភាក្សាក្នុងពេលសិក្សាយេនឌ័រ-រាជធានីភ្នំពេញ

សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយសង្គ្រោះជនរងគ្រោះពីការជួញដូរ។ ក្រសួងកិច្ចការនារីបានចុះហត្ថលេខាលើការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាម សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរស្ត្រីនិងកុមារ និងជួយសង្គ្រោះជនរងគ្រោះពីការជួញដូរ និងបានរៀបចំសេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៣-២០១៤។

## លទ្ធផលដែលសម្រេចបានបញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាលន្ទាប់

**លទ្ធផលដែលសម្រេចបាន៖** ប្រទេសកម្ពុជាស្ថិតនៅលើវិថីដែលនឹងសម្រេចបាននូវសមធម៌យេនឌ័រផ្នែកការសិក្សាអប់រំទាំងកម្រិតមធ្យមសិក្សាទុតិយភូមិនិងកម្រិតឧត្តមសិក្សា។ ទន្ទឹមនឹងនេះកម្ពុជាក៏សម្រេចបាននូវសមភាពយេនឌ័រនៅក្នុងការងារដែលទទួលបានប្រាក់កម្រៃក្នុងវិស័យកសិកម្ម និងវិស័យឧស្សាហកម្ម។ ទោះបីជាមិនមានសមភាពយេនឌ័រក្នុងការងារដែលទទួលបានប្រាក់កម្រៃ ក្នុងវិស័យសេវាកម្មក៏ដោយប៉ុន្តែភាគច្រើនស្ត្រីប្រកបអាជីវកម្មដោយខ្លួនឯងក្នុងវិស័យសេវាកម្ម។ ស្ត្រីក្នុងវិស័យរដ្ឋបាលសាធារណៈកំពុងតែមានចំនួនកើនឡើងជាលំដាប់។ តាមរយៈនិន្នាការកំណើននេះកម្ពុជានឹងអាចសម្រេចបានចំណុចដៅនៅឆ្នាំ២០១៥ ទោះបីជាការបោះឆ្នោតឃុំសង្កាត់នឹងប្រព្រឹត្តក្នុងឆ្នាំ២០១៧ហើយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនឹងរៀបចំធ្វើនៅឆ្នាំ២០១៨ក៏ដោយ។ ដោយឡែកចំណុចដៅនៃការបង្កើនចំនួនស្ត្រីឱ្យមានការយល់ដឹងពីគោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាលជាពិសេសចំណេះដឹងពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីគឺជាបទឧក្រិដ្ឋកម្មត្រូវបានសម្រេចរួចហើយ។

**ភាពប្រឈម៖** ទោះបីជាវឌ្ឍនភាពជាច្រើនត្រូវបានធ្វើឱ្យកើតឡើងក្តី ជារួមអត្រាចូលរួមរបស់ស្ត្រី និងបុរសក្នុងការសិក្សាអប់រំនៅតែមានចំនួនទាប ក្នុងបរិបថកិច្ចអភិវឌ្ឍនិងក្រោយ គ.អ.ស.ក. ឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ គម្លាតនៅតាមខេត្តនៅតែបន្តមាន។ ការមិនមានសំភារសិក្សាអប់រំគ្រប់គ្រាន់នៅកម្រិតក្រោយកម្រិតបឋមសិក្សា គឺជាហេតុផលដ៏សំខាន់ដែលធ្វើឱ្យការបន្តសិក្សាមានកម្រិតទាប។ ក្នុងន័យនេះការមិនមានមូលធនមនុស្សគ្រប់គ្រាន់នឹងជាហេតុផលបង្កឱ្យមានផលិតភាពទាប។ សមាមាត្រនៃស្ត្រីដែលធ្វើការក្នុងគ្រួសារដោយគ្មានប្រាក់កម្រៃមានចំនួនច្រើន ធ្វើឱ្យមានការប៉ះពាល់ដល់កំណើនទីផ្សារពលកម្មជាពិសេសក្រោយឆ្នាំ២០១៥។

**គោលនយោបាយរបស់រាជរដ្ឋាភិបាល៖** រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការសម្រេចឱ្យបានយុគភាពយេនឌ័រ នៅក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិ។ រាជរដ្ឋាភិបាលនឹងបន្តផ្តល់ភាពអង់អាចដល់ស្ត្រីប្រកបដោយប្រសិទ្ធភាព នៅពេលដែលសេដ្ឋកិច្ចមានកំណើនប្រកបដោយចីរភាពនិងបរិយាប័ន្នដូចមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណថារាជរដ្ឋាភិបាលបន្តផ្តល់អាទិភាពខ្ពស់ដល់កំណើនប្រកបដោយបរិយាប័ន្ន។ ជាមួយគ្នានេះរដ្ឋាភិបាលបានរៀបចំផែនការយុទ្ធសាស្ត្រនារីរតនៈដែលមានគោលបំណងផ្តល់សិទ្ធិអំណាចដល់ស្ត្រី តាមរយៈការពង្រឹងជំនាញ កាលានុវត្តភាពទាំងការងារមានកម្រៃ និងមិនមានកម្រៃ និងការបង្កើនចំនួនស្ត្រីក្នុងរាជការស៊ីវិល និងការិយាល័យសាធារណៈ។ រដ្ឋាភិបាល ក៏បានរៀបចំនិងដាក់ឱ្យប្រើប្រាស់ក្របខ័ណ្ឌពន្លឿនគ.អ.ស. សំដៅជំរុញការងារ ដែលនៅសេសសល់មិនទាន់បានសម្រេច។ រាជរដ្ឋាភិបាលក៏បានអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទព្រមទាំងផែនការសកម្មភាពជាតិលើកទី១ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

## គោលដៅទី៤ កាត់បន្ថយអត្រាមរណភាពកុមារ

នៅក្នុងគោលដៅនេះ មានចំណុចដៅចំនួន៤ គឺ ៖

១. កាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំឱ្យបានពាក់កណ្តាលរវាងឆ្នាំ១៩៩៨ និងឆ្នាំ២០១៥។

២. កាត់បន្ថយអត្រាមរណភាពរបស់កុមារអាយុក្រោម៥ឆ្នាំ ឱ្យបានពាក់កណ្តាលរវាងឆ្នាំ១៩៩៨ និងឆ្នាំ២០១៥។

៣. បង្កើនការផ្តល់វ៉ាក់សាំងដល់កុមារឱ្យបាន៩០%។

៤. បង្កើនការបំបៅដោះម្តាយដល់កុមាររហូតអាយុ៦ខែ ឱ្យបាន៧០%។

### ៤.១ មរណភាពរបស់កុមារ និងកុមារអាយុក្រោម៥ឆ្នាំ

ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ និងកុមារអាយុក្រោម៥ឆ្នាំ។ រូបភាពទី២.២១ បង្ហាញពីការកាត់បន្ថយអត្រាមរណភាពរបស់កុមារ ក្នុងរវាងឆ្នាំ២០០០ និងឆ្នាំ២០០៥។ នេះមានន័យថាចំណុចដៅនៃគ.អ.ស.ក. ត្រូវបានសម្រេចមុនកាលកំណត់ដែលជាសមិទ្ធផលមួយសម្រាប់សេដ្ឋកិច្ចដែលមានចំណូលទាបនិងក្រោយសង្គ្រាម។ ចំណុចដៅអត្រាមរណភាពរបស់កុមារ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៨ដោយមានមូលដ្ឋានលើជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ១៩៩៨។ យោងតាមជំរឿននេះអត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ មាន១២៤នាក់នៅក្នុងឆ្នាំ១៩៩៨។ វិទ្យាស្ថានជាតិស្ថិតិបានទទួលស្គាល់ថា អង្កេតសុខភាពដូចជាអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាអាចផ្តល់លទ្ធផលល្អប្រសើរជាងជំរឿនប្រជាជន។ ប៉ុន្តែចំណុចដៅសម្រាប់អត្រាមរណភាពកុមារនៅឆ្នាំ២០១៥នៅតែមិនមានការផ្លាស់ប្តូរទោះបីជាអង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជាបង្ហាញពីតួលេខផ្សេងគ្នាក៏ដោយ។

**រូបភាព២.២.១ ៖ និន្នាការរបស់អត្រាមរណភាពកុមារ និងកុមារអាយុក្រោម៥ឆ្នាំ នៅឆ្នាំ២០០០ ឆ្នាំ២០០៥ ឆ្នាំ២០១០ និងឆ្នាំ២០១៥**




*ប្រភព ៖ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០០០ ឆ្នាំ២០០៥ និងឆ្នាំ២០១០*

ការកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ធ្វើឱ្យកម្ពុជាសម្រេចបានចំណុចដៅនៃគ.អ.ស.ក. មុនកាលកំណត់៥ឆ្នាំ (រូបភាពទី២.២២)។ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១០បង្ហាញពីវឌ្ឍនភាពជាច្រើនដូចជាការថែទាំមុនពេលសម្រាល និងក្រោយពេលសម្រាលដែលជាមូលហេតុធ្វើឱ្យធ្លាក់ចុះអត្រាមរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំ។ ឧទាហរណ៍សមាមាត្រទារកដែលសម្រាលដោយបុគ្គលិកសុខភាពជំនាញបានកើនពី៤៤% ក្នុងឆ្នាំ២០០៥ ទៅ ៧១% ក្នុងឆ្នាំ២០១០។ ទិន្នន័យប្រព័ន្ធព័ត៌មានរបស់ក្រសួងសុខាភិបាលបង្ហាញថាសមាមាត្រនេះបានកើនដល់៧៥% នៅឆ្នាំ២០១២។ សមាមាត្រទារកដែលបានសម្រាលនៅមន្ទីរពេទ្យឬមណ្ឌលសុខភាពបានកើនជាងពីរដងពី២២% នៅឆ្នាំ២០០៥ទៅ៥៤% នៅឆ្នាំ២០១០យោងតាមអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា។ សមាមាត្រនេះបានកើនដល់៦៦% នៅឆ្នាំ២០១២។ វឌ្ឍនភាពនេះច្រើនកើតមាននៅតំបន់ទីប្រជុំជនដែលមានទារកប្រមាណ៨៦% បានសម្រាលនៅមណ្ឌលសុខភាពដោយឡែកនៅតំបន់ជនបទមានទារកតិចជាង៥០%បានសម្រាលនៅមណ្ឌលសុខភាព។ ការអប់រំរបស់ស្ត្រីដើរតួនាទីសំខាន់ក្នុងការស្វែងរកការសម្រាលតាមបែបវេជ្ជសាស្ត្រទំនើប។ លើសពីនេះទៀតគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ការលើកទឹកចិត្តដល់ពេទ្យឆ្មបចាប់តាំងពីឆ្នាំ២០០៦មក និងការផ្សព្វផ្សាយពីការសម្រាលនៅតាមមណ្ឌលសុខភាពបានជួយជំរុញដល់ការសម្រេចបានសមិទ្ធផលនេះ។ រូបភាពទី២.២២បង្ហាញពីទិន្នន័យខេត្តស្តីពីអត្រាមរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំនៅគ្រប់ខេត្តទាំងអស់។ ខេត្តជាច្រើននៅមិនទាន់សម្រេចបាននូវចំណុចដៅគ.អ.ស.ក. ដូចជាខេត្តនៅតំបន់ភាគខាងជើង និងជុំវិញបឹងទន្លេសាបជាដើម ដូចនេះការងារបន្ទាប់ គឺការបំបាត់គម្លាតវិសមភាពនៅខេត្តទាំងនោះ។



ស្ត្រីកំពុងថ្លឹងទម្ងន់ទារកនាពេលត្រួតពិនិត្យសុខភាព-ខេត្តក្រចេះ

រូបភាពទី២.២២ ៖ អត្រាមរណភាពកុមារ និងកុមារអាយុក្រោម៥ឆ្នាំ ទិន្នន័យតាមរាជធានីខេត្ត




*ប្រភព៖ អង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជា ឆ្នាំ២០១០*

អត្រាមរណភាពរបស់កុមារក្រោម១ឆ្នាំ និងកុមារអាយុក្រោម៥ឆ្នាំមានទំនាក់ទំនងគ្នាទៅវិញទៅមក និងមានទំនាក់ទំនងជាមួយអត្រាភាពក្រីក្រ និងកម្រិតជីវភាពរស់នៅរបស់ប្រជាជន (រូបភាពទី២.២៣)។ នៅពេលអត្រាភាពក្រីក្របានធ្លាក់ចុះស្ថានភាពនៃមរណភាពកុមារនឹងបានប្រសើរឡើងផងដែរ។ បញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារ និងភាពក្រីក្រក៏មានទំនាក់ទំនងគ្នាផងដែរ។ ដូចនេះ ការកាត់បន្ថយភាពក្រីក្រ គឺជាការងារស្នូលសម្រាប់សម្រេចបានគោលដៅទី១ ដល់ទី៤ នៃ គ.អ.ស.ក.។

ក្រសួងសុខាភិបាលបានបញ្ជាក់ថា បញ្ហាប្រឈមសំខាន់នាពេលបច្ចុប្បន្ននេះគឺអត្រាមរណភាពទារកទើបកើត (ការស្លាប់ពេលកើតបាន២៨ថ្ងៃដំបូងដែលជាផ្នែកមួយសំខាន់ នៃអត្រាមរណភាពរបស់ទារក)។ បញ្ហានេះតម្រូវឱ្យមានអន្តរាគមន៍ដើម្បីជួយទប់ស្កាត់ជំងឺឆ្លងការសម្រាលមិនគ្រប់ខែ និងការស្ទះដង្ហើមរបស់ទារកពេលសម្រាល។ អន្តរាគមន៍ទាំងនោះរួមមានការការពារជំងឺតេតាណុស ការផ្សព្វផ្សាយពីការសម្រាលនៅតាមមណ្ឌលសុខភាពការពង្រឹងជំនាញរបស់បុគ្គលិកសុខភាព និងការពង្រឹងប្រព័ន្ធផ្តល់ការប្រឹក្សាជំងឺ និងការពង្រឹងគុណភាពនៃការថែទាំសុខភាព។

រូបភាពទី២.២៣ ៖ ចំណាត់ថ្នាក់អត្រាមរណភាពកុមារ និងកុមារអាយុក្រោម៥ឆ្នាំ (តាមខេត្ត) និងកម្រិតជីវភាពរស់នៅរបស់ប្រជាជននៅកម្ពុជាឆ្នាំ២០១០










*ប្រភព៖ អង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជា ឆ្នាំ២០១០*

## ៤.២ ការផ្តល់ថ្នាំបង្ការជំងឺសម្រាប់កុមារ

កុមារម្នាក់ទទួលបានវ៉ាក់សាំងពេញលេញ ប្រសិនបើទទួលបានវ៉ាក់សាំងជំងឺរបេង វ៉ាក់សាំងDTCយ៉ាងតិចបីលើកសម្រាប់ការពារជំងឺខាន់ស្លាក់ ជំងឺតេតាណុស និងជំងឺក្អកមាន់ វ៉ាក់សាំងគ្រុនស្វិតដៃជើងឱ្យបានយ៉ាងតិចបីលើក និងវ៉ាក់សាំងជំងឺកញ្រ្ជិលមួយលើក។ វ៉ាក់សាំងទាំងនេះ ត្រូវផ្តល់ជូនកុមារនៅពេលពួកគេស្ថិតនៅអាយុមួយឆ្នាំ។ចាប់តាំងពីឆ្នាំ២០០៦ កម្មវិធីជាតិផ្តល់ថ្នាំបង្ការបានជំនួសវ៉ាក់សាំងDTCដោយវ៉ាក់សាំងតេត្រាវ៉ាឡង់ដែលរួមមានDTC និងវ៉ាក់សាំងការពារគ្រុនផ្តាសាយបក្សី ប្រភេទB (Hib) និងវ៉ាក់សាំងប៉ង់តាវ៉ាឡង់ដែលរួមមានDTC, Hib, និងថ្លើមប្រភេទ B(HepB)។

សមាមាត្រកុមារអាយុពី១២-២៣ខែ ប្រមាណ៧៩% ទទួលបានវ៉ាក់សាំងគ្រប់មុខ។ នេះជាលទ្ធផលល្អប្រសើរជាងឆ្នាំ២០០៥ ដែលមានកុមារប្រមាណតែ៦៧% ក្នុងក្រុមអាយុដូចគ្នា ដែលទទួលបានវ៉ាក់សាំងគ្រប់មុខ។ កុមារច្រើនជាង៩0% បានទទួលវ៉ាក់សាំង BCG វ៉ាក់សាំងតេតរាវ៉ាឡង់ឬប៉ង់តាវ៉ាឡង់ពីរលើក និងវ៉ាក់សាំងគ្រុនស្វិតដៃជើងពីរលើក (ចំណុចដៅគ.អ.ស.ក. ឆ្នាំ២០១៥សម្រាប់DPT3ត្រូវបានចំនួន៩៥%)។ សមាមាត្រកុមារទទួលបានវ៉ាក់សាំងតេតាវ៉ាឡង់ និងវ៉ាក់សាំងគ្រុនស្វិតដៃជើងលើកទីបីមានចំនួន៨៥%។ កុមារច្រើនជាង៩៣% បានទទួលវ៉ាក់សាំងHepatitis 0(ចំណុចដៅគ.អ.ស.ក. ឆ្នាំ២០១០ គឺ៩៥%)ហើយកុមារ៩៣% ទទួលបានវ៉ាក់ស៊ាំងកញ្រ្ជិល (ចំណុចដៅនៃគ.អ.ស.ក. គឺ៩៥%)។

ការទទួលបានវ៉ាក់សាំងគ្រប់មុខប្រែប្រួលតាមការអប់រំរបស់មាតា។ មានតែប្រមាណ៥៨% ក្នុងចំណោមកុមារដែលមានមាតាមិនមានការអប់រំប៉ុណ្ណោះដែលទទួលបានវ៉ាក់សាំង តែអត្រានេះមានកម្រិតខ្ពស់បន្តិច (៨០%) ចំពោះកុមារដែលមានមាតាទទួលបានការអប់រំកម្រិតបឋមសិក្សា និង៨៨% ចំពោះកុមារដែលមានមាតាមានការអប់រំដល់កម្រិតមធ្យមសិក្សា ឬខ្ពស់ជាងនេះ។ យោងតាមអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០១០ ស្ថានភាពជីវភាពរស់នៅរបស់គ្រួសារនីមួយៗ មានទំនាក់ទំនងជិតស្និតជាមួយនឹងការទទួលបានវ៉ាក់សាំង។ ប្រជាជនរស់នៅទីប្រជុំជនទទួលបានវ៉ាក់សាំងប្រសើរជាងប្រជាជននៅតំបន់ជនបទ។ ការទទួលបានវ៉ាក់សាំងគ្រប់មុខមានប្រមាណ៨៦% ក្នុងតំបន់ទីប្រជុំជន និង៧៧% សម្រាប់តំបន់ជនបទ។ សរុបមក ការទទួលបានវ៉ាក់សាំងនេះ អាស្រ័យលើការអប់រំរបស់មាតាស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារ និងទីតាំងរស់នៅ។ សារនេះបញ្ជាក់ថាការលុបបំបាត់ភាពក្រីក្រការអប់រំរបស់ស្ត្រីនិងលទ្ធភាពក្នុងការទទួលបានសេវា គឺជាចំណុចសំខាន់នៃសុខភាពកុមារ និងសុខុមាលភាពគ្រួសារ។

សម្រាប់គ.អ.ស.ក. ឆ្នាំ២០១៥សូចនាករទាំងនេះបានសម្រេចរួចហើយ ឬស្ថិតតាមគោលដៅដែលនឹងត្រូវសម្រេចបាន។

ការបំបៅដោះម្តាយ គឺជាការងារពេញនិយមនៅកម្ពុជា។ ក្នុងឆ្នាំ២០១០ កុមារក្រោមអាយុ៦ខែ ប្រមាណ៧៤% ដែលបានទទួលការបំបៅដោះម្តាយ។ នេះជាការកើនឡើងដ៏គួរឱ្យកត់សម្គាល់ ធៀបនឹងឆ្នាំ២០០៥ នៅពេលដែលលទ្ធផលអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាបានបង្ហាញថាមានតែប្រមាណ៦០% ប៉ុណ្ណោះ។ មានទារកអាយុក្រោម៦ខែប្រមាណ៣% ប៉ុណ្ណោះដែលមិនបានទទួលការបំបៅដោះពីម្តាយក្នុងឆ្នាំ២០១០។ កុមារស្ទើរទាំងអស់ទទួលបានការបំបៅដោះនៅពេលចាប់កំណើតក្នុងឆ្នាំទី១ ប៉ុន្តែ នៅពេលមានអាយុពី៦-៩ខែ ភាគច្រើននៃកុមារបៅដោះទទួលបានអាហារបន្ថែមក្រៅពីទឹកដោះម្តាយ។ ការបំបៅទឹកគោមិនពេញនិយមទេក្នុងប្រទេសកម្ពុជា ប៉ុន្តែវាបានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីឆ្នាំ២០០៥។ កុមារ១៤% ដែលមានអាយុតិចជាង៦ខែបានបៅទឹកដោះគោ ធៀបនឹង១១% ក្នុងឆ្នាំ២០០៥។ កុមារដែលធ្លាប់ទទួលបានការបំបៅដោះមានក្នុងចន្លោះពី៨៧% ក្នុងខេត្តមណ្ឌលគិរី និងរតនគិរី ទៅដល់៩៩% នៅខេត្តស្វាយរៀង។ ប្រមាណ២/៣នៃកុមារទទួលបានការបំបៅដោះម្តាយក្នុងរយៈពេល ១ម៉ោងបន្ទាប់ពីចាប់កំណើតហើយមានប្រមាណ៨៩% ទទួលបានការបំបៅក្នុងរយៈពេល១ថ្ងៃបន្ទាប់ពីការចាប់កំណើត។ ជាទូទៅការចាប់ផ្តើមបំបៅដោះឱ្យបានឆាប់ គឺជាការពេញនិយមសម្រាប់កុមារដោយម្តាយរបស់ពួកគេទទួលបានការណែនាំពីបុគ្គលិកសុខភាពនៅពេលសម្រាល។

ពិនិត្យជារួមចំណុចដៅគ.អ.ស.ក.ឆ្នាំ២០១៥បានសម្រេចរួចហើយ។

## លទ្ធផលដែលបានសម្រេចបាន បញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

**លទ្ធផលដែលសម្រេចបាន ៖** ប្រទេសកម្ពុជាបានសម្រេចនូវសូចនាករស្ទើរទាំងអស់ដែលពាក់ព័ន្ធនឹងសុខភាពកុមារអត្រាមរណភាពរបស់កុមារ អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំវ៉ាក់សាំងបង្ការជំងឺនិងការបំបៅកូនដោយទឹកដោះម្តាយ។

**ភាពប្រឈម ៖** គម្លាតនៅតាមខេត្តទាក់ទងនឹងសូចនាករសុខភាពកុមារ គឺការឆ្លុះបញ្ចាំងពីកម្រិតជីវភាពរស់នៅទ្រព្យសម្បត្តិ និងការពង្រីកសេវាមិនស្មើគ្នាដែលតម្រូវឱ្យមានការលុបបំបាត់គម្លាតនេះ។

**គោលនយោបាយរាជរដ្ឋាភិបាល ៖** ថ្វីត្បិតតែវឌ្ឍនភាពជាច្រើនត្រូវបានធ្វើឱ្យកើតមានក្តី កម្ពុជានៅតែមានអត្រាមរណភាពទារក និងកុមារអាយុក្រោម៥ឆ្នាំខ្ពស់ធៀបនឹងបណ្តាប្រទេសដទៃទៀតនៅក្នុងតំបន់ហើយការគ្របដណ្តប់ និងគុណភាពសេវាសុខាភិបាលនៅមិនទាន់បានឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការនៅឡើយ។ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលបានដាក់ចេញកម្មវិធីសុខាភិបាលចំនួន១០ចំណុចដែលពាក់ព័ន្ធទៅនឹងសុខភាពទារក និងកុមារ។ កម្មវិធីនេះបញ្ជាក់ថា សុខភាពទារក និងកុមារ រួមទាំងស្ថានភាពអាហារូបត្ថម្ភនឹងត្រូវបានលើកកម្ពស់តាមរយៈការពង្រឹងគុណភាពនិងប្រសិទ្ធភាព ការថែទាំសុខភាពបន្តពូជ ការសម្រាលកូនសេវាគាំពារទារក និងកុមារដោយផ្តោតលើការពង្រីកវិសាលភាពគ្របដណ្តប់នៃការសម្រាលកូនដោយឆ្មប និងគ្រូពេទ្យជំនាញ ការពង្រីកសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងសេវាថែទាំទារកការពង្រីកសេវាផ្តល់មធ្យោបាយពន្យារកំណើតការបង្កើនអត្រាគ្របដណ្តប់នៃការផ្តល់វ៉ាក់សាំងបង្ការជំងឺដល់កុមារជាពិសេសវ៉ាក់សាំងជំងឺកញ្ជ្រឹល និងជំងឺតេតាណូសការផ្តល់មីក្រូសារជាតិ និងជីវជាតិដល់ទារកអាយុ១០០០ថ្ងៃដំបូង និងសេវាថែទាំព្យាបាលជំងឺកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។



មន្ត្រីសុខាភិបាលកំពុងផ្តល់ថ្នាំបង្ការដល់សិស្សនៅសាលារៀន-ខេត្តកំពង់ចាម

## គោលដៅទី៥ ការធ្វើឱ្យប្រសើរឡើងសុខភាពមាតា

គ.អ.ស.ក. កំណត់ចេញនូវសូចនាករទាំង៦ សម្រាប់វាស់ស្ទង់សុខភាពមាតា ដូចខាងក្រោម៖

១. អត្រាមរណភាពមាតា(១០០.០០០ក្នុងកំណើតរស់) ចំណុចដៅឆ្នាំ២០១៥ គឺ ២៥០។

២. សមាមាត្រស្ត្រីសម្រាលកូនដោយបុគ្គលិកសុខាភិបាលជំនាញ (%) ចំណុចដៅឆ្នាំ២០១៥ គឺ ៨៧។

៣. អត្រាផ្តល់កំណើតសរុប - ចំណុចដៅឆ្នាំ២០១៥ គឺ៣នាក់។

៤. សមាមាត្រស្ត្រីដែលបានរៀបការ និងបានប្រើប្រាស់វិធីពន្យារកំណើត(%)ចំណុចដៅឆ្នាំ២០១៥ គឺ៦០។

៥. សមាមាត្រស្ត្រីមានផ្ទៃពោះដែលទទួលបានការពិនិត្យផ្ទៃពោះពីរដងឬច្រើនជាង ដោយបុគ្គលិកសុខាភិបាលជំនាញ (%) ចំណុចដៅឆ្នាំ២០១៥ គឺ៩០។

៦. សមាមាត្រស្ត្រីមានផ្ទៃពោះដែលសម្រាលកូនដោយធ្វើការវះកាត់ - ចំណុចដៅឆ្នាំ២០១៥ គឺ ៤។

### ៥.១ អត្រាមរណភាពមាតានិងការសម្រាលកូនដោយបុគ្គលិកសុខាភិបាលជំនាញ

ចំណុចដៅនៃអត្រាមរណភាព ក៏ដូចជាចំណុចដៅប្រជាសាស្ត្រ/សុខភាពជាច្រើនដទៃទៀតដែរ ត្រូវបានកំណត់ចំណុចដៅឱ្យមកនៅត្រឹម ១៤០នាក់ក្នុង១០០.០០០កំណើតរស់ដោយផ្អែកលើជំរឿនឆ្នាំ១៩៩៨ និង ការព្យាករណ៍ដោយផ្អែកលើការប៉ាន់ស្មានប្រជាសាស្ត្រ ធ្វើឡើងនៅទសវត្សរ៍ឆ្នាំ១៩៩០។ ដោយមើលឃើញពីលទ្ធផលអត្រាមរណភាពមាតាមានចំនួនច្រើននៅក្នុង អង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០០០ ព្រមទាំងការពង្រីកវិសាលភាពសេវាសុខាភិបាល និងការឆ្លើយតបផ្នែកសុខាភិបាល នៅមានកម្រិតទាប ចំណុចដៅអត្រាមរណភាពមាតា មក២៥០ ក្នុង១០០.០០០កំណើតរស់។

រូបភាពទី២.២៤ ៖ និន្នាការក្នុងអត្រាមរណភាពមាតា ឆ្នាំ២០០០-២០១០




*ប្រភព៖ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០០០ ២០០៥ និង២០១០*

រូបភាពទី២.២៤ បង្ហាញថា អត្រាមរណភាពមាតានៅក្នុងឆ្នាំ២០០០ ឆ្នាំ២០០៥ និងឆ្នាំ២០១០។តាមការប៉ាន់ស្មានសម្រាប់ឆ្នាំ២០០០ និង ឆ្នាំ២០០៥ បង្ហាញថាអត្រាមរណភាពមាតាមានកម្រិតខ្ពស់ជាង៤០០នាក់។ ទោះជាដូចនេះក្តី អត្រាមរណភាពមាតាថយចុះគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ២០១០ ដល់២០៦ដែលគោលដៅ២៥០នាក់ ក្នុងឆ្នាំ២០១៥នឹងសម្រេចបាន៥ឆ្នាំមុនកំណត់។

ហេតុផលមួយចំនួននៃការធ្លាក់ចុះអត្រាមរណភាពមាតា រួមមាន៖

១. សមាមាត្រស្ត្រីសម្រាលកូនដោយបុគ្គលិកសុខាភិបាលជំនាញ និង ការសម្រាលនៅមូលដ្ឋានសុខាភិបាលមានចំនួនកើនឡើងយ៉ាងឆាប់រហ័សរវាងឆ្នាំ២០០៥ និងឆ្នាំ២០១០។

២. ការកែលម្អការផ្គត់ផ្គង់ឧបករណ៍សង្គ្រោះបន្ទាន់បឋម និង ការពិគ្រោះមុន និងក្រោយសម្រាល ដែលត្រូវបានគិតថា ចំណុចទាំងអស់នេះរួមចំណែកសង្គ្រោះជីវិតមាតាបានច្រើន។

៣. ប្រព័ន្ធលើកទឹកចិត្តធួបជំនាញសម្រាប់ការសម្រាលនៅមូលដ្ឋានសុខាភិបាល ដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០០៦ ដោយក្រសួងសុខាភិបាល។

៤. ការធ្វើឱ្យប្រសើរឡើងនៃស្ថានភាពកម្រិតសិក្សា និងចំណេះដឹងរបស់មាតា។

ដោយឡែក ការវិភាគលម្អិតបន្ថែមអំពីអត្រាមរណភាពមាតា តាមបណ្តាឆ្នាំនីមួយៗ ក៏ដូចជាថ្នាក់ខេត្ត ឬក៏ការបែងចែកទ្រព្យទៅតាមក្រុម ដោយប្រើប្រាស់នូវទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា គឺមិនគ្រប់គ្រាន់នោះទេ។ ដូច្នេះទិន្នន័យមូលដ្ឋានឃុំ ត្រូវបានយកមកប្រើប្រាស់ ហើយលទ្ធផលបានបង្ហាញថាខេត្តដាច់ស្រយាល និងមានការអភិវឌ្ឍតិចតួចមួយចំនួន ដូចជាខេត្តស្ទឹងត្រែង កោះកុង រតនគិរី និងមណ្ឌលគិរីមានអត្រាមរណភាពមាតាខ្ពស់ជាង អត្រាមធ្យមភាគនៅថ្នាក់ជាតិ។ ភាគរយស្ត្រីសម្រាលកូនដោយបុគ្គលិកសុខាភិបាលទទួលការបណ្តុះបណ្តាលមានចំនួន៥៨% ក្នុងឆ្នាំ២០០៨ និងបានកើនឡើងដល់៧៥% ក្នុងឆ្នាំ២០១២។ ដូច្នេះ ដោយមើលឃើញពីការកើនឡើងថេរនៃអត្រាមរណភាពមាតានោះ កម្ពុជានឹងសម្រេចបាននូវចំណុចដៅ៨៧% ក្នុងឆ្នាំ២០១៥ ខាងមុខ។

រូបភាពទី២.២៥ ៖ ភាគរយស្ត្រីសម្រាលកូនដោយបុគ្គលិកសុខាភិបាលទទួលការបណ្តុះបណ្តាល តាមខេត្ត ឆ្នាំ២០១២




*កំណត់សម្គាល់៖ ទិន្នន័យថ្នាក់ជាតិនេះ មិនបានរួមបញ្ចូលមន្ទីរពេទ្យជាតិនានា ឬក៏មណ្ឌលថែទាំសុខភាពរបស់ឯកជន។ ប្រភព៖ ក្រសួងសុខាភិបាល*



ស្ត្រីមានផ្ទៃពោះកំពុងស្នាក់នៅឯបន្ទប់រង់ចាំមុនពេលសម្រាល-ខេត្តស្ទឹងត្រែង

រូបភាពទី២.២៥ បង្ហាញនូវគម្លាតខុសគ្នានៃភាគរយស្ត្រីសម្រាលកូនដោយបុគ្គលិកសុខាភិបាលទទួលការបណ្តុះបណ្តាលនៅតាមបណ្តារាជធានីខេត្ត ជាពិសេសរវាងរាជធានី ខេត្តដែលមានការអភិវឌ្ឍខ្ពស់ និងទាប។ ក្នុងន័យនេះ កិច្ចអន្តរាគមន៍ដោយផ្ទាល់ ទៅតាមបណ្តាខេត្តមានការអភិវឌ្ឍតិចតួច ដូចជាខេត្តស្ទឹងត្រែង កោះកុង រតនគិរី និងមណ្ឌលគិរី គឺអាចផ្តល់នូវលទ្ធផលដែលមានប្រសិទ្ធភាពខ្ពស់។

## ៥.២. អត្រាផ្តល់កំណើតសរុប

អត្រាល់កំណើតសរុប គឺជាចំនួនកុមារ ដែលនឹងចាប់កំណើតក្នុងមួយជីវិតរបស់ស្ត្រីម្នាក់ ឬម្តាយម្នាក់ ដែលផ្តល់កំណើត ឬការបន្តពូជក្នុងមួយជីវិតរបស់ពួកគាត់ ដោយគិតចាប់ពីអាយុដែលអាចបង្កកំណើតបាន បន្តរហូតដល់អាយុចុងក្រោយនៃការបង្កកំណើត។ ប្រសិនបើអត្រានេះខ្ពស់មានន័យថា ស្ត្រីមានការផ្តល់កំណើតឬចូលរួមក្នុងសកម្មភាពបន្តពូជច្រើនក្នុងមួយជីវិតរបស់ពួកគាត់ ដែលសកម្មភាពនេះ ធ្វើឱ្យប៉ះពាល់ទាំងការងារពេលកម្មក្នុងវិស័យសេដ្ឋកិច្ច ទាំងស្ថានភាពសុខភាព ព្រមទាំងឆាប់ទទួលមរណភាពនៅវ័យក្មេង។ ចំណុចដៅអត្រាផ្តល់កំណើតសរុបរបស់ គ.អ.ស.ក. សម្រាប់ឆ្នាំ២០១៥ គឺសរុប៣នាក់ក្នុងមួយជីវិតរបស់ស្ត្រីម្នាក់។

រូបភាពទី២.២៦ ៖ អត្រាផ្តល់កំណើតសរុប




*ប្រភព ៖ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០០០ ២០០៥ និង២០១០*

រូបភាពទី២.២៦ បង្ហាញពីការធ្លាក់ចុះនៃអត្រាផ្តល់កំណើតសរុបពីឆ្នាំ ២០០០ ដល់ឆ្នាំ២០១០។ អត្រាផ្តល់កំណើតសរុបនៅតាមតំបន់ទីប្រជុំជន បានធ្លាក់ចុះយឺតជាងអត្រាផ្តល់កំណើតសរុបនៅតាមតំបន់ជនបទនានា។ ជារួម ទោះបីជាចំណុចដៅអត្រាផ្តល់កំណើតសរុបរបស់ គ.អ.ស.ក. សម្រេចបានមុនកាលកំណត់ក៏ដោយ ក៏អត្រារវាងតំបន់ទីប្រជុំជន និងតំបន់ជនបទផ្សេងៗ មានគម្លាតគ្នាច្រើន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស។

អត្រាផ្តល់កំណើតសរុប ក៏ឃើញមានភាពខុសគ្នានៅតាមកម្រិតជីវភាពរស់នៅរបស់គ្រួសារនីមួយៗ។ ក្នុងន័យនេះ គ្រួសារដែលមានជីវភាពខ្សត់ខ្សោយមានអត្រាផ្តល់កំណើតសរុបខ្ពស់ជាងគ្រួសារដែលមានជីវភាពធូរធារ (រូបភាពទី២.២៧)។

រូបភាពទី២.២៧៖ អត្រាផ្តល់កំណើតសរុប តាមកម្រិតជីវភាព ឆ្នាំ២០១០




*ប្រភព ៖ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០*

ដោយយោងតាមវិធីសាស្ត្រប្រៀបធៀបទំនាក់ទំនងរវាងអត្រាផ្តល់កំណើតសរុប និងកម្រិតភាពក្រីក្រតាមបណ្តាខេត្តនីមួយៗ [គម្លាតអត្រាផ្តល់កំណើតសរុបមានច្រើន (-) ០,៧៦]។ មានន័យថា ខេត្តដែលមានអត្រាក្រីក្រខ្ពស់ ខេត្តនោះ ក៏មានអត្រាផ្តល់កំណើតសរុបខ្ពស់ផងដែរ (រូបភាពទី២.២៨)។

រូបភាពទី២.២៨ ៖ អត្រាផ្តល់កំណើតសរុបតាមបណ្តាខេត្ត ឆ្នាំ២០១០




*ប្រភព ៖ អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០*



ស្ត្រីកំពុងបំបៅដោះកូនរបស់គាត់នៅផ្ទះ-ខេត្តកណ្តាល

## ៥.៣. ការប្រើប្រាស់វិធីសាស្រ្តពន្យារកំណើតទំនើបនិងការពិគ្រោះយោបល់ពីការថែទាំមុនពេលសម្រាល

ក្នុងឆ្នាំ២០០០ ក្នុងចំណោមស្រ្តីដែលមានអាយុ១៥-៤៩ឆ្នាំដែលរៀបការរួច មាន១៩% បាន និងកំពុងប្រើប្រាស់វិធីសាស្រ្តពន្យារកំណើតទំនើប។ សមាមាត្រនេះបានកើនឡើងដល់២៧,២% ក្នុងឆ្នាំ២០០៥ និង៣៥% ក្នុងឆ្នាំ២០១០។ ដូច្នេះ កំណើនប្រហែលជា១,៥%ទៅ២% សម្រាប់មួយឆ្នាំនឹងនៅតែជាការងារប្រឈមសម្រាប់កម្ពុជាដើម្បីសម្រេចបាននូវ គ.អ.ស.ក. ប្រមាណ៦០% ក្នុងឆ្នាំ២០១៥។

## ៥.៤. ការសម្រាលដោយវះកាត់

សមាមាត្រស្រ្តីមានផ្ទៃពោះទៅទទួលការពិគ្រោះផ្ទៃពោះពីរលើក ឬច្រើនជាង ពីបុគ្គលិកសុខាភិបាលទទួលការបណ្តុះបណ្តាលបានកើនឡើងពី៨៣% ដល់៨៧% សម្រាប់ឆ្នាំ២០០៩ និងឆ្នាំ២០១២។ កំណើននេះ គឺជាសញ្ញាមួយល្អសម្រាប់ការសម្រេចបាននូវចំណុចដៅរបស់ គ.អ.ស.ក. ៩០នៅឆ្នាំ២០១៥។

សមាមាត្រស្រ្តីមានផ្ទៃពោះ ទទួលបានការពិនិត្យផ្ទៃពោះពីរដង ឬច្រើនជាងនេះ ដោយបុគ្គលិកសុខាភិបាលជំនាញ បានកើនឡើងពី ៨៣ភាគរយ ដល់ ៨៧ភាគរយ សម្រាប់ឆ្នាំ២០០៩ និងឆ្នាំ២០១២។ កំណើននេះ គឺជាសញ្ញាមួយល្អ ប៉ុន្តែទាមទារនូវការពន្លឿន សម្រាប់ការសម្រេចបាននូវចំណុចដៅរបស់ គ.អ.ស.ក. នៅឆ្នាំ២០១៥ គឺ ៩០។

ការកើនឡើងក្នុងការសម្រាលកូនដោយធ្វើការវះកាត់ បង្ហាញពីភាពស្មុគស្មាញនានា និងហានិភ័យ ខ្ពស់ចំពោះសុខភាពម្តាយ និងទារក ដែលចាំបាច់ទាមទារនូវសំភារៈ និងបរិក្ខារគ្រប់គ្រាន់សម្រាប់ធ្វើការវះកាត់។ សមាមាត្រនៃការសម្រាលកូនដោយធ្វើការវះកាត់ បានកើនឡើងពី០.៧៧ភាគរយ នៅឆ្នាំ២០០៨ ទៅ២.៨៣ភាគរយ នៅឆ្នាំ២០១២ ធៀបនឹងចំណុចដៅដែលមាន ៤ភាគរយ នៅឆ្នាំ២០១៥។ នៅពេលដែលការមានផ្ទៃពោះ និងការសម្រាលកូន គឺជាដំណើរការធម្មជាតិ នោះការបកស្រាយនានា ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន ជាពិសេសក្នុងករណីដែលអត្រាសម្រាលកូន លើសពី ៥ភាគរយ ពីព្រោះថា វិធីវះកាត់ ត្រូវបានអនុវត្តក្នុងករណី ដែលមាតាពិបាកក្នុងការសម្រាល ដោយធម្មតាឬធម្មជាតិ។



អ្នកស្រី កែវ មិកឌីណា ពេទ្យឆ្មបនៃមន្ទីរពេទ្យបង្អែកខេត្តស្ទឹងត្រែងកំពុងពិនិត្យសុខភាពស្រ្តីមានផ្ទៃពោះមុនពេលសម្រាល

### ប្រអប់ទី ២.១០៖ សំភារៈនិងបរិក្ខារនិងការប្រើប្រាស់សេវាថែទាំសុខភាព

ចាប់ពីឆ្នាំ២០០៧មក ប្រជាជនរស់នៅនៅតាមភូមិជាច្រើន កត់សម្គាល់ថា សេវាថែទាំសុខភាពមានភាពប្រសើរឡើង។ មជ្ឈមណ្ឌលសុខភាពជាច្រើន ត្រូវបានកសាងឡើង ដោយមានបុគ្គលិកជំនាញប្រមាណជា ៨-១០ នាក់ (ក្រៅម៉ោង និងពេញម៉ោង) ក្នុងមជ្ឈមណ្ឌលសុខភាពនីមួយៗ។ បុគ្គលិកទាំងអស់នោះ បានជួយថែទាំសុខភាពមាតាដែលទើបតែផ្តល់កំណើត និងកូនតូចៗ បានយ៉ាងល្អ ដោយពួកគាត់ធ្វើការរហូតដល់ម៉ោងឈប់សម្រាក។ ភាពប្រសើរឡើង ក៏រួមបញ្ចូលនូវចំណេះដឹង និងលទ្ធភាពស្វែងរកសេវាថែទាំសុខភាព។ ដូច្នេះ បណ្តាស្រ្តីមានផ្ទៃពោះ មានទំនុកចិត្តច្រើនពីសុវត្ថិភាព ពីព្រោះថាពួកគាត់អាចដឹងពីកន្លែងណា ដែលពួកគាត់អាចស្វែងរកជំនួញទាន់ពេលនៅពេលដែលមានបញ្ហា។ ក្នុងន័យនេះដែរ ភូមិនីមួយៗមាន ក្រុមគាំទ្រសេវាសុខភាពភូមិ ចំនួន ២នាក់ អាចជាស្រ្តី ឬបុរសដោយត្រូវបានបោះឆ្នោតជាសមាជិក។ ពួកគាត់មានភារកិច្ចសំខាន់សម្រាប់ផ្តល់ការប្រឹក្សាអំពីវិធីសាស្រ្តពន្យាកំណើតទំនើប គុណសម្បត្តិនៃការធ្វើតេស្តជាទៀងទាត់ មុនមានផ្ទៃពោះ ក៏ដូចជាអត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្តាយ ការបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យរួមទាំងការការពារជីវិតកុមារតូច ដោយការទទួលបានថ្នាំវ៉ាក់សាំងឱ្យបានគ្រប់មុខ។

ស្ទើរតែស្រ្តីពេញវ័យបន្តពូជទាំងអស់ យល់ពីសេវាកម្មសុខភាពបន្តពូជ ដែលផ្តល់ដោយមជ្ឈមណ្ឌលសុខភាព។ សេវាកម្មដោយឥតគិតថ្លៃទាំងនោះ រួមមាន៖ ការធ្វើតេស្តមុនមានផ្ទៃពោះ គ្រាប់ថ្នាំជីវជាតិ ដែក និងហ្វូលិកអាស៊ីដ ចំនួន ៩០គ្រាប់ និងអត្ថប្រយោជន៍នៃការផ្តល់កំណើតកូនដោយបុគ្គលិកពេទ្យ មានជំនាញ។ សម្រាប់រយៈពេល ២ឬ៣ ឆ្នាំកន្លងមកនេះ ស្រ្តីមួយចំនួនដែលផ្តល់កំណើតដោយឆ្មបប្រើប្រាស់វិធីសាស្រ្តបុរាណ ត្រូវបានបញ្ជូនទៅ មន្ទីរពេទ្យបង្អែកថ្នាក់ខេត្ត ក្នុងករណីសង្គ្រោះបន្ទាន់។ ដូច្នេះ ករណីនេះ គឺជាមេរៀនសម្រាប់ស្រ្តីមានផ្ទៃពោះដទៃ ដើម្បីប្រឹក្សាជាមួយបុគ្គលិកពេទ្យជំនាញ។ សេវាកម្ម ដែលផ្តល់ដោយមណ្ឌលសុខភាព ដូចជាអត្តចរិកបុគ្គលិក ពេទ្យ និងតម្លាភាពនៃតម្លៃ មានភាពប្រសើរឡើងជាងបណ្តាឆ្នាំមុនៗ។ រាល់តម្លៃនៃការចំណាយនានា ត្រូវបានផ្សាយដាក់នៅជញ្ជាំង។ ឧទាហរណ៍៖ ប្រជាជនក្រីក្រជាពិសេសស្រ្តី ដែលទទួលបានការគាំពារពីមូលនិធិសមធម៌ មិនត្រូវបានយកថ្លៃសេវាឬក៏ត្រូវបានបង់ថ្លៃជួស ដោយរាជរដ្ឋាភិបាល និងដោយអង្គការមិនមែនរដ្ឋាភិបាល។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះមានអត្ថប្រយោជន៍ជាខ្លាំង សម្រាប់ប្រជាជនក្រីក្រ។

លើមូលដ្ឋាននេះ សុខភាពបន្តពូជ បច្ចេកវិទ្យាទំនើប ត្រូវបានប្រើប្រាស់ក្នុងករណីកំពុងផ្តល់កំណើត។ ក្រៅពីនេះ ស្រ្តីក្រោយពីឆ្លងទន្លេរួច អាចវិលទៅរកវិធីសាស្រ្តបែបបុរាណ ដូចជា ការពិសាស្រាមានជាតិថ្នាំបុរាណ ផ្អើភ្លើង ការប្រើប្រាស់វត្ថុស័ក្តសិទ្ធិចងភ្ជាប់ជុំវិញគ្រែដំណេករបស់ម្តាយ សម្រាប់ការពារពីព្រាយបីសាច និងការមិនអនុញ្ញាតឱ្យស្នាក់នៅតែម្នាក់ឯង ជាដើម។ វិធីសាស្រ្តមួយចំនួនដូចជា ការពិសាស្រា និងផ្អើភ្លើង មិនត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ដោយវិជ្ជបណ្ឌិត។ ប៉ុន្តែ ស្រ្តីជាម្តាយទាំងនោះ នៅតែអនុវត្តតាមតំបូន្មានរបស់មនុស្សចាស់ៗ ដោយខ្លាចថា នឹងទទួលការស្តីបន្ទោសនៅពេលដែលអ្វីមិនល្អកើតឡើង។

ប្រមាណជា ៩០ភាគរយ នៃកុមារតូចដែលមានអាយុពី ១២-២៤ ខែ បានទទួលបានវ៉ាក់សាំងគ្រប់ប្រភេទ តាមរយៈការទទួលបាននូវសៀវភៅវ៉ាក់សាំងកុមារ។ បុគ្គលិកមណ្ឌលសុខភាព ផ្តល់វ៉ាក់សាំងដល់កុមារនៅតាមភូមិ និងក្រុមគាំទ្រសេវាសុខភាពភូមិ ក៏បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការនាំកុមារមកទទួលបានវ៉ាក់សាំង។

រីឯកុមារតូចចំនួន ១០ភាគរយ ទៀតដែលមិនបានទទួលវ៉ាក់សាំងគ្រប់ប្រភេទ គឺស្ថិតនៅក្នុងគ្រួសារក្រីក្រ។ ក្រុមគ្រួសារក្រីក្រទាំងនេះក៏មានចំនួនជនចាស់ជរាភាគច្រើនរស់នៅក្នុងបន្ទុក។ ក្រុមស្ត្រីវ័យចំណាស់ អាយុពី ៦០-៧០ ឆ្នាំ ភាគច្រើន មិនជឿជាក់នូវតំបូន្មានវិជ្ជបណ្ឌិត ហើយក៏មិនយល់ពីអត្ថប្រយោជន៍នៃការទទួលបានវ៉ាក់សាំងផងដែរ។ ក្នុងន័យនេះ ទោះបីជាបុគ្គលិកមណ្ឌលសុខភាពបានមកដល់ផ្ទះរបស់ពួកគាត់ក៏ដោយ ក៏ពួកគាត់បដិសេធក្នុងការឱ្យកូនចៅរបស់ពួកគាត់ទទួលបានវ៉ាក់សាំង។

*ប្រភព៖ កិច្ចសម្ភាសន៍នៅតាមភូមិក្នុងខេត្តក្រចេះ កំពង់ធំ និងបាត់ដំបង។*

## លទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

**លទ្ធផលដែលសម្រេចបាន៖** កម្ពុជាបានសម្រេចបានមុនកាលកំណត់នូវចំណុចដៅនានានៃ គ.អ.ស.ក. ស្តីពីអត្រាមរណភាពមាតា និងអត្រាផ្តល់កំណើតសរុប។ វឌ្ឍនភាពសំខាន់ៗ ក៏ត្រូវបានធ្វើឱ្យកើតមាននៅក្នុងការសម្រាលកូនដោយបុគ្គលិកសុខាភិបាលជំនាញនិងការពិគ្រោះមុន និងក្រោយសម្រាល។ សរុបមកប្រទេសកម្ពុជាកំពុងឆ្ពោះទៅរកការសម្រេចបានគោលដៅនៃគ.អ.ស.ក. នៅឆ្នាំ២០១៥។

**ភាពប្រឈម៖** ការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើត នឹងមិនសម្រេចបានតាមកាលកំណត់អាស្រ័យលើផ្នត់គំនិតរបស់ប្រជាជនមានការកែប្រែយឺត។

**គោលនយោបាយរាជរដ្ឋាភិបាល៖** ដូចបានបង្ហាញពីខាងលើ យុទ្ធសាស្ត្រចតុកោណបានដាក់ចេញនូវកម្មវិធីចំនួន១០ សម្រាប់វិស័យសុខាភិបាល ពាក់ព័ន្ធនឹងការគាំពារថែទាំសុខភាពមាតា តាមរយៈការពង្រឹងគុណភាព និងប្រសិទ្ធភាពបន្តពូជការសម្រាលកូនសេវាគាំពារទារក និងកុមារដោយផ្តោតលើការពង្រីកវិសាលភាពគ្របដណ្តប់នៃការសម្រាលកូនដោយឆ្មប និងគ្រូពេទ្យជំនាញការពង្រីកសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងសេវាថែទាំទារកការពង្រីកសេវាផ្តល់មធ្យោបាយពន្យារកំណើត។

## 6 គោលដៅទី៦ ការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត

ជំងឺចម្បងចំនួនបី ដែលរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចដាក់បញ្ចូលក្នុង គ.អ.ស.ក. មាន៖

១. កាត់បន្ថយប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ មកនៅត្រឹម ០,៤% ក្នុងចំណោមប្រជាជនសរុប។

២. កាត់បន្ថយប្រេវ៉ាឡង់ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម មកនៅ ០,៨%។

៣. កាត់បន្ថយប្រេវ៉ាឡង់ជំងឺរបេងមកនៅ ៦៥៣ ក្នុងចំណោមប្រជាជន ១០០០០០នាក់។

### ៦.១ មេរោគអេដស៍ជំងឺអេដស៍

ក្នុងឆ្នាំ១៩៩៨ សមាមាត្រប្រជាជនដែលបានផ្ទុកមេរោគអេដស៍ មានប្រមាណជា ២% នៃប្រជាជនសរុប។ ដោយផ្អែកលើលទ្ធផលនេះ របាយការណ៍អភិវឌ្ឍមនុស្សឆ្នាំ២០០២ របស់កម្ពុជាបានបង្ហាញពីការរីករាលដាលរបស់មេរោគអេដស៍/ជំងឺអេដស៍។



ស្ត្រីកំពុងទទួលប្រឹក្សាអំពីអាហាររូបបមក្នុងពេលពិនិត្យសុខភាព-ខេត្តក្រចេះ

**តារាងទី២.៥ ៖ ស្ថិតិស្តីពីវឌ្ឍនភាពនិងចំណុចដៅនៃមេរោគអេដស៍ជំងឺអេដស៍ គ្រុនចាញ់ និងរបេង**

| | | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៥ ចំណុចដៅ |
|---|---|---|---|---|---|---|---|
| ប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ | ភាគរយ យុវវ័យ ១៥-៤៩ ឆ្នាំ | ០,៧ | ២០០៩ | ០,៧ | - | - | ០,៤ |
| អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ | ប្រជាជន ១០០,០០០ នាក់ | ១,៥ | ០,៧ | ០,៩៨ | ០,៦៥ | ០,២៩ | ០,៨ |
| ប្រេវ៉ាឡង់ជំងឺរបេងគ្រប់ប្រភេទ | ប្រ/ជន ១០០,០០០ នាក់ | ១២៣០ (២០០៥) | ២ | | | ៧៦៤ | ៦៥៣ |

*ចំណាំ ៖ បន្ទាត់ដួរដេកក្រោមគេបង្អស់ មិនទាន់ត្រូវបានប្រើប្រាស់ជាផ្លូវការ ដោយសារតែការមិនយល់ស្របច្បាស់លាស់អំពី ភាគបែង ។*

*ប្រភព ៖ ក្រសួងសុខាភិបាល*

ស្ថានភាពប្រេវ៉ាឡង់ទាំងឡាយនាពេលបច្ចុប្បន្ននេះ ស្ថិតក្នុងបរិបទមួយដែលអាចគ្រប់គ្រងបាន។ ប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ បានធ្លាក់ចុះយ៉ាងច្រើនក្នុងទសវត្សរ៍ចុងក្រោយនេះ មកនៅត្រឹម០,៧%ក្នុងចំណោមយុវវ័យអាយុ១៥-៤៩ឆ្នាំ (តារាងទី២.៥)។ នាពេលបច្ចុប្បន្នស្រុកប្រតិបត្តិចំនួន៥១ នៅក្នុង២១ខេត្ត ផ្តល់ការព្យាបាលសម្រាប់ជំងឺឆ្លងនេះ និងផ្តល់សេវាលកម្មប្រឆាំងនឹងការចម្លង។ ក្នុងនោះ ៣២កន្លែងផ្តល់ការថែទាំព្យាបាលដល់កុមារ។ ទន្ទឹមនេះ៩០% នៃអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍នៅឆ្នាំ២០១២បាន និងកំពុងទទួលបានការព្យាបាល ដោយបន្តការរស់រានមានជីវិតយ៉ាងហោចណាស់បាន១២ខែ បន្ទាប់ពីការព្យាបាល ធៀបនឹង៨៦% ក្នុងឆ្នាំ២០០៩។ ទិន្នន័យរបស់ក្រសួងសុខាភិបាលបានបង្ហាញថាចំនួនកន្លែងផ្តល់ការប្រឹក្សា និងធ្វើតេស្តឈាមដោយសម្ងាត់ និងស្ម័គ្រចិត្តក្នុងមន្ទីរពេទ្យបង្អែកនិងក្នុងមណ្ឌលសុខភាព បានកើនឡើងពី២១២ ក្នុងឆ្នាំ២០០៨ ដល់២៣៣ ក្នុងឆ្នាំ២០០៩ និង កើនដល់ ២៣៩ ក្នុងឆ្នាំ២០១០។

ដោយយោងតាមលទ្ធផលសិក្សាកន្លងមក រាជរដ្ឋាភិបាលជឿជាក់ថាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍នឹងកើនឡើង ៤ដង ប្រសិនបើមិនមានសកម្មភាពសម្រាប់ទប់ស្កាត់ការរីករាលដាលនៃមេរោគនេះ។ ក្រុមជនដែលងាយឆ្លងមេរោគនេះ គឺអ្នកដែលធ្វើការងារតាមកន្លែងកំសាន្តផ្សេងៗ ឬស្វែងរកការកំសាន្តអ្នកដែលអនុវត្តMSMឬអ្នកប្រើប្រាស់ចាក់ថ្នាំញៀន។ ដើម្បីទប់ស្កាត់នូវបញ្ហានេះ ផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍លើកទី៣ (ផ.យ.ជ.) ២០១១-២០១៥ បាន និងកំពុងអនុវត្តនូវយុទ្ធសាស្ត្រមួយចំនួនដូចតទៅ (១) ពង្រីកបន្ថែមកន្លែងផ្តល់ការប្រឹក្សា និងធ្វើតេស្តឈាម ដោយសម្ងាត់ និងស្ម័គ្រចិត្តឱ្យបានទូលំទូលាយ (២) ផ្តល់សេវាកម្មសម្រាប់ការគាំពារឱ្យមានប្រសិទ្ធភាព (៣) លើកកម្ពស់ការថែទាំនិងព្យាបាល (៤) កាត់បន្ថយផលប៉ះពាល់ពីជំងឺ (៥) បង្កើតបរិស្ថានអនុគ្រោះមួយ (៦) ផ.យ.ជ. លើកទី៣ រំពឹងថានឹងទប់ស្កាត់ការរាលដាលនៃមេរោគអេដស៍ ក្នុងចំណោមអ្នកដែលធ្វើការងារតាមកន្លែងកំសាន្តផ្សេងៗ ឬស្វែងរកការកំសាន្តអ្នកដែលអនុវត្តMSM ឬអ្នកប្រើប្រាស់ចាក់ថ្នាំញៀន។

ការសម្រេចបាននូវចំណុចដៅប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍របស់ គ.អ.ស.ក. អាស្រ័យលើទំហំនៃភាពជោគជ័យរបស់កម្មវិធីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ទាំងឡាយ។ កិច្ចខិតខំប្រឹងប្រែងជាច្រើនទៀតចាំបាច់ត្រូវតែបន្ត សំដៅការពារ និងទប់ស្កាត់ ពីព្រោះថាកំណើនវិស័យទេសចរណ៍ នឹងនៅតែមានតួនាទីសំខាន់សម្រាប់ពង្រឹងសេដ្ឋកិច្ចជាតិឱ្យរំកិលទៅមុខ។ ទន្ទឹមនឹងនេះ ការហូរចេញចូលនូវពលករក្នុងស្រុក និងក្រៅស្រុក នៅពេលដែលព្រះរាជាណាចក្រកម្ពុជា នឹងធ្វើសមាហរណកម្មក្នុងសហមគមន៍សេដ្ឋកិច្ចអាស៊ាននឹងក្លាយជាក្តីបារម្ភក្នុងការពារ និងទប់ស្កាត់ជំងឺអេដស៍។

## ៦.២ ជំងឺគ្រុនចាញ់គ្រុនឈាមនិងជំងឺផ្សេងៗ

ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម ដែលបង្កដោយមូស ស្ថិតនៅក្រោមការទប់ស្កាត់បានល្អធៀបនឹងឆ្នាំមុនៗ។ ដើម្បីបន្តការទប់ស្កាត់ជំងឺគ្រុនចាញ់ និងជំងឺដែលចម្លងដោយមូស រាជរដ្ឋាភិបាលបានចែកចាយមុងជ្រលក់ថ្នាំចំនួន ជាង ៣.៧០០.០០០ ក្នុងចន្លោះឆ្នាំ២០១១-២០១២។



គ្រួសារកំពុងចងមុងនាពេលរាត្រី-ខេត្តកណ្តាល

ប្រជាជនដែលរស់នៅក្បែរជម្រកព្រៃឈើ ងាយនឹងឆ្លងជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាមជាងគេ។ ប្រសិនណាបើប្រជាជនក្នុងភូមិទាំងអស់នេះ ប្តូរទៅរស់នៅតំបន់ទំនាប/ស្រឡះ នោះការផ្លាស់ប្តូរនេះ នឹងបម្រើនូវគោលបំណង៣យ៉ាង គឺការកាត់បន្ថយប្រេវ៉ាឡង់ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម ការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់ និងការអភិរក្សព្រៃឈើ។ ចំណុចទាំងអស់នេះនៅមិនទាន់ត្រូវបានរៀបចំជាគោលនយោបាយនៅឡើយ។

ជំងឺរបេង គឺជាជំងឺមួយដែលពាក់ព័ន្ធជាមួយភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភហើយប្រេវ៉ាឡង់នៃជំងឺនេះ មិនឃើញមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ឡើយ។ ចំណុចដៅលើកតំបូងសម្រាប់ប្រេវ៉ាឡង់ជំងឺរបេង គឺ ៤៦៤នាក់ ក្នុងចំណោមប្រជាជន១០០.០០០នាក់ សម្រាប់ឆ្នាំ២០១៥។ ចំណុចដៅនេះនឹងត្រូវបានកែសម្រួល។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានពង្រឹងការប្រើប្រាស់ DOTS សម្រាប់ព្យាបាលជំងឺរបេងតាមសហគមន៍។ មណ្ឌលសុខភាពផ្តល់នូវសេវាកម្ម DOTS បានកើនឡើងជារៀងរាល់ឆ្នាំ ចាប់ពី៥០៦ សម្រាប់ឆ្នាំ២០០៨ មក៧៤៤ (ឆ្នាំ២០០៩) ៨៣៩ សម្រាប់ឆ្នាំបន្ទាប់។ កម្មវិធីភាពជាដៃគូរវាងរដ្ឋាភិបាល និងឯកជនបានផ្តល់ការព្យាបាលជំងឺរបេង នៅតាមស្រុកចំនួន៣៩ សម្រាប់ ១១ខេត្ត។ ចំណុចដៅរបស់ គ.អ.ស.ក. អាចសម្រេចបានតាមគោលដៅពីព្រោះកម្រិតជីវភាពរស់នៅនិងស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង។

មណ្ឌលសុខភាពថ្មីចំនួន១២ ត្រូវបានសាងសង់តាមព្រំដែនខេត្តព្រះវិហារ បន្ទាយមានជ័យ និងឧត្តរមានជ័យ។ ចំនួនប្រជាជនក្រីក្រទទួលបានការគាំពារដោយមូលនិធិសមធម៌ និងទទួលបានការឧបត្ថម្ភធនសម្រាប់សេវាថែទាំសុខភាពបានកើនឡើងពី៧៣% ក្នុងឆ្នាំ២០០៩ ដល់ ៧៧% ក្នុងឆ្នាំ ២០១០។ ទន្ទឹមនេះ ការអនុវត្តច្បាប់ប្រឆាំងនឹងឱសថស្ថានលក់ថ្នាំមិនស្របច្បាប់ត្រូវបានពង្រឹង។ ក្នុងន័យនេះ ឱសថស្ថានលក់ថ្នាំមិនស្របច្បាប់ ត្រូវបានកាត់បន្ថយពី៣៨,៥% ក្នុងឆ្នាំ២០០៩ មកត្រឹម ៥,៤%។ ដូចគ្នានេះដែរ កន្លែងផ្តល់សេវាសុខភាពឯកជនខុសច្បាប់បានធ្លាក់ចុះពី ២៨% មកត្រឹម ៧% សម្រាប់រយៈពេលដូចគ្នា។



វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកាកំពុងពិនិត្យសុខភាពស្ត្រីបន្ទាប់ពីសម្រាលកូន នៅមន្ទីរពេទ្យបង្អែក-ខេត្តក្រចេះ

### លទ្ធផលដែលបានសម្រេចបាន បញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

**លទ្ធផលដែលសម្រេចបាន៖** ប្រទេសកម្ពុជា សម្រេចបានចំណុចដៅមួយចំនួន ដូចជា ជំងឺគ្រុនចាញ់ របេង និងមេរោគអេដស៍/ជំងឺអេដស៍ តាមគោលដៅកំណត់។

**ភាពប្រឈម ៖** ទោះបីជាមិនមានភាពប្រឈមក៏ពិតមែនរាជរដ្ឋាភិបាលចាំបាច់ត្រូវការប្រព័ន្ធតាមដានប្រកបដោយប្រសិទ្ធផល និងធនធានគ្រប់គ្រាន់ ដើម្បីរក្សានូវវឌ្ឍនភាពកន្លងមក។

**គោលនយោបាយរបស់រាជរដ្ឋាភិបាល៖** ដូចបានបង្ហាញពីខាងលើ យុទ្ធសាស្ត្រចតុកោណបានដាក់ចេញនូវកម្មវិធីចំនួន១០ សម្រាប់វិស័យសុខាភិបាលពាក់ព័ន្ធនឹងការគាំពារថែទាំសុខភាព ដោយផ្តោតការយកចិត្តទុកដាក់លើការកាត់បន្ថយបន្ថែមទៀតនូវជំងឺ និងអត្រាមរណៈភាពដែលមកពីជំងឺឆ្លងដូចជាមេរោគអេដស៍/ជំងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម និងបណ្តាជំងឺផ្សេងទៀតដែលកើតមានតាមរយៈភ្នាក់ងារចម្លង និងកិច្ចខិតខំប្រឹងប្រែងផ្សេងទៀត ដើម្បីលុបបំបាត់ជំងឺគ្រុនចាញ់ឱ្យអស់ត្រឹមឆ្នាំ ២០២៥។

## គោលដៅទី៧ ការធានានិរន្តរភាពបរិស្ថាន

ចំណុចដៅចម្បងចំនួន៤ ដែលរាជរដ្ឋាភិបាលកម្ពុជា បានកំណត់ដាក់ក្នុង គ.អ.ស.ក. រួមមាន៖

១. ស្តារធនធានបរិស្ថានដែលបានបាត់បង់។

២. បង្កើនសមាមាត្រប្រជាជនមានលទ្ធភាពប្រើប្រាស់ទឹកស្អាតឱ្យបានពាក់កណ្តាល នៅឆ្នាំ២០១៥។

៣. កាត់បន្ថយការប្រើប្រាស់អុស សម្រាប់ចម្អិនអាហារ មកត្រឹម ៥២% នៃគ្រួសារសរុប។

៤. បង្កើនសមាមាត្រប្រជាជន ទទួលបានសុវត្ថិភាពដីធ្លី។

### ៧.១ គម្របព្រៃឈើ

ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ព្រះរាជាណាចក្រកម្ពុជា មានគម្របព្រៃឈើប្រមាណជា ៧០% នៃផ្ទៃដីសរុប។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០មក ព្រៃឈើ គឺជាធនធានមួយក្នុងចំណោមធនធានធម្មជាតិដទៃទៀត ត្រូវបានប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម និងកសិកម្ម ដែលធ្វើឱ្យការកាប់បំផ្លាញព្រៃឈើ ដោយខុសច្បាប់មានការកើនឡើង។ ក្រៅពីប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ការកាប់បំផ្លាញព្រៃក៏ធ្វើឱ្យប៉ះពាល់ដល់ទឹកក្រោមដី និងមច្ឆាជាតិផងដែរ ហើយបញ្ហានេះក៏ត្រូវបាននិងកំពុងព្យាយាមដោះស្រាយដោយរាជរដ្ឋាភិបាល។

រូបភាពទី២.២៩ ៖ គម្របព្រៃឈើនាពេលបច្ចុប្បន្ន និងចំណុចដៅពេលអនាគត




*ប្រភព៖ របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០១១ នៃការអនុវត្តផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩ -២០១៣*

រវាងឆ្នាំ១៩៩០ និងឆ្នាំ២០១០ រាជរដ្ឋាភិបាលបានប៉ាន់ស្មានថា កម្ពុជាបានបាត់គម្របព្រៃឈើប្រហែល២២% ឬក៏ប្រមាណជាង២៨៥០០០០ហិកតា។ ការវាយតម្លៃពីគម្របព្រៃឈើជាតិមួយ ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០៦ បានរកឃើញថា គម្របព្រៃឈើបានថយចុះពី៦១,២% ក្នុងឆ្នាំ២០០២ មក ៥៩,១%ក្នុងឆ្នាំ២០០៦ ឬ ៣៧៣៥១០ហិកតា ដែលបណ្ដាលមកពីការពង្រីកផ្ទៃដីកសិកម្ម និងការដាំដុះបែបពាណិជ្ជកម្មផ្សេងៗ។ រដ្ឋបាលព្រៃឈើ បានប៉ាន់ស្មានថា គម្របព្រៃឈើ ក្នុងឆ្នាំ២០១០ មានប្រមាណ ៥៧,៥៩% (រូបភាពទី២.២៩)។

ព្រៃឈើមាននៅក្នុងខេត្តភាគពាយព្យ និងភាគឦសាន ដែលការកាប់ដោយខុសច្បាប់នេះ កើតមាននៅក្នុងតំបន់អភិរក្ស ហើយទោះបីជាចំនួននេះស្ថិតក្នុងទ្រង់ទ្រាយតូចក៏ដោយក៏ប៉ុន្តែការកាប់បំផ្លាញព្រៃឈើក្នុងតំបន់ទាំងនេះបានកើតឡើងអស់រយៈពេលយូរឆ្នាំមកហើយ។

បញ្ហាបរិស្ថាន គឺជាវិស័យអាទិភាពខ្ពស់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី បានបញ្ជាក់ច្បាស់លាស់ថា ការអភិវឌ្ឍដោយមានចីរភាពបរិស្ថាន គឺគោលដៅសំខាន់មួយរបស់ប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀតក្នុងតំបន់។ អាជ្ញាធរកម្ពុជាបានដោះស្រាយបញ្ហាទាំងឡាយដើម្បីរក្សាគម្របព្រៃឈើឱ្យបាន ៦០% នៃផ្ទៃដីសរុប។ នេះក៏ជាគោលដៅមួយក្នុងចំណោមគោលដៅទាំង៩ របស់គ.អ.ស.ក. ឆ្នាំ២០១៥។ ដើម្បីសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាលបានរៀបចំផែនការនានា ដើម្បីពង្រឹងការអភិរក្ស និងការគ្រប់គ្រងព្រៃឈើ កាត់បន្ថយសំពាធលើព្រៃឈើដោយពង្រឹងបច្ចេកទេសកសិកម្ម កាត់បន្ថយការប្រើប្រាស់អុសសម្រាប់ចំអិនអាហារ និងចូលរួមក្នុងកម្មវិធីស្ដារ និងដាំព្រៃឈើឡើងវិញរួមទាំងការដាំព្រៃឈើសម្រាប់ធ្វើពាណិជ្ជកម្មផងដែរ។

## ៧.២ តំបន់អភិរក្សព្រៃឈើ

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់តំបន់អភិរក្ស និងតំបន់ព្រៃសហគមន៍ ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រអភិរក្សបរិស្ថាន។ ប្រព័ន្ធអភិរក្សបច្ចុប្បន្នរួមមានតំបន់អភិរក្សចំនួន២៣តំបន់ ស្មើនឹង ៣,១លានហិកតា (តារាងទី២.៦) ឬ ២៧% នៃផ្ទៃដីសរុប (ជាចំនួនខ្ពស់បំផុតមួយក្នុងពិភពលោក) ដូចមានក្នុងតារាងទី ២.៦។ តំបន់ដែលស្ថិតនៅក្រោមតំបន់អភិរក្សទាំង ២៣ នឹងត្រូវរក្សាឱ្យថេរក្នុងពេលអនាគត ហើយតំបន់អភិរក្សសហគមន៍នឹងមានការកើនឡើងបន្ថែមទៀត។ ជាមួយនឹងការអភិវឌ្ឍប្រកបដោយវិជ្ជមាន រាជរដ្ឋាភិបាលមានសុទិដ្ឋិនិយមថា គោលដៅឆ្នាំ២០១៥ នឹងសម្រេចបានតាមកាលកំណត់។



អ្នកការពារព្រៃឈើកំពុងដកផ្សិតសម្រាប់ធ្វើម្ហូបក្នុងព្រៃសហគមន៍ព្រះសង្ឃ-ខេត្តឧត្តរមានជ័យ

### តារាងទី២.៦ ៖ សូចនាករចីរភាពបរិស្ថាន

| | | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៥ ប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|---|
| ផ្ទៃដីតំបន់អភិរក្សទាំង២៣ | ហ.ត. | ៣១០០១៩៩ | ៣១០០១៩៩ | ៣១១១០៤១ | ៣១១១០៤១ | ៣១១១០៤១ | ៣១១១០៤១ | ៣១១១០៤១ |
| តំបន់អភិរក្សសហគមន៍ | ចំនួន | ៨២ | ៨៤ | ៩៨ | ១១០ | ១១៥ | ១២០ | ១៤០ |

*ប្រភព៖ ក្រសួងបរិស្ថាន*

## ៧.៣ កិច្ចខិតខំប្រឹងប្រែងក្នុងដាំកូនឈើឡើងវិញ

ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរួមគ្នាលើកកម្ពស់ការដាំកូនឈើក្នុងប្រទេស។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានអនុម័តច្បាប់សម្រាប់តំបន់អភិរក្ស ដែលចាត់ថ្នាក់ព្រៃឈើជា៤តំបន់ គឺតំបន់ស្នូល តំបន់អភិរក្សការប្រើប្រាស់ដោយចីរភាព និងសហគមន៍ផ្សេងៗ។ ក្រសួងបរិស្ថានកំពុងរៀបចំគូសផែនទី និងកំណត់ព្រំប្រទល់តំបន់ទាំង៤។

### រូបភាពទី២.៣០ ៖ កិច្ចខិតខំប្រឹងប្រែងក្នុងការដាំកូនឈើឡើងវិញ




*ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យមានការកែប្រែតំបន់កាប់ព្រៃឈើរួចនៅតាមបណ្តាដីសម្បទានសេដ្ឋកិច្ច ក្រោមរូបភាពការអភិវឌ្ឍប្រកបដោយចីរភាព ( ដាំកូនឈើឡើងវិញ ) សំដៅបម្រើជាខ្សែក្រវ៉ាត់បៃតងសម្រាប់ការពារតំបន់អភិរក្សនិងតំបន់ស្នូល និងជំរុញលើកទឹកចិត្តការអភិវឌ្ឍសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់។

ទោះជាដូចនេះក្តី បញ្ហាប្រឈមនោះគឺការកំណត់និយមន័យព្រៃឈើ និងការពង្រឹងច្បាប់ឱ្យបានច្បាស់លាស់។ជារួមការងារត្រូវធ្វើបន្តទៀតនោះគឺកំណត់និយមន័យព្រៃឈើ កំណត់តំបន់ព្រំប្រទល់ឱ្យបានច្បាស់លាស់សម្រាប់ពង្រឹងនូវតំបន់ការពារ និងគ្រប់គ្រងតំបន់ទាំងអស់នោះ។

សម្រាប់អត្ថន័យនៃការគ្រប់គ្រង កង្វះខាតធនធាន ដូចជាធនធានមនុស្សនិងហិរញ្ញវត្ថុ នៅតែជាបញ្ហាប្រឈម។ ឧទាហរណ៍ ទោះបីជាចំនួនមន្ត្រីអភិរក្សតំបន់ការពារនៅក្នុងឆ្នាំ២០១២ មានចំនួន ៩៦០នាក់ក៏ដោយក៏ចំនួននេះត្រូវបានកាត់បន្ថយពី៩១០នាក់ក្នុងឆ្នាំ២០០៩ មក៤៨០នាក់ក្នុងឆ្នាំ២០១០ ដោយសារតែកង្វះខាតហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ ចំនួនមន្ត្រីអភិរក្សការពារព្រៃឈើក៏បានថយចុះពី៥០០នាក់ មកនៅត្រឹម៣១៥នាក់ក្នុងឆ្នាំដដែល។ ដូច្នេះ ដើម្បីទទួលបានជោគជ័យលើបញ្ហានេះ ការចូលរួមពីប្រជាជនសហគមន៍មូលដ្ឋាន ក្នុងតំបន់ការពារព្រៃឈើ សំដៅគ្រប់គ្រងធនធានដែលមាន។ ទោះបីជាសហគមន៍ព្រៃឈើខ្លះមិនត្រូវបានទទួលស្គាល់ជាផ្លូវការក៏សហគមន៍ទាំងអស់មានចំនួន៤៥៧សហគមន៍គិតមកដល់ឆ្នាំ២០១៣ បន្តជួយអភិរក្សតំបន់ដែលមានផ្ទៃដីសរុបជាង៤០០.០០០ហិកតា។ តំបន់ការពារសហគមន៍ចំនួន១២០ កំពុងគ្របដណ្តប់លើផ្ទៃដី១៦៤.៤៨០ហិកតា។

បញ្ហាប្រឈមដទៃទៀត គឺបច្ចេកវិទ្យា និងបច្ចេកទេសសម្រាប់ការដាំដុះព្រៃឈើឡើងវិញនៅមានកម្រិត ការលើកទឹកចិត្តសម្រាប់មន្ត្រីនៅមានកម្រិតទាប ប្រជាជនពឹងផ្អែកលើព្រៃឈើសម្រាប់ជីវភាពរស់នៅៗមានកម្រិតខ្ពស់នៅឡើយ ការកាប់ឈើខុសច្បាប់និងការកំណត់ព្រំប្រទល់តំបន់ព្រៃឈើមិនទាន់ត្រូវបានអនុវត្តពេញលេញ។

កម្ពុជានឹងផ្តោតការយកចិត្តទុកដាក់លើការអភិរក្សព្រៃឈើ និងការគ្រប់គ្រងប្រកបដោយចីរភាពនូវប្រព័ន្ធអេកូព្រៃឈើ ដើម្បីទាញយកអត្ថប្រយោជន៍ច្រើនយ៉ាង ដូចជាវិស័យសេដ្ឋកិច្ច បរិស្ថាន វប្បធម៌ និងសង្គម។ កម្ពុជាក៏នឹងធ្វើការវិនិយោគធំៗ ក្នុងការអភិវឌ្ឍតំបន់ជនបទ ទឹកនិងអនាម័យ ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធដទៃបន្ថែមលើការវិនិយោគអប់រំ និងសុខភាព។ កិច្ចការទាំងអស់នេះអាចជួយកាត់បន្ថយសំពាធលើព្រៃឈើ។

### វិធានការគាំទ្រនានា

រាជរដ្ឋាភិបាលបានរៀបចំវិធានការមួយចំនួនក្នុងវិស័យបរិស្ថាន។ ក្នុងចំណោមវិធានការទាំងនោះវិធានការដែលសំខាន់បំផុតនោះ គឺផ្នែកច្បាប់និងការកសាងសមត្ថភាព។ ច្បាប់មួយចំនួនត្រូវបានអនុម័តដើម្បីការពារបរិស្ថាន និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព ជាពិសេសធនធានទឹកក្រោមដី។ មន្ត្រីជាច្រើនត្រូវបានបញ្ជូនឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងកម្មសិក្សាផ្សេងៗ។ ការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាននៃគម្រោងពាណិជ្ជកម្មត្រូវបានធ្វើឡើងជាចាំបាច់ មុនពេលធ្វើការផ្តល់អាជ្ញាប័ណ្ណ។ ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយសម្រាប់ការតាមដានត្រួតពិនិត្យបរិស្ថានកំពុងត្រូវបានរៀបចំឡើង ហើយប្រព័ន្ធទិន្នន័យស្តីពីបរិស្ថាននឹងមានក្នុងពេលឆាប់ៗនេះ។



អ្នកភូមិរស់នៅជុំវិញព្រៃសហគមន៍ព្រះសង្ឃខេត្តឧត្តរមានជ័យប្រមូលអនុផលព្រៃឈើសម្រាប់លក់

## ៧.៤ វិស័យជលផល

វិស័យនេសាទ បានឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងប្រទេសកម្ពុជា បន្ទាប់ពីមានកំណែទម្រង់ជាច្រើនពីឆ្នាំ២០០០ដល់ឆ្នាំ២០១៣។ ទាំងនេះរួមមានការបង្កើតសហគមន៍នេសាទ និងការលុបបំបាត់ឡូត៍នេសាទពីប្រតិបត្តិការនេសាទទ្រង់ទ្រាយធំ (ដែលបច្ចុប្បន្ន ត្រូវបានផ្តល់ឱ្យដំណើរការនេសាទខ្នាតតូច តាមរយៈការត្រួតពិនិត្យរបស់សហគមន៍)។ ការកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២របស់រាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទទាំងអស់ទុកសម្រាប់ប្រជាពលរដ្ឋទូទាំងប្រទេសធ្វើអាជីវកម្មជាលក្ខណៈគ្រួសារ និងជាកន្លែងអភិរក្សជលផលបច្ចុប្បន្នកំពុងផ្តល់នូវផលចំណេញដល់ប្រជាពលរដ្ឋ។

ចំនួនសហគមន៍នេសាទបានកើនឡើងបន្តិចម្តងៗពីចំនួន២៤៦ ក្នុងឆ្នាំ២០០២ ដល់ចំនួន ៤៦៩ ក្នុងឆ្នាំ២០១០និង៥១៦ក្នុងឆ្នាំ២០១៣ ដោយមានផ្ទៃទឹក៦៨៣.៧៣៤ហិកតា។ ប៉ុន្តែមានតែសហគមន៍ចំនួន៣៦០ប៉ុណ្ណោះ ដែលមានផ្ទៃទឹក៨០០០០០ហិកតា បានចុះបញ្ជីត្រឹមត្រូវក្នុងឆ្នាំដដែល។ ជាងនេះទៅទៀត ជម្រកត្រីសហគមន៍ចំនួន៣៩០ ដែលមានផ្ទៃទឹក១១៧០ហិកតា និងព្រៃជម្រកសុវត្ថិភាពរបស់មច្ឆាចំនួន៣៣៥កន្លែង ដែលមានផ្ទៃទឹក៤៦.៦១៨ហិកតា ត្រូវបានបង្កើតឡើងនិងមានស្រះជម្រកត្រីសហគមន៍ចំនួន៧៨៨កន្លែង។ ការបង្កើតជម្រកព្រៃសុវត្ថិភាពរបស់មច្ឆាកំពុងដើរចំទិសដៅឆ្ពោះទៅសម្រេចបានចំណុចដៅក្នុងឆ្នាំ២០១៥។

ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ រដ្ឋបាលជលផលបានសម្រេចដោយជោគជ័យគ្រប់អនុវិស័យទាំងអស់ ដូចជាការរៀបចំឧបករណ៍ច្បាប់នានា ការពង្រឹងសហគមន៍នេសាទ បង្កើតស្រះជម្រកត្រីសហគមន៍ ការអភិវឌ្ឍវារីវប្បកម្មការរៀបចំការស្រាវជ្រាវ ការអភិរក្ស ការលុបបំបាត់សកម្មភាពនេសាទខុសច្បាប់ និងការពង្រីកការនេសាទ។ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងបទបញ្ជាបច្ចេកទេសត្រូវបានរៀបចំឡើង ពិនិត្យ កែសម្រួល និងអនុម័ត ដើម្បីធានាពីការគ្រប់គ្រងជលផលដោយចីរភាព។

ភាពប្រឈមសំខាន់នោះ គឺការគ្រប់គ្រងអេកូឡូស៊ីនៅទន្លេសាប។ ការកាប់បំផ្លាញព្រៃឈើនៅតាមដងទន្លេក្នុងតំបន់នេសាទ ធ្វើឱ្យបិទផ្លូវទឹកដោយសារបាក់ដី ទឹកជំនន់និងគ្រោះរាំងស្ងួត កើតឡើង ញឹកញាប់។ ទឹកមានពាសពេញក្នុងផ្ទៃប្រទេសនារដូវវស្សា ប៉ុន្តែទឹកមានការខ្វះខាត/រាំងស្ងួតនៅរដូវវស្សា។ ម្យ៉ាងវិញទៀត បញ្ហាប្រឈមនៅតែមានសម្រាប់ការត្រួតពិនិត្យការនេសាទដោយខុសច្បាប់ និងការប្រើប្រាស់វិធីសាស្ត្រមិនប៉ះពាល់អេកូឡូស៊ី។ បញ្ហាប្រឈមបន្តទៀតនោះ ពាក់ព័ន្ធនឹងការការពារទុកដាក់និងកែច្នៃ និងទីផ្សារពាណិជ្ជកម្មដើម្បីផលិតផលនេសាទអាចទទួលតម្លៃបន្ថែមខ្ពស់ និងប្រជានេសាទទទួលបានចំណូលខ្ពស់សម្រាប់កាត់បន្ថយភាពក្រីក្រ។



កសិករកំពុងចាប់ត្រីពីស្រះ-ខេត្តសៀមរាប

## ៧.៥ ទឹកស្អាត និងអនាម័យ

ទឹកស្អាត និងអនាម័យល្អ គឺជាស្នូលក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅគ្រប់ប្រទេសទាំងអស់។ ដូចនេះ រាជរដ្ឋាភិបាលបានចាត់ទុកទឹកនិងអនាម័យជាវិស័យអាទិភាពមួយ។

ចំណុចដៅ គ.អ.ស.ក. សម្រាប់ឆ្នាំ២០១៥ គឺ៥០% នៃប្រជាជនទាំងអស់មានលទ្ធភាពទទួលបានការផ្គត់ផ្គង់ទឹកស្អាតតំបន់ជនបទ។ ចំណុចដៅនេះ នឹងអាចសម្រេចបាន ប៉ុន្តែទាមទារនូវកិច្ចខំប្រឹងប្រែងបន្ថែមទៀត (រូបភាពទី២.៣១)។ ប្រទេសកម្ពុជា ទំនងជាអាចសម្រេចបានចំណុចដៅផ្នែកអនាម័យជនបទ ៣៣% នៅឆ្នាំ២០១៥។ ចំណុចដៅ គ.អ.ស.ក. សម្រាប់ឆ្នាំ២០១៥ ទាក់ទងនឹងទឹកស្អាត គឺបង្កើនសមាមាត្រប្រជាជនរស់នៅតំបន់ទីប្រជុំជនមានទឹកស្អាតប្រើប្រាស់រហូតដល់៨០%។ ជាលទ្ធផលសមាមាត្រប្រជាជនរស់នៅតំបន់ទីប្រជុំជនមានទឹកស្អាតប្រើប្រាស់ មានប្រមាណ៨១% ក្នុងឆ្នាំ២០១១ ដែលលើសពីចំណុចដៅរួចហើយ។ រីឯចំណុចដៅអនាម័យក្នុងតំបន់ទីប្រជុំជនរបស់ គ.អ.ស.ក. បង្ហាញថាសមាមាត្រប្រជាជនមានអនាម័យរហូតដល់៧៤% នៅឆ្នាំ២០១៥ ក៏សម្រេចបានមុនកំណត់ផងដែរ។



សិស្សសាលាកំពុងយកទឹកបរិភោគពីធុងទឹកក្នុងថ្នាក់រៀន-ខេត្តកណ្តាល

## រូបភាពទី២.៣១ ៖ សមាមាត្រប្រជាជននៅតាមតំបន់ជនបទនិងតំបន់ទីប្រជុំជនមានទឹកស្អាតនិងបង្គន់អនាម័យ




*ប្រភព ៖ អង្កេតសេដ្ឋកិច្ចនិងសង្គមកិច្ច*

ដោយពិនិត្យមើលពីលទ្ធភាពប្រើប្រាស់ទឹកស្អាត តាមរយៈការគណនាចំណាយរបស់មនុស្សម្នាក់ៗ ឬក៏កម្រិតជីវភាពតាមក្រុមនីមួយៗបង្ហាញថា គម្លាតលទ្ធភាពប្រើប្រាស់ទឹកស្អាត មិនខុសគ្នាច្រើនរវាងក្រុមប្រជាជនដែលមានកម្រិតជីវភាពក្រីក្របំផុត ក្រីក្រ និងមធ្យម។ ប៉ុន្តែគម្លាតមានភាពខុសគ្នាច្រើនធៀបនឹងក្រុមប្រជាជនមានកម្រិតជីវភាពខ្ពស់។ ផ្ទុយទៅវិញលទ្ធភាពប្រើប្រាស់បង្គន់អនាម័យ មានគម្លាតខុសគ្នាច្រើនរវាងកម្រិតជីវភាពតាមក្រុមនីមួយៗ (រូបភាពទី២.៣២ ១និង២)។ ក្នុងន័យនេះ លទ្ធភាពប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យតាមខេត្តនីមួយៗ ក៏នៅមានគម្លាតខុសគ្នាច្រើន នឹងត្រូវបានកំណត់អាទិភាព ចំពោះខេត្តដែលមានលទ្ធភាពប្រើប្រាស់ទឹកស្អាត និងអនាម័យតិចជាងគេ។

## រូបភាពទី ២.៣២-១ និង២.៣២-២៖ លទ្ធភាពប្រើទឹកស្អាតនិងបង្គន់អនាម័យ តាមក្រុមកម្រិតជីវភាព និងខេត្ត ឆ្នាំ២០១១







*ប្រភព ៖ អង្កេតសេដ្ឋកិច្ចនិងសង្គមកិច្ច*

អុស និងធ្យូងដែលជាប្រភពចម្អិនអាហារ កំពុងធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងកំណើនកំដៅផែនដី។ ចង្ក្រានដី ក៏នៅតែជៀសមិនផុតពីប្រើអុស។ ជាងនេះទៅទៀត ផ្សែងអាចបង្កជាផលប៉ះពាល់ដល់ភ្នែក និងប្រព័ន្ធដង្ហើមរបស់អ្នកចម្អិន។ ការដុតឈើក្នុងឡ ដើម្បីបានជាធ្យូង បានដុតបំផ្លាញបំនែកកាបូន ដែលរួមចំណែកដល់ឧស្ម័នផ្ទះកញ្ចក់។

យោងតាមអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១០ បង្ហាញថា គ្រួសារជាង ៨៤ភាគរយ ប្រើអូសដុត ចម្អិនអាហារ ក្នុងឆ្នាំ២០០៥ ដែលបានថយចុះពី ៧៩.៥ភាគរយ ក្នុងឆ្នាំ២០០០។ ជំរឿនប្រជាជនឆ្នាំ ១៩៩៨ និង២០០៨ ក៏បានបង្ហាញពីភាគរយថយចុះនៃគ្រួសារប្រើប្រាស់អូសចម្អិនម្ហូបអាហារ ( ពី ៩០.៤ភាគរយ មក៨៣.៦ភាគរយ )។ ទន្ទឹមនេះ ៨៥ភាគរយ នៃគ្រួសារប្រើប្រាស់អូសសម្រាប់ចម្អិនម្ហូបអាហារ ( ទិន្នន័យពីអង្កេត សេដ្ឋកិច្ចនិងសង្គមកិច្ច ឆ្នាំ២០១១ )។ ប្រសិនបើ ធ្យូង និងអុសត្រូវបានប្រើព្រមគ្នាសម្រាប់ចម្អិនអាហារ នោះលទ្ធផលនឹងកើនឡើងដល់ ៩០ ភាគរយ។ យោងតាមលទ្ធផលទាំងអស់នេះ ការកាត់បន្ថយសមាមាត្រគ្រួសារប្រើប្រាស់អូសចម្អិនម្ហូបអាហារឱ្យបាន ៥២ភាគរយ គឺមិនអាចសម្រេចបានក្នុងឆ្នាំ២០១៥ នោះទេ។

យុទ្ធសាស្ត្ររយៈពេលខ្លី សម្រាប់កាត់បន្ថយសមាមាត្រគ្រួសារប្រើប្រាស់អូសចម្អិនម្ហូបអាហារ គឺការលើកទឹកចិត្តឱ្យប្រើប្រាស់ចង្ក្រានដែលសន្សំសំចៃ និងតំលៃសមរម្យ។ ឆ្លើយតបនឹងយុទ្ធសាស្ត្រនេះ ចង្ក្រានប្រមាណជា ១លាន ត្រូវបានកែលម្អហើយបែងចែកក្នុងទីផ្សារ ចាប់តាំងពីឆ្នាំ២០០៣ ដែលអាចជួយទប់ស្កាត់កាប់ព្រៃឈើប្រមាណជា ៥,០០០ ហិកតា។ រយៈពេលវែង រាជរដ្ឋាភិបាលកំពុងអនុវត្តយុទ្ធសាស្ត្រ ការភ្ជាប់បណ្តាញអគ្គីសនីនៅតាមទីជនបទ តាមរយៈការប្រើប្រាស់ថាមពលកើតឡើងវិញ ខ្នាតតូចៗជាច្រើន ដូចជាការប្រើប្រាស់ជីវឧស្ម័ន។ រីឯការដាំដើមឈើធំៗដែលធាប់លូតលាស់សម្រាប់ ជាអូសដុត ក៏ជាជម្រើសមួយ ដែលត្រូវបន្តអនុវត្តផងដែរ។



កសិករខេត្តកំពង់ឆ្នាំងប្រើប្រាស់អុសសម្រាប់ផលិតស្ករត្នោត។ គម្រោង UNDP កំពុងជម្រុញលើកទឹកចិត្ត កសិករប្រើចង្ក្រានថ្មីដែលប្រើអុសតិច។

## ៧.៦ ការប្រើប្រាស់អុស

អុស និងធ្យូងដែលជាប្រភពថាមពលចម្អិនអាហារ កំពុងធ្វើឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងកំណើនកំដៅដល់ផែនដី។ ការប្រើប្រាស់អុសបង្កើតផ្សែងច្រើនជាងប្រើធ្យូង។ ជាងនេះទៅទៀត ផ្សែងអាចបង្កជាផលប៉ះពាល់ដល់សុខភាពរបស់អ្នកចម្អិន។ ការដុតឈើក្នុងឡដើម្បីបានជាធ្យូងបានដុតបំផ្លាញបំណែកកាបូន ដែលរួមចំណែកដល់ឧស្ម័នផ្ទះកញ្ចក់។ ការប្រើប្រាស់ឡធ្យូងប្រសិទ្ធភាពដែលសាងសង់តាមបច្ចេកវិទ្យាថ្មី បានជួយបង្កើនគុណភាពធ្យូង និងជួយសន្សំសំចៃឈើប្រមាណ ៣០% បើធៀបនឹងការប្រើប្រាស់ឡបុរាណ ។

គ្រួសារជាង៨៤%បានប្រើប្រាស់អុសដុតចម្អិនអាហារក្នុងឆ្នាំ២០០៥ ដែលបានថយចុះមកត្រឹម៧៩,៥% ក្នុងឆ្នាំ២០១០ និងប្រមាណ៦២% ក្នុងឆ្នាំ២០១៣។

យុទ្ធសាស្ត្ររយៈពេលខ្លី សម្រាប់កាត់បន្ថយសមាមាត្រគ្រួសារប្រើប្រាស់អុសចម្អិនម្ហូបអាហារ គឺការលើកទឹកចិត្តឱ្យប្រើប្រាស់ចង្ក្រានប្រសិទ្ធភាពដែលមានគុណភាពសន្សំសំចៃធ្យូងបានប្រមាណ២០%ធៀបនឹងចង្ក្រានឡូវធម្មតា និងមានតម្លៃសមរម្យ។ ឆ្លើយតបនឹងយុទ្ធសាស្ត្រនេះ ចង្ក្រានប្រសិទ្ធភាពប្រមាណ២,៥លាន ត្រូវបានលក់ចែកចាយនៅលើទីផ្សារចាប់តាំងពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០១៣ ដែលគួបផ្សំនឹងការប្រើប្រាស់ឡធ្យូងប្រសិទ្ធភាពបានជួយទប់ស្កាត់ និងកាត់បន្ថយការកាប់ព្រៃឈើសម្រាប់ធ្វើអុស-ធ្យូងបានយ៉ាងច្រើន ។

ក្នុងរយៈពេលវែង រាជរដ្ឋាភិបាលកំពុងអនុវត្តយុទ្ធសាស្ត្រតភ្ជាប់បណ្តាញបញ្ជូន និងការពង្រីកបណ្តាញបញ្ជូនរងឱ្យដល់ទីជនបទ ជំរុញអភិវឌ្ឍថាមពលកកើតឡើងវិញ និងប្រើប្រាស់ជីវឧស្ម័ន។ ការដាំដើមឈើដែលឆាប់លូតលាស់សម្រាប់ធ្វើជាអុសដុត ក៏ជាជម្រើសមួយដែលត្រូវបន្តអនុវត្តផងដែរ។

យោងតាមលទ្ធផលទាំងអស់នេះ និងការរីកចម្រើនខាងថាមពលអគ្គិសនីការប្រើប្រាស់ឧស្ម័នធម្មជាតិនិងជីវឧស្ម័នការកាត់បន្ថយសមាមាត្រគ្រួសារប្រើប្រាស់អុសចម្អិនម្ហូបអាហារឱ្យបាន៥២% គឺអាចសម្រេចបានក្នុងឆ្នាំ២០១៥។

## ៧.៧ កម្មសិទ្ធិដីធ្លី

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បានផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីចំនួន២.២៥៧.១៥១ប័ណ្ណ ដល់ប្រជាជនកម្ពុជា (ការប៉ាន់ស្មានដល់ដើមឆ្នាំ២០១៣) តាមរយៈការចុះបញ្ជីជាប្រព័ន្ធ។ កម្មសិទ្ធិធីធ្លីចំនួន៦០៣.៣៣២ប័ណ្ណ ត្រូវបានផ្តល់ជូនតាមរយៈការចុះបញ្ជីដីធ្លីដាច់ដោយដុំៗ។ កម្មសិទ្ធិដីធ្លីសរុបដែលបានផ្តល់ជូនប្រជាជនមានចំនួន ២ ៨៦០ ៤៥៣ប័ណ្ណ។ អត្រាការចុះបញ្ជីដីកសិកម្មដែលវាស់វែងដោយគិតជាភាគរយនៃប្លង់ដីសរុប ដែលបានចុះបញ្ជីក្នុងមួយឆ្នាំៗបានកើនឡើងពី២២%ក្នុងឆ្នាំ២០០៩ទៅ២៤%ក្នុងឆ្នាំ២០១០ និង២៨% ក្នុងឆ្នាំ២០១១។ គោលបំណង គឺដើម្បីសម្រេចឱ្យបាន៤៣% នៅឆ្នាំ២០១៥ (ដោយកែសម្រួលបន្ថយពីចំណុចដៅ៦៥%)។ ដើម្បីសម្រេចបានចំណុចដៅនេះ រាជរដ្ឋាភិបាលនឹងពន្លឿនវឌ្ឍនភាពនេះបន្ថែមទៀត។

ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិភាគតិច បានបញ្ចប់ក្នុងតំបន់សាកល្បងចំនួនបីកន្លែង គឺទី១ ក្នុងភូមិអណ្តូងក្រឡាំង ស្រុកអូរាំងឪ ខេត្តមណ្ឌលគិរី ទី២ និងទី៣ ក្នុងស្រុកអូឈំ និងស្រុកកូនមុំ ក្នុងខេត្តរតនគិរី។ ដើម្បីពង្រឹងសមត្ថភាពសម្រាប់អនុវត្តទាំងការចុះបញ្ជីជាប្រព័ន្ធ រួមទាំងការចុះបញ្ជីដីធ្លីដាច់ដោយដុំៗក្រសួងដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំវគ្គបណ្តុះបណ្តាលជាច្រើនដល់មន្ត្រីរបស់ខ្លួន។

### លទ្ធផលដែលបានសម្រេចបាន បញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

**ធលទ្ធផលដែលសម្រេចបាន៖** រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចឬកំពុងឆ្ពោះទៅរកការសម្រេចបាន គ.អ.ស.ក. នៅឆ្នាំ២០១៥ ស្តីពីការធ្វើឱ្យដូចដើមវិញនូវបរិស្ថានដែលបានបាត់បង់ (ដែលរួមមាន ព្រៃឈើ និងជលផល) ក៏ដូចជាទឹកស្អាតនិងអនាម័យ។

**បញ្ហាប្រឈម៖** ទន្ទឹមនឹងភាពជោគជ័យដែលសម្រេចបាន ការធានាបាននូវសមិទ្ធផលប្រកបដោយចីរភាព តាមរយៈប្រព័ន្ធតាមដាន និងត្រួតពិនិត្យសម្រាប់សម្បទានព្រៃឈើនិងសម្បទានសេដ្ឋកិច្ច ការវាស់វែងតំបន់ព្រៃឈើឱ្យបានឆាប់រហ័ស ការលើកកម្ពស់គុណភាពធនធានមនុស្សសម្រាប់ការអភិរក្ស ការជំរុញបន្ថែមបច្ចេកវិទ្យាថ្មីៗសម្រាប់ការងារអភិរក្ស ការការពារសិទ្ធិប្រជាជនដែលពឹងផ្អែកលើអនុផលព្រៃឈើ គឺជាការងារប្រឈមដ៏ចម្បង។ ការផ្តល់កម្មសិទ្ធិដីធ្លី ទាមទារចាំបាច់ត្រូវតែបង្កើនល្បឿន។ ដោយឡែក កម្ពុជាទំនងជាមិនអាចសម្រេចបានការកាត់បន្ថយការប្រើប្រាស់អុស និងធ្យូងសម្រាប់ចម្អិនអាហារតាមចំណុចដៅ ក្នុងឆ្នាំ២០១៥ បានទេ។

**គោលនយោបាយរបស់រាជរដ្ឋាភិបាល៖** ដូចបានលើកឡើងពីខាងដើម យុទ្ធសាស្ត្រចតុកោណបានដាក់ចេញនូវទិសដៅសម្រាប់ពង្រឹងច្បាប់ រៀបចំក្របខ័ណ្ឌនានារបស់ស្ថាប័ន និងការកសាងសមត្ថភាពធនធន និងស្ថាប័ន។ ការងារដែលនឹងអនុវត្តបន្ត រួមមានដូចជា៖

**វិស័យព្រៃឈើ៖** រាជរដ្ឋាភិបាលនឹងជំរុញកម្មវិធីព្រៃឈើជាតិ ២០១០-២០២៩ ដែលផ្តោតលើចំណាត់ថ្នាក់ និងការចុះបញ្ជីដែនព្រៃឈើ ការគ្រប់គ្រងព្រៃឈើរដ្ឋ និងឯកជន ការចូលរួមពីសហគមន៍ដែលអាស្រ័យលើអនុផលព្រៃឈើ ការគ្រប់គ្រងវិធានការអភិរក្ស ការកាត់បន្ថយនូវការបាត់បង់ និងរិចរិលព្រៃឈើ និងការបង្កើនការដាំ និងស្តារព្រៃឈើឡើងវិញ។

**វិស័យជលផល៖** រាជរដ្ឋាភិបាលនឹងជំរុញក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ២០១០-២០១៩។សមាសភាគសំខាន់គឺ សំដៅពង្រឹងការត្រួតពិនិត្យឧបករណ៍នេសាទ និងរដូវនេសាទ កាត់បំបាត់ការនេសាទហួសកម្រិត ពង្រឹងសមត្ថភាពសហគមន៍នេសាទក្នុងការគ្រប់គ្រង កាត់បន្ថយនូវការបំពុលបរិស្ថាន និងកំណត់ព្រំប្រទល់ព្រៃលិចទឹក និងតំបន់អភិរក្សជលផល។

**វិស័យដីធ្លី៖** រាជរដ្ឋាភិបាលនឹងបន្តកម្មវិធីទាំង៩ ដែលរួមមាន ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងដីធ្លី និងនគររូបនីយកម្ម និងច្បាប់ស្តីពីកសិកម្ម និងការពន្លឿនការចុះបញ្ជីដីធ្លី និងការផ្តល់កម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ ដីឯកជន និងដីសហគមន៍ជនជាតិភាគតិច។

**ទឹកស្អាតនិងអនាម័យ៖** រាជរដ្ឋាភិបាលនឹងពង្រីកវិសាលភាពគ្របដណ្តប់ការផ្គត់ផ្គង់ទឹកស្អាត ទៅដល់តំបន់ទីប្រជុំជននិងតំបន់ជនបទតាមរយៈការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ២០១១-២០២៥ ដោយរួមទាំងការរៀបចំផែនការសកម្មភាព និងការលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន។

## គោលដៅទី៨ បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ

គ.អ.ស.ក. មិនមានសូចនាករច្បាស់លាស់សម្រាប់វាស់វែងពីការសម្រេចបានគោលដៅនេះឡើយ លើកលែងតែគោលបំណងចំនួន៤ ត្រូវបានកំណត់ដូចខាងក្រោម៖

១. បង្កើនបរិមាណ និងប្រើប្រាស់ធនធានហិរញ្ញប្បទានក្រៅប្រទេសឱ្យមានប្រសិទ្ធភាពការសម្របសម្រួល និងសុខដុមនីយកម្មហិរញ្ញប្បទាន។

២. រក្សានូវការបើកចំហរសេដ្ឋកិច្ច។

៣. បន្តស្វែងរកភាពជាដៃគូ។

៤. សហការជាមួយវិស័យឯកជនដើម្បីបង្កើតផលប្រយោជន៍បច្ចេកវិទ្យាថ្មីៗ ជាពិសេសបច្ចេកវិទ្យាព័ត៌មានវិទ្យា។

### ៨.១ ការកៀរគរធនធាន ការសម្របសម្រួល និងសុខដុមនីយកម្ម

រាជរដ្ឋាភិបាលទទួលបានជោគជ័យក្នុងការកៀរគរហិរញ្ញប្បទានពីក្រៅប្រទេសប្រមាណ១ ០០០ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ តាមរយៈកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច។ ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍មិនគ្រាន់តែរួមចំណែកដល់កំណើនផលិតក្នុងស្រុកសរុបប្រមាណជា ៨-៩% នាពេលថ្មីៗនោះទេ ថែមទាំងបានជួយប្រទេសឱ្យសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់កាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យប្រទេសកម្ពុជាឆ្ពោះទៅរកការសម្រេចបាន គ.អ.ស.ក.។ហិរញ្ញប្បទានសហប្រតិបត្តិការ បានបង្កើតនូវបរិស្ថានវិជ្ជមានមួយសម្រាប់ការវិនិយោគឯកជនក្នុងវិស័យកសិកម្ម ឧស្សាហកម្មកាត់ដេរ សំណង់ ហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។ រាជរដ្ឋាភិបាលកម្ពុជា ស្ថិតក្នុងជំហរមួយដ៏ល្អដើម្បីជំរុញ និងធ្វើឱ្យមានស្ថិរភាពកំណើនសេដ្ឋកិច្ច និងជំរុញកម្ពុជាឱ្យទទួលបាននូវឋានៈជាប្រទេសមានចំណូលមធ្យម រួមទាំងការទទួលបានអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមសមាហរណកម្មក្នុងតំបន់ និងក្នុងសកលលោកសម្រាប់អនាគតដ៏ខ្លីខាងមុខ។

ការបែងចែកហិរញ្ញប្បទានឥតសំណងបានកើនឡើងពី៦៦-៧៥% រវាងឆ្នាំ២០០៤ និងឆ្នាំ២០១០។ ទន្ទឹមនឹងនេះបរិមាណឥណទានកម្ចីបានចាប់ផ្តើមកើនឡើង ទោះបីជាហិរញ្ញប្បទានឥតសំណងនៅមានចំនួនច្រើនក្តី។ ជាមួយនឹងកម្ចីដែលមានការកើនឡើងជាលំដាប់ កម្ពុជានឹងមានវិធានការចាំបាច់ក្នុងការប្រើប្រាស់ថវិកាឱ្យមានប្រសិទ្ធភាពស្របពេលនឹងការទូទាត់បំណុលកម្ចីពីនាពេលមុនៗ (រូបភាពទី២.៣៣)។

រូបភាពទី ២.៣៣៖ និន្នាការរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការ កម្ចី ជំនួយឥតសំណង និងសរុប (លាន ដុល្លា)




*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ ផ្តោតជាសំខាន់លើវិស័យសុខាភិបាល អប់រំ ដឹកជញ្ជូន អភិបាលកិច្ច កសិកម្ម និងអភិវឌ្ឍន៍ជនបទ (រូបភាពទី២.៣៤)។ រីឯបណ្តាសូចនាករតាមដានសុខភាព និងអត្រាភាពក្រីក្រ បានបង្ហាញពីលទ្ធផលល្អក្នុងឆ្នាំថ្មីៗនេះ។ ផ្អែកលើមូលដ្ឋាននេះ ការវិនិយោគលើវិស័យសង្គម បានចូលរួមចំណែកយ៉ាងច្រើនក្នុងការធ្វើឱ្យមានកំណើនសេដ្ឋកិច្ច។

រូបភាពទី២.៣៤ ៖ ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការតាមវិស័យ (ប៉ាន់ស្មានឆ្នាំ២០១៣)




*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

### ៨.២ ដំណើរការនៃភាពជាដៃគូការសម្របសម្រួល និងសុខដុមនីយកម្ម

ទម្រង់នៃភាពជាដៃគូ រវាងប្រទេសកម្ពុជាជាមួយនឹងតួអង្គអភិវឌ្ឍន៍មានចំនួន៣ គឺ៖

១. ភាពជាដៃគូជាមួយនឹងដៃគូអភិវឌ្ឍ។

២. ភាពជាដៃគូរបស់វិស័យឯកជន។

៣. ភាពជាដៃគូរវាងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។

ប្រទេសកម្ពុជាបានបង្កើតយន្តការនៃភាពជាដៃគូ ដូចខាងក្រោម៖

១. វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា។

២. គណៈកម្មការសម្របសម្រួលរវាងរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍ។

៣. បណ្តាញក្រុមការងារបច្ចេកទេសចម្រុះ ដែលមានក្រុមការងារបច្ចេកទេសចំនួន១៩ធ្វើការតាមវិស័យ និងវិស័យដែលពាក់ព័ន្ធ។

៤. កិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។

៥. កិច្ចប្រជុំពិគ្រោះយោបល់ រវាងរាជរដ្ឋាភិបាលជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល។

### រូបភាពទី ២.៣៥៖ ការកន្សីជំនួយកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាមួយ ផ.យ.អ.ជ ឆ្នាំ២០០៦ និង២០១១




*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

រាជរដ្ឋាភិបាលបានបង្កើតវឌ្ឍនភាពល្អៗ តាមរយៈការពង្រឹងប្រសិទ្ធិភាពនិងភាពស័ក្តសិទ្ធិ ក្នុងការ ប្រើប្រាស់ជំនួយធនធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ឈរលើន័យនេះ ប្រទេសកម្ពុជា សម្រេចបាន ចំពោះការអនុវត្តប្តេជ្ញាចិត្តពង្រឹងប្រសិទ្ធិភាពជំនួយ ដែលបានប្រកាសជាសកលនៅទីក្រុងប៉ារីស ក្នុងឆ្នាំ ២០០៥ និងការសម្រេចបានការអនុវត្តប្តេជ្ញាចិត្តក្នុងផែនការសកម្មភាពទីក្រុងអាក្រា "The Accra Agenda for Action" ក្នុងឆ្នាំ២០០៨។ តម្លាភាពក្នុងលំហូរនិងការប្រើប្រាស់ធនធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រូវបានលើកកម្ពស់ ក៏ដូចជាប្រព័ន្ធព័ត៌មានជាតិមូលដ្ឋានទិន្នន័យ ODA ត្រូវបានបំពេញបន្ថែម ជាទៀងទាត់។

សុខដុមនីយកម្មនៃការគាំទ្រនានារបស់ដៃគូអភិវឌ្ឍន៍ ត្រូវបានពង្រឹងជាមួយនឹងការណែនាំនិងការអនុវត្តឧបករណ៍ដូចជា នីតិវិធីផ្អែកលើកម្មវិធី (Program based approaches) ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា និងវឌ្ឍនភាព កំពុងបន្តមានក្នុងកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្របខ័ណ្ឌលទ្ធផលនៃការអភិវឌ្ឍ ត្រូវបានធ្វើសមាហរណកម្មទៅក្នុងផ.យ.អ.ជ. ហើយនឹងត្រូវបានពង្រឹងបន្ថែមសំដៅបម្រើជាក្របខ័ណ្ឌតាមដានជាតិ ដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់លទ្ធភាពនៃការអភិវឌ្ឍ។ ទន្ទឹមនេះ ទោះបីជាដំណើរស្តីពីការបន្សីជំនួយជាមួយអាទិភាពរបស់រាជរដ្ឋាភិបាល កំពុងដំណើរការមិនទាន់បានរលូនប្រាកដមែន (រូបភាពទី ២.៣៥) ជាគោលការណ៍ ធនធានអភិវឌ្ឍន៍ត្រូវបានវិភាជ ដើម្បីគាំទ្រវិស័យអាទិភាពជាតិ ដូចបានបញ្ជាក់ក្នុងយុទ្ធសាស្ត្រចតុកោណ និងផ.យ.អ.ជ. (បង្ហាញពីក្របខ័ណ្ឌគោលនយោបាយសម្រាប់បន្សីគ្នាជាមួយផែនការជាតិ) ។



កសិករកំពុងបូមទឹកបញ្ចូលស្រែនារដូវប្រាំង-ខេត្តស្វាយរៀង

នៅក្នុងបរិការណ៍អភិវឌ្ឍន៍កម្រិតសកល និងកម្រិតជាតិ ចាំបាច់ត្រូវចង្អុលបង្ហាញពីការសម្រេចបានលទ្ធផលពីការអភិវឌ្ឍ និងការជ្រើសរើសនីតិវិធីប្រើប្រាស់ ដែលគាំទ្រដល់ការរៀបចំផែនការ ការបង្កើតភាពជាដៃគូនិងប្រព័ន្ធតាមដានត្រួតពិនិត្យ។ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពនូវនីតិវិធីអភិវឌ្ឍន៍ប្រកបដោយអត្ថន័យនោះសកម្មភាពនានាដែលមានតួនាទីពង្រឹងភាពជាដៃគូសម្រេចលទ្ធផល ក៏ដូចជាអភិវឌ្ឍសមត្ថភាពប្រកបដោយចីរភាព ត្រូវបានបន្សីជាមួយផែនការជាតិ ថវិកាជាតិ និងក្របខ័ណ្ឌតាមដានត្រួតពិនិត្យ។ កិច្ចខិតខំប្រឹងប្រែងគាំទ្រដោយជំនួយអភិវឌ្ឍន៍ផ្លូវការចាំបាច់ត្រូវធ្វើសមាណហរណកម្មយ៉ាងជិតស្និទ្ធជាមួយនឹងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល សំដៅកសាងស្ថាប័នឱ្យមានប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកំពុងរិះរកវិធីសាស្ត្រឆ្ពោះទៅរកការបង្កើតក្របខ័ណ្ឌលទ្ធផលសម្រាប់ការតាមដានត្រួតពិនិត្យនៅកម្រិតជាតិនិងវិស័យ ដើម្បីជំរុញនិងណែនាំភាពជាដៃគូអភិវឌ្ឍឱ្យមានប្រសិទ្ធភាព។

យោងទៅតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានធ្វើសមាហរណកម្មចូលក្នុងសេដ្ឋកិច្ចពិភពលោក។ ក្នុងឋានៈជាសមាជិកពេញសិទ្ធិនៃសមាគមអាស៊ាន កម្ពុជាបានបំពេញតួនាទីយ៉ាងសកម្មនៅក្នុងក្រុមការងារជាតិនេះ។ សកម្មភាពនេះ ក៏រួមទាំងការធ្វើជាប្រធានសមាគមអាស៊ាននៅឆ្នាំ២០១២។ ប្រទេសកម្ពុជាបានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក(WTO)ក្នុងឆ្នាំ២០០៤ ដែលធ្វើឱ្យកម្ពុជាក្លាយប្រទេសដែលទទួលបានការលើកលែងពន្ធជាច្រើន (MFN) សម្រាប់ការនាំចេញ។ ប្រទេសកម្ពុជាក៏បានទទួលប្រយោជន៍ពីការលើកលែងពន្ធគ្រប់ប្រភេទលើកលែងតែអាវុធ "Everything But Arms (EBA) Initiative" របស់ប្រព័ន្ធលើកលែងពន្ធ (GSP) របស់សហភាពអឺរ៉ុប។ កម្ពុជាបានចូលរួមក្នុងគំនិតផ្តួចផ្តើមសហប្រតិបត្តិការក្នុងតំបន់ អនុតំបន់ និងសកលលោក ដូចជាសហប្រតិបត្តិការជាមួយបណ្តាប្រទេសអាស៊ាន កិច្ចសហប្រតិបត្តិការនៃបណ្តាប្រទេសអឺរ៉ុប និងសហរដ្ឋអាមេរិក។ ក្រោមគំនិតផ្តួចផ្តើមទាំងនេះ ការវិនិយោគបានកើនយ៉ាងច្រើនពីបណ្តាប្រទេសជាសមាជិកអាស៊ាន។

*កំណត់ចំណាំ៖ មានកត្តាជាច្រើនដែលកម្ពុជាមិនអាចធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសដទៃទៀត ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ច។ ឧទាហរណ៍ទីផ្សារភាគហ៊ុន ដែលទើបតែចាប់ដំណើរការពីរឬបីឆ្នាំកន្លងមកប៉ុណ្ណោះទីផ្សារនេះមិនអាចធ្វើពាណិជ្ជកម្មនៅលើទីផ្សារអន្តរជាតិបានទេ លុះត្រាតែក្រុមហ៊ុននិងទីផ្សារក្នុងស្រុកមានភាពចាស់ទុំ។ ផ្ទុយទៅវិញស្ថានភាពរូបិយវត្ថុក៏មានលក្ខណៈស្រដៀងគ្នានេះដែរ។*



សិស្សសាលាជិះកង់កាន់ដៃគ្នាតាមផ្លូវពីសាលាមកផ្ទះ

## ៨.៣. ការបើកចំហរសេដ្ឋកិច្ច

នៅពេលចុះសន្ធិសញ្ញាទីក្រុងប៉ារីសឆ្នាំ១៩៩១ ប្រទេសកម្ពុជាជាប្រទេសតូច សេដ្ឋកិច្ចត្រូវបានហ៊ុំព័ទ្ធខ្ទេចខ្ទាំដោយសង្គ្រាម ហើយសេដ្ឋកិច្ចមានទំហំតូច ដោយស្ថាប័ននៃការគ្រប់គ្រងសេដ្ឋកិច្ច និងអភិបាលកិច្ចត្រូវបានបំផ្លិចបំផ្លាញ។ អ្វីដែលនៅសល់គឺប្រព័ន្ធផែនការប្រមូលផ្តុំសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ច ហើយយុទ្ធសាស្ត្រវិភាជន៍ធនធាន គឺធ្វើឡើងតាមរយៈការត្រួតពិនិត្យនិងបញ្ជាពីរដ្ឋាភិបាលកណ្តាល។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ សេដ្ឋកិច្ចបានបើកចំហភ្លាមៗ រូបិយប័ណ្ណបានអណ្តែត[sic: ង៉ើបឡើង] របបពាណិជ្ជកម្មសេរីបានបង្កើតឡើង (មិនមានច្បាប់គ្រប់គ្រាន់) វិស័យឯកជនត្រូវបានអនុញ្ញាតឱ្យដំណើរការក្នុងបណ្តាវិស័យនានា ហើយអ្នកវិនិយោគបរទេសជាច្រើនបានចូលមកប្រទេសកម្ពុជា។

ពីរទសវត្សរ៍ក្រោយមកប្រទេសកម្ពុជានៅតែតូច ប៉ុន្តែមានសេដ្ឋកិច្ចទីផ្សារនាំចេញ និងបើកចំហជាមួយនឹងកម្រិតកំណើនសេដ្ឋកិច្ចខ្ពស់ក្នុង ផ.ស.ស. ហើយអត្រាប្តូរប្រាក់អនុញ្ញាតឱ្យមានការប្រែប្រួលតាមតម្លៃទីផ្សារ។ ទោះបីសេដ្ឋកិច្ច នៅតែបើកចំហ ប៉ុន្តែច្បាប់ជាច្រើនត្រូវបានបង្កើត និងពង្រឹងបន្ថែម ដែលរួមទាំងច្បាប់ស្តីពីលំហូរចូល និងលំហូរចេញនៃមូលធន ទំនិញ និងសាច់ប្រាក់។

ដូច្នេះ ដើម្បីវាស់វែងពីភាពបើកចំហសេដ្ឋកិច្ចសម្រាប់កម្ពុជា សូចនាករចំនួន២ ត្រូវបានបង្កើត៖

១. សារៈសំខាន់នៃពាណិជ្ជកម្ម -សមាមាត្រការនាំចូល និងការនាំចេញ (ពាណិជ្ជកម្មទៅវិញទៅមក) (ពាណិជ្ជ ធៀបនឹងផ.ស.ស.។

២. ទំហំនៃលំហូរចូលវិនិយោគទុនពីបរទេស - និន្នាការវិនិយោគពីបរទេស។

តារាងទី២.៧៖ សមាមាត្រពាណិជ្ជកម្ម ធៀបនឹងផ.ស.ស. %នៃផ.ស.ស.

| | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ (ប៉ាន់ស្មាន) | ២០១៤ (ព្យាករណ៍) |
|---|---|---|---|---|---|---|---|
| ការនាំចេញទំនិញ (%នៃ ផ.ស.ស.) | ៣៣,៨ | ២៨,៨ | ៣៣,៤ | ៣៦,៨ | ៣៩,២ | ៤១,៧ | ៤៥,០ |
| ការនាំចូលទំនិញ (%នៃ ផ.ស.ស) | ៤៩,១ | ៤៣,២ | ៤៧,០ | ៤៧,៧ | ៤៨,៣ | ៥០,០ | ៥២,៧ |
| (ការនាំចេញ+ការនាំចូល) * 100/GDP (ពាណិជ្ជកម្មទ្វេទិស) | ៨២,៩ | ៧០,០ | ៨០,៤ | ៨៤,៥ | ៨៧,៥ | ៩១,៧ | ៩៧,៧ |

*ប្រភព៖ ក្រសួងផែនការ*

បន្ទាត់ក្រោមគេបង្អស់នៃតារាងទី២.៧ បង្ហាញថា ការប្រទាក់ក្រឡាអន្តរជាតិនៃសេដ្ឋកិច្ចកម្ពុជា ដែលត្រូវបានវាស់វែងដោយសូចនាករជំនួសមួយ "ពាណិជ្ជកម្មទ្វេទិស" មានអត្រាលើសពី៩០% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣។ វិបត្តិសេដ្ឋកិច្ចសកលលោក គឺជាកត្តាចម្បងដែលធ្វើឱ្យការនាំចូល និងការនាំចេញរបស់កម្ពុជាក្នុងឆ្នាំ២០០៩ មានការធ្លាក់ចុះ។

រូបភាពទី២.៣៧ បង្ហាញពី សមាមាត្រនៃវិនិយោគផ្ទាល់ពីក្រៅប្រទេស ធៀបនឹង ផ.ស.ស. បានកើនឡើងរហូតដល់ឆ្នាំ២០០៧ បន្ទាប់មកបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០០៩ ប៉ុន្តែបានកើនឡើងម្តងទៀតក្នុងឆ្នាំ២០១០ ឆ្នាំ២០១១។ នេះគឺជាវដ្តនៃការវិនិយោគ នៅពេលដែលគម្រោងសំណុំត្រូវបានបញ្ចប់ ភាពអន់ថយមួយនឹងកើតមាននៅពេលដែលសំណុំនៃគម្រោងមួយទៀតមិនទាន់ត្រូវបានផ្តួចផ្តើម។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក និងភាពមិនប្រាកដប្រជានៃទីផ្សារអន្តរជាតិ គឺជាមូលហេតុបង្កឱ្យមានផលប៉ះពាល់ដល់លំហូរចូលមូលធន។ ការធ្លាក់ចុះនេះ មិនបណ្តាលឱ្យសេដ្ឋកិច្ចកម្ពុជា រួមតូចនោះទេ។

រូបភាពទី២.៣៦៖ វិនិយោគផ្ទាល់ពីបរទេស នៅកម្ពុជា (ភាគរយនៃ ផ.ស.ស.)




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា*

## ៨.៤. អត្ថប្រយោជន៍នៃបច្ចេកវិទ្យាថ្មី ការភ្ជាប់ទំនាក់ទំនង

រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណងជំរុញការធ្វើទំនើបកម្ម និងលើកកម្ពស់គុណភាពបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍។ ដើម្បីសម្រេចគោលបំណងនេះ រាជរដ្ឋាភិបាលបានអនុវត្តវិធានការកំណែទម្រង់មួយចំនួនដែលលទ្ធផលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសូចនាករមួយចំនួន៖

១. ចំនួននៃទូរស័ព្ទចល័តដែលត្រូវបានទិញ បានកើនឡើងពី៣,៨លានគ្រឿងនៅក្នុងឆ្នាំ២០០៨ ដល់ចំនួនប្រហែល១៩លានគ្រឿងនៅក្នុងឆ្នាំ២០១២ សមមូលទៅ១៣០គ្រឿងត្រូវបានទិញក្នុងមនុស្ស ១០០នាក់និងត្រូវបានគ្របដណ្តប់ប្រមាណជា៩០% នៃតំបន់ទីជុំជន។

២. ចំនួននៃអតិថិជនប្រើប្រាស់សេវាអ៊ិនធឺណិតបានកើនឡើងពី២០.០០០ នៅក្នុងឆ្នាំ២០០៨ ដល់ ២,៧លាននាក់ នៅឆ្នាំ២០១២។

៣. គុណភាពនៃបណ្តាញទូរគមនាគមន៍ និងសេវាត្រូវបានពង្រឹងឥតឈប់ឈរួមជាមួយនឹងការអភិវឌ្ឍបន្តិចម្តងនៃសេវាទូរស័ព្ទអចល័ត។

៤. បណ្តាញ និងការគ្របដណ្តប់សេវាខ្សែកាបអុបទិច បច្ចុប្បន្ននេះបានតភ្ជាប់រាជធានីភ្នំពេញ ជាមួយនឹងបណ្តាក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់ទាំងអស់នៅទូទាំងប្រទេសក៏ដូចជាបណ្តាប្រទេសជិតខាងនៅក្នុងតំបន់។

ភាពជាដៃគូជាមួយវិស័យឯកជនត្រូវបានពង្រឹងដើម្បីពង្រីក និងគ្របដណ្តប់ប្រព័ន្ធផ្សព្វផ្សាយឱ្យស៊ីជម្រៅ តាមរយៈការបំពាក់បច្ចេកវិទ្យា ការកសាងស្ថានីយផ្សាយបន្ថែមទៀតនៅក្នុងខេត្តដែលពាក់ព័ន្ធ ធ្វើឱ្យមានការពាក់ព័ន្ធក្របខណ្ឌអភិបាលកិច្ចវិមជ្ឈការនិងវិសហមជ្ឈការនៅក្នុងបច្ចេកវិទ្យាគមនាគមន៍ព័ត៌មាន ធ្វើឱ្យប្រសើរឡើងសមត្ថភាពមនុស្ស ការបញ្ជ្រាបយេនឌ័រការកសាងសមត្ថភាពសាប័ន និងការលើកទឹកចិត្តជាមួយនឹងច្បាប់ស្តីពីរបបសារពត៌មាន។

## លទ្ធផលដែលសម្រេចបាន បញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

**លទ្ធផលដែលសម្រេចបាន ៖** តាមរយៈការដែលកម្ពុជាបានទទួលហិរញ្ញប្បទានបរទេសជាទៀងទាត់មកពីប្រភពផ្សេងៗគ្នាសម្រាប់រយៈពេល៥-៦ឆ្នាំ កន្លងមកនេះ អាចបង្ហាញថា យុទ្ធសាស្ត្រភាពជាដៃគូរបស់រាជរដ្ឋាភិបាល គឺមានប្រសិទ្ធភាពខ្ពស់។ កម្ពុជាបានបង្កើតឡើង និងដំណើរការនូវស្ថាប័ន ដើម្បីអនុវត្តតាមស្តីពីសេចក្តីប្រកាសទីក្រុងប៉ារីស និងសេចក្តីប្រកាសទីក្រុងអាក្រាស្តីពីប្រសិទ្ធភាពជំនួយ ដែលបានបង្ហាញចាស់ទុំពីមួយថ្ងៃទៅមួយថ្ងៃ។ កម្ពុជាគឺជាប្រទេសមួយដែលមានសេដ្ឋកិច្ចបើកចំហ បានក្លាយជាសមាជិកមួយនៃអង្គការពាណិជ្ជកម្មពិភពលោក នៅក្នុងឆ្នាំ២០០៤។ ក្នុងនាមជាសមាជិកមួយនៃអង្គការពាណិជ្ជកម្មពិភពលោកតម្រូវឱ្យបើកចំហនូវស្ថានភាពនៅក្នុងប្រទេសរបស់ខ្លួនដែលជាលក្ខខណ្ឌមួយមិនមានការរំលោភបំពានរហូតមកដល់បច្ចុប្បន្ន។ ភាពជោគជ័យក្នុងផ្នែកទូរស័ព្ទចល័តបានប្រែក្លាយជារូបភាពការតភ្ជាប់គ្នាគ្រប់កិច្ចការទាំងអស់។

**បញ្ហាប្រឈម ៖** ប្រទេសកម្ពុជានឹងប្រឈមមុខជាមួយបញ្ហានានាស្របគ្នានឹងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅក្នុងឆ្នាំ២០១៥។ បញ្ហាមួយចំនួននឹងអាចប៉ះពាល់ដល់វិស័យឧស្សាហកម្ម និងការងារ និងប្រាក់ចំណូលថវិកាមួយចំនួន។ ក្នុងន័យនេះកម្ពុជាចាកចេញពីឋានៈជាប្រទេសដែលមានចំណូលតិច។ ដូច្នេះ សម្បទានហិរញ្ញប្បទាននឹងមានការធ្លាក់ចុះ ជាមួយគ្នានេះកម្ចីនឹងមានការកើនឡើងខ្ពស់ជាងមុន។



បុរសប្រើប្រាស់ទូរស័ព្ទចល័តដើម្បីទំនាក់ទំនងពេលធ្វើដំណើរត្រឡប់ពីស្រែមកផ្ទះ

**គោលនយោបាយរាជរដ្ឋាភិបាល ៖** រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តោតលើការទាក់ទាញការវិនិយោគពីប្រភពក្នុងស្រុកនិងក្រៅស្រុក សម្រាប់ការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម ការជំរុញការតភ្ជាប់បណ្តាញគមនាគមន៍ដឹកជញ្ជូន និងប្រព័ន្ធឡូជីស្ទិក ការកែលម្អក្របខ័ណ្ឌគតិយុត្តការពង្រឹងយន្តការស្ថាប័ន និងការលើកកម្ពស់សមត្ថភាពដើម្បីធានានូវបរិស្ថានអនុគ្រោះសម្រាប់កិច្ចអភិវឌ្ឍកម្ពុជា។ រាជរដ្ឋាភិបាលនឹងប្តេជ្ញាចិត្តបំពេញតួនាទីរបស់ខ្លួនក្នុងកិច្ចការក្នុងតំបន់ និងអន្តរជាតិដោយដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម សំដៅជំរុញកម្ពុជាឱ្យឈានឡើងមួយកម្រិតទៀត ក្នុងខ្សែចង្វាក់តម្លៃនៃសេដ្ឋកិច្ចក្នុងតំបន់ និងក្នុងពិភពលោក កែលម្អបន្ថែមទៀតនូវក្របខ័ណ្ឌគតិយុត្តសំដៅធ្វើឱ្យប្រសើរការងារធុរកិច្ចពាណិជ្ជកម្ម និងការវិនិយោគ ចាត់វិធានការណ៍ដើម្បីពង្រីកទីផ្សារនាំចេញទំនិញពីកម្ពុជា ចាត់វិធានការណ៍គោលនយោបាយចាំបាច់នានា ដើម្បីចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ ពិសេសតាមរយៈការអនុវត្តដោយប្រសិទ្ធភាព នូវកិច្ចព្រមព្រៀងដែលមានការពាក់ព័ន្ធនឹងអាស៊ាន។

## 9 គោលដៅទី៩ ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងសង្គ្រោះជនរងគ្រោះការវិភាគពីស្ថានភាពមីននៅកម្ពុជា

កម្ពុជាគឺជាប្រទេសមួយដែលផលប៉ះពាល់ដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ រាជរដ្ឋាភិបាលកម្ពុជាបានអះអាងថាការសម្អាតតំបន់ទាំងនេះគឺជាអាទិភាពមួយ និងបានរួមបញ្ចូលជាមួយគោលដៅមួយនៃគ.អ.ស.ក.(គោលដៅទី៩) ក្នុងបញ្ជីនៃគ.អ.ស.ក. នេះ។ ទោះជាដូចនេះក្តី ក្នុងគោលដៅនេះ ពុំត្រូវបានកំណត់ចំណុចដៅ ឬសូចនាករដាក់លាក់នៅក្នុងបញ្ជីទេ។ រាជរដ្ឋាភិបាលកម្ពុជាដោយមានការគាំទ្រពីសហគមន៍អន្តរជាតិបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងរយៈពេល ២០ឆ្នាំ ចុងក្រោយនេះ ដើម្បីលុបបំបាត់គ្រាប់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម។ នៅចន្លោះឆ្នាំ២០០៩ និងឆ្នាំ២០១២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដោយមានការគាំទ្រពីភាគីពាក់ព័ន្ធនឹងសកម្មភាពមីនបានអនុវត្តការអង្កេតមូលដ្ឋានមួយក្នុងស្រុក១២៤ ដែលមានគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះពីសង្គ្រាម។

ចន្លោះពីឆ្នាំ២០០៩ និងឆ្នាំ២០១២ ប្រតិបត្តិករបោសសម្អាតគ្រាប់មីនបានដោះមីន និងសម្អាតដីបាន៤០.៥២៩ហិកតានៃដីមានគ្រាប់មីនសម្រាប់ការប្រើប្រាស់ប្រកបដោយផលិតភាព ការអភិវឌ្ឍវិស័យកសិកម្ម ការតាំងទីលំនៅថ្មីនិងហេដ្ឋារចនាសម្ព័ន្ធ (សាលារៀន មណ្ឌលសុខភាព។



យុវជនកម្ពុជាពិភាក្សាក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនារាជធានីភ្នំពេញ

### ប្រអប់ទី២.១២ គ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ប៉ះពាល់ច្រើនជាងជីវិតរស់នៅនិងប្រាក់ចំណូល

បើទោះបីជាទំនាស់ផ្ទៃក្នុងបាបញ្ចប់ជាងមួយទសវត្សរ៍កន្លងទៅក្ដី ប្រជាជនដែលរស់នៅលើ ឬនៅក្នុងតំបន់ជុំវិញនៃអតីតតំបន់គ្រាប់មីនដែលរងផលប៉ះពាល់នៅតែមានអារម្មណ៍ថាមិនមានសុវត្ថិភាព។ ផលប៉ះពាល់នៃគ្រាប់មីនគឺ មិនមែនតែទៅលើតែរូបវន្តប៉ុណ្ណោះទេ តែក៏មានការប៉ះពាល់ដល់ផ្នែកផ្លូវចិត្តផងដែរ។ ឧទាហរណ៍មនុស្សដែលមានទស្សនៈទូលាយគឺ រស់នៅគ្រាន់តែសម្រាប់ថ្ងៃនេះ ពួកគេមិនមានគម្រោងសាងសង់ផ្ទះមួយឱ្យបានត្រឹមត្រូវ និងមិនខ្វល់អំពីទឹកសុវត្ថិភាព ការអប់រំសម្រាប់កូនរបស់ខ្លួនទេ។

ការរស់នៅក្នុងតំបន់ជុំវិញតំបន់មានគ្រាប់មីនឬលើតំបន់ដែលត្រូវបានជម្រះនៃមីនទាំងនោះនៅតែមានការព្រួយបារម្ភថាមានគ្រាប់មីនប្រឆាំងរថក្រោះជាច្រើនដែលកប់នៅលើដីរបស់ពួកគេ។ ការភ័យខ្លាចរបស់ពួកគេគឺរកមិនឃើញទាំងអស់ទេ គឺជាធាតុសម្រាប់ហេតុផលក្បួនយុទ្ធសាស្ត្រដីមួយចំនួនមិនត្រូវបានជម្រះគ្រាប់មីនទេ នៅក្នុងដីឡូលើកដំបូងប៉ុន្តែមានមនុស្សពុំមានឆន្ទៈដើម្បីរង់ចាំសម្រាប់ការបោសសម្អាតទេ ខណៈពេលដែលពួកគេត្រូវការរកចំណូលដើម្បីការរស់នៅ។ ក្នុងឆ្នាំ២០១០គ្រោះថ្នាក់មួយបានកើតមាននៅទីនេះដែលក្នុងនោះ ១៣ នាក់បានស្លាប់និងម្នាក់បានរងរបួសធ្ងន់ធ្ងរ។

ប្រជាជនបានចាប់ផ្ដើមដាំដំណាំលើដីទាំងនេះក្រោយពីត្រឡប់មកវិញនៅក្នុងឆ្នាំ១៩៩៧ ដោយប្រើវិធីសាស្ត្រធ្វើកសិកម្មតាមបែបប្រពៃណីដ៏សាមញ្ញដែលមិនតម្រូវឱ្យមានការជីកដីជ្រៅទេព្រោះពួកគេភ័យខ្លាចថាពួកគេនឹងប៉ះនឹងគ្រាប់មីនឬសំណល់ជាតិផ្ទុះដែលមិនទាន់ផ្ទុះកប់នៅខាងក្រោម។ វិធីសាស្ត្រនៃការដាំដុះនេះមិនផ្ដល់នូវទិន្នផលច្រើនទេ ហើយប្រាក់ចំណូលរបស់ពួកគេមានកម្រិតទាប។

កម្ពុជា ក៏កំពុងចូលរួមក្នុងបេសកកម្មរបស់អង្គការសហប្រជាជាតិស្ដីពីការបោសសម្អាតមីនវាបានបញ្ជូន២៧៨ បុគ្គលិកបោសសម្អាតមីនទៅប្រទេសស៊ូដង់ និងប្រទេសលីបង់រវាងឆ្នាំ២០១០ និងឆ្នាំ២០១២ ដោយបានចែករំលែកបទពិសោធន៍របស់ខ្លួន នៅក្នុងសកម្មភាពមីនជាមួយនឹង បណ្ដាប្រទេសផ្សេងទៀត ដែលរងផលប៉ះពាល់ដោយគ្រាប់មីននៅក្នុងដី និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។

ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ)។ គ្រោះថ្នាក់ដោយសារគ្រាប់មីនបានថយចុះ។ ការបោសសម្អាតមីនពីដី មានភាពជឿនលឿនពីឆ្នាំ២០០៩ដល់ឆ្នាំ២០១១រួមបញ្ចូលទាំងដីជម្រះនៅខាងក្រៅការអង្កេតធ្វើជាមូលដ្ឋានគោល (BLS) ពហុកោណ។ ការបោសសម្អាតមីនៅក្នុងដី មិនរាប់បញ្ចូលក្នុងឆ្នាំ២០១២ ជម្រះនៅខាងក្រៅការអង្កេតធ្វើជាមូលដ្ឋានគោលពហុកោណ។

កម្ពុជាក៏កំពុងចូលរួមក្នុងបេសកកម្មរបស់អង្គការសហប្រជាជាតិស្ដីពីការបោសសម្អាតមីន ដោយបានបញ្ជូនបុគ្គលិកបោសសម្អាតមីន២៧៨នាក់ទៅប្រទេសស៊ូដង់ និងប្រទេសលីបង់រវាងឆ្នាំ២០១០ និងឆ្នាំ២០១២ ដោយបានចែករំលែកបទពិសោធន៍របស់ខ្លួននៅក្នុងសកម្មភាពមីនជាមួយនឹងបណ្ដាប្រទេសផ្សេងទៀតដែលរងផលប៉ះពាល់ដោយមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។



កំពុងជួសជុលកង់ក្នុងហាងតូចរបស់គាត់។ គាត់ជាទាហានរហូតដល់ឆ្នាំ១៩៨៧ បានបាត់បងជើងម្ខាងដោយសារជាន់មីន

តារាងទី២.៨ វាស់វែងនូវសមិទ្ធផលនានានៅក្នុងស្ថានភាពនៃការកាត់បន្ថយគ្រោះថ្នាក់ និងការបោសសម្អាតគ្រាប់មីនពីក្នុងដី ក្នុងរវាងឆ្នាំ២០០៩ និងឆ្នាំ២០១២។

**តារាងទី២.៨ ៖ ស្ថានភាពនៃការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម**

| សូចនាករ | ឯកតា | គោលដៅ/លទ្ធផល | ២០០៩ | ២០១០ | ២០១១ | ២០១២ |
|---|---|---|---|---|---|---|
| ចំនួននៃជនរងគ្រោះដែលបង្កឡើងដោយគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ( ស្លាប់និងរងរបួស ) | មនុស្ស | ចំណុចដៅ | ២៤៤ | ២៤០ | ២២០ | ២០០ |
| | | លទ្ធផល | ២៤៤ | ២៨៦ | ២១១ | ១៨៦ |
| ផ្ទៃដីដែលមានត្រូវបានសម្អាតគ្រាប់មីនិងសំណល់ជាតិផ្ទុះពីសង្គ្រាម (ចំណុចដៅប្រចាំឆ្នាំ) | ហ.ត | ចំណុចដៅ | ៥ ២៦៨ | ៥ ៣៧៤ | ៥ ៤៨១ | ៥ ៥៩១ |
| | | លទ្ធផល | ៦ ១៣៦ | ១១ ៩៥០ | ១៤ ១៥០ | ៨ ២៩៣ |

*ប្រភព ៖ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន*

## លទ្ធផលដែលសម្រេចបានបញ្ហាប្រឈម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល

**នៅលទ្ធផលដែលសម្រេចបាន៖** អង្កេតមូលដ្ឋានគោលមួយត្រូវបានបញ្ចប់ នៅក្នុងខេត្តសំខាន់ៗទាំងអស់នៃកម្ពុជា ដែលជាកន្លែងដែលទទួលស្គាល់ថាមានគ្រាប់មីន តាមរយៈរបាយការណ៍ឆ្នាំ២០១២។ គិតត្រឹមដំណាច់ឆ្នាំ២០១២ ផ្ទៃដីប្រមាណជា ១៩១,៤៨២ហិកតា ត្រូវបានរកឃើញថា នៅមានបន្សល់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលត្រូវបន្តបោសសម្អាត។

**បញ្ហាប្រឈម ៖** ផ្ទៃដីជាច្រើនផ្សេងទៀត ដែលសង្ស័យថាមានបន្សល់គ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលចាំបាច់ត្រូវធ្វើការស្រាវជ្រាវជាលក្ខណៈប្រព័ន្ធនៅក្នុងឆ្នាំខាងមុខ។ ប្រជាជនដែលកំពុងរស់នៅក្នុងតំបន់បោសសម្អាតមីន រស់នៅដោយភាពភ័យខ្លាច។ ហេតុការណ៍ផ្ទុះដោយចៃដន្យបានកើតមានជារឿយៗ ដែលធ្វើឱ្យការភ័យខ្លាចកាន់តែខ្លាំងឡើងៗ។ ដោយហេតុថា សកម្មភាពបោសសម្អាតមីននៅកម្ពុជា ពឹងផ្អែកទាំងស្រុងលើការផ្តល់ហិរញ្ញប្បទានគាំទ្រពីដៃគូអភិវឌ្ឍ និងថវិកាជាតិ រដ្ឋាភិបាលមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការថយចុះនូវហិរញ្ញប្បទានគាំទ្រពីដៃគូអភិវឌ្ឍចាប់ពីឆ្នាំ២០១១ មក។

**គោលនយោបាយរបស់រាជរដ្ឋាភិបាល ៖** រាជរដ្ឋាភិបាលមានគោលនយោបាយជំហរមួយ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ស្តីពីការបន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១០-២០១៩ ជាពិសេសការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមដែលនៅសល់សម្រាប់ការពង្រីកផ្ទៃដីកសិកម្ម ការធ្វើឱ្យមានសុវត្ថិភាពការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។



កសិករកម្ពុជា ប្រាក់ ជ្រិន កំពុងដាំសណ្តែកបាយលើដីថ្មីរបស់គាត់ដែលទើបតែសំអាត់មីនរួចក្នុងស្រុក សំឡូត ខេត្តបាត់ដំបង

## សង្ខេបភាពជឿនលឿននៃ គ.អ.ស.ក.

| គ.អ.ស.ក. | ការវាយតម្លៃ |
|---|---|
| គោលដៅទី១ ការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ | សម្រេចបានសូចនាករសំខាន់ៗ |
| គោលដៅទី២ សម្រេចឱ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា | ទំនងជានឹងសម្រេចបានសូចនាករសំខាន់ៗ |
| គោលដៅទី៣ ការលើកកម្ពស់សមភាពយេនឌ័រ និងសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | សម្រេចបានសូចនាករសំខាន់ៗ |
| គោលដៅទី៤ កាត់បន្ថយមរណភាពកុមារ | សម្រេចបាន |
| គោលដៅទី៥ លើកកម្ពស់សុខភាពមាតា | សម្រេចបាន |
| គោលដៅទី៦ ប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺឆ្លងផ្សេងៗទៀត | សម្រេចបាន |
| គោលដៅទី៧ ធានាចីរភាពបរិស្ថាន | សម្រេចបានសូចនាករសំខាន់ៗ |
| គោលដៅទី៨ បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ | សម្រេចបាន |
| គោលដៅទី៩ ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងសង្គ្រោះជនរងគ្រោះ | បន្តមានបញ្ហាប្រឈម |




អ្នកដោះមីននៃសកម្មភាពបោសសំអាតមីនកម្ពុជាកំពុងរុករកមីន និងសំណល់មិនទាន់ផ្ទុះក្នុងខេត្តបន្ទាយមានជ័យ

**ជំពូកទី ៣**

# ដំណើរឆ្ពោះទៅមុខ និងក្រោយឆ្នាំ២០១៥

## សេចក្តីផ្តើម

ប្រទេសកម្ពុជា បានសម្រេចនូវកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងរយៈពេល១០-១៥ឆ្នាំកន្លង មកនេះ និងត្រូវបានធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងលុបបំបាត់ភាពក្រីក្រម្ហូបអាហារ។ អភិបាលកិច្ចក៏ត្រូវបានធ្វើឱ្យប្រសើរឡើង ទន្ទឹមនឹងរដ្ឋាភិបាលក៏អាចឆ្លើយតបទៅនឹងវិបត្តិផ្សេងៗ ដូចជាគ្រោះមហន្តរាយគ្រោះធម្មជាតិកាន់តែមានប្រសិទ្ធភាព។ ទោះដូចនេះក្តីកម្ពុជាក៏នៅមានចំណុចខ្វះខាត និងភាពងាយរងគ្រោះមួយចំនួនទៀត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមនៅក្នុងឆ្នាំបន្ទាប់។ ក្នុងចំណោមការព្រួយបារម្ភដែលលេចធ្លោជាងគេ គឺកម្រិតជីវភាពរស់នៅរបស់ប្រជាជនទោះបីជាប្រជាជនជាច្រើនបានឆ្លងកាត់ខ្សែបន្ទាត់ភាពក្រីក្រក៏ដោយ ក៏នៅមានគម្លាតពីកម្រិតជីវភាពរស់នៅរបស់ប្រជាជន ទាំងខាងក្នុង/ខាងក្រៅខេត្ត និងវិសមភាពក្នុងសណ្ឋានផ្សេងទៀតជាច្រើន។ នៅក្នុងបរិការណ៍នៃគ.អ.ស.ក. ភារកិច្ចដែលនៅសល់ជាចម្បង គឺស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ការអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិ ការតាមដានត្រួតពិនិត្យបរិស្ថាន និងការបោសសម្អាតមីន។

ដោយមើលឃើញពីទស្សនវិស័យនៃកិច្ចអភិវឌ្ឍរយៈពេលវែង ការងារភារកិច្ចដែលនឹងត្រូវបន្តអនុវត្ត មានទំហំធំជាងមុន។ ការធានាឱ្យមានកំណើនឆាប់រហ័ស កំណើនប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន គឺជាចំណុចស្នូលនៃតម្រូវការរបស់ប្រជាជន (ជាពិសេសយុវជន) ក្នុងការទទួលបានការងារប្រកបដោយផលិតភាព និងសមរម្យ។ ទាំងអស់នេះ បានធានាដល់ការចែកចាយដោយផ្លែផ្កាដល់ប្រជាជនគោលដៅបានច្រើនជាងមុន។ ការធ្វើឱ្យប្រសើរឡើងមូលធនមនុស្សដើម្បីឈានចូលដល់ដំណាក់ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងការប្រកួតប្រជែងនៅក្នុងតំបន់អាស៊ានមានការកើនឡើង។ គោលនយោបាយអភិវឌ្ឍន៏វិស័យឧស្សាហកម្ម និងគោលនយោបាយកសិកម្ម របស់រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តឱ្យបានយ៉ាងឆាប់រហ័ស ដើម្បីធានាទទួលបានតម្លៃបន្ថែមជាអតិបរមានៅក្នុងប្រទេស។ បណ្តាអាទិភាពក្នុងផ្នែកសង្គមកិច្ច (ការអប់រំ សុខភាព ការគាំពារសង្គម) និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវ អគ្គិសនី និងវិស័យផ្សេងៗទៀត) ទាមទារឱ្យមានការអភិវឌ្ឍជាបន្តទៀត យ៉ាងហោចណាស់រហូតដល់ចាប់ពី១៥ ទៅ២៥ឆ្នាំយ៉ាងតិច។

ជំពូកនេះបង្ហាញពីការគិតគូររបស់រាជរដ្ឋាភិបាលថា តើចំណុចដៅនានានៃគ.អ.ស.ក. និងគោលដៅអភិវឌ្ឍន៍ធំៗផ្សេងទៀតនឹងត្រូវអនុវត្តដោះស្រាយបន្ទាប់ពីឆ្នាំ២០១៥។ ការងារនេះ នឹងត្រូវបន្តអនុវត្តក្នុងភាពជាដៃគូជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ហើយដោយសារតែរាជរដ្ឋាភិបាលនៅមិនទាន់អនុម័តការងារនេះជាគោលនយោបាយរបស់រាជរដ្ឋាភិបាល នៅឡើយ។ ជំពូកនេះ ក៏ដាក់ស្នើសិក្សាឱ្យបានហ្មត់ចត់ពីជម្រើសវិធានការណ៍ពីព្រោះតែការគិតគូរទាំងអស់នេះ គឺប្រហាក់ប្រហែលគ្នានឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ន។ ជំពូកនេះ ក៏បានបង្ហាញពីការសម្រេចបាន គ.អ.ស.ក. ដោយផ្អែកលើការពិភាក្សាយ៉ាងលម្អិតច្រើនលើកច្រើនសារ។

## ១. ការរំពឹងទុកសម្រាប់ពេលអនាគត

### ១.១. សំណើអនុវត្ត

របៀបវារៈ ៖ ដែលបានស្នើឡើងពីដំណើរការដោយឯករាជ្យសម្រាប់ពេលអនាគត មានចំនួន ៤។ អនុសាសន៍មួយចំនួន ក៏ត្រូវបានឆ្លងកាត់ការពិគ្រោះយោបល់ បន្ទាប់មកនឹងត្រូវបានបញ្ចូលក្នុងក្របខ័ណ្ឌ ពន្លឿន។ របៀបវារៈទាំង ៤ នេះ រួមមាន៖



ក្មេងកំពុងរៀននៅសាលាបឋមសិក្សាសហគមន៍-ខេត្តក្រចេះ

**សំណើកម្រិតសកល/ថ្នាក់តំបន់៖** សេចក្ដីស្នើសុំទាំងឡាយមានកំណើតពីក្រុមការងារកម្រិតខ្ពស់ ដែលបានបង្កើតឡើងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ក្នុងសេចក្ដីស្នើសុំនេះ កិច្ចព្រមព្រៀងស្នើរតែពេញលេញមួយ ពីរបៀបវារៈដែលនៅសេសសល់មិនទាន់បានបញ្ចប់នៅក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នោះ ចាំបាច់ត្រូវមានវិធានការណ៍អនុវត្តជាបន្តបន្ទាប់។ ដូច្នេះសេចក្ដីត្រូវការចាំបាច់ គឺបង្កើតឡើងនូវគោលដៅរួមមួយចំនួនដែលប្រទេសទាំងអស់អាចអនុវត្តតាមសម្រាប់ការធ្វើឱ្យមនុស្សកាន់តែប្រសើរ ក្នុងនោះ អភិបាលកិច្ចល្អ សន្តិភាព និងសន្តិសុខ។ ភាពក្រីក្រ និងវិសមភាពនៅតែបន្តបង្កឱ្យមានការរាំងស្ទះហើយការប្រយុទ្ធប្រឆាំងនឹងការរាំងស្ទះទាំងនោះ គឺជាអាទិភាពខ្ពស់បំផុតក្នុងក្របខណ្ឌអភិវឌ្ឍន៍ប្រកបដោយចីរភាព។ លើសពីនេះទៀតការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រីក្នុងវិស័យទាំងអស់នៃជីវិត (សាធារណៈ និងឯកជន) នឹងតម្រូវឱ្យត្រូវអនុវត្តបន្ត។ បម្រែបម្រួលអាកាសធាតុ និងបរិស្ថាន គឺជាអាទិភាពសម្រាប់សង្គ្រោះសម្បត្តិបេតិកភ័ណ្ឌរួមរបស់យើង។ សំណើនេះត្រូវបានដាក់នៅក្នុងសំណុំបែបបទនៃគោលដៅចំនួន ដែលមានបង្ហាញជូននៅក្នុងតារាងទី៣.១។

**ទស្សនៈរបស់ប្រទេសកម្ពុជា៖** ការិយាល័យអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជាបានរៀបចំការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល យុវជន អ្នកដើរតួរក្នុងការផ្លាស់ប្ដូរអាកាសធាតុ វិស័យឯកជន និងតំបន់ជនបទនិងតំបន់ទីប្រជុំជន តាមរយៈការប្រជុំពិភាក្សាជាក្រុមដោយផ្ដោតជាសំខាន់លើកិច្ចប្រជុំតុមូល និងយុទ្ធនាការពហុប្រព័ន្ធផ្សព្វផ្សាយ។ សារចម្បងដែលទទួលបានពីក្រុមប្រជាជនជាង២០០០០នាក់និងបណ្ដាក្រុមអាទិភាពដទៃគឺការពង្រឹងការអប់រំនិងការធ្វើឱ្យប្រសើរឡើងនូវសុខភាព ការសង្គ្រោះបរិស្ថាន និងការបង្កើនកំណើនសេដ្ឋកិច្ច។ សំណុំបែបបទសង្ខេបទាំងនេះ មានបង្ហាញជូននៅក្នុងតារាងទី៣.១។

**គោលនយោបាយរបស់រដ្ឋាភិបាល ៖** គោលនយោបាយចម្បងរបស់រាជរដ្ឋាភិបាល មានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣។ ទោះជាដូចនេះក្ដី ការសង្កត់ធ្ងន់ជាគោលការណ៍និងបន្តសម្រេចឱ្យបាននូវគោលដៅកំណើនសេដ្ឋកិច្ច៧% ក្នុងមួយឆ្នាំនិងកាត់បន្ថយភាពក្រីក្រយ៉ាងហោចណាស់បាន១% ក្នុងមួយឆ្នាំ និងសម្រេចបាននូវគោលដៅផ្សេងទៀតរបស់ គ.អ.ស.ក. ការបង្កើតការងារធ្វើបន្ថែមនិងការពង្រឹងសមត្ថភាពស្ថាប័ន។ ទាំងនេះត្រូវបានដាក់នៅក្នុងតារាងទី៣.១ផងដែរ។

**កិច្ចពិគ្រោះយោបល់រួមគ្នារវាងក្រសួងផែនការ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ៖** ក្រសួងផែនការ បានរៀបចំកិច្ចប្រជុំចំនួនពីរលើក ទាំងកម្រិតបច្ចេកទេស (រវាងរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ) ទាំងកម្រិតនយោបាយ ដើម្បីពិភាក្សាលើសំណើទាំងបីខាងលើ។ ការរកឃើញដោយលម្អិត នឹងបកស្រាយក្នុងតារាងទី៣.១។



ចៅអធិការ ប៊ុន សាលូត និមន្តក្នុងព្រៃសហគមន៍សង្ឃក្នុងខេត្តឧត្តរមានជ័យ



សមាជិកសហគមន៍ឆ្នេរកំពុងដាំដើមកោងកាងដើម្បីអភិរក្សព្រៃឆ្នេរក្នុងខេត្តកោះកុង

តារាងទី២.៩ ៖ បញ្ហាគន្លឹះនិងសំណើសម្រាប់ពេលអនាគត អាចមើលឃើញពីចំណុចចូលចំនួនបួន

| គោលដៅក្រោយឆ្នាំ២០១៥ (គោលដៅសកលរបស់អង្គការសហប្រជាជាតិ ៖ ពេលអនាគតដែលយើងចង់បាន | ការិយាល័យអង្គការសហប្រជាជាតិនៅកម្ពុជា ៖ ការប្រឹក្សាថ្នាក់ជាតិ |
|---|---|
| គោលដៅទី១ ៖ ការបំបាត់ភាពក្រីក្រ<br>គោលដៅទី២ ៖ ផ្ដល់សិទ្ធិអំណាចដល់កុមារីនិងស្ត្រីនិងសម្រេចបាននូវសមភាពយេនឌ័រ<br>គោលដៅទី៣ ៖ ផ្ដល់ការអប់រំដែលមានគុណភាពនិងការសិក្សាពេញមួយជីវិត<br>គោលដៅទី៤ ៖ ធានាការរស់នៅមានសុខភាពល្អ<br>គោលដៅទី៥ ៖ ធានាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភល្អ<br>គោលដៅទី៦ ៖ សម្រេចបាននូវសិទ្ធិទទួលបានជាសកលចំពោះទឹកស្អាតនិងអនាម័យ<br>គោលដៅទី៧ ៖ ធានានូវថាមពលប្រកបដោយចីរភាព<br>គោលដៅទី៨ ៖ បង្កើតការងារ ការចិញ្ចឹមជីវិតប្រកបដោយចីរភាព និងកំណើនប្រកបដោយសមធម៌<br>គោលដៅទី៩ ៖ គ្រប់គ្រងសម្បត្តិធនធានធម្មជាតិប្រកបដោយចីរភាព<br>គោលដៅទី១០ ៖ ធានាអភិបាលកិច្ចល្អនិងស្ថាប័នដែលមានប្រសិទ្ធភាព<br>គោលដៅទី១១ ៖ ធានាស្ថិរភាពសង្គមនិងសន្តិភាព<br>គោលដៅទី១២ ៖ បង្កើតការជំរុញបរិស្ថានជាសកលនិងចលករហិរញ្ញវត្ថុរយៈពេលវែង | **១. យុវជនចង់បាន ៖**<br>ការអប់រំ ការងារ សេដ្ឋកិច្ច បរិស្ថាន សុខភាព អភិបាលកិច្ចល្អ ស្ថិរភាពសង្គមនិងសន្តិសុខ សមភាពយេនឌ័រ និងការចូលរួម សិទ្ធិទទួលបានសេវាអ៊ិនធឺណិត/ការភ្ជាប់<br>**២. ការចង់បានរបស់តួអង្គនៃការផ្លាស់ប្ដូរអាកាសធាតុ ៖**<br>ការទទួលបានចំណេះដឹង ពត៌មាន  អប់រំ មូលធន ការផ្គត់ផ្គង់ទឹកស្អាត និងថាមពល<br>**៣.ការចង់បានរបស់វិស័យឯកជននៅតាមតំបន់ជនបទ និងតំបន់ទីប្រជុំជន ៖**<br>លក្ខខណ្ឌការងារ មុខរបរនិងការងារ អភិបាលកិច្ចល្អ សិទ្ធិទទួលបានការអប់រំ ព័ត៌មាន ចំណេះដឹង បច្ចេកវិទ្យា ហិរញ្ញវត្ថុ ការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព អភិបាលកិច្ចល្អ សមភាពយេនឌ័រ<br>**៤. ការចង់បានរបស់សង្គមស៊ីវិល ៖**<br>ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្នអភិបាលកិច្ច និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន សកម្មភាពលើការផ្លាស់ប្ដូរអាកាសធាតុ និងការវិចវិលបរិស្ថាន សិទ្ធិមនុស្ស និងការអភិវឌ្ឍ ការអភិវឌ្ឍមនុស្ស និងសង្គមប្រកបដោយបរិយាប័ន្នឪណាមិចប្រជាជន។<br><br>*គន្លឹះសំខាន់ ៖ ការអប់រំ ការងារ សុខភាពបរិស្ថាន កំណើនសេដ្ឋកិច្ច* |
| **យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា** | **អនុសាសន៍នានា ផ.យ.អ.ជ / គ.អ.ស.ក ឆ្នាំ២០១៣** |
| ១.សម្រេចបាននូវកំណើនសេដ្ឋកិច្ច ៧% ក្នុងមួយឆ្នាំការកាត់បន្ថយភាពក្រីក្រយ៉ាងហោចណាស់ឱ្យបាន ១%ក្នុងមួយ ឆ្នាំ និងសម្រេចឱ្យបាននូវ គ.អ.ស.ក. ផ្សេងទៀត ការបង្កើតការងារបន្ថែមទៀត និងការពង្រឹងសមត្ថភាពស្ថាប័ន។<br>២.ការលើកកម្ពស់ធនធានមនុស្សតាមរយៈការអប់រំ និងការបណ្ដុះបណ្ដាលបច្ចេកវិទ្យា និងការអភិវឌ្ឍវិទ្យាសាស្ត្រនិងជំនាញបច្ចេកវិទ្យា ធានាការប្រកួតប្រជែងសម្រាប់ការធ្វើសមាហរណកម្មចូលទៅក្នុងទីផ្សារការងារក្នុងតំបន់<br>៣. ការវិនិយោគនៅក្នុងការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត និងការធ្វើឱ្យប្រសើរឡើងនូវការសម្រួលពាណិជ្ជកម្មក្នុងគោលបំណងនៅក្នុងអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនដើម្បីសម្រួលដល់ការតភ្ជាប់គ្នា និងនគរូបនីយកម្មប្រសើរជាងមុន។<br>៤.ការលើកកម្ពស់តម្លៃបន្ថែមក្នុងវិស័យកសិកម្ម (ស្រូវ កៅស៊ូ និងដំណាំផ្សេងទៀត) តាមរយៈការធ្វើ ទំនើបកម្មដំណាំ/ ពាណិជ្ជកម្មនិងការកែច្នៃផលដំណាំ ការលើកកម្ពស់ផលិតកម្មបសុសត្វ និងវារីវប្បកម្ម។<br>៥. ពង្រឹងសមត្ថភាពស្ថាប័ននិងអភិបាលកិច្ចតាមរយៈការបន្តកំណែទម្រង់ច្បាប់ និងតុលាការ និងបន្តលើកកម្ពស់វិមជ្ឈការនិងវិសហមជ្ឈការ បន្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការទាក់ទាញការវិនិយោគក្នុងស្រុក និងបរទេសតាមរយៈមធ្យោបាយខុសៗគ្នា។ | ១. ភាពក្រីក្រ វិសមភាព អាហារូបត្ថម្ភកុមារ និងសន្តិសុខស្បៀង<br>២. អញ្ញាតអន្តរខេត្តលើសូចនាករទាំងអស់<br>៣. ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ និងខ្ពស់ជាង<br>៤. មូលធនមនុស្ស<br>៥. ការទិញយកបច្ចេកវិទ្យា បណ្ដុះបណ្ដាបច្ចេកទេស<br>៦. ព្រៃឈើ បរិស្ថាន និងធនធានធម្មជាតិ<br>៧. ទឹកស្អាតនិងអនាម័យ<br>៨. ការបោសសម្អាតមីន<br>៩. កំណើនយ៉ាងឆាប់រហ័ស ដោយមានបរិយាប័ន្ន និងពិពិធកម្ម<br>១០. ជំរុញ ក្រុមយុវជន "ជួយខ្លួនឯង" ជាមួយជំនួយអន្តរជាតិសម្រាប់ការផ្ដួចផ្ដើមអាជីវកម្មនៅក្នុងវិស័យថាមពលបៃតងការពារបរិស្ថានកសិកម្ម សុខភាព និងវិស័យផ្សេងទៀត<br>១១. ប្រពលវប្បកម្មពលកម្មឧស្សាហូបនីយកម្ម<br>១២. នគរូបនីយកម្ម និងចំណាកស្រុក<br>១៣. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត<br>១៤. ការសម្របសម្រួលឱ្យប្រសើរជាងមុន រវាងក្រសួងនានានិងថ្នាក់ក្រោមជាតិ<br>១៥. តាមដាន និងវាយតម្លៃឱ្យកាន់តែប្រសើរ និងបង្កើតទិន្នន័យ<br>១៦. យេនឌ័រ និងជនជាតិដើមភាគតិច |

## ១.២. វិធីសាស្ត្រសំខាន់ និងឧបសគ្គ

គោលការណ៍រួមដែលកើតឡើងពីកត្តាទាំងនេះ គឺចាំបាច់ត្រូវសមស្រប នឹងការសន្និដ្ឋានលើគោលដៅរបស់គ.អ.ស.ក. សមហេតុផល ហើយលើស ពីនោះ ចាំបាច់លើកកម្ពស់កំណើនប្រកបដោយចីរភាព និងបរិយាប័ន្នធនធាន មនុស្ស (រួមទាំងសុខភាព អប់រំ និងកិច្ចគាំពារសង្គម) ការបង្កើតការងារ បរិស្ថាន និងធនធានធម្មជាតិ អភិបាលកិច្ច ភាពក្រីក្រ វិសមភាព អាហារូបត្ថម្ភ សុខភាព ទឹក និងអនាម័យ និងភាពជាដៃគូជាសកល។ ទោះជាដូចនេះក្តី បណ្តាដំណោះស្រាយ និងបញ្ហារាំងនានាមានបង្ហាញ ក្នុងតារាងទី៣.២។



កសិករកម្ពុជាកំពុងបើកបរត្រាក់ទ័រកសិកម្មក្នុងខេត្តបាត់ដំបង

**តារាងទី៣.០ ៖ វិធីសាស្ត្រនៃការផ្លាស់ប្តូរនិងឧបសគ្គ ៖ កត្តាជះឥទ្ធិពលលើគ.អ.ស.ក.**

| គ.អ.ស.ក. | កម្មវិធីបញ្ហា / កត្តាដែលដាក់កម្រិតនានា |
|---|---|
| កត្តារួមនានា | សន្តិភាពនិងស្ថេរភាព កំណើនយ៉ាងឆាប់រហ័សប្រកបដោយចីរភាព ការប្រែប្រួលអាកាសធាតុមូលធនមនុស្ស អភិបាលកិច្ច ទឹកស្អាតនិងអនាម័យ និងយេនឌ័រ |
| គោលដៅទី ១ | ធារាសាស្ត្រ ចំណាយលើសុខភាព មូលធនមនុស្ស និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ព័ត៌មាន ការដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធទីផ្សារ សិទ្ធិទទួលបានហិរញ្ញវត្ថុមានការប្រាក់សមរម្យ ការវិនិយោគនៅក្នុងសន្តិសុខសង្គម ការផ្តល់សេវា/គណនេយ្យភាពជាសាធារណៈ ការចុះបញ្ជីដីធ្លី មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងបរិស្ថានខាងក្រៅ |
| គោលដៅទី២ | គោលដៅទី១ គោលដៅទី៣គោលដៅទី៧ (ទឹកនិងអនាម័យ)៖<br>ចំនួននៃសាលារៀន និងគ្រឿងបរិក្ខារ គុណភាពនៃការបង្រៀន ចម្ងាយ និងការដឹកជញ្ជូន សន្តិសុខ និងសុវត្ថិភាព ការចំណាយក្រៅផ្លូវការ សុខភាពកុមារ និងការធ្វើផែនការគ្រួសារ និងសមត្ថភាពគ្រូបង្រៀន។ |
| គោលដៅទី៣ | គោលដៅទី១ គោលដៅទី២គោលដៅទី៥ការអប់រំកាន់តែខ្ពស់ ពុទ្ធិផ្អែកលើការអនុវត្តបណ្តុះបណ្តាលវិជ្ជាជីវៈ ជីវិតជំនាញ សមត្ថភាព អន្តេវាសិកដ្ឋាននៅក្នុងសាលារៀន បទប្បញ្ញត្តិច្បាប់ប្រឆាំងនឹងអំពើហិង្សា ការបម្រុងនៅគ្រប់កម្រិតទាំងអស់នៅក្នុងនយោបាយ និងការគ្រប់គ្រងសម្រាប់១៥ឆ្នាំ ការលើកកម្ពស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សម្រាប់ស្ត្រី (ម.អ.ស.) និងសហគ្រិនភាព។ |
| គោលដៅទី៤ និងទី៥ | គោលដៅទី១ គោលដៅទី៧ (ទឹកនិងអនាម័យ) ពុទ្ធិផ្អែកលើការអនុវត្តការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធ ការដឹកជញ្ជូន និងទំនាក់ទំនង ការផ្តល់សេវាសុខភាព តម្លៃសមរម្យ សិទ្ធិទទួលបានការថែទាំសុខភាពកម្រិតទី២ និងទី៣ ថ្នាំបង្ការ ANC/PNC ផែនការគ្រួសារ និងមណ្ឌលសុខភាព។ |
| គោលដៅទី៦ | គោលដៅទី១ គោលដៅទី៤&៥ គោលដៅទី៧ (ទឹកនិងអនាម័យ) ពង្រឹកមូលនិធិសមធម៌ មុងការពារមូស ការលើកកម្ពស់សុខភាពបន្តពូជការជួញដូរមនុស្ស ការទទួលបានព័ត៌មាននិងការអប់រំ តាមដានជំងឺរបេងនិងគ្រុនចាញ់ ការដឹកជញ្ជូននិងការប្រាស្រ័យទាក់ទង ពុទ្ធិផ្អែកលើការអនុវត្តនិងការត្រួតពិនិត្យផលិតផលឱសថ។ |
| គោលដៅទី៧ | គោលដៅទី១ បង្កើនការអប់រំ និងការយល់ដឹងថាមពលកកើតឡើងវិញបែបទំនើបការវិនិយោគរបស់រដ្ឋាភិបាលនៅក្នុងទឹក និងអនាម័យរួមទាំង O&M ការកាប់ឈើខុសច្បាប់ ការអនុវត្តសុរិយោដីសម្បទានដីសេដ្ឋកិច្ច និងការកំណត់ទីតាំងភូមិ។ |
| គោលដៅទី៨ | ប្រសិទ្ធិភាពជំនួយផុសឡើងដៃគូរអភិវឌ្ឍដូចជាប្រទេសចិន និងកូរ៉េជាដើមមានតម្លាភាព និងការចូលរួមរបស់អង្គការសង្គមស៊ីវិលកំណែទម្រង់យឺតអាទិភាពរបស់ដៃគូអភិវឌ្ឍ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកល។ |
| គោលដៅទី៩ | ជំនាញ និងបច្ចេកវិទ្យា ធនធានអាទិភាពរបស់ដៃគូអភិវឌ្ឍ និងការអប់រំ និងការលើកកំពស់ការយល់ដឹង។ |

បណ្តាគោលដៅនៃគ.អ.ស.ក. ត្រូវបានបន្សីគ្នាយ៉ាងល្អ ដែលមានទំនាក់ទំនងនឹងគ្នាពីផ្អែកពីមួយទៅមួយផ្សេងទៀត។ ដូច្នេះបើសិនជាសំណុំណាមួយនៃសកម្មភាពត្រូវបានជំរុញចំណុចរួមគ្នាផ្សេងៗទៀតក៏ត្រូវបានបង្កើតឡើង ដើម្បីសម្រេចបានចំនុចដៅដ៏ទៃនៃ គ.អ.ស.ក.។ ផ្ទុយទៅវិញ បើសិនជាសំណុំណាមួយនៃសកម្មភាពមានឧបសគ្គ នោះសំណុំផ្សេងៗទៀត ក៏ធ្វើឱ្យប៉ះពាល់ដល់ការសម្រេចបាន គ.អ.ស.ក.។

## ២. ក្របខ័ណ្ឌដែលបានស្នើឡើង សម្រាប់ពន្លឿន គ.អ.ស.ក.

ក្របខ័ណ្ឌដែលកំពុងត្រូវបានរៀបចំសំដៅធ្វើជាក្របខ័ណ្ឌពន្លឿនតាមរយៈការផ្តល់អនុសាសន៍ទៅក្នុងវិស័យអាទិភាពចំនួន៧ ដើម្បីពន្លឿនវឌ្ឍនភាពនៃគ.អ.ស.ក. និងគោលដៅការអភិវឌ្ឍមនុស្សផ្សេងទៀត។ ការធ្វើដូចនេះ គឺដោយសារតែក្របខ័ណ្ឌ គ.អ.ស.ក. មិនមែនជាគោលដៅតាមវិស័យ។ ដូច្នេះ អ្នកដែលបង្កើត និងអនុវត្តកម្មវិធីអភិវឌ្ឍន៍ គឺជាសមត្ថកិច្ចរបស់ក្រសួង/មន្ទីរ។ ក្នុងករណីមួយចំនួនក្រសួងតែមួយអនុវត្តគោលដៅច្រើនជាងមួយ ខណៈពេលដែលក្រសួងផ្សេងទៀតអនុវត្តគោលដៅតែមួយតែមានការទទួលខុសត្រូវរួមគ្នារវាងសមត្ថកិច្ចរបស់ក្រសួង/មន្ទីរ។ ឧទាហរណ៍ សុខភាពបន្តពូជ (គោលដៅទី៥) ការទប់ស្កាត់ជំងឺ (គោលដៅទី៦) និងសុខភាពកុមារ (គោលដៅទី៤) គឺជាការទទួលខុសត្រូវដ៏វិសាលភាពធំមួយរបស់ក្រសួងសុខាភិបាល ខណៈពេលដែលគោលដៅទី១ គឺត្រូវបានអនុវត្តរួមគ្នាដោយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទក្រសួងអប់រំយុវជន និងកីឡា ក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ និងក្រសួងសុខាភិបាល និងក្រសួងផ្សេងទៀត។ ដូច្នេះ វិធីសាស្ត្រដ៏ទូលំទូលាយនិងគ្រប់ជ្រុងជ្រោយមួយ គឺចាំបាច់មានបំណងដោះស្រាយរាល់បញ្ហាប្រឈមទាំងអស់។ ក្របខ័ណ្ឌពន្លឿនស្វះស្វែងរកវិធីសាស្ត្រចម្រុះដូចជាការកសាងមូលធនមនុស្ស ការផ្តល់ប្រាក់មានលក្ខខណ្ឌ (conditional cash transfers) ការដាក់ឱ្យមានប្រព័ន្ធការងារថ្មីនិងការលើកកម្ពស់ភាពជាដៃគូសាធារណៈ និងឯកជនសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសង្គម និងទីផ្សារ។ ក្របខ័ណ្ឌពន្លឿនក៏បានផ្តោតលើការចូលរួមមួយចំនួននៃបុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន រួមទាំងផ្លូវថ្នល់និងអគ្គិសនី (ជនបទ) ឱ្យទៅដល់ទីតាំងដែលមានការអភិវឌ្ឍតិចតួច។ ក្របខ័ណ្ឌនេះក៏ផ្តោតលើចីរភាពផងដែរ។ ហើយចុងបញ្ចប់នេះគ្រប់វិធីសាស្ត្រដែលបានស្នើឡើងត្រូវរក្សាទុកថវិកា និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បន្ថែមទៅលើការចូលរួមរបស់ប្រជាជន និងភាពជាម្ចាស់។

អនុសាសន៍ទាំងនេះ គឺស្របគ្នានឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលសំដៅបន្តឆ្ពោះទៅការអនុវត្តយុទ្ធសាស្ត្រតាមវិស័យ និងអនុវត្តកំណែទម្រង់តាមលំដាប់ដើម្បីបន្ធូរបន្ថយឧបសគ្គដែលរាំងស្ទះដល់កំណើនប្រកបដោយបរិយាប័ន្ន និងសមិទ្ធផលគ.អ.ស.ក.។

### ២.១. ការអភិវឌ្ឍមនុស្ស ការអភិវឌ្ឍវិស័យឧស្សាហកម្ម កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការសម្រេចបាន គ.អ.ស.ក.

បន្តពីជំពូកទី២ ការរកឃើញផ្សេងៗទៀតដែលទាក់ទងនឹងភាពក្រីក្រ និងកំណើនគឺ៖

ក) សេដ្ឋកិច្ចកម្ពុជាបានកើនឡើងពីរខ្ទង់ក្នុងអំឡុងពេលឆ្នាំ ២០០៤-២០០៧។ កំណើនបានបន្តកើនឡើងវិញយ៉ាងឆាប់បន្ទាប់ពីមានការធ្លាក់ចុះហើយកំណើននេះបានចូលរួមយ៉ាងសំខាន់នៅក្នុងការកាត់បន្ថយភាពក្រីក្រ។

ខ) កំណើននេះបានជួយដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើតការងារ។ ឧទាហរណ៍ វិស័យកសិកម្ម វិស័យកាត់ដេរ សំណង់ និងវិស័យទេសចរណ៍គឺទាំងអស់ពឹងផ្អែកលើកម្លាំងពលកម្ម។ ការផ្ទេរកម្មករយ៉ាងឆាប់រហ័សតាមអន្តរវិស័យនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះជួយគាំទ្រដល់កំណើន និងកាត់បន្ថយភាពក្រីក្រនេះ។

គ) ក្នុងឆ្នាំ២០០៨ តម្លៃស្បៀងអាហារបានកើនឡើងនៅទូទាំងពិភពលោក ហើយកសិករភាគច្រើនគឺជាអ្នកលក់ម្ហូបអាហារ ដូច្នេះពួកគាត់បានទទួលផលចំណេញពីការកើនឡើងតម្លៃនេះ។ មានមនុស្សតិចតួចប៉ុណ្ណោះជាអ្នកទិញម្ហូបអាហារសុទ្ធពីកសិករ ។ ផលចំណេញនេះ បានធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត។ សម្បទានដីសង្គមកិច្ចក៏បានចូលរួមចំណែកផងដែរ។

ឃ) ជនចំណាកស្រុកពីភូមិ បានកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប្រជាជនវ័យក្មេងមានជម្រើសបំលាស់ទីពីតំបន់ដែលមានផលិតភាពទាបទៅតំបន់ដែលមានផលិតភាពខ្ពស់ជាង ហើយការផ្លាស់ប្តូរទីលំនៅ/ការងារនេះ កំពុងជួយបង្កើនប្រាក់ឈ្នួល/ចំណូល និងកាត់បន្ថយភាពក្រីក្រ។

ង) និន្នាការធ្លាក់ចុះនៃវិសមភាពលទ្ធភាពចំណាយ គឺជាហេតុផលដ៏សំខាន់មួយ នៅក្នុងការកាត់បន្ថយអត្រាភាពក្រីក្រ។

ច) ផលចំណេញទាំងពីរ ទាំងនៅក្នុងវិស័យអប់រំ និងសុខភាពជួយពង្រឹងចំណុច (ក) និង (ង) បន្ថែមលើការអភិវឌ្ឍរចនាសម្ព័ន្ធខាងលើ។

ដូច្នេះ បណ្តាចំណុចខាងក្រោមនេះ អាចជាកត្តាគន្លឹះសម្រាប់ការទ្រទ្រង់កំណើនក្នុងការបង្កើតការងារប្រកបដោយចីរភាព។

ក. ការអភិវឌ្ឍយុទ្ធសាស្ត្រជំរុញមូលធនមនុស្ស។

ខ. ការបញ្ចប់ និងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មសម្រាប់ការលើកកម្ពស់ការបង្កើតការងារបន្ថែមទៀតក្នុងសកម្មភាពមិនមែនជាកសិកម្ម។

គ. ការបង្កើតលក្ខខណ្ឌសម្រាប់ការបង្កើនផលិតភាពកសិកម្ម/ជនបទនិងប្រាក់ចំណូលនៅតាមតំបន់ជនបទ។

ឃ. ការបង្កើតសមត្ថភាព ដើម្បីបង្កើតបណ្តាញថាមពលឱ្យមានចីរភាព ការសាងសង់/ការជួសជុល

តារាងទី៣.១ ៖ ផែនការគោលនយោបាយ យុទ្ធសាស្ត្រ និងឧបករណ៍បង្កើនល្បឿន កំណើនប្រកបដោយចីរភាពនិងបរិយាប័ន្នដើម្បីការកាត់បន្ថយភាពក្រីក្រ (ក្របខ័ណ្ឌពន្លឿនទី១)

| ការសម្រេចគោលដៅទី១ គោលដៅទី២ គោលដៅទី៣ | | | | | |
|---|---|---|---|---|---|
| ចំណុចដៅ | បង្កើនចំនួនការងារដែលបានបង្កើត | | ការអប់រំគ្រប់គ្រាន់ និងមានជំនាញក្នុងការធានាឱ្យមានការងារធ្វើរបស់ប្រជាជន | | ធានាការចែករំលែកនូវផលផល និងការទទួលបាននូវសេវាគន្លឹះដ៏សំខាន់ឆ្ពោះទៅរកសមធម៌ភាគច្រើន |
| ឧបករណ៍បង្កើនល្បឿន | ការវិនិយោគនៅក្នុងវិស័យពឹងផ្អែកលើកម្លាំងពលកម្ម (រួមបញ្ចូលទាំងការធ្វើពាណិជ្ជកម្ម) | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរួមទាំងនៅក្នុងតំបន់ជនបទដាច់ស្រយាល(ផ្តោតលើផ្លូវ និងថាមពល) | កម្មករដែលចេះអក្សរ មានជំនាញ និងមានសុខភាពល្អ | អភិបាលកិច្ចល្អ និងអាចទស្សន៍ទាយបាន | ការចល័តពលករ និងការធ្វើនគរូបនីយកម្ម |
| គោលនយោបាយ | ការបង្កើនចំណូលថវិការដ្ឋ និងការបែងចែកទៅជាវិស័យអាទិភាព និងការចំណាយរបប | ការបង្កើនមូលធនមនុស្ស និងការអភិវឌ្ឍជំនាញ | ការវិនិយោគសាធារណៈក្នុងការបង្កើនហេដ្ឋារចនាសម្ព័ន្ធ | គោលនយោបាយគាំទ្រកំណើនសេដ្ឋកិច្ច និងការបង្កើតមជ្ឈមណ្ឌលកំណើន គោលនយោបាយនគរូបនីយកម្ម៖ វិមជ្ឈការនិងការពង្រឹងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ | ការកែលម្អប្រព័ន្ធតាមដាន និងវាយតម្លៃថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានស្រាប់ |
| យុទ្ធសាស្ត្រ | ពង្រីកសាលារៀនបឋមភូមិការអប់រំឧត្តមសិក្សា ការអប់រំបណ្តុះបណ្តាលសម្រាប់មុខរបរនិងការងារ កម្មវិធីក្រុមគោលដៅ និងពង្រីកទឹក/អនាម័យ | ឈានទៀងមួយជំហានទៀតលើវិស័យ អគ្គិសនី ការទំនាក់ទំនង ប្រព័ន្ធធារាសាស្ត្រ ផ្លូវជនបទ ឧស្សាហូបនីយកម្ម ហិរញ្ញវត្ថុ និងពិពិធកម្មវិស័យពាណិជ្ជកម្ម និងការប្រកួតប្រជែង | បង្កើនល្បឿនការចាត់តាំងមុខងារ /ត្រិភូនៃសិទ្ធិអំណាចដល់ស្ថាប័នរដ្ឋាភិបាលថ្នាក់ក្រោមជាតិ | ការអភិវឌ្ឍយុទ្ធសាស្ត្ររសើបទាក់ទងភាពងាយរងគ្រោះ / ភាពក្រីក្រដែលត្រូវធ្វើតាមបរិការណ៍ភូមិសាស្ត្រ និងទឹកដីជាក់លាក់ | ពង្រឹងមូលដ្ឋានទិន្នន័យ និងការប្រមូលទិន្នន័យសង្គម និងសេដ្ឋកិច្ច និងការបកស្រាយជាពិសេសនៅគ្រប់កម្រិតតាមបែបវិមជ្ឈការតាមរយៈយន្តការវិមជ្ឈការ និងវិសហមជ្ឈការ |



កសិករកម្ពុជា លឹម សារឿន ប្រមូលផលស្រូវនាពេលច្រូតកាត់-ខេត្តតាកែវ

## ២.២. ការអនុវត្តប្រកបដោយចីរភាពសម្រាប់ធ្វើឱ្យប្រសើរឡើងសន្តិសុខស្បៀង និងចីរភាពបរិស្ថាន

ប្រជាជនដែលងាយរងគ្រោះប្រមាណ១៩-២០% កំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ ការបែងចែកនៃចំណាយសម្រាប់មនុស្សម្នាក់ក្នុងមួយខែបង្ហាញថាយ៉ាងហោចណាស់ប្រជាជនប្រហែលជា ៣០% អាចប្រឈមមុខនឹងភាពងាយរងគ្រោះដោយគ្រោះរាំងស្ងួត ទឹកជំនន់ ឬព្រឹត្តិការណ៍ធម្មជាតិឬដោយទង្វើរបស់មនុស្ស។ ដូច្នេះ យុទ្ធសាស្ត្រដែលផ្តោតតែលើកំណើនអាចនឹងមិនគ្រប់គ្រាន់នោះទេ។ ការសម្រេចបានវឌ្ឍនភាពក៏រួមបញ្ចូលនូវកម្រិតជីវភាពរស់នៅ/ទ្រព្យសម្បត្តិ អប់រំសុខាភិបាល ទឹកនិងអនាម័យ ឬកត្តាផ្សេងទៀត។ វឌ្ឍនភាពក៏មានការប្រែប្រួលទៅតាមខេត្តនីមួយៗដែលគួរតែរិះរកវិធីសាស្ត្រកំណត់ចំណុចដៅបន្ថែមទៀត។ ជាក់ស្តែង ខេត្តសៀមរាបនិងខេត្តបាត់ដំបង ក្នុងចំណោមបណ្តាខេត្តផ្សេងទៀតមានភាពក្រីក្រខ្ពស់ជាងគេ។ ដូច្នេះ សេចក្តីត្រូវការចាំបាច់គឺឱ្យជនក្រីក្រនិងជនងាយរងគ្រោះក្លាយជាដៃគូដោយផ្ទាល់ក្នុងការអភិវឌ្ឍ។ ទន្ទឹមនឹងនេះ ពួកគាត់នឹងក្លាយជាដៃគូក្នុងការចែកចាយនូវផលចំណេញផងដែរ ជាជាងគ្រាន់ជាអ្នកទទួលនូវកម្មវិធីជំនួយ។ លើសពីនេះទៀតកង្វះអាហារូបត្ថម្ភរបស់កុមារនិងស្ត្រីមានជំងឺស្លេកសាំង នៅតែជាបញ្ហាចម្បង។

ជាតុផ្សំគោលនយោបាយចំនួនពីរគឺផ្តល់សិទ្ធិអំណាចដល់ជនក្រីក្រ ដើម្បីក្លាយជាដៃគូស្មើភាពគ្នាក្នុងការអភិវឌ្ឍ និងដើម្បីអនុវត្តការផ្ទេរធនធានសម្រាប់ការលើកកម្ពស់ស្ថានភាពសុខភាពរបស់កុមារនិងស្ត្រី។ គោលនយោបាយដ៏ទូលំទូលាយចំនួនបួន ឆ្លើយតបនឹងគោលគំនិតខាងលើ រួមមាន៖

១. ការផ្តល់ធនធានផលិតភាព ដើម្បីជនក្រីក្រនៅតំបន់ជនបទតាមរយៈការចែកចាយដីសម្បទានសង្គមកិច្ច ជាពិសេសនៅតាមបណ្តាខេត្ត គោលដៅ ការកែលម្អ និងការធ្វើពិពិធកម្មការអនុវត្តកសិកម្មជាពិសេសពិពិធកម្មដំណាំ (ខុសពីស្រូវ) ដំណាំដែលធន់ទ្រាំនឹងគ្រោះរាំងស្ងួត ជលផល (ទាំងតំបន់កោះ និងសមុទ្រ) សត្វចិញ្ចឹម ជាថ្មីម្តងទៀតជាមួយនឹងការសង្កត់ធ្ងន់លើបណ្តាខេត្តគោលដៅ ការលើកកម្ពស់វិធីសាស្ត្រមួយជា 'ប្រព័ន្ធដាំដុះ'។

២. ការជួយផ្តួចផ្តើមប្រជាជនតាមជនបទ (មូលដ្ឋានផ្ទះ) សកម្មភាពដែលមិនមែនជាកសិកម្មនៅក្នុងការកែច្នៃម្ហូបអាហារ/កសិផល។

៣. ការផ្តល់ជាតុចូលពីមីក្រូសារជាតិ ជាពិសេសដល់កុមារនិងស្ត្រីដើម្បីកាត់បន្ថយភាពក្រិន និងកុមារកង្វះទម្ងន់ និងកាត់បន្ថយភាពស្លេកស្លាំងរបស់កុមារ និងស្ត្រី។

៤. ការពង្រីកសុវត្ថិភាពទឹក និងអនាម័យដល់ជនក្រីក្រនិងជន ដែលនៅក្នុងតំបន់ដាច់ស្រយាល។

តារាងទី៣.២ ៖ គោលនយោបាយ យុទ្ធសាស្ត្រនិងឧបករណ៍បង្កើនល្បឿនកំណើនដែលមានលក្ខណៈបរិយាប័ន្ន និង ប្រកបដោយចីរភាព ដើម្បីគោលនយោបាយកាត់បន្ថយភាពក្រីក្រ នឹងគាំទ្រដល់ជនក្រីក្រជាក់លាក់ (ក្របខ័ណ្ឌពន្លឿនទី២)

<table>
<tr><th colspan="7">គោលដៅដែលបម្រើឱ្យ គោលដៅទី១ និង គោលដៅទី៧</th></tr>
<tr><td>ចំណុចដៅ</td><td colspan="3">បង្កើនលទ្ធភាពទទួលបាននិងភាពជាម្ចាស់នៃធនធានក្នុងស្រុកដោយជនក្រីក្រ និងអ្នកដែលមានប្រាក់ចំណូលទាប ធ្វើដូច្នេះ ជនក្រីក្រអាចចូលរួមប្រសើរជាងមុន ក្នុងដំណើរការអភិវឌ្ឍន៍</td><td colspan="3">ជនក្រីក្រទទួលបានការចែករំលែកដោយយុត្តិធម៌នៅក្នុងការចែកចាយនៃសមិទ្ធផល</td></tr>
<tr><td>ឧបករណ៍បង្កើនល្បឿន</td><td colspan="2">ការកើនឡើងដីសម្បទានសង្គមកិច្ច ធនធានសាធារណៈបន្ថែមទៀត ដែលបានបម្រុងទុក សម្រាប់វិស័យគាំទ្រជនក្រីក្រ ទស្សនវិស័យគាំទ្រជនក្រីក្រនៅក្នុងគោលនយោបាយ</td><td>ការផ្តល់សេវាវប្បកម្មកសិដ្ឋានដើម្បីលើកកម្ពស់អត្រាទិន្នផលជម្រើសនៅក្នុងការងារ មិនមែនកសិកម្ម/ការងារតាមរដូវ ជម្រើសការធ្វើចំណាកស្រុកប្រកបដោយចីរភាពនិងមានសុវត្ថិភាពតាមបណ្តាខេត្តផ្សេងៗ ឬប្រទេសពលកម្មផ្សេងៗ វិធីសាស្ត្រប្រព័ន្ធកសិកម្មសរីរាង្គដែលបានអភិវឌ្ឍសម្រាប់សកម្មភាពពេញមួយឆ្នាំ</td><td colspan="2">ការអភិវឌ្ឍទឹកនិងអនាម័យ សិទ្ធិទទួលបានអាហារូបត្ថម្ភទូលំទូលាយ</td><td>ព័ត៌មានត្រឹមត្រូវឈរមូលដ្ឋាន ភូមិសាស្ត្រនៃធនធាន និងភូមិសាស្ត្រមនុស្សសាស្ត្រ</td></tr>
<tr><td>គោលនយោបាយ</td><td colspan="2">ឈានមួយជំហានទៀតលើការអនុវត្តសុរិយោដី ដើម្បីកំណត់ពីតម្រូវការដីលើសដែលអាចបង្កបង្កើនផល( និងធនធានផ្សេងទៀត )ដែលមានស្រាប់មានប៉ុន្មាន</td><td>ជំរុញឱ្យមានការផ្តល់សេវាប្រពលវប្បកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ននិងពេលអនាគត រួមទាំង ការបណ្តុះបណ្តាលពលករ ផ្តល់នូវធនធាន O&M ទៅមជ្ឈមណ្ឌលប្រពលវប្បកម្មដាំដុះនានា</td><td colspan="2">សកម្មភាពកំណត់ទីតាំងជាក់លាក់នៅក្នុងវិស័យក្រៅពីកសិកម្ម</td><td>លើកទឹកចិត្តដល់ការវិនិយោគនៅក្នុង ទឹកនិងអនាម័យ និងការចំណាយលើអាហាររូបត្ថម្ភ</td></tr>
<tr><td>យុទ្ធសាស្ត្រ១</td><td>ធានាបាននូវការចុះបញ្ជីដីប្រកបដោយសុវត្ថិភាព ការចែកចាយចលនទ្រព្យដីនិងផ្សេងទៀតចំពោះក្រុមគោលដៅ</td><td>ធានាបាននូវការផ្តល់សេវាប្រពលវប្បកម្ម, ទស្សនាការបង្ហាញពីប្រភេទ T&Vវិធីសាស្ត្រធ្វើប្រព័ន្ធកសិកម្មដែលមានទីតាំងជាក់លាក់ និងការចែកចាយ ឧបត្ថម្ភធននៃគ្រាប់ពូជHYV</td><td>ធានាបាននូវសិទ្ធិទទួលបាននូវប្រាក់កម្ចីដល់កសិករសម្រាប់ជាធាតុចូល កសិក និងបរិក្ខារសាមញ្ញ និងអណ្តូងឯកជន</td><td>ផ្តល់ការបណ្តុះបណ្តាកសិករជាជំនាញសម្រាប់កសិដ្ឋាននិងការងារមិនមែនកសិកម្ម</td><td>លើកកម្ពស់ជម្រើសម្ហូបអាហារ/ កសិផលិតផល អភិវឌ្ឍគំរូអាជីវកម្មសម្រាប់សហគ្រាសធុនតូច និងផ្តួចផ្តើមគម្រោងសាកល្បង (កម្មវិធីតាមច្រកតាមរយៈយន្តការវិមជ្ឈការ និងសហមជ្ឈការ)</td><td>វិនិយោគ ទឹកនិងអនាម័យនៅក្នុងតំបន់ដាច់ស្រយាល និងផ្តល់នូវអាហារូបត្ថម្ភខ្នាតតូចបន្ថែមតាមរយៈមជ្ឈមណ្ឌលសុខភាព និងសាលារៀន</td></tr>
<tr><td>យុទ្ធសាស្ត្រ ២</td><td colspan="3">ការសង្កត់ធ្ងន់ជាពិសេសឱ្យសមស្របនឹងទីតាំងជាក់លាក់ ឧទាហរណ៍ ជនជាតិភាគតិច ប្រភេទនៃដំណាំដាំដុះមានលក្ខណៈបែបប្រពៃណីនិងតំបន់មានមីន។ល។</td><td colspan="3">ការសង្កត់ធ្ងន់ជាពិសេស៖ កំណត់គោលដៅជនក្រីក្រនិងស្ត្រី / ស្ត្រីមេគ្រួសារ</td></tr>
</table>

## ២.៣. មូលធនមនុស្សសម្រាប់ការអភិវឌ្ឍមនុស្សជាមួយសមធម៌យេនឌ័រ

កុមារមួយចំនួនធំ បញ្ឈប់ការសិក្សារបស់ខ្លួន បន្ទាប់ពីការបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា។ ប្រមាណជាមួយភាគប្រាំនៃកុមារស្ថិតនៅក្នុងក្រុមអាយុពី ៦ ទៅ ១៧ឆ្នាំបានឈប់រៀន។ ក្នុងចំណោមមូលហេតុនានាដែលធ្វើឱ្យកុមារទាំងនោះបោះបង់ចោលការសិក្សាគឺ ការមិនមានសាលាមធ្យមសិក្សាបឋមភូមិ ការចំណាយពាក់ព័ន្ធនឹងការសិក្សា តម្រូវការពលកម្មសម្រាប់កុមារ (ជីវភាពរស់នៅទាបផ្ទាល់ខ្លួនរបស់កុមារ) និងដែលជាយល់ឃើញថាផលត្រឡប់មកវិញទាប បើសិក្សាលើសពីកម្រិតសាលាបឋមសិក្សា។ លើសពីនេះទៅទៀត គុណភាពនៃការអប់រំ ចាំបាច់ត្រូវលើកកម្ពស់នៅគ្រប់កម្រិតសិក្សាទាំងអស់។

ប្រទេសកម្ពុជាមានគោលបំណងឆ្ពោះទៅរកសេដ្ឋកិច្ចឧស្សាហកម្ម ដែលតម្រូវការដ៏សំខាន់មួយនោះ គឺមូលធនមនុស្ស។ នេះមានន័យថា មូលធនមនុស្សនឹងត្រូវការលើសពីកម្រិតបឋមសិក្សា ឬកម្រិតមធ្យមសិក្សាបឋមភូមិ ឆ្ពោះទៅកាន់ការងារជំនាញបច្ចេកទេស វិទ្យាសាស្ត្រ វិស្វកម្ម ស្ថាបត្យកម្ម ភូគពសាស្ត្រ និងផ្សេងទៀត។

ក្នុងចំណោមគោលនយោបាយដែលរដ្ឋាភិបាលអាចអនុវត្ត រួមមាន៖

ក. នៅក្នុងកម្រិតគោលនយោបាយមួយការបង្កើនសមាមាត្រចំណាយរបស់រដ្ឋលើវិស័យអប់រំឱ្យបានហួសពីបច្ចុប្បន្ន គឺពីកម្រិតតិចជាង ៣% ឱ្យបានដល់កម្រិតមួយខ្ពស់។ កំណើននេះនឹងផ្តល់នូវអានុភាពដើម្បីកំណត់អាទិភាពមួយចំនួន។ នៅក្នុងលក្ខខណ្ឌនៃអាទិភាពដើម្បីពង្រីកធនធានទាំងនេះ គឺតម្រូវឱ្យមានសាលាមធ្យមសិក្សាបឋមភូមិ (និងសាលារៀនកម្រិតខ្ពស់ជាង) ជាច្រើនទៀត។ លើសពីនេះទៀត តម្រូវការចាំបាច់មួយដើម្បីពង្រឹងការអប់រំដោយឥតគិតថ្លៃពិតប្រាកដមួយ គឺគ្មានថ្លៃចំណាយក្រៅផ្លូវការ។ ការកំណត់គោលដៅសម្រាប់បណ្តាខេត្តនានា ដែលនៅដាច់ស្រយាល និងការផ្តល់ផងដែរនូវអាហារូបករណ៍ដល់ជនងាយរងគ្រោះ និងអ្នកទីទាល់ក្រគឺជាជម្រើសអាទិភាព។ លើសពីកម្រិតបឋមសិក្សា/អនុវិទ្យាល័យចំបាច់ត្រូវពង្រឹងការអប់រំផ្នែកបច្ចេកទេសនិងឧត្តមសិក្សា សម្រាប់ការលើកកម្ពស់គុណភាពនៃមូលធនមនុស្ស។

ខ. ការកែលម្អគុណភាពនិងប្រសិទ្ធភាពនៃការអប់រំ ការអប់រំគ្រូ ការធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្របង្រៀនមុខវិជ្ជាគណិតវិទ្យានិងវិភាគ និងមុខវិជ្ជាផ្សេងទៀត។ ក្នុងចំណោមជម្រើសទាំងនេះ ការផ្តួចផ្តើមពិនិត្យទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ ដើម្បីពង្រឹងគុណភាព គឺជាការចាំបាច់។

គ. ធានាលទ្ធភាពទទួលបានស្មើគ្នារបស់កុមារីនិងស្ត្រីគ្រប់កម្រិតទាំងអស់នៃការអប់រំ។

តារាងទី៣.៣ ៖ គោលនយោបាយយុទ្ធសាស្ត្រ និងឧបករណ៍បង្កើនល្បឿន មូលធនមនុស្សសម្រាប់ការអភិវឌ្ឍមនុស្ស(ក្របខ័ណ្ឌពន្លឿនទី៣)

<table>
<tr><th colspan="6">គោលដៅដែលបម្រើឱ្យគោលដៅទី១ គោលដៅទី២ និងគោលដៅទី៣</th></tr>
<tr><td>ចំណុចដៅ</td><td colspan="3">ប្រជាជនកម្ពុជាភាគច្រើន (រាប់ទាំងស្ត្រី) ត្រូវបានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងត្រូវបានរកឃើញថាជាការងារដែលផ្តល់ប្រាក់កម្រៃខ្ពស់ជាងនៅគ្រប់កម្រិត</td><td colspan="2">បច្ចេកវិទ្យាទទួលយកកម្លាំងពលកម្មនៅកម្ពុជា ទាំងជនជាតិដើមភាគតិចមានសមត្ថភាពក្នុងការយល់ដឹង និងប្រើប្រាស់បច្ចេកវិទ្យាទាំងនោះបាន</td></tr>
<tr><td>ឧបករណ៍បង្កើនល្បឿន</td><td>ការវិនិយោគសាធារណៈកាន់តែច្រើនឡើងនៅក្នុងធនធានមនុស្ស</td><td colspan="2">គោលនយោបាយ ជំនាញមនុស្ស/អំណាច ច្បាស់លាស់មួយក្នុងភាពជាដៃគូជាមួយសាធារណៈនិងឯកជន</td><td colspan="2">ការបង្កើនតម្រូវការពីគ្រួសារសម្រាប់វិស័យអប់រំតាមរយៈការអនុវត្តក្របខណ្ឌបង្កើនល្បឿនទី១និងទី២និងការតស៊ូមតិដោយផ្ទាល់</td></tr>
<tr><td>គោលនយោបាយ</td><td>គោលនយោបាយ ជំនាញ/អំណាចមនុស្សច្បាស់លាស់មួយដោយផ្អែកលើការវាយតម្លៃលើតម្រូវការជាក់លាក់មួយនិងត្រូវការតាមប្រភេទនិងតាមតំបន់</td><td colspan="2">លើកកំពស់គុណភាពអប់រំពង្រីកការសិក្សាអប់រំបច្ចេកទេស និងបង្កើតការបញ្ជ្រាបអប់រំ ផ្អែកតាមតម្រូវការ(នាពេលអនាគត)</td><td colspan="2">រៀបចំវេទិការៀបចំផែនការរួមគ្នារវាងក្រសួងមហាផ្ទៃក្រសួងអ.យ.ក. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកិច្ចការនារី និងក្រសួងផែនការសម្រាប់ការរៀបចំផែនការសំរាប់ការអភិវឌ្ឍធនធានមនុស្ស និងស្វែងរកការចូលរួមរបស់វិស័យឯកជន</td></tr>
<tr><td>យុទ្ធសាស្ត្រទី១</td><td>វាយតម្លៃតម្រូវការមូលធនមនុស្សតាមប្រភេទនិងតំបន់ដោយផ្អែកលើប្រជាសាស្ត្រនិងបង្កើតឡើងនូវស្ថាប័នសាធារណៈកើនឡើង បង្កើតឡើងនូវស្ថាប័នបឋមភូមិតាមតម្រូវការសាកល្បងចង្កោមសាលារៀនសាលារៀនពហុថ្នាក់ កំណត់ឡើងនូវស្ថាប័នបច្ចេកទេសបន្ថែមទៀតនៅគ្រប់កម្រិតឧត្តមសិក្សា ធ្វើឱ្យពេញនិយមនៃស្ថានប័នមិនផ្លូវការ សម្រាប់អក្ខរកម្មយុវជន និងលើកកម្ពស់សង្គមឱ្យរៀនវិទ្យាសាស្ត្រ</td><td>កំពស់ការចំណាយ O&Mរបស់សាលាសម្រាប់ធ្វើឱ្យសាលារៀន 'ពេញលេញ' (រួមទាំងទឹកនិងបង្គន់) ដូច្នេះកុមារលើកគ្មានការចំណាយកើតឡើងរហូតដល់ថ្នាក់ទី៩</td><td>ការចូលរួមរបស់និយោជកនិងដៃគូអភិវឌ្ឍ សម្រាប់កសាងផែនការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងអភិវឌ្ឍន៍ធនធានមនុស្សទូលំទូលាយ រៀបចំសាលាគំរូ មួយ(ល្អជាងគេ)<br>- នៅក្នុងខេត្តនីមួយៗ លើមូលដ្ឋានសាកល្បង សាកលវិទ្យាល័យបច្ចេកទេសមួយ(ដោយមានជំនួយពីខាងក្រៅ)និងពិនិត្យការបង្កើតវិទ្យាស្ថានមួយសម្រាប់ការរៀបចំផែនការអប់រំ</td><td>អាហារូបករណ៍សប្បុរសសម្រាប់អ្នកដែលសមនឹងទទួល និងបម្រើចំពោះអ្នកត្រូវការចាំបាច់កម្មវិធីផ្តល់អាហារសាលា ពិសេសផ្តោតជាសំខាន់នៅលើស្ត្រី</td><td>គ្រូវគ្គបណ្តុះបណ្តាលជំនាញគណិតវិទ្យាជំនាញក្នុងវិធីសាស្ត្រវិភាគផ្តល់នូវការលើកទឹកចិត្តដល់គ្រូកែលម្អវគ្គនិងការវាយតម្លៃ</td></tr>
<tr><td>យុទ្ធសាស្ត្រទី២</td><td colspan="2">ការសង្កត់ធ្ងន់ពិសេស៖ ទីតាំងនីមួយៗធ្វើតាមគុណសម្បត្តិនិងតាមភាពលាយឡំគ្នារបស់ពួកគេ</td><td colspan="3">ការសង្កត់ធ្ងន់ពិសេស កំណត់ចំណុចដៅ សម្រាប់ស្ត្រី ជនក្រីក្រ និងកុមារងាយរងគ្រោះ</td></tr>
</table>

## ២.៤. ការអភិរក្សធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនិងជីវភាពរស់នៅ

ប្រទេសកម្ពុជា បានជួបប្រទះនឹងការកាប់ព្រៃឈើដោយខុសច្បាប់ធ្វើឱ្យមានការខ្វះខាតទឹក ជួបប្រទះនឹងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ រាជរដ្ឋាភិបាលបានចាប់ផ្តើមដោះស្រាយបញ្ហាទាំងនេះប៉ុន្តែ ការងារនេះពុំមានភាពងាយស្រួលទេ។ ក្នុងចំណោមបញ្ហាទាំងនេះមូលដ្ឋានទិន្នន័យស្តីពីធនធានធម្មជាតិមិនមានពេញលេញទេ ហើយប្រជាជនមួយចំនួនធំ ទាំងអ្នកក្រីក្រ និងអ្នកមិនក្រ បាននិងកំពុងរស់នៅពឹងផ្អែកលើព្រៃឈើ។ ការដោះស្រាយបញ្ហាទាំងនេះចាំបាច់ត្រូវប្រើប្រាស់វិធីសាស្ត្រចម្រុះ។

### ជម្រើសវិធីសាស្ត្រមួយចំនួន មានដូចខាងក្រោម ៖

ក. ការកំណត់ផែនទីធនធានឈើនិងធនធានទឹកនៅក្នុងពេលវេលាមូលដ្ឋានមួយ នៅក្នុងកម្រិតដាច់ដោយឡែក (ខេត្ត ស្រុក ឃុំ និងភូមិ) ការបង្កើនការតាមដានព្រៃឈើដោយហ្មត់ចត់ ដោយអភិវឌ្ឍជាប្រព័ន្ធតាមដាន និងវាយតម្លៃពេញលេញសម្រាប់ការត្រួតពិនិត្យព្រៃឈើ ដែលគួរតែរួមបញ្ចូល រុក្ខជាតិ និងសត្វ ការអនុវត្តការបង្កកជីសម្បទានសេដ្ឋកិច្ច និងត្រួតពិនិត្យជាទៀងទាត់ពីសកម្មភាពដែលមានស្រាប់ និងតាមការលើកកម្ពស់ជីវចម្រុះនៅក្នុងព្រៃឈើ។

ខ. ស្វែងរកជម្រើសសម្រាប់ធ្វើឱ្យប្រសើរឡើងនូវជំនាញ និងជីវភាពរស់នៅដែលពឹងផ្អែកលើព្រៃឈើនៅក្នុងការធ្វើកសិកម្ម ឬសកម្មភាពមិនមែនកសិកម្ម។

គ. ការលើកកម្ពស់ថាមពលកកើតឡើងវិញជាពិសេសជីវឥន្ទនៈតាមរយៈការដាំប្រភេទឈើដែលលូតលាស់ឆាប់ jatropha និងផ្សេងទៀត ការបង្កើតរោងចក្រវារីអគ្គិសនីខ្នាតតូច (នៅក្នុងតំបន់ដាច់ស្រយាល) ។

តារាងទី៣.៤ ៖ ផែនការ គោលនយោបាយ យុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើម ក្នុងការអភិរក្សធនធានធម្មជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការចិញ្ចឹមជីវិត (ក្របខ័ណ្ឌពន្លឿនទី៤)

<table>
<tr><th colspan="8">គោលដៅដែលបម្រើឱ្យ ៖ គោលដៅទី៧ និង គោលដៅទី១</th></tr>
<tr><td>ចំណុចដៅ</td><td colspan="3">អ្នករៀបចំគោលនយោបាយនិងប្រជាជនមើលឃើញពីគុណសម្បត្តិនៃការអភិរក្សជាជាងការទាញយករ៉ែ/ការកាប់ឈើ ដែលមានចំនួនកាន់តែច្រើនឡើងនៃប្រជាជនទទួលបានប្រាក់ចំណូលពីប្រភពមិនផ្អែកលើព្រៃឈើ/ដី</td><td colspan="4">ប្រជាជនតិចជាងមុនអាស្រ័យលើធនធានធម្មជាតិ និងច្រើនទៀតបានបង្កើតម្លៃ</td></tr>
<tr><td>ឧបករណ៍បង្កើនល្បឿន</td><td>អ្នករស់នៅតំបន់ព្រៃឈើទទួលបានជម្រើសនៃការចិញ្ចឹមជីវិតជំនួស</td><td colspan="3">ពុំមានការកាប់ឈើកាន់តែច្រើនថែមទៀត គិតគូរល្អិតល្អន់ពីសម្បទានសេដ្ឋកិច្ច និងលុបចោលសម្បទានសេដ្ឋកិច្ចដែលមិនដំណើការ</td><td colspan="3">ការប្តេជ្ញាចិត្តដ៏ខ្លាំងក្លារបស់រដ្ឋាភិបាលដែលគាំទ្រដោយធនធាន</td></tr>
<tr><td>គោលនយោបាយ</td><td>រៀបចំផែនទីព្រៃឈើ និងធនធានទឹកនិង អភិវឌ្ឍប្រព័ន្ធទិន្នន័យ ដើម្បីធ្វើឱ្យទាន់សម័យ</td><td colspan="2">អភិវឌ្ឍវេទិកាដ៏រឹងមាំដើម្បីពិភាក្សាពីការធ្វើឱ្យប្រសើរឡើងជីវភាពអ្នករស់នៅតំបន់ព្រៃឈើ និងអ្នកផ្សេងទៀតមានជម្រើសផលិតភាពប្រកបដោយនិរន្តរភាព និងកាន់តែខ្ពស់ជាងមុន</td><td colspan="2">កែតម្រូវឡើងវិញនូវគោលនយោបាយការប្រើប្រាស់ដី និងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តសុរិយោដី</td><td colspan="2">ស្វែងរកប្រភពជម្រើសឥន្ធនៈផ្សេងទៀត</td></tr>
<tr><td>យុទ្ធសាស្ត្រទី១</td><td>បញ្ចូលទៅក្នុងកិច្ចសន្យាមិនលំអៀង និងឯករាជ្យរយៈពេលវែងជាមួយក្រុមហ៊ុនឯកជន ដើម្បីរៀបចំផែនទីព្រៃឈើ និងធនធានធម្មជាតិ (រាប់បញ្ចូល ទឹក រុក្ខជាតិ និងសត្វ) (ក្របខ័ណ្ឌ PPP) ការអភិវឌ្ឍសមត្ថភាពដើម្បីធ្វើដូចនៅក្នុងរដ្ឋាភិបាល</td><td>អភិវឌ្ឍប្រព័ន្ធM&Eដ៏រឹងមាំសម្រាប់តាមដានពីវឌ្ឍនភាពនៅក្នុងវិស័យព្រៃឈើ និងតាមដានត្រួតពិនិត្យសម្បទានសេដ្ឋកិច្ចដែលមានស្រាប់</td><td colspan="2">កំណត់អត្តសញ្ញាណតំបន់និងជម្រើសសម្រាប់ប្រជាជនរស់នៅ/ធ្វើការក្នុងផលិតភាព / ប្រាក់ចំណូលខ្ពស់ជាងដោយបញ្ជូនការបណ្តុះបណ្តាលនិងធនធាន និងធ្វើ M&Eដោយឡែកសម្រាប់ការងារនេះ</td><td colspan="2">នាំមកនូវច្បាប់ដើម្បីចាត់ចែងសម្បទានសេដ្ឋកិច្ច ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមា ដោយឱ្យមានការគៀបសង្កត់នៅលើការកាប់ឈើ</td><td>បង្កើនថាមពលកកើតឡើងវិញ ដោយដាំដំណាំ jatropha ពិនិត្យមើលជម្រើសវារីអគ្គសនីខ្នាតតូច និងស្វែងរកជម្រើសដែលមិនប្រើប្រព័ន្ធខ្សែកាបផ្សេងទៀត</td></tr>
<tr><td>យុទ្ធសាស្ត្រទី២</td><td colspan="7">ការផ្តោតការយកចិត្តទុកដាក់ពិសេស៖ ទីតាំងនីមួយៗ ធ្វើតាមគុណសម្បត្តិ និងតាមភាពលាយឡំគ្នា</td></tr>
</table>

## ២.៥. ការចូលរួមស្មើភាពគ្នា និងភាពមានសិទ្ធិអំណាចរបស់ស្ត្រី

មានសមធម៌យេនឌ័រមានកាន់តែខ្ពស់ឡើងនៅក្នុងប្រទេសកម្ពុជា ធៀបនឹងបណ្តាប្រទេសដទៃទៀតប៉ុន្តែគម្លាតនៅតែបន្តមាន។ គម្លាតនេះអាចនឹងត្រូវបានបង្រួមដោយមិនចាំបាច់ចំណាយធនធានច្រើន ឬក៏តម្រូវឱ្យមានការផ្លាស់ប្តូរស្ថាប័ន។ ជម្រើសមួយចំនួន រួមមាន៖

ក. ការលើកកម្ពស់/ការរក្សាសមធម៌នៅក្នុងវិស័យអប់រំនៅគ្រប់កម្រិតសិក្សាទាំងអស់ ជាពិសេសមធ្យមសិក្សាបឋមភូមិ និងកម្រិតខ្ពស់ជាង។

ខ. ការជំរុញ/រក្សាបាននូវសមភាពយេនឌ័រក្នុងការងារ ជាពិសេសការងារដែលមានប្រាក់ឈ្នួល និងកាត់បន្ថយស្ត្រីជា'កម្មករដែលធ្វើការងារផ្ទះដោយគ្មានប្រាក់កម្រៃ'។ ការងារនេះអាចសម្រេចបានតាមរយៈការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន និងការកសាងសមត្ថភាព។

គ. ការបញ្ចូលស្ត្រីកាន់តែច្រើនទៀតនៅក្នុងការងារផ្ទាល់ខ្លួនដែលមានគុណភាពខ្ពស់។

ឃ. ការធានាឱ្យមានតំណាងជាស្ត្រីក្នុងចំនួនមួយសមរម្យនៅក្នុងសមាជិករាជរដ្ឋាភិបាល និងក្នុងការិយាល័យរដ្ឋបាលសាធារណៈ ដែលការងារនេះអាចសម្រេចបានតាមរយៈសកម្មភាពរដ្ឋបាល។

ង. ការកាត់បន្ថយ/ការបំបាត់អំពើហិង្សាក្នុងគ្រួសារ។

តារាងទី៣.៥ ៖ ផែនការ គោលនយោបាយ យុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើម ដែលជាការចូលរួមស្មើភាពគ្នា និងការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី (ក្របខ័ណ្ឌពន្លឿនទី៥)

| គោលដៅដែលបម្រើឱ្យ ៖ គោលដៅទី៣ គោលដៅទី២គោលដៅទី១ គោលដៅទី៥ | | | | |
|---|---|---|---|---|
| ចំណុចដៅ | ច្បាប់និងឥរិយាបទរបស់មនុស្សដែលជំរុញសមធម៌យេនឌ័រ | | | ស្ត្រីបន្ថែមទៀតនៅក្នុងកម្លាំងពលកម្មមានការងារសមរម្យ |
| ឧបករណ៍បង្កើនល្បឿន | អប់រំ | ការងារ | | ការលានុវត្តភាព |
| គោលនយោបាយ | ធានានូវការចូលរួមកាន់តែច្រើនរបស់កុមារីនិងស្ត្រីនៅក្នុងវិស័យអប់រំ លើសពីកម្រិតបឋមសិក្សា និងការអប់រំបច្ចេកទេស | គោលនយោបាយយេនឌ័រគឺជាការងារដែលមានភាពរសើប ហើយការលើកកម្ពស់ការចូលរួមប្រកបដោយគុណភាពរបស់ស្ត្រីនៅក្នុងកម្លាំងពលកម្ម ដោយការកែលម្អគុណភាពនៃការងារផ្ទាល់ខ្លួនសម្រាប់ស្ត្រី | គោលនយោបាយដើម្បីខិតខំថែមទៀតដើម្បីឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងជីវិតជាសាធារណៈ | អំពើហិង្សាលើយេនឌ័រត្រូវបានគិតថាជាអំពើខុសច្បាប់នៅក្នុងការអនុវត្តជាក់ស្តែង និងត្រូវបានបង្រួមជាអប្បបរមា |
| យុទ្ធសាស្ត្រទី១ | សាងសង់បង្គន់អនាម័យដាច់ដោយឡែកសម្រាប់ក្មេងស្រីក្នុងសាលា ផ្តល់ប្រឹក្សាយោបល់ដោយឡែក ជួលគ្រូបង្រៀនជាស្ត្រីកាន់តែច្រើន និងសាកល្បងវិធីសាស្ត្រអនុញ្ញាតផ្សេងទៀត | ធ្វើឱ្យស្ត្រីទទួលបានការបណ្តុះបណ្តាលបច្ចេកទេសសម្រាប់ការងារធ្វើច្បាប់នៅកន្លែង ការងារ "សម្រួលដល់ស្ត្រី"លើសពីនេះទៀតលើកកម្ពស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី | ពិសោធន៍ដោយប្រើប្រាស់ប្រព័ន្ធកូតាសម្រាប់ស្ត្រីក្នុងតួនាទីជាក់លាក់ទាំងនៅក្នុងនយោបាយ និងរដ្ឋបាល | ធ្វើច្បាប់យ៉ាងតឹងរ៉ឹងច្រើនថែមទៀត និងមានការអនុលោមតាមច្បាប់ល្អប្រសើរជាងមុន លើកកម្ពស់ការយល់ដឹងស្តីពីCEDAWដោយអនុវត្តM&Eបានទៀងទាត់ ថែមទៀត |
| យុទ្ធសាស្ត្រទី២ | ការផ្តោតជាពិសេស៖ ទីតាំងនីមួយៗ ធ្វើតាមគុណសម្បត្តិ និងតាមភាពលាយឡំគ្នារបស់ពួកគេ | | ការផ្តោតជាពិសេស៖ ចំណុចដៅក្មេងស្រីក្រីក្រ ស្ត្រីក្រីក្រ និងកុមារងាយរងគ្រោះ | |

## ២.៦. ការកែលម្អសេវាសុខាភិបាលឱ្យខិតជិតប្រជាជន និងការបង្កើនគុណភាពសុខភាពមាតា និងកុមារនិងត្រួតពិនិត្យជំងឺ

វិភាគនៅក្នុងជំពូកទី២បង្ហាញថាសូចនាករសុខភាពជាច្រើនត្រូវបានភ្ជាប់ទៅនឹងកម្រិតជីវភាពរស់នៅរបស់ប្រជាជន។ ប្រសិនបើវឌ្ឍនភាពប្រកបដោយប្រសិទ្ធភាព គឺត្រូវបានធ្វើឡើងដោយជោគជ័យលើក្របខណ្ឌពន្លឿនទី១ និងទី២ នោះកត្តាទាក់ទងនឹងសុខភាពអាចត្រូវបានដោះស្រាយ។ ជាមួយនឹងសេវាសុខាភិបាលកំពុងត្រូវការទាំងជំនាញខ្ពស់និងការចំណាយថ្លៃ ដូច្នេះកិច្ចអន្តគមន៍របស់រដ្ឋគឺជាការចាំបាច់។ ការចំណាយចរន្តរបស់រដ្ឋលើវិស័យសុខាភិបាលនាពេលបច្ចុប្បន្នមានកម្រិតទាបជាង២% នៃផ.ស.ស.ទន្ទឹមនឹងការចំណាយ "ដោយបុគ្គលផ្ទាល់"មានចំនួនខ្ពស់ជាងច្រើន។ ក្នុងករណីនេះ គួរបង្កើនសមាមាត្រនៃធនធានរបស់រដ្ឋសម្រាប់វិស័យសុខាភិបាលឱ្យបានខ្ពស់ជាងមុន។ ក្នុងពេលជាមួយគ្នានេះ ការពង្រីកសេវាសុខាភិបាលក្នុងតំបន់ក៏គួរត្រូវបានជួយឱ្យកើតមានដែរ។ សំណើមួយចំនួនដែលបានលើកឡើងដើម្បីដោះស្រាយ រួមមាន៖

ក. ការកែលម្អនិងការធ្វើឱ្យអាចទទួលបានច្រើនជាងនេះ នូវសេវាសុខភាពរបស់រដ្ឋ/គាំទ្រដោយរដ្ឋ ក្នុងតម្លៃមួយតិចតួច (ឬដោយឥតគិតថ្លៃ)។

ខ. ការនាំយកសេវាកម្មMNCHឱ្យកាន់តែខិតជិតប្រជាជននៅក្នុងតំបន់ដាច់ស្រយាលជាច្រើន (និងក្រុមជនដែលងាយរងគ្រោះ)។

គ. ការបង្កើតកម្មវិធីបញ្ចូលមីក្រូសារជាតិសម្រាប់ស្ត្រី និងកុមារ។

ឃ. ត្រួតពិនិត្យឱ្យមានប្រសិទ្ធភាពយ៉ាងហោចណាស់នូវជំងឺចំនួនបីប្រភេទ គឺមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺរបេង។

តារាងទី៣.៦ ៖ ផែនការ គោលនយោបាយ យុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើម ការធ្វើឱ្យប្រសើរឡើង MNCH និងការត្រួតពិនិត្យជំងឺ (ក្របខណ្ឌពន្លឿនទី៦)

<table>
<tr><th colspan="7">គោលដៅដែលបម្រើឱ្យ៖ គោលដៅទី៤ គោលដៅទី៥ គោលដៅទី៦ គោលដៅទី១</th></tr>
<tr><td>ចំណុចដៅ</td><td colspan="2">ការចំណាយរបស់រដ្ឋសម្រាប់សុខភាពលើសពី ២% នៃ ផ.ស.ស.</td><td colspan="2">ចំណេះដឹងរបស់មនុស្ស ឥរិយាបទនិងការអនុវត្តការផ្លាស់ប្តូរឆ្ពោះទៅរកអារម្មណ៍គិតអំពីវិទ្យាសាស្ត្រ</td><td colspan="2">ប្រជាជនកាន់តែច្រើនឡើងប្រើប្រាស់/អាចប្រើប្រាស់សេវាសុខភាពតាមស្ថាប័ននៅពេលដែលត្រូវការ</td></tr>
<tr><td>ឧបករណ៍បង្កើនល្បឿន</td><td colspan="2">សេវាសុខភាពដែលមានថ្លៃទាបឱ្យមាននៅក្នុងស្រុកឱ្យបានច្រើនជា អតិបរមា</td><td colspan="2">លទ្ធភាពប្រើប្រាស់ផ្លូវ ការដឹកជញ្ជូននិងការទំនាក់ទំនង ជីវភាពរស់នៅ ត្រូវបានធ្វើឱ្យប្រសើរឡើង</td><td colspan="2">ការអប់រំសុខភាព ការអប់រំទូទៅ ប្រាក់ចំណូលត្រូវបានលើកកំពស់</td></tr>
<tr><td>គោលនយោបាយ</td><td>ផ្តល់ទាយជ្ជទានមណ្ឌលសុខភាពជាមួយនឹងសម្ភារបរិក្ខារកាន់តែច្រើន និងបុគ្គលិកដែលបានបណ្តុះបណ្តាលប្រសើរជាងមុន ពង្រីកសេវាសុខភាពកម្រិត ២ និង៣ និងផ្តល់មូលនិធិបន្ថែមទៀតសម្រាប់មូលនិធិសមធម៌សុខាភិបាល</td><td colspan="2">ការលើកទឹកចិត្តខ្លាំងឡើងសម្រាប់ MNCH និងការកសាងផែនការគ្រួសារ កែលម្អប្រព័ន្ធច្បាប់សម្រាប់ផលិតផលឱសថនិងការផ្តល់សេវាសុខភាពឯកជននិងលើកកម្ពស់សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ</td><td colspan="2">បណ្តុះបណ្តាលមនុស្សដើម្បីក្លាយជាបុគ្គលិកសុខភាពនិងផ្តល់ការបណ្តុះបណ្តាលពាក់កណ្តាលអាជីពសិក្សាពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAP) (នៅក្នុងផ្នែកសុខភាព)</td><td>ធ្វើឱ្យស៊ីគ្នាកម្មវិធីសុខភាពជាមួយកម្មវិធីដទៃនៅក្នុងវិស័យអប់រំ ពង្រឹងកម្មវិធីអត្តសញ្ញាណកម្មជនក្រីក្រនិងការបណ្តុះបណ្តាលវិជ្ជាជីវៈ</td></tr>
<tr><td>យុទ្ធសាស្ត្រទី១</td><td colspan="2">កែលម្អសំវិធានធនហេដ្ឋារចនាសម្ព័ន្ធសុខភាព ដោយកែលម្អ / ពង្រីកការគ្រប់គ្រងរួមបញ្ចូលគ្នានៃជំងឺកុមារ កែលម្អការផ្តល់សេវាផ្សព្វផ្សាយសម្រាប់ការផ្តល់សេវា MNCHបង្កើនលទ្ធភាពរបស់ធ្មបលើកទីពីរ កែលម្អការគ្របដណ្តប់និងស្ថិរភាពនៃទារកនិងការបំបៅកូន ប្រឹក្សាយោបល់ជាមួយមាតាសម្រាប់សុខភាពនិងការផ្តល់រូបវន្តនៃសារជាតុចិញ្ចឹម និងបង្កើនការត្រួតពិនិត្យនិងការព្យាបាលសម្រាប់មេរោគអេដស៍ គ្រុនចាញ់ និងរបេង</td><td colspan="2">ពង្រីកការអប់រំវេជ្ជសាស្ត្រ កែលម្អជំនាញរបស់បុគ្គលិកសុខាភិបាលនៅ តាមភូមិ អនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានស្តីពីអាហារល្អសម្រាប់សុខភាព ប្រឆាំងនឹងថ្នាំជក់ និងលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត</td><td colspan="2">កែលម្អឃ្លាំងផ្ទុកម្ហូបអាហារទឹកនិងអនាម័យ ពង្រីកវិសាលភាពនៃការចែកចាយ មីក្រូសារជាតិនិងប្រូតេអ៊ីនបន្ថែម ពង្រីកប្រភេទសេវា ការធានារ៉ាប់រងសុខភាពដែលគាំទ្រអ្នកក្រីក្រនិងសាលភាពនៃមូលនិធិសមធម៌ ផ្តល់ការផ្ទេរសាច់ប្រាក់និងការឧបត្ថម្ភស្បៀងអាហារតាមលក្ខខណ្ឌដោយភ្ជាប់ទៅនឹង MNCH</td></tr>
<tr><td>យុទ្ធសាស្ត្រទី២</td><td colspan="3">ការផ្តោតជាពិសេស៖ ទីតាំងនីមួយៗ ធ្វើតាមគុណសម្បត្តិ និងតាមភាពលាយឡំគ្នារបស់ពួកគេ</td><td colspan="3">ការផ្តោតជាពិសេស៖ ចំណុចដៅក្មេងស្រីក្រីក្រ ស្ត្រីក្រីក្រ និងកុមារងាយរងគ្រោះ</td></tr>
</table>

## ២.៧. ផ្តល់ផ្គង់ទឹកមានសុវត្ថិភាព និងធ្វើឱ្យប្រសើរឡើងនូវអនាម័យសម្រាប់តំបន់ជនបទ

ទឹកដែលមានសុវត្ថិភាពនិងអនាម័យ (ទឹកនិងអនាម័យ) អាចជួយដោះស្រាយបញ្ហានៅក្នុងការចិញ្ចឹមជីវិតក្នុងវិស័យសុខភាព អប់រំ និងវិស័យ ផ្សេងទៀត។ ជំពូកទី២ បង្ហាញជារួមថា សមាមាត្រនៃចំនួនប្រជាជនទទួលបានទឹកនិងអនាម័យដែលមានការកែលម្អនៅមានកម្រិតទាប។ ចំនួនប្រជាជនទទួលបានទឹកនិងអនាម័យអាចកើនដល់ច្រើនជាង៨០% នៅក្នុងតំបន់ទីប្រជុំជន ប៉ុន្តែនៅក្នុងតំបន់ជនបទគឺមានសមាមាត្រ តិចជាង៥០%។ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ រវាងសិទ្ធិទទួលបានទឹកនិងអនាម័យដែលមានសុវត្ថិភាព និងកម្រិតជីវភាពរស់នៅ (ក៏ដូចជាក្នុងស្រុក)។

កិច្ចអន្តរាគមន៍ដ៏ធំមួយអាចធានានូវភាពជោគជ័យបាន។ កម្រិតខុសគ្នារវាងខេត្តនីមួយៗ ចាំបាច់ត្រូវបង្រួម។ សំណើមួយចំនួនដែលបានលើកឡើងរួមមាន៖

ក. បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ទឹកស្អាតនិងអនាម័យ

ខ. លើកកម្ពស់ការសម្អាតទឹកនិងអនាម័យនៅក្នុងគ្រួសារជាពិសេសជ្រើសរើសយកតម្លៃថោក ការជំរុញការផ្គត់ផ្គង់ទឹកស្អាតនៅតាមសហគមន៍និងការផ្តួចផ្តើមអនាម័យនៅតាមតំបន់ជនបទ ការលើកកម្ពស់សហគមន៍នាំមុខដោយអនាម័យទូទៅ (CLTS) និងការផ្តល់ការបណ្តុះបណ្តាលនិងយុទ្ធនាការលើកកម្ពស់បង្កើនការយល់ដឹងពីអនាម័យនិងទឹកនិងអនាម័យគ្រប់ផ្នែកនៃសង្គម។

តារាងទី៣.៧ ៖ ផែនការ គោលនយោបាយ យុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើម អំពីទឹកសុវត្ថិភាពនិងការធ្វើឱ្យប្រសើរឡើងអនាម័យ ជាពិសេសនៅក្នុងតំបន់ជនបទ (ក្របខ័ណ្ឌពន្លឿនទី៧)

<table>
<tr><th colspan="7">គោលដៅដែលបម្រើឱ្យ៖ គោលដៅទី៧ គោលដៅទី១ គោលដៅទី៤ គោលដៅទី៥ និងគោលដៅទី៦</th></tr>
<tr><td>ចំណុចដៅ</td><td colspan="2">ធនធានទំហំធំបានវិភាជន៍ឆ្ពោះទៅរកទឹកនិងអនាម័យ</td><td colspan="2">ប្រជាជនបានអប់រំនិងទទួលពត៌មានល្អប្រសើរជាងមុន ស្តីពីទឹកស្អាតនិងអនាម័យ</td><td colspan="2">មានលទ្ធភាពទទួលបានទឹកនិងអនាម័យធំធេងជាងមុន</td></tr>
<tr><td>ឧបករណ៍បង្កើនល្បឿន</td><td colspan="2">អគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធជីវភាពដែលបានកែលម្អ</td><td colspan="2">ផែនទីលក្ខណៈភូមិសាស្ត្រកំណត់អត្តសញ្ញាណជ្រលងជងអូនិងទិសរបស់វា និងការធ្វើអង្កេតទឹកក្រោមដី</td><td colspan="2">ការអនុវត្តអាកប្បកិរិយាស្រាវជ្រាវចំណេះដឹងរបស់មនុស្សត្រូវបានផ្អែកលើគោលការណ៍វិទ្យាសាស្ត្រ</td></tr>
<tr><td>គោលនយោបាយ</td><td>រៀបចំការណែនាំថ្នាក់ជាតិមួយសម្រាប់ទឹកនិងអនាម័យ ដោយកំណត់ថ្លៃដើមនិងបច្ចេកវិទ្យាតាមទីតាំង</td><td colspan="2">ការអប់រំមនុស្សក្នុងភូមិនៅសហគមន៍ដើម្បីជួសជុលសម្ភារបរិក្ខារ ទឹកនិងអនាម័យ</td><td colspan="2">ស្វែងរកជម្រើសសម្រាប់តំបន់ដាច់យាល និងលក្ខណៈភូមិសាស្ត្រដីទួល</td><td>ធ្វើឱ្យស៊ីគ្នា ទឹកនិងអនាម័យ ជាមួយកម្មវិធីក្របខណ្ឌបង្កើនល្បឿនទី១ ទី២ និងទី៦</td></tr>
<tr><td>យុទ្ធសាស្ត្រទី១</td><td colspan="2">បង្កើនការពង្រីកទឹកស្អាតបរិភោគតាមប្រព័ន្ធសុវត្ថិភាព សង់រោងចក្រសម្អាតសំណល់រាវសាមញ្ញជាពិសេសសម្រាប់ក្រុមភូមិនិងភូមិធំៗ ផ្តល់នូវគ្រឿងបរិក្ខារអនាម័យធ្វើឱ្យប្រសើរឡើងបរិក្ខារអនាម័យ នៅក្នុងបរិស្ថាន តំបន់ ប្រើប្រាស់វិធីសាស្ត្រដែលមានតំលៃថោកនិងងាយស្រួលបន្សុទ្ធទឹក ឧទាហរណ៍ SODIS ផ្តួចផ្តើមបច្ចេកវិទ្យាសម្រាប់ធ្វើឱ្យប្រសើរឡើងអនាម័យ នៅក្នុងតំបន់ជនបទរួមទាំងបង្គន់អនាម័យបានរចនាឡើងក្នុងមូលដ្ឋាន</td><td colspan="2">អភិវឌ្ឍក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីជូនដំណឹងស្តីពីសកម្មភាពរបស់ភ្នាក់ងាររដ្ឋាភិបាល សំវិធានធនដៃគូនិងឯកជន ស្វែងរកភាពជាដៃគូPPPសម្រាប់សេវាផ្គត់ផ្គង់ទឹកនិងអនាម័យ</td><td colspan="2">បើកដំណើរការគម្រោងសាកល្បងលើកកម្ពស់ការផ្តួចផ្តើមទឹកនិងអនាម័យ នៅតាមសហគមន៍; លើកកម្ពស់អនាម័យការអប់រំនៅក្នុងសាលារៀន; ទីផ្សារការចល័តអប់រំនិងសង្គមសម្រាប់ CLTS; បង្កើនការយល់ដឹងស្តីពីភ្ជាប់គ្នារវាងអនាម័យនិងសុខភាព; បណ្តុះបណ្តាលគ្រួសារស្តីពីការស្តុកនិងការសម្អាតទឹក; ការបោះបង់ចោលកាកសំណល់</td></tr>
<tr><td>យុទ្ធសាស្ត្រទី២</td><td colspan="6">ការផ្តោតជាពិសេស៖ ទីតាំងនីមួយៗ ធ្វើតាមគុណសម្បត្តិ និងតាមភាពលាយឡំគ្នារបស់វា</td></tr>
</table>

## ៣. តម្រូវការសកម្មភាពនៅកម្រិតមូលដ្ឋាននិងធានាការសម្របសម្រួល

ការធ្វើឱ្យមានវឌ្ឍនភាពដ៏ទូលំទូលាយក្នុងអាទិភាពទាំងប្រាំពីរ ចាំបាច់ត្រូវអំពាវនាវឱ្យមានការពឹងផ្អែកខ្លាំងលើកិច្ចខិតខំប្រឹងប្រែងមួយដើម្បីគាំទ្រសកម្មភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ខេត្តស្រុក ឃុំ និងភូមិ។ បទពិសោធន៍បានពីគំនិតផ្តួចផ្តើមមុនៗ (នៅក្នុងរៀបចំផែនការ និងការអនុវត្តផែនការ ដើម្បីសម្រេចគ.អ.ស.ក. និងចំណុចដៅតាមវិស័យ) នៅថ្នាក់មូលដ្ឋានក្នុងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ អាចនឹងត្រូវបានសិក្សាយ៉ាងប្រុងប្រយ័ត្នបន្ថែមទៀត សម្រាប់ការស្គាល់នូវការបង្កើនឡើងគំនិតផ្តួចផ្តើមដែលទទួលបានជោគជ័យ។ ក្នុងន័យនេះការកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋាន (ជាពិសេសនៅកម្រិតខេត្តក៏ដូចជាកម្រិតទាបជាងនេះ ទោះបីមិនពិតប្រាកដនៅក្នុងរយៈពេលខ្លី/មធ្យមក៏ដោយ ក៏ការងារនេះគឺជាចំណុចស្នូលដើម្បីទទួលបានភាពជោគជ័យ។ តំបន់ដាច់ស្រយាលគួរតែអាចទទួលបានអត្ថប្រយោជន៍ផងដែរពីការច្នៃប្រឌិត ការផ្តួចផ្តើមការវិនិយោគដែលមានតម្លៃទាបនៅក្នុងវិស័យសុខភាព ផលិតផលម្ហូបអាហារ ការអប់រំ លទ្ធភាពទទួលបានទឹកស្អាតនិងហេដ្ឋារចនាសម្ព័ន្ធដែលសំខាន់និងការរួចចាកផុតចេញពីភាពក្រីក្រ។

ការអនុវត្តក្របខ័ណ្ឌពន្លឿនអាចត្រូវបានសម្របសម្រួលនិងត្រួតពិនិត្យតាមរយៈរចនាសម្ព័ន្ធសម្របសម្រួលដែលបង្កើតឡើងស្រាប់ ដោយកម្រិតជាតិ អភិបាលខេត្ត និងអភិបាលស្រុកជាមួយនឹងកិច្ចការផ្សេងៗ ដែលបានធ្វើរួមគ្នាដោយក្រសួងមហាផ្ទៃ និងក្រសួងផែនការ។ ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃក្នុង ផ.យ.អ.ជ. អាចផ្តល់នូវធាតុចូលដែលចាំបាច់ជាមួយនឹងគោលបំណងចែករំលែកដល់ការសម្រេចបាននូវក្របខ័ណ្ឌពន្លឿនការកំណត់ចំណុចខ្វះខាតផ្នែកហិរញ្ញវត្ថុនិងការចាត់ចែងការទទួលខុសត្រូវជាក់លាក់។

ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃបច្ចុប្បន្នរបស់ផ.យ.អ.ជ. នឹងត្រូវបានទាមទារឱ្យមានការកែប្រែរចនាសម្ព័ន្ធយ៉ាងទូលាយតាមរយៈការណែនាំនូវប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ ដែលមានដំណើរការ តម្រង់ទិស បន្ថែមនឹងប្រព័ន្ធដែលមានលក្ខណៈជាលទ្ធផល។ ក្រសួងផែនការ មានគម្រោងអភិវឌ្ឍន៍ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ នៅក្នុងភាពជាដៃគូយុទ្ធសាស្ត្រជាមួយក្រសួងពាក់ព័ន្ធ និងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ។

## ៤. ការផ្តល់ហិរញ្ញប្បទាននិងការកៀរគរធនធាន

ដំណើរឆ្ពោះទៅការសម្រេចបាននូវគ.អ.ស.ក. និងគោលដៅដទៃទៀតនៅក្នុងការអភិវឌ្ឍមនុស្សត្រឹមឆ្នាំ២០១៥ និងក្រោយពីគ.អ.ស.ក. ឆ្នាំ២០១៥នឹងតម្រូវឱ្យមានការខិតខំប្រឹងប្រែងពិសេសដើម្បីកៀរគរមូលនិធិដែលជាម្ចាស់ជំនួយជាច្រើនប្រហែលជា 'បិទ' នៅលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ត្រូវបានឈានដល់ឆ្នាំ២០១៥នេះ។ ការអនុវត្តរៀបចំថវិកាសម្រាប់គ.អ.ស.ក. មិនទាន់ត្រូវបានអនុវត្តនៅឡើយទេនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក្តីក្រសូងផែនការ និងបណ្តាក្រសួងផ្សេងទៀតក៏មានជាគំនិតប៉ាន់ស្មានទំហំថវិកាចំណាយប៉ុន្មាននឹងត្រូវការ។ កម្មវិធីវិនិយោគសាធារណៈផ្តល់នូវទិន្នន័យ គម្រោងជាក់លាក់រួចហើយនៅលើអ្វីដែលនឹងទទួលបាន ដើម្បីឱ្យត្រូវនឹងការចំណាយទាំងនេះ។ ប្រសិនបើបរិកាសធនធានមានការលំបាក នោះការកំណត់អាទិភាពចាំបាច់ត្រូវបានធ្វើឡើងដោយឱ្យទម្ងន់ទៅលើកិច្ចអន្តរាគមន៍ណាដែលចំណាយទាប ហើយផ្តល់លទ្ធផលខ្ពស់។

## ៥. សេចក្តីសង្ខេប

មានបញ្ហាប្រឈម និងជម្រើសជាច្រើនសម្រាប់រយៈពេលក្រោយពីឆ្នាំ២០១៥។ ទោះជាដូចនេះក្តី ភារកិច្ចដំបូងនេះគឺដើម្បីបំពេញចំណុចដៅឆ្នាំ២០១៥ ដែលមិនពេញលេញទាំងអស់ នៅក្នុងពេលវេលាកំណត់។ ជាមួយគ្នានេះ តាមភស្តុតាងពីការព្រួយបារម្ភនៅកម្រិតជាតិនិងអន្តរជាតិដែលបានពិភាក្សានៅក្នុងអត្ថបទនេះគឺទាមទារនូវការបង្កើតសំណុំចំណុចដៅថ្មី។

បញ្ហាបន្ទាន់បំផុតគឺត្រូវដោះស្រាយភាពក្រីក្រ និងវិសមភាព។ ចំពោះបញ្ហាទាំងនេះ វិធានការដ៏សំខាន់មួយចំនួន គឺត្រូវពង្រឹងការអភិវឌ្ឍមនុស្ស (ពោលគឺការអប់រំ សុខភាព និងគាំពារសង្គម) និងមូលធនមនុស្ស (ជំនាញ) ការបង្កើនអភិបាលកិច្ចល្អ និងនីតិរដ្ឋ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលសមរម្យ ក្នុងការលើកកម្ពស់តម្លៃបន្ថែមសម្រាប់កសិកម្ម និងការបង្កើតលក្ខខណ្ឌសម្រាប់វិស័យឯកជន ដើម្បីបង្កើតអត្ថប្រយោជន៍ទៅវិញទៅមកទាំងអស់នៅក្នុងសង្គម ពោលគឺកំណើនប្រកបដោយបរិយាប័ន្ន។ លើសពីនេះទៀត អាទិភាពចំនួនបីផ្សេងទៀតគឺប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុគ្រប់គ្រងធនធានរួម (ឧទាហរណ៍ ធនធានធម្មជាតិនិងទឹក) និងធ្វើឱ្យមានសមភាពយេនឌ័របន្ថែមទៀត។

រាជរដ្ឋាភិបាល មានគោលបំណងដោះស្រាយរាល់បណ្តាបញ្ហាដែលមាន ក្នុងការអនុវត្តផែនការ រយៈពេល ៥ឆ្នាំ កន្លងមក ដែលរួមមានសេចក្តីលម្អិតក្នុងកម្មវិធី ហិរញ្ញវត្ថុ និងក្នុងរចនាសម្ព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ។ រាជរដ្ឋាភិបាលនឹងខិតខំប្រឹងប្រែង សំដៅពង្រឹងមូលដ្ឋានទិន្នន័យរបស់សង្គម និងសេដ្ឋកិច្ចកម្ពុជា។



ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសគម្រោងអភិវឌ្ឍន៍ក្នុងសហគមន៍របស់គេ-ខេត្តកោះកុង

# ជំពូកទី ៤

# សេចក្តីសន្និដ្ឋាន

របាយការណ៍ស្តីពីការសម្រេចបាន គ.អ.ស.ក ឆ្នាំ២០១៣នេះ ជារបាយការណ៍គ.អ.ស.ក.ប្រចាំឆ្នាំលើកទីបួនដែលបង្ហាញដោយសង្ខេបពីការពិនិត្យឡើងវិញនូវវឌ្ឍនភាពកន្លងមក លើសូចនាករម៉ាក្រូសេដ្ឋកិច្ចនានា និងធ្វើការវាយតម្លៃពីវឌ្ឍនភាពរបស់ប្រទេសកម្ពុជាក្នុងការសម្រេចបាន គ.អ.ស.ក.។ របាយការណ៍នេះបង្ហាញពីលទ្ធផលនៅគ្រប់កម្រិតទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ហើយក៏ពិនិត្យមើលផលដែរ ពីផលប៉ះពាល់នៃទំហំវិសមភាព មកលើការសម្រេចបានគោលដៅអភិវឌ្ឍន៍មនុស្ស។ របាយការណ៍នេះ ក៏បង្ហាញពីលទ្ធផលនៃការអនុវត្តរបស់ "ក្រុមការងារ" ដែលពឹងផ្អែកលើមូលដ្ឋានគ្រឹះសម្រាប់ក្របខ័ណ្ឌពន្លឿន គ.អ.ស.ក. ឆ្ពោះទៅមុខ។



ប៊ុន ស្រីពេ អាយុ៣ឆ្នាំកំពុងអានសៀវភៅ

នៅកម្រិតម៉ាក្រូសេដ្ឋកិច្ច ទោះបីជា កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់លើស ៧% នៃផ.ស.ស. នៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះឬច្រើនជាងក៏ដោយក៏សកម្មភាពសេដ្ឋកិច្ចនៅមានលក្ខណៈតូចចង្អៀតវិស័យកាត់ដេរ សំណង់ ទេសចរណ៍ និងកសិកម្ម។ នៅជាមួយគ្នានេះកម្រិតសកម្មភាពទាំងនោះមានលក្ខណៈ "មិនស៊ីជម្រៅ" ដែលមានតម្លៃបន្ថែមតិចតួច។ ភាគច្រើននៃកំណើននេះបានផុសចេញពីការពង្រីកសកម្មភាពនៅពេលក្រោយ។ នៅក្នុងឆ្នាំខាងមុខនេះ ពេលដែលកម្ពុជាធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននោះមូលធនមនុស្សឧស្សាហូបនីយកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគរបស់វិស័យឯកជនដែលបញ្ហាទាំងអស់នេះ នឹងត្រូវបានសន្មតថា កាន់តែមានសារៈសំខាន់ឡើង។ ចំណុចដៅភាគច្រើននៃ គ.អ.ស.ក. តម្រូវឱ្យរដ្ឋាភិបាលពង្រីកធនធានបន្ថែមទៀត តាមក្រសួង និងវិស័យពាក់ព័ន្ធនឹងការអភិវឌ្ឍមនុស្ស កំណើនសេដ្ឋកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធផល និងការបង្កើនធនធានសាធារណៈឱ្យបានលឿន គឺជាស្នូលនៃការទទួលបានភាពជោគជ័យ។



សមាជិកសមាគម បឹង ការឆេង កំពុងល្បាតមើលកន្លែងសត្វព្រៃពាមក្រសោប ដើម្បីការពារការកាប់ព្រៃកោងកាងខុសច្បាប់

### របាយការណ៍ស្តីពី គ.អ.ស.ក. ត្រូវបានសង្ខេបក្នុងតារាងដូចខាងក្រោម ៖

**គោលដៅទី១៖ ការលប់បំបាត់ភាពក្រីក្រនិងភាពអត់ឃ្លានធ្ងន់ធ្ងរ**
វឌ្ឍនភាពគួរឱ្យកត់សម្គាល់ត្រូវសម្រេចបាននៅក្នុងការកាត់បន្ថយភាពក្រីក្រតាមលទ្ធភាពចំណាយនិងភាពក្រីក្រម្ហូបអាហារ។ ទោះជាយ៉ាងណា គម្លាតនៅតាមតំបន់ នៅបន្តមានច្រើន។ ការលើកកម្ពស់ម្ហូបអាហារូបត្ថម្ភរបស់កុមារ មានវឌ្ឍនភាពយឺតយាវ។ រីឯពលកម្មកុមារគឺជានៅតែខ្ពស់ជាងចំណុចដៅ។

**គោលដៅទី២៖ សម្រេចឱ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា**
មានវឌ្ឍនភាពល្អនៅក្នុងសាលារៀនបឋមសិក្សា និងទំនងសម្រេចបានចំណុចដៅ។ ប៉ុន្តែបញ្ហាប្រឈមគឺកម្រិតក្រោយបឋមសិក្សា។

**គោលដៅទី៣៖ លើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រី**
ទន្ទឹមនឹងសម្រេចបានចំណុចដៅជាច្រើនសមាមាត្ររវាងបុរសនិងស្ត្រីក្នុងស្ថាប័នសាធារណៈ នៅបន្តមានគម្លាតខ្ពស់។

**គោលដៅទី៤៖ កាត់បន្ថយមរណភាពកុមារ**
អត្រាមរណភាពរបស់ទារកនិងអត្រាអត្រាមរណភាពរបស់កុមារអាយុក្រោម៥ឆ្នាំបានកាត់បន្ថយយ៉ាងខ្លាំង។ សម្រេចបានចំនុចដៅទាំងអស់នេះ។ ប៉ុន្តែគម្លាតនៅបន្តមានតាមខេត្ត និងកម្រិតជីវភាពរស់នៅរបស់គ្រួសារ។

**គោលដៅទី៥៖ លើកកម្ពស់សុខភាពមាតា**
អត្រាមរណៈភាពរបស់មាតា ត្រូវបានកាត់បន្ថយយ៉ាងខ្លាំង និងសម្រេចបានមុនពេលកំណត់។ សេវាថៃទាំសុខភាពមុនពេលផ្តល់កំណើតកូន ត្រូវបានផ្តល់យ៉ាងទូលំទូលាយ ហើយចំណុចដៅនេះ សម្រេចបានមុនកាលកំណត់។ យ៉ាងណាមិញ សូចនាករមួយចំនួន នៅមិនទាន់សម្រេចបាន ជាពិសេសនៅតាមខេត្ត និងតាមកម្រិតជីវភាពរស់នៅរបស់គ្រួសារ។

**គោលដៅទី៦៖ ប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺផ្សេងៗទៀត**
ការកំណត់សញ្ញាណជំងឺឆ្លង និងមេរោគអេដស៍/ជំងឺអេដស៍ គឺទំនងនឹងសម្រេចបានតាមកាលកំណត់។

**គោលដៅទី៧៖ ធានាចីរភាពបរិស្ថាន**
នឹងសម្រេចបានបណ្តាចំនុចដៅនៃកិច្ចការពារបរិស្ថាន តាមកាលកំណត់នៅឆ្នាំ២០១៥។ ប៉ុន្តែ មានសេចក្តីត្រូវការចាំបាច់ សំដៅបន្តចីរភាព វឌ្ឍនភាពដែលមានកន្លងមក តាមរយៈប្រព័ន្ធតាមដាន និងវាយតម្លៃ ដ៏មុតមាំមួយ នឹងអាចធានាជួយដល់ចីរភាពបរិស្ថាន ។

**គោលដៅទី៨៖ បង្កើតភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍន៍**
រដ្ឋាភិបាលបានបន្តរក្សានូវភាពជាដៃគូបានយ៉ាងល្អប្រសើរ។ សន្ទុះនេះត្រូវតែត្រូវបានរក្សាទុក ដោយសារតែ លំហូរសម្បទានហិរញ្ញវត្ថុ នឹងមានចំនួនតិចជាងមុន ហើយប្រាក់កម្ចី នឹងកើនខ្ពស់ជាងមុននាពេលអនាគតដ៏ខ្លី។ ភាពមិនប្រាកដប្រជានៃវិបត្តិសកលលោក និងបម្រែបម្រួលអាកាសធាតុ ក៏ជាបញ្ហាប្រឈម។

**គោលដៅទី៩៖ ការបោសសម្អាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការជួយជនរងគ្រោះ**
តំបន់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម មួយចំនួនធំត្រូវបានសម្អាតប៉ុន្តែនៅតែមានជនរងគ្រោះ ដោយសារតែការផ្ទុះមីន។ កង្វះធនធាន គឺជាឧបសគ្គចម្បង។

បញ្ហាប្រឈមជាច្រើននឹងមានក្រោយឆ្នាំ២០១៥។ ដូច្នេះភារកិច្ចដំបូង គឺបំពេញរាល់ចំណុចដៅឆ្នាំ២០១៥ ដែលមិនបានពេញលេញទាំងអស់ នៅក្នុងពេលដែលនៅសេសល់។ជាមួយគ្នាដែរឆ្លងតាមភស្តុតាងពីការកង្វល់នៅកម្រិតជាតិនិងអន្តរជាតិ ដូចបានពិភាក្សានៅក្នុងរបាយការណ៍នេះ នោះចក្ខុវិស័យសម្រាប់អនាគតមួយចាំបាច់ត្រូវរៀបចំឡើង។ ការផ្លាស់ប្តូរ ដែលបានផ្តល់តុល្យភាពសេដ្ឋកិច្ចពិភពលោកបែរឆ្ពោះ មករកតំបន់អាស៊ីនេះនឹងតម្រូវឱ្យប្រទេសកម្ពុជាតម្រឹមឡើងវិញនូវផ្នែកខាងក្រៅរបស់ខ្លួនដើម្បីបន្ស៊ីជាមួយនឹងការផ្លាស់ប្តូរនោះ។

បញ្ហាសំខាន់នេះ គឺការធានាបាននូវកំណើនការកាត់បន្ថយភាពក្រីក្រ និងវិសមភាពប្រកបដោយចីរភាព។ វិធានការដ៏សំខាន់មួយចំនួន គឺការពង្រឹងការអភិវឌ្ឍធនធានមនុស្ស (ពោលគឺការអប់រំ សុខភាព អាហារូបត្ថម្ភ គាំពារសង្គម និងទឹកនិងអនាម័យ) និងមូលធនមនុស្ស (ជំនាញ) ការបង្កើតអភិបាលកិច្ចល្អ (និងនីតិរដ្ឋ) ការរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលសមរម្យការលើកកម្ពស់តម្លៃបន្ថែមសម្រាប់កសិកម្ម និងការបង្កើតលក្ខខណ្ឌសម្រាប់វិស័យឯកជន បង្កើតអត្ថប្រយោជន៍ទៅវិញទៅមកនៅក្នុងសង្គម ពោលគឺកំណើនដែលមានលក្ខណៈបរិយាបន្ន័ទាំងអស់គ្នា។ លើសពីនេះទៀត នៅមានអាទិភាពចំនួនបីផ្សេងទៀត ដែលត្រូវផ្តោតការយកចិត្តទុកដាក់គឺ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានរូម ( ឧទាហរណ៍ ធនធានធម្មជាតិ និងទឹក) និងសមភាពយេនឌ័របន្ថែមទៀត។

# ឧបសម្ព័ន្ធទី ១

## វឌ្ឍនភាពស្តីពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

| ល.រ | សូចនាករ | ខ្នាត | ២០០៥ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៥ ចំណុចដៅ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| គោលដៅទី១ លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ | | | | | | | | | | | | |
| 1.1 | កាត់បន្ថយសមមាត្រប្រជាជនរស់នៅក្នុងភាពក្រីក្រ | % | - | ៤៧,៨ | ២៩,៩ | ២៩,៩ | ២១,១ | ១៩,៨ | - | - | ≤១៩,៥ | CSES |
| 1.2 | កាត់បន្ថយសមមាត្រប្រជាជនរស់នៅក្នុងភាពអត់ឃ្លាន | % | - | ១៨,៧ | ៧,៧ | ៤,៣ | ៤,១ | ២,៧ | - | - | ≤១០ | CSES |
| 1.3 | បង្កើនចំណែកក្នុងការប្រើប្រាស់របស់ប្រជាជនក្រីក្របំផុត ២០ភាគរយនៃចំនួនប្រជាជនសរុប | % | - | ៦,៨៥ | ៧,៤៦ | ៨,០០ | ៨,៣៤ | ៨,៩៨ | - | - | ≥១១ | CSES |
| 1.4 | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារមិនគ្រប់ទម្ងន់ (អាយុក្រោម០៥ឆ្នាំ) | % | ២៨ | - | - | - | ២៨ | - | - | - | ≤១៩ | CSES |
| 1.5 | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារគ្រិន | % | ៤៣ | - | - | - | ៤០ | - | - | - | ≤២៥ | CDHS |
| 1.6 | កាត់បន្ថយប្រេវ៉ាឡង់នៃកុមារស្គមស្គាំង | % | ៨ | - | - | - | ១១ | - | - | - | ≤៦៥ | CDHS |
| 1.7 | កាត់បន្ថយប្រេវ៉ាឡង់កង្វះគ្រាប់ឈាម របស់កុមារអាយុ ៦-៥៩ខែ | % | ៦២ | - | - | - | ៥៥ | - | - | - | ៤២ | CDHS |
| 1.8 | កាត់បន្ថយប្រេវ៉ាឡង់កង្វះគ្រាប់ឈាម របស់ស្ត្រី អាយុ ១៥-៤៩ឆ្នាំ | % | ៤៧ | - | - | - | ៤៤ | - | - | - | ៤២ | CDHS |
| 1.9 | បង្កើនសមាមាត្រគ្រួសារដែលប្រើប្រាស់អំបិលអ៊ីយ៉ូដ | % | ៧៣ | - | - | - | ៨៣ | - | - | - | ៩០ | CDHS |
| 1.10 | កាត់បន្ថយប្រេវ៉ាឡង់នៃពលកម្មកុមារ (តិចជាង ឬស្មើអាយុ១៧ឆ្នាំ) នៃចំនួនកុមារសរុបនៅក្នុងក្រុមអាយុនោះ | % | - | - | - | ២០,៤ | ១៦,៨ | ១៣,៨ | - | - | ≤៨ | CSES |
| គោលដៅទី២ សម្រេចឱ្យបានសកលកម្មការនិងការអប់រំបឋមសិក្សា | | | | | | | | | | | | |
| 2.1 | បង្កើនអត្រាអក្ខរភាព សម្រាប់ប្រជាជនអាយុ១៥-២៤ឆ្នាំ | % | ៨០,៤ | ៨៨,៥ | ៨៩,៤ | ៨៧,៤ | ៨៩,១ | ៩២,១ | ៩១,៥ | ៩២,៥ | ៩៤,៥ | MoEYS |
| 2.2 | បង្កើនអត្រាពិតនៃការសិក្សានៅបឋមសិក្សា | % | - | - | - | ៩៤,៤ | ៩៤,៨ | ៩៥,២ | ៩៦,៤ | ៩៧ | ៩៩ | MoEYS |
| 2.3 | បង្កើនអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | - | - | - | ៦១,៦ | ៥៨,១ | ៥៨,៥ | ៥៥ | ៥៣,៦ | ១០០ | MoEYS |
| 2.4 | បង្កើនអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | % | - | - | - | ៨៥,៦ | ៨៣,២ | ៨៥,៣ | ៨៩,៧ | ៨៧,៤ | ១០០ | MoEYS |
| 2.5 | បង្កើនអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | - | - | - | ៤៩,១ | ៤៨,៧ | ៤៤,៤ | ៤២,១ | ៤០,៦ | ៥៧ | MoEYS |
| 2.6 | សម្រេចឱ្យបាននូវសមភាពយេនឌ័រក្នុងការអប់រំនៅបឋមសិក្សា | សន្ទស្សន៍ | - | - | - | ០,៩៩ | ១ | ០,៩៩ | ០,៩៩ | ១ | - | MoEYS |
| 2.7 | សម្រេចឱ្យបាននូវសមភាពយេនឌ័រក្នុងការអប់រំនៅ មធ្យមសិក្សាបឋមភូមិ | សន្ទស្សន៍ | - | - | - | ០,៩២ | ០,៩៧ | ០,៩៨ | ១ | ១,០២ | - | MoEYS |
| គោលដៅទី៣ លើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | | | | | | | | | | | | |
| 3.1 | កាត់បន្ថយឱ្យបានច្រើននូវគម្លាតភាពយេនឌ័រក្នុងការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ | % | - | - | ៦៩,៤ | ៧២,៩ | ៧៧,១ | ៨១,៧ | ៨៤,៣ | ៨៧,៣ | ១០០ | MoEYS |
| 3.2 | កាត់បន្ថយឱ្យបានច្រើននូវគម្លាតភាពយេនឌ័រក្នុងការអប់រំកម្រិតឧត្តមសិក្សា | % | ៧៤,២ | - | - | ៨៦,៧ | - | - | - | - | ១០០ | CSES |
| 3.3 | លុបបំបាត់គម្លាតយេនឌ័រក្នុងការទទួលបានប្រាក់កម្រៃការងារនៅក្នុងគ្រប់វិស័យ | % | - | - | - | ៤៥ | ៤២,២ | ៤៥,៨ | - | - | ៥០ | CSES |
| 3.4 | លុបបំបាត់គម្លាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ | % | - | ៣២ | - | - | - | - | ៣៥ | - | ៥០ | MoWA |
| 3.5 | កាត់បន្ថយឱ្យបានច្រើនរាល់ទម្រង់នៃហឹង្សាប្រឆាំងនឹងស្ត្រីនិងកុមារ | % | - | - | - | ២៣,៩ | - | - | - | - | - | MoWA |
| គោលដៅទី៤ កាត់បន្ថយអត្រាមរណភាពកុមារ | | | | | | | | | | | | |
| 4.1 | កាត់បន្ថយអត្រាមរណភាពរបស់ទារកឱ្យបានពាក់កណ្តាល នៅឆ្នាំ២០១៥ | % | ៩៥ | ៦៥ | - | - | ៤៥ | - | - | - | ៥០ | CDHS |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 4.2 | កាត់បន្ថយអត្រាមរណភាពរបស់កុមារអាយុក្រោម០៥ឆ្នាំ | % | ១២៤ | ៨៣ | - | - | ៥៤ | - | - | - | ៦៥ | CDHS |
| 4.3 | បង្កើនការផ្តល់វ៉ាក់សាំងដល់កុមារឱ្យបាន៩០ភាគរយ | % | - | ៦៧ | - | - | ៧៩ | - | - | - | >៩០ | CDHS |
| 4.4 | បង្កើនការបំបៅដោះដល់កុមាររហូតអាយុ០៦ខែ ឱ្យបាន៧០ភាគរយ | % | - | ៦៥ | - | - | ៧៤ | - | - | - | ៧០ | CDHS |
| គោលដៅទី៥ លើកកម្ពស់សុខភាពមាតា | | | | | | | | | | | | |
| 5.1 | អត្រាមរណភាពមាតា (ក្នុង១០០,០០០ កំណើតរស់) | ផលធៀប | ៤៣៧ | ៤៧២ | - | - | ២០៦ | - | - | - | ២៥០ | CDHS |
| 5.2 | សមាមាត្រស្ត្រីសម្រាលកូនដោយបុគ្គលិកសុខាភិបាលជំនាញ | % | - | - | ៥៨ | - | - | - | ៧៥ | - | ៨៧ | MoH |
| 5.3 | អត្រាលទ្ធភាពផ្តល់កំណើតសរុប | - | ៤ | ៣,៤ | - | - | ៣ | - | - | - | ៣ | CDHS |
| 5.4 | សមាមាត្រស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ ប្រើប្រាស់វិធីពន្យាកំណើត | % | ១៩ | ២៧,២ | - | - | ៣៥ | - | - | - | ៦០ | CDHS |
| 5.5 | សមាមាត្រស្ត្រីមានផ្ទៃពោះ ទទួលបានការពិនិត្យផ្ទៃពោះពីរដង ឬច្រើនជាងនេះ | % | - | - | - | ៨៣ | - | - | ៨៧ | - | ៩០ | CDHS |
| 5.6 | សមាមាត្រស្ត្រីមានផ្ទៃពោះ ដែលសម្រាលកូនដោយធ្វើការវះកាត់ | % | - | - | ០,៧៧ | - | - | - | ២,៨៣ | - | ៤ | CDHS |
| គោលដៅទី៦ ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត | | | | | | | | | | | | |
| 6.1 | កាត់បន្ថយប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍(ប្រជាជនអាយុពី១៥-៤៩ឆ្នាំ) | % | - | - | ០,៧ | ០,៧ | ០,៧ | - | - | - | ០,៤ | MoH |
| 6.2 | កាត់បន្ថយប្រេវ៉ាឡង់ជំងឺគ្រុនចាញ់ (ក្នុងប្រជាជន ១០០ ០០០នាក់) | - | - | - | ១,៥ | ២,០ | ០,៩៨ | ០,៦៥ | ០,២៩ | - | ០,៨ | MoH |
| 6.3 | កាត់បន្ថយប្រេវ៉ាឡង់ជំងឺរបេង | ចំនួន | - | - | ១ ២៣០ | - | - | - | ៧៦៤ | - | ៦៥៣ | MoH |
| គោលដៅទី៧ ធានាចីរភាពបរិស្ថាន | | | | | | | | | | | | |
| 7.1 | ស្តុកធនធានបរិស្ថានដែលបានបាត់បង់ | % | - | - | - | ៥៥,៩៩ | ៥៧,៥៩ | ៥៨,៣៩ | - | ៥៩,១៩ | ៦០ | NSDP/MTR ២០០៩-១៣ |
| 7.2 | បង្កើនសមាមាត្រប្រជាជនមានទឹកស្អាតប្រើប្រាស់ | | | | | | | | | | | |
| | តំបន់ជនបទ | % | - | - | - | ៤២ | ៤០,៥ | ៤២,៧ | - | - | ៥០ | CSES |
| | តំបន់ទីប្រជុំជន | % | - | - | - | ៧៨,៥ | ៨០,៥ | ៨១,១ | - | - | ៨០ | CSES |
| 7.3 | បង្កើនសមាមាត្រប្រជាជនដែលទទួលបានអនាម័យ | | | | | | | | | | | |
| | តំបន់ជនបទ | % | - | - | - | ២២,៩ | ២៨,៧ | ៣៣,៤ | - | - | ៣៣ | CSES |
| | តំបន់ទីប្រជុំជន | % | - | - | - | ៨៥ | ៨៦,៦ | ៨៧,៨ | - | - | ៧៤ | CSES |
| 7.4 | កាត់បន្ថយការប្រើប្រាស់អុស សម្រាប់ចម្អិនអាហារ | % | - | ៨៤ | - | - | ៧៩,៥ | - | - | - | ៥២ | CDHS |
| 7.5 | បង្កើនសមាមាត្រប្រជាជន ទទួលបានកម្មសិទ្ធិដីធ្លី | % | - | - | - | ២២ | ២៤ | ២៨ | - | - | ៤៥ | MLMUC |
| គោលដៅទី៩ ការបោសសម្អាតមីន សំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនពិការដោយសារមីន | | | | | | | | | | | | |
| 9.1 | ចំនួនជនរងគ្រោះប្រចាំឆ្នាំដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស្លាប់/របួស) | ចំណុចដៅ | | | | ២៤៤* | ២៤០* | ២២០* | ២០០* | - | - | CMAA |
| | | លទ្ធផល | | | | ២៤៤ | ២៨៦ | ២១១ | ១៨៦ | - | - | CMAA |
| 9.2 | ផ្ទៃដែលបានបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមរួច | ចំណុចដៅ | | | | ៥ ២៦៨* | ៥ ៣៧៤* | ៥ ៤៨១* | ៥ ៥៩១* | - | - | CMAA |
| | | លទ្ធផល | | | | ៦ ១៣៦ | ១១ ៩៥០ | ១៤ ១៥០ | ៨ ២៩៣ | - | - | CMAA |

# ឧបសម្ព័ន្ធទី ២

| ទំព័រ | ម្ចាស់រូបភាព |
|---|---|
| VIII | UNDP Cambodia/Thomas Cristofoletti |
| 1 | UNDP Cambodia/Nicolas Axelrod |
| 2 | UNDP Cambodia/Thomas Cristofoletti |
| 3 | NDP Cambodia/Thomas Cristofoletti |
| 4 | UNDP Cambodia/Nicolas Axelrod |
| 8 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 10 | UNDP Cambodia/Alejandro Boza |
| 15 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 17 | UNDP Cambodia/Nicolas Axelrod |
| 19 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 21 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 21 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 24 | UNDP Cambodia/Thomas Cristofoletti |
| 25 | UNDP Cambodia/Nicolas Axelrod |
| 27 | UNDP Cambodia/Nicolas Axelrod |
| 28 | UNFPA Cambodia |
| 29 | UNFPA Cambodia |
| 30 | UNFPA Cambodia |
| 31 | UNDP Cambodia/Nicolas Axelrod |
| 32 | UNDP Cambodia/Nicolas Axelrod |
| 33 | UNDP Cambodia/Thomas Cristofoletti |
| 34 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 35 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 36 | UNDP Cambodia/Alejandro Boza |
| 36 | UNDP Cambodia/Thomas Cristofoletti |
| 37 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 40 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 40 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 42 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 42 | UNRC |
| 43 | UNDP Cambodia/Thomas Cristofoletti |
| 44 | UNDP Cambodia/Alejandro Boza |
| 45 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 46 | UNDP Cambodia/Nicolas Axelrod |
| 47 | UNDP Cambodia/Thomas Cristofoletti |
| 47 | UNDP Cambodia/ឡៃ ចន្ទសុខ |
| 49 | UNDP Cambodia/Alejandro Boza |
| 51 | កសិករកម្ពុជា លឹម សារឿន ប្រមូលផលស្រូវនាពេលច្រូតកាត់-ខេត្តតាកែវ |
| 58 | UNDP Cambodia/ឈុំ សុវណ្ណ |
| 59 | ប៊ុន ស្រីពេ អាយុ៣ឆ្នាំកំពុងអានសៀវភៅ |
| 59 | សមាជិកសមាគម បឹង ការឆេង កំពុងល្បាតមើលកន្លែងសត្វព្រៃពាមក្រសោបដើម្បីការពារការកាប់ព្រៃកោងកាងខុសច្បាប់ |

**ក្រសួងផែនការ**

អគារ ៣៨៦ មហាវិថី ព្រះមុនីវង្ស រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៧២០ ៩០១
ទូរសារ ៖ ០២៣ ២១០ ៩៤៤
០២៣ ២១០ ៦៩៨
គេហទំព័រ៖ www.mop.gov.kh



ឧបត្ថម្ភដោយ៖


Empowered lives.
Resilient nations.


**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

វិថី ប៉ាស្ទ័រ សង្កាត់ បឹងកេងកង
ប្រអប់សំបុត្រលេខ ៨៧៧ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ ៖ +៨៥៥ (0)២៣ ២១៦ ១៦៧ ឬ ២១៤ ៣៧១
ទូរសារ ៖ +៨៥៥ (0)២៣ ២១៦ ២៥៧ ឬ ៧២១ ០៤២
អ៊ីម៉ែល ៖ registry.kh@undp.org
www.kh.undp.org